សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economic

## សារណាបញ្ចប់ការសិក្សា

# អំពីនគរបាលយុត្តិធម៌ និងអង្គការ
# អយ្យការអមសាលាដំបូងរាជធានី-ខេត្ត

(ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១)

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **លោក រស្មី ច័ន្ទរដ្ឋ**

**កញ្ញា ព្រហ្ម ម៉ារីណា**

សាស្ត្រាចារ្យណែនាំ

**លោក ហ៊ាង ឡេង**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្ដីថ្លែងអំណរគុណ

ក្រុមសិក្សាស្រាវជ្រាវសារណាយើងខ្ញុំ ដែលជានិស្សិតនៃសាកលវិទ្យាល័យភូមិនីតិន្ទសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច នៃមហាវិទ្យាល័យនីតិសាស្រ្ត ដែលមានសមាជិកពីររូបៈ

**១.លោក រស្មី ច័ន្ទរដ្ឋ**

**២.កញ្ញា ព្រហ្ម ម៉ារីនណា**

## សូមគោរពជូនចំពោះ

លោកឪពុក អ្នកម្ដាយ ដែលជាអ្នកមានគុណដ៏លើសលប់ ដោយលោកទាំងពីរបាន ផ្ដល់កំណើត លះបង់នូវកម្លាំងកាយចិត្ត ពុះពារគ្រប់ឧបសគ្គ នូវចិត្តសន្ដោសប្រណីក្នុងការចិញ្ចឹមបីបាច់ថែរក្សា អប់រំ ទូន្មានប្រៀនប្រដៅ និងជួយឧបត្ថម្ភគ្រប់បែបយ៉ាងទាំងស្មារតី ទាំងសម្ភារៈតាំងពីកូននៅកុមារភាព រហូតដល់កូនទាំងអស់គ្នាបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ ដោយលោកទាំងពីរខិតខំធ្វើការមិនគិតពីការនឿយហត់របស់លោកទាំងទ្វេឡើយ។

គុណូបការៈយ៉ាងធំអនេក និងវិសេសវិសាលនេះធ្វើឱ្យកូនៗទាំងពីរចងចាំ និងមិនអាចបំភ្លេចបាននូវការលះបង់របស់លោកអ្នកមានគុណទាំងពីរដែលជាម្លប់ដ៏ប្រពៃហើយ និងជាម្លប់ដ៏ត្រជាក់ត្រជុំសម្រាប់កូនៗគ្រប់រូបមានទំហំធំធេងគ្មានអ្វីប្រៀបផ្ទឹមបានឡើយ។ ទាំងអស់នេះដែលស្ថិតក្នុងការចងចាំរបស់កូនៗជានិច្ច និងគ្មានថ្ងៃបំភ្លេចបានដែលស្ថិតក្នុងដួងព្រលឹងកូនៗជាដរាបគ្មានថ្ងៃសាបសូន្យឡើយ។

ឯកឧត្ដម **លុយ ចណ្ណា** សាកលវិទ្យាធិការ និងឯកឧត្ដមសាកលវិទ្យាធិការរង លោក លោកស្រី ព្រឹទ្ធបុរស រួមទាំងគណៈគ្រប់គ្រង និងសាស្រ្តាចារ្យទាំងអស់នៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានអនុញ្ញាតឱ្យយើងខ្ញុំទាំងពីររូបបានចូលសិក្សានៅទីនេះ ហើយថែមទាំងយកចិត្តទុកដាក់ ខិតខំអប់រំ និងពង្រឹងវិន័យសាកលវិទ្យាល័យ តាំងពីចូលរៀនរហូតមកដល់ការសរសេរនូវសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ។ ទីកន្លែងនេះហើយ ដែលជាថ្នាលបណ្ដុះបណ្ដាលឱ្យយើងទាំងពីររូប បានសិក្សាស្វែងយល់នូវទិដ្ឋភាព ផ្នែកទ្រឹស្ដី និងទិដ្ឋភាពផ្នែកសង្គម ហើយធ្វើឱ្យយើងទាំងពីររូបបានក្លាយជានិស្សិតល្អ មិត្តភក្ដិល្អ និងពលរដ្ឋល្អក្នុងសង្គមជាតិ។

សូមថ្លែងអំណរគុណជូនចំពោះលោក **ញឹក វុទ្ធី** ប្រធានការិយាល័យសិក្សាស្រាវជ្រាវនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច និងបុគ្គលិកទាំងអស់ដែលបានជួយសម្របសម្រួលបែបបទរដ្ឋបាល និងជួយសម្រួលកិច្ចការផ្សេងៗនៃកិច្ចការស្រាវជ្រាវសារណានេះ។

ជាពិសេសយើងខ្ញុំសូមថ្លែងអំណរគុណជូនចំពោះលោកសាស្រ្តាចារ្យ **ប៉ាង ឡេង** សាស្រ្តាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានផ្ដល់ចំណេះដឹង និងពេលវេលាដ៏មានតម្លៃក្នុងការរួមចំណែកធ្វើជាសាស្រ្តាចារ្យណែនាំដល់យើងខ្ញុំទាំងពីរនាក់ ដើម្បីបង្កើតនូវសៀវភៅសារណាមួយនេះ។

# អារម្ភកថា

សៀវភៅសារណា មានចំណងជើងថា **"អំពីនគរបាលយុត្តិធម៌ និងអង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្ត"** ដែលកំពុងតែមានវត្តមានក្នុងដៃរបស់លោកអ្នក គឺវាបានឧប្បត្តិឡើង តាមរយៈការខិតខំប្រឹងប្រែងសិក្សាស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់ជាទីបំផុត ក្នុងការសម្រិតសម្រាំងចម្រាញ់យកខ្លឹមសារ ដែលមានគុណភាព និងសារៈប្រយោជន៍យ៉ាងចាំបាច់ ដើម្បីយកមកចងក្រងជាសៀវភៅនេះឡើង ហើយក្នុងគោលបំណងឱ្យអ្នកសិក្សាផ្នែកនីតិសាស្ត្រ ក៏ដូចជាអ្នកដែលចង់ចេះ ចង់ដឹង និងចង់សិក្សាស្វែងយល់ពាក់ព័ន្ធនឹងរឿងក្តីព្រហ្មទណ្ឌ ជាពិសេសគឺនីតិវិធីព្រហ្មទណ្ឌ ដែលចាប់ពីដំណាក់កាល នគរបាលយុត្តិធម៌ រហូតដល់ដំណាក់កាល អង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្ត។ ម្យ៉ាងវិញទៀត ក្នុងខ្លឹមសារនៃសៀវភៅនេះ គឺបានស៊ីជម្រៅយ៉ាងក្បោះក្បាយអំពីដំណាក់កាលនគរបាលយុត្តិធម៌ និងដំណាក់កាលអង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ទៅតាមគោលការណ៍ដែលមានចែងនៅក្នុងច្បាប់ ក៏ដូចជាការអនុវត្តជាក់ស្តែង ដោយយើងខ្ញុំ បានលើកយកចំណុចគោលសំខាន់ៗ មកបកស្រាយពន្យល់ ព្រមទាំងធ្វើការប្រៀបធៀប ដើម្បីឱ្យលោកអ្នកកាន់តែងាយយល់។

បើចង់ដឹងថា ខ្លឹមសារនៃសារណានេះ មានអត្ថន័យ អត្ថរស មានអត្ថប្រយោជន៍យ៉ាងណាចំពោះលោកអ្នក គឺលោកអ្នកគ្រាន់តែបង្អោនចិត្ត ដាក់កាយ ហើយចំណាយពេលវេលាខ្លះៗ ដើម្បីអាន និងកត់ត្រានៅចំណុចសំខាន់ៗទុក អ្នកនឹងដឹងថា សៀវភៅមួយនេះមានអត្ថប្រយោជន៍អ្វីខ្លះ។

ជាចុងក្រោយ យើងខ្ញុំទាំងពីរនាក់ ដែលជាអ្នកសិក្សាស្រាវជ្រាវ និងតាក់តែងសៀវភៅសារណាមួយនេះ ក៏សូមលើកដៃប្រណមឡើង ខន្តីអភ័យទោសចំពោះលោកអ្នកសិក្សាស្រាវជ្រាវទាំងឡាយ នូវរាល់កំហុសឆ្គងទាំងអត្ថន័យ អត្ថរស ខ្លឹមសារ ពាក្យពេចន៍ ឃ្លោងឃ្លា និងអក្ខរាវិរុទ្ធជាដើម ដែលកើតឡើងដោយអចេតនា។ ហើយយើងខ្ញុំ សង្ឃឹមជឿជាក់យ៉ាងមុតមាំថាសៀវភៅនេះ នឹងបានជាអត្ថប្រយោជន៍ ក៏ដូចជាឯកសារយោង និងជាពុទ្ធិយ៉ាងសម្បូរបែបជូនដល់អ្នកសិក្សាស្រាវជ្រាវទៅអនាគត។

# មាតិកា

**ទំព័រ**

## សេចក្តីផ្តើម

១.លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១
២.ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ១
៣.គោលបំណងនៃការស្រាវជ្រាវ ........ ២
៤.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ២
៥.សារៈសំខាន់នៃការស្រាវជ្រាវ ........ ២
៦.វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៣
៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣

## ជំពូកទី១

## ការរំលឹកទ្រឹស្តី

**ផ្នែកទី១៖ ប្រព័ន្ធស្ថាប័នតុលាការនៃព្រះរាជាណាចក្រកម្ពុជា** ........ ៥
កថាខណ្ឌទី១៖ ប្រវត្តិស្ថាប័នតុលាការកម្ពុជា ........ ៦
១.១.អំពីសាលាដំបូងរាជធានី-ខេត្ត ........ ៧
១.២.អំពីតុលាការយោធា ........ ៧
កថាខណ្ឌទី២៖ មូលហេតុនៃរឿងក្តីព្រហ្មទណ្ឌ ........ ៨
២.១.ដំណាក់កាលនៃនីតិវិធីព្រហ្មទណ្ឌ ........ ៨
២.២.តួអង្គសំខាន់ៗក្នុងរឿងក្តីព្រហ្មទណ្ឌ ........ ១០

## ជំពូកទី២

## អំពីនគរបាលយុត្តិធម៌

**ផ្នែកទី១៖ សមាសភាពនគរបាលយុត្តធម៌** ........ ១២
កថាខណ្ឌទី១៖ មន្ត្រីនគរបាលយុត្តិធម៌ ........ ១២
១.១.ការទទួលបានតាមរយៈឋានន្តរស័ក្តិ ........ ១២
១.២.ការទទួលបានតាមរយៈការប្រឡងប្រជែង ........ ១៣

១.៣.ការទទួលបានដោយស្វ័យប្រវត្តិ.......................................................................... ១៣
កថាខណ្ឌទី២៖ភ្នាក់ងារនគរបាលយុត្តិធម៌ .................................................................................. ១៥
២.១.ការទទួលគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌ ............................................... ១៥
២.២.បេសកកម្មរបស់ភ្នាក់ងារនគរបាលយុត្តិធម៌ ........................................................... ១៦
២.៣.សមត្ថកិច្ចរបស់ភ្នាក់ងារនគរបាលយុត្តិធម៌............................................................ ១៦
២.៤.កំហុសដែលត្រូវបានប្រព្រឹត្តនៅពេលបំពេញមុខងារ.................................................. ១៧
កថាខណ្ឌទី៣៖ មន្ត្រីរាជការ និង ភ្នាក់ងារសាធារណៈដែលមាននីតិសម្បទា ................................ ១៧
៣.១.ការទទួលបាននូវនីតិសម្បទាតាមរយៈច្បាប់ដោយឡែកមួយចំនួន ............................ ១៧
៣.១.១.តាមរយៈច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ...១៧
៣.១.២.តាមរយៈច្បាប់ស្តីពីព្រៃឈើ......................................................................... ១៨
៣.២.ការតែងតាំងចំពោះមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ............................. ១៩
៣.២.១.បុគ្គលដែលមានអំណាចក្នុងការតែងតាំង ....................................................... ២០
៣.២.២.សេចក្តីសម្រេចក្នុងការតែងតាំង .................................................................. ២០
៣.៣.សម្បថរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត...................................... ២០
៣.៣.១.ទីកន្លែងត្រូវធ្វើសម្បថ.................................................................................. ២០
៣.៣.២.នត្ថិភាពនៃអញ្ញត្រកម្មចំពោះសម្បថរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត .២១
៣.៤.កំហុសរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតក្នុងពេលបំពេញមុខងារ.......... ២១
៣.៤.១.នីតិវិធីខាងវិន័យ ......................................................................................... ២១
៣.៤.២.ទណ្ឌកម្មចំពោះមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ........................... ២២
**ផ្នែកទី២៖ សមត្ថកិច្ច និងអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌** .............................. ២២
កថាខណ្ឌទី១៖សមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ .................................................. ២២
១.១.សមត្ថកិច្ចដែនដី ............................................................................................ ២២
១.២.សមត្ថកិច្ចសម្ភារៈ........................................................................................... ២៣
កថាខណ្ឌទី២៖ អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌.................................................... ២៣
២.១.ការស៊ើបអង្កេតបទល្មើសជាក់ស្តែង .................................................................. ២៤
២.១.១.លក្ខខណ្ឌនៃការបើកការស៊ើបអង្កេតករណីជាក់ស្តែង........................................ ២៤
២.១.២.ដំណើរការស៊ើបអង្កេត................................................................................. ២៤

២.១.៣.វិធាននៃការស្រាវជ្រាវរបស់មន្ត្រីនគរបាលយុត្តិធម៌ ..........................................២៥
២.១.៤.វិធានក្នុងការឃាត់ខ្លួន..............................................................................២៥
២.១.៥.វិធាននៃការបញ្ជូនជនដែលត្រូវបានឃាត់ខ្លួនដល់ព្រះរាជអាជ្ញា ...........................២៧
២.២.ការស៊ើបអង្កេតបឋម ...........................................................................................២៧
២.២.១.វិធាននៃការស្រាវជ្រាវរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងបទល្មើសមិនជាក់ស្តែង........២៨
២.២.២.វិធានក្នុងការឃាត់ខ្លួន និងបញ្ជូនជនដែលត្រូវបានឃាត់ខ្លួន .............................២៨
**ផ្នែកទី៣៖ ភាពចំណុះនៃនគរបាលយុត្តធម៌**.........................................................................៣១
កថាខណ្ឌទី១៖ ដំណាក់កាលស៊ើបអង្កេត ..................................................................................៣១
កថាខណ្ឌទី២៖ ដំណាក់កាលស៊ើបសួរ .......................................................................................៣១
កថាខណ្ឌទី៣៖ បេសកកម្មរបស់នគរបាលយុត្តិធម៌..................................................................៣២
**ផ្នែកទី៤៖ ករណីការអនុវត្តជាក់ស្តែង និងការបាត់បង់សមាជិកភាពនៃនគរបាលយុត្តធម៌** .......................................................................................................៣២
កថាខណ្ឌទី១៖ ករណីការអនុវត្តជាក់ស្តែង.................................................................................៣២
១.១.បញ្ហាដែលកើតមានចំពោះមន្ត្រីនគរបាលយុត្តិធម៌..................................................៣៣
១.២.ដំណោះស្រាយចំពោះបញ្ហាប្រឈម .......................................................................៣៥
កថាខណ្ឌទី២៖ ការបាត់បង់សមាជិកភាព...................................................................................៣៧
២.១.តាមរយៈការពិន័យ ............................................................................................៣៧
២.២.តាមរយៈការចូលនិវត្តន៍ ......................................................................................៣៧

## ជំពូកទី៣

## អង្គការអយ្យការ

**ផ្នែកទី១៖ សញ្ញាណទូទៅនៃអង្គការអយ្យការ** ..................................................................៣៨
កថាខណ្ឌទី១៖ រចនាសម្ព័ន្ធរបស់អង្គការអយ្យការ .....................................................................៣៨
១.១.អង្គការអយ្យការអមសាលាដំបូង...........................................................................៣៨
១.១.១.ព្រះរាជអាជ្ញា...............................................................................................៣៨
១.១.២.ព្រះរាជអាជ្ញារង ...........................................................................................៣៩
១.២.អង្គការមហាអយ្យការ ..........................................................................................៣៩

១.២.១.មហាអយ្យការអមសាលាឧទ្ធរណ៍ ..........................................................................៣៩

១.២.២.មហាអយ្យការអមតុលាការកំពូល. .........................................................................៤០

កថាខណ្ឌទី២៖ សមត្ថកិច្ច ភារកិច្ច សិទ្ធិអំណាច និងតួនាទីរបស់អង្គការអយ្យការ .........................៤០

២.១.សមត្ថកិច្ចរបស់ព្រះរាជអាជ្ញា ..................................................................................៤០

២.២.ភារកិច្ចរបស់ព្រះរាជអាជ្ញា.....................................................................................៤០

២.៣.សិទ្ធិអំណាចរបស់ព្រះរាជអាជ្ញា ..............................................................................៤១

២.៤.តួនាទីរបស់ព្រះរាជអាជ្ញា .......................................................................................៤២

កថាខណ្ឌទី៣៖ គោលការណ៍សំខាន់របស់អង្គការអយ្យការ........................................................៤២

៣.១.គោលការណ៍អវិភាគ .............................................................................................៤២

៣.២.គោលការណ៍ឯកភាព ...........................................................................................៤៣

៣.៣.គោលការណ៍ឯករាជ្យ...........................................................................................៤៣

៣.៤.គោលការណ៍មិនអាចប្ដឹងជំទាស់ ........................................................................៤៤

៣.៥.គោលការណ៍នៃការមិនទទួលខុសត្រូវ.......................................................................៤៤

**ផ្នែកទី២៖ ការរៀបចំអង្គការអយ្យការ** ...........................................................................៤៤

កថាខណ្ឌទី១៖ ការជ្រើសរើសព្រះរាជអាជ្ញា ...........................................................................៤៥

កថាខណ្ឌទី២៖ សមាសភាពរបស់អង្គការអយ្យការ ..................................................................៤៦

កថាខណ្ឌទី៣៖ កាតព្វកិច្ចព្រះរាជអាជ្ញា....................................................................................៤៧

**ផ្នែកទី៣៖ ចំណាត់ការលើសំណុំរឿងរបស់អយ្យការ** .....................................................៤៨

កថាខណ្ឌទី១៖ បណ្ដឹងព្រហ្មទណ្ឌ និងបញ្ជីឈ្មោះសៀវភៅនៃសំណុំរឿងព្រហ្មទណ្ឌ .....................៤៨

១.១.នីតិវិធីទទួលបណ្ដឹងព្រហ្មទណ្ឌ ...............................................................................៤៩

១.១.១.ពាក្យបណ្ដឹងទាមទារ និងពាក្យបណ្ដឹងបរិហារដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក . ៤៩

១.១.២.ពាក្យបណ្ដឹងទាមទារ និងពាក្យបណ្ដឹងបរិហារដែលព្រះរាជអាជ្ញា ទទួលដោយផ្ទាល់ ៥១

១.១.៣.ការបញ្ជូនពាក្យបណ្ដឹងដោយចៅក្រមស៊ើបសួរ ................................................៥២

១.១.៤.ការបញ្ជូនពាក្យបណ្ដឹងដោយចៅក្រមជំនុំជម្រះ ................................................៥២

១.១.៥.ពាក្យបណ្ដឹងដែលមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី .............................៥២

១.២.បញ្ជីរាយឈ្មោះសៀវភៅនៃសំណុំរឿងព្រហ្មទណ្ឌ....................................................៥៤

កថាខណ្ឌទី២៖ ជម្រើសនៃការចោទប្រកាន់ ......54
២.១.ការតម្កល់រឿងទុកឥតចាត់ការ ......៥៥
២.១.១.សញ្ញាណទូទៅនៃការតម្កល់រឿងទុកឥតចាត់ការ ......៥៥
២.១.២.លក្ខខណ្ឌតម្កល់រឿងទុកឥតចាត់ការ ......៥៦
២.១.៣.មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ ......៥៦
២.១.៤.នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ ......៦០
២.១.៥.នីតិវិធី និងសេចក្ដីសម្រេចនៃបណ្ដឹងតវ៉ា ......៦១
២.២.ការចោទប្រកាន់ ......៦១
២.២.១.ការបើកការស៊ើបសួរ ......៦២
២.២.២.ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ......៦៨
២.២.៣.កំណត់ហេតុស្ដីពីនីតិវិធីបង្ហាញខ្លួនភ្លាម ......៧១
**ផ្នែកទី ៤៖ ការបញ្ជាប់មុខងារជាព្រះរាជអាជ្ញា និងករណីការអនុវត្តជាក់ស្ដែង** ...៧៥
កថាខណ្ឌទី១៖ ករណីការអនុវត្តជាក់ស្ដែង ......៧៥
១.១.បញ្ហាដែលកើតមានចំពោះព្រះរាជអាជ្ញា ......៧៦
១.២.ដំណោះស្រាយចំពោះបញ្ហាប្រឈមរបស់ព្រះរាជអាជ្ញា ......៧៧
កថាខណ្ឌទី២៖ ការបញ្ចប់មុខងារជាព្រះរាជអាជ្ញា ......៧៧
២.១.ការដាក់ទណ្ឌកម្ម ......៧៧
២.២.ការចូលនិវត្តន៍ ......៧៩

## សេចក្ដីសន្និដ្ឋាន និងអនុសាសន៍

**១.សេចក្ដសន្និដ្ឋាន** ......៨០
**២.អនុសាសន៍** ......៨១
**គន្ថនិទេស**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

បន្ទាប់ពីការរលត់នូវភ្លើងសង្គ្រាមសព្វគ្រប់នាឆ្នាំ១៩៩៣ មក កម្ពុជាបានស្រុះស្រួលព្រមព្រៀង ឯកភាពគ្នាធ្វើការបង្រួបបង្រួមជាតិឡើងវិញ ក្រោមកិច្ចខិតខំប្រឹងប្រែងដឹកនាំយ៉ាងយកចិត្តទុកដាប្រកបដោយគតិបណ្ឌិត និងគោលនយោបាយឈ្នះៗរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលធ្វើឱ្យប្រទេសកម្ពុជាទទួលបាននូវសុខសន្តិភាព ស្ថេរភាព ភាតរភាព និងការអភិវឌ្ឍស្ទើរគ្រប់វិស័យ។

ទន្ទឹមនឹងអ្វីដែលកំពុងអភិវឌ្ឍនេះហើយ ដែលធ្វើឱ្យប្រទេសកម្ពុជា ជួបនឹងបញ្ហាជាច្រើនដែលជាកត្តារាំងស្ទះដល់ការរីកចម្រើនរបស់ប្រទេសជាតិ។ ដើម្បីជាការរួមចំណែកក្នុងការកាត់បន្ថយនូវ ភាពអវិជ្ជមានទាំងនោះ គឺត្រូវមានការចូលរួមយ៉ាងយកចិត្តទុកដាក់បំផុត ពីសំណាក់រាជរដ្ឋាភិបាល ថ្នាក់ដឹកនាំក្រសួង ស្ថាប័នពាក់ព័ន្ធ ជាពិសេសគឺប្រជាពលរដ្ឋទាំងមូល ដែលជាស្នូលក្នុងការជួយជាតិមាតុភូមិ។ ដើម្បីប្រទេសជាតិមួយខ្លាំងក្លាទៅបាន គឺត្រូវមានច្បាប់សម្រាប់គ្រប់គ្រង។ ដើម្បីធ្វើឱ្យមានប្រសិទ្ធិភាពតទៅបាន គឺត្រូវមានការចូលរួមគោរពនូវវិធានច្បាប់ទាំងអស់គ្នា ហើយដើម្បីប្រជាពលរដ្ឋគោរពវិធានច្បាប់ទាំងនោះបាន លុះត្រាតែប្រជាពលរដ្ឋទាំងអស់មានចំណេះដឹងគ្រប់គ្រាន់ ជាពិសេសគឺយល់ដឹងអំពីវិធានច្បាប់ទាំងនោះ ព្រោះថាប្រជាពលរដ្ឋមិនត្រូវនិយាយថា **ខ្លួន មិនចេះច្បាប់នោះទេ**។ ដើម្បីអាចឱ្យប្រជាពលរដ្ឋចេះដឹងបាន គឺត្រូវមានការអ្នកផ្សព្វផ្សាយ និងការបង្ហាត់បង្រៀនទៅដល់ពួកគាត់។

យ៉ាងណាមិញ សៀវភៅសារណាស្តី **អំពីនគរបាលយុត្តិធម៌ និងអង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្ត** ស្ថិតក្នុងទីនេះ ដែលយើងខ្ញុំជានិស្សិតច្បាប់ បានខិតខំស្រាវជ្រាវយកមកសរសេរយ៉ាងក្បោះក្បាយពាក់ព័ន្ធនឹងនីតិវិធីព្រហ្មទណ្ឌ ជាពិសេស មុខងារ តួនាទី និងបុគ្គលសំខាន់ៗ មួយចំនួនក្នុងរឿងក្តីព្រហ្មទណ្ឌមកលាតត្រដាងធ្វើការបង្ហាញដល់សាធារណៈជន ដើម្បីឱ្យកាន់តែយល់ច្បាស់ និងស៊ីជម្រៅកាន់តែលម្អិតអំពីវិស័យច្បាប់ដែលពាក់ព័ន្ធទៅនឹងរឿងក្តីព្រហ្មទណ្ឌ។ ជាពិសេស យើងខ្ញុំសង្ឃឹមយ៉ាងជឿជាក់ថា សៀវភៅនេះនឹងបានចូលរួមចំណែកផ្តល់នូវចំណេះដឹងក្នុងវិស័យច្បាប់ ក៏ដូចជារឿងក្តីព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌដល់សិស្ស និស្សិត និងប្រជាពលរដ្ឋផងដែរ។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

សៀវភៅសារណា ដែលមានចំណងជើងថា **"អំពីនគរបាលយុត្តិធម៌ និងអង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្ត"** គឺយើងខ្ញុំ បានធ្វើការកំណត់នូវសំណួរស្រាវជ្រាវយ៉ាងជាក់លាក់ដូចខាងក្រោម៖

១.តើស្ថាប័ន និងតួអង្គណាខ្លះ ដែលជាអ្នកមានសមត្ថកិច្ចដោះស្រាយរឿងក្តីព្រហ្មទណ្ឌ?

២.តើនគរបាលយុត្តិធម៌ និងអង្គការអយ្យការ មានតួនាទី ភារកិច្ចយ៉ាងដូចម្តេច?

ចំពោះចម្លើយនៃសំណួរស្រាវជ្រាវទាំងនេះ នឹងត្រូវបានបង្ហាញនៅក្នុងជំពូកទី១ ទី២ និងជំពូកទី៣ នៃសារណាមួយនេះ។

## ៣.គោលបំណងនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបនឹងចំណោទបញ្ហា នៃការស្រាវជ្រាវខាងលើនេះ យើងខ្ញុំបានស្រាវជ្រាវយកមកសរសេរចងក្រងឡើង ដោយមានគោលបំណងផ្តោតសំខាន់ទៅលើ៖

-ការស្វែងយល់អំពីស្ថាប័ន ភាគី និងតួអង្គសំខាន់ៗ ក្នុងដំណើរការនៃរឿងក្តីព្រហ្មទណ្ឌ។

-ការស្វែងយល់អំពីមូលហេតុនៃរឿងរ៉ាវ និងទ្រឹស្តីច្បាប់ ស្តីពីកិច្ចនៃនីតិវិធីព្រហ្មទណ្ឌ។

-លើកពីបញ្ហាប្រឈម ដែលកើតមានឡើង និងស្វែងរកដំណោះស្រាយដ៏សមរម្យ។

## ៤.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ចំពោះការស្រាវជ្រាវសារណានេះ យើងខ្ញុំ បានធ្វើការបែងចែងជាពីរផ្នែកសំខាន់ៗ ដើម្បីឱ្យកាន់តែងាយស្រួលដល់ខ្លឹមសារនៃសារណា ដែលផ្នែកទាំងពីរនោះរួមមានដូចជា៖

**ក.ទំហំនៃការស្រាវជ្រាវ៖** គឺនៅក្នុងសាលាដំបូងរាជធានី-ខេត្ត នៃព្រះរាជាណាចក្រកម្ពុជា។

**ខ.ដែនកំណត់នៃការស្រាវជ្រាវ៖** គឺការសរសេររៀបរាប់ចាប់ពី **ដំណាក់កាលនគរបាលយុត្តិធម៌ រហូតដល់ដំណាក់កាលអង្គការអយ្យការ**។

## ៥.សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាទៅលើប្រធានបទណាមួយ គឺពិតជាមានការលំបាកណាស់ ព្រោះយើងត្រូវការចំណាយពេលវេលាច្រើន ចំណាយកម្លាំងកាយចិត្ត ក៏ដូចជាថវិកាជាដើម ជាពិសេសគឺត្រូវមានចំណងចំណូលចិត្ត និងការព្យាយាមបន្ថែមទៀតផងដែរ ទើបការសិក្សាស្រាវជ្រាវរបស់យើង ទទួលបានជោគជ័យ។

ទោះបីមានការលំបាកយ៉ាងណាក៏ដោយ ក៏យើងខ្ញុំនៅតែខិតខំជម្នះឱ្យទាល់តែបាន ពីព្រោះថាការសិក្សាស្រាវជ្រាវប្រធានបទនេះ គឺពិតជាមានសារៈសំខាន់ខ្លាំងណាសម្រាប់ យើងខ្ញុំ ដែលក្នុងនោះរួមមានដូចជា៖

-ទទួលបានចំណេះដឹងថ្មីៗ ពាក់ព័ន្ធនឹងវិធីសាស្ត្រស្រាវជ្រាវ

-ទទួលបាប្រភពឯកសារជាច្រើនដែលទាក់ទងទៅនឹងប្រធានបទ

-យល់ដឹងកាន់តែលម្អិតទៅលើប្រធានបទ ដែលបានសិក្សាស្រាវជ្រាវ

-ចេះធ្វើរបៀបប្រៀបធៀបរវាងចំណុចខ្លាំង ចំណុចខ្សោយ បញ្ហាប្រឈម និងដំណោះស្រាយ

-ធ្វើឱ្យកាន់តែច្បាស់បន្ថែមទៀត អំពីរបៀបប្រយោគ ឃ្លោងឃ្លា អក្ខរាវិរុទ្ធ

-ទទួលបានបទពិសោធន៍ល្អៗ ពីអ្នកមានចំណេះដឹង និងព្រមទាំងអ្នកមានបទពិសោធន៍

-ពិសេស គឺបានបន្សល់ស្នាដៃទុកសម្រាប់សិស្ស និស្សិត បានសិក្សាស្រាវជ្រាវបបន្តទៀត។

## ៦.វិធីសាស្ត្រនៃការស្រាវជ្រាវ

ចំពោះវិធីសាស្ត្រនៃការស្រាវជ្រាវ យើងខ្ញុំ បានខិតខំប្រើប្រាស់នូវវិធីសាស្ត្រជាច្រើនដើម្បីយកមកធ្វើការសរសេរសារណានេះឡើង ក្នុងនោះរួមមានដូចជា៖

**ក.កម្មវិធីប្រមូលទិន្នន័យ**

ដើម្បីធ្វើការប្រមូលទិន្នន័យ គឺយើងខ្ញុំ បានសម្រេចចិត្តរៀបរៀងសារណានេះឡើង ដោយបានធ្វើការប្រមូលទិន្នន័យ គឺតាមបែបគុណវិស័យ ដែលជាទិន្នន័យបានមកពីការ ប្រមូលឯកសារទ្រឹស្តី ព័ត៌មាន របាយការណ៍ ការជួបសម្ភាសន៍ ការសាកសួរដោយផ្ទាល់មាត់ និងការស្នើសុំឯកសារ ដើម្បីឱ្យដំណើរការនៃការស្រាវជ្រាវនេះទទួលបានជោគជ័យ។

ចំពោះប្រភព និងប្រភេទនៃវិធីប្រមូលទិន្នន័យ ឯកសារ ព្រមទាំងព័ត៌មានដែលបានសរសេរតាមគុណវិស័យរួមមាន៖

-រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ

-លិខិតបទដ្ឋានគតិយុត្ត យុត្តិសាស្ត្រ សាលក្រម សាលដីកា និងបទបញ្ញត្តិនានា

-របាយការណ៍ និងសៀវភៅមេរៀនរបស់សាស្ត្រាចារ្យផ្សេងៗ

-ការជួបសម្ភាសន៍ជាមួយសាស្ត្រាចារ្យ គ្រូដឹកនាំ ក៏ដូចជាស្ថាប័នដែលពាក់ព័ន្ធផងដែរ

-និងការប្រមូលឯកសារទិន្នន័យជាច្រើនទៀតតាមប្រព័ន្ធផ្សព្វផ្សាយនានា។

**ខ.វិធីចងក្រង បញ្ចូលទិន្នន័យ និងព័ត៌មាន**

បន្ទាប់ពីប្រមូលឯកសារ និងរបាយការណ៍បានគ្រប់គ្រាន់ហើយ យើងខ្ញុំបានប្រើប្រាស់វិធីចងក្រងឯកសារ ទៅតាមផ្នែកនីមួយៗ ដើម្បីកុំឱ្យមានការភ័ន្តច្រឡំគ្នា ហើយក៏បានចងក្រងឯកសារទាំងនោះបញ្ចូលគ្នាទៅក្នុងប្រព័ន្ធកុំព្យូទ័រទៅតាមប្រភេទ និងផ្នែកដែលបានព្រៀងទុក។

## ៧.រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ

ក្នុងរចនាសម្ព័ន្ធនៃការស្រាវជ្រាវប្រធានបទៈ **អំពីនគរបាលយុត្តិធម៌ និងអង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្ត** គឺបានបែងចែករចនាសម្ព័ន្ធនេះជា **៣ជំពូក** ដូចខាងក្រោមគឺ៖

**ជំពូកទី១ ការរំលឹកទ្រឹស្តី៖** ជាការប្រមូលទ្រឹស្តីច្បាប់នានា ដែលពាក់ព័ន្ធយកមកសរសេរ និងរឿងរ៉ាវខ្លះៗ ដែលនាំឱ្យកើតមានបទល្មើសព្រហ្មទណ្ឌ ព្រមទាំងព្រឹត្តិការណ៍ដដែលនាំឱ្យមានការកកើតប្រព័ន្ធតុលាការ។

**ជំពូកទី២ នគរបាលយុត្តិធម៌៖** គឺជាការសរសេររៀបរាប់យ៉ាងពិស្តារ អំពីតួនា ភារកិច្ច មុខងារ និងកិច្ចការសំខាន់ៗ របស់នគរបាលយុត្តិធម៌ ជាពិសេសគឺការស្វែងរកអំពីបញ្ហាប្រឈម ព្រមទាំងដំណោះស្រាយជាដើម។

**ជំពូកទី៣ អង្គការអយ្យការ៖** គឺជាការសរសេររៀបរាប់អំពីដំណើរការនៃ អង្គការអយ្យការ អំពីតួនាទី មុខងារ ភារកិច្ច ដើណើរការរឿងក្តីព្រហ្មទណ្ឌដំណាក់កាលអយ្យការ បញ្ហាប្រឈម និងដំណោះស្រាយ។

**សេចក្តីសន្និដ្ឋាន និងអនុសាសន៍៖** គឺជាការសរុបនូវខ្លឹមសារទាំងមូលនៃការសិក្សាស្រាវជ្រាវទៅលើប្រធាន និងជាការផ្តល់យោបល់ក្នុងការចូលរួមកែលម្អទៅលើប្រព័ន្ធគ្រប់គ្រងរដ្ឋបាល នៃនគរបាលយុត្តិធម៌ និងអង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ក្នុងន័យអភិវឌ្ឍដល់ស្ថាប័នទាំងពីរនេះឱ្យកាន់តែមានភាពរីកចម្រើន ដែលជាហេតុនាំឱ្យមានការផ្តល់ជូនយុត្តិធម៌ដល់បុគ្គលដែលរងគ្រោះ និងផ្តន្ទាទោសដល់ជនដែលប្រព្រឹត្តបទល្មើសឱ្យទាន់ពេលវេលា។

## គំនូសបំព្រួញនៃជំពូកនីមួយៗ



# ជំពូកទី១

# ការរំលឹកទ្រឹស្តី

# ជំពូកទី១
# ការរំលឹកទ្រឹស្តី

## ផ្នែកទី១៖ ប្រព័ន្ធស្ថាប័នតុលាការនៃព្រះរាជាណាចក្រកម្ពុជា

កាលសម័យអាណាចក្រភ្នំចេឡា សម័យអង្គរ។ល។ ការដាក់ទោស ឬការដាក់ពិន័យទៅលើជនណាម្នាក់វាប្រព្រឹត្តទៅដោយការបើកសវនការក្រោមព្រះរាជធិបតីភាពរបស់ព្រះមហាក្សត្រ ពោល គឺអំណាចវិនិច្ឆ័យទោសស្ថិតលើព្រះមហាក្សត្រ ដែលព្រះអង្គជាអ្នកកាន់កាប់អំណាចគ្រប់វិស័យទាំងអស់។ សម័យនោះ ព្រះមហាក្សត្រមានអំណាចធំធេងណាស់ និយាយរួមគឺអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ គឺព្រះអង្គជាអ្នកសម្រេច។ ដូច្នេះស្ថាប័នតុលាការនា សម័យនោះ ពុំទាន់មានទេ ទើបតែមានពេលប្រទេសបារាំងមកដាក់អាណានិគម មកលើប្រទេសខ្មែរ។ ក្រោយពីពេលបារាំងបានមកដាក់អាណានិគមលើប្រទេសខ្មែរតាំងពីឆ្នាំ១៨៦៣ មក បារាំងបានរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងដឹកនាំស្ថាប័នតុលាការពីរដាច់ពីគ្នាគឺ តុលាការជំនុំជម្រះក្តីមនុស្សក្នុងស្រុក និងតុលាការសហភាពបារាំង។ តុលាការជំនុំជម្រះក្តីមនុស្សក្នុងស្រុក ជាតុលាការដែលវិនិច្ឆ័យតែករណីវិវាទដែលបង្កឡើងដោយជនជាតិខ្មែរ ដោយជនជាតិខ្មែរដូចគ្នា ឬ ពិរុទ្ធជនជនជាតិខ្មែរតែប៉ុណ្ណោះ។ រីឯតុលាការសហភាពបារាំង ជាតុលាការដែលវិនិច្ឆ័យសេចក្តីចំពោះវិវាទដែលបង្កដោយជនជាតិបារាំង ឬ បរទេស។ ប្រសិនបើមានអំពើល្មើសណាមួយដែលពិរុទ្ធជនច្រើននាក់ ត្រូវជាប់ទោសពីបទផ្សំគំនិតដែលក្នុងនោះមានទាំងជនជាតិខ្មែរ ឬ ជនជាតិបារាំង ឬ ជនជាតិបរទេសផង នោះនីតិវិធីអាណានិគម និងធ្វើការបំបែករឿង ព្រមទាំងជនល្មើសដោយឡែកពីគ្នា ទៅតាមសមត្ថកិច្ចតុលាការផ្សេងៗពីគ្នា។ បើជនល្មើសជាជនជាតិខ្មែរ នោះសមត្ថកិច្ចរបស់តុលាការ ក្នុងស្រុកធ្វើការវិនិច្ឆ័យសេចក្តី បើសិនជនជាប់ចោទជាជនជាតិបារាំង ឬ ជនបរទេសវិញនោះ គឺជាសមត្ថកិច្ចរបស់តុលាការសហភាពបារាំងធ្វើការវិនិច្ឆ័យសេចក្តីសម្រេចក្តីវិញ។ នៅសម័យនោះ ប្រទេសកម្ពុជា មានសាលាជំនុំជម្រះក្តីតិចតួចណាស់។ មកដល់ពេលដែលសម័យប្រទេសកម្ពុជាទទួលបានឯករាជ្យពីអាណានិគមបារាំង នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ប្រទេសកម្ពុជា បានរៀបចំប្រទេសខ្លួនឡើងវិញ ហើយបានធ្វើវិសោធនកម្មជាបន្តបន្ទាប់នូវរដ្ឋធម្មនុញ្ញតាំងឆ្នាំ១៩៤៧ រហូតមកដល់ ការបង្កើតរដ្ឋធម្មនុញ្ញថ្មីនៅឆ្នាំ១៩៩៣។ បន្ទាប់ពីសម័យកម្ពុជាប្រជាធិបតេយ្យឆ្នាំ(១៩៧៥-១៩៧៩) បានបញ្ចប់រួចមកសម័យសាធារណៈរដ្ឋប្រជាមានិតមកម្ពុជាឆ្នាំ(១៩៧៩-១៩៩៣) បានឈានមកដល់ ហើយបានបង្កើតប្រព័ន្ធតុលាការសម័យសាធាណៈរដ្ឋប្រជាមានិតកម្ពុជា តាមរយៈច្បាប់ស្តីពីការចាត់តាំងអង្គការតុលាការ និងអង្គការអយ្យការដែល ប្រកាស់ឱ្យប្រើដោយក្រឹត្យលេខ០២ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨២ ដោយក្រុមប្រឹក្សារដ្ឋ។ តុលាការនេះជាតុលាការ ប្រជាជនខេត្តក្រុង ដែលជាតុលាការជាន់ដំបូងកាត់ក្តីជំនុំជម្រះឡើងវិញ។ នៅក្នុងឆ្នាំ១៩៨៥

តុលាការកំពូលក៏ ត្រូវបានបង្កើតឡើង (ដោយច្បាប់ស្តីពី ការបង្កើតតុលាការប្រជាជនកំពូល និងមហាអយ្យការអមតុលាការកំពូល ដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ២៨ ករ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៨៥ របស់ក្រុមប្រឹក្សារដ្ឋ)។ លុះដល់ អាជ្ញាធរអង្គការសហប្រជាជាតិនៅកម្ពុជាអ៊ុនតាក់ (UNTAC) បានមកដល់ប្រទេសកម្ពុជា អាជ្ញាធរអង្គការ សហប្រជាជាតិនេះបានជួយ រៀបចំវិស័យច្បាប់ និងប្រព័ន្ធតុលាការថ្មីមួយសម្រាប់ប្រទេសកម្ពុជា។ ពេលនេះហើយ ដែលប្រព័ន្ធតុលាការត្រូវបានបន្ថែមសាលាជម្រះក្តីមួយថ្នាក់ទៀតគឺ សាលាឧទ្ធរណ៍ និងនីតិវិធីព្រហ្មទណ្ឌនៅកម្ពុជាក្នុងសម័យអន្តរកាល។

## កថាខណ្ឌទី១៖ ប្រវត្តិស្ថាប័នតុលាការកម្ពុជា

នៅក្នុងសង្គម ដែលប្រកាន់របបប្រជាធិបតេយ្យ អំណាចត្រូវបានបែងចែកជាបីធំៗដាច់ចេញពីគ្នាគឺ **អំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ**។ ចំពោះរដ្ឋធម្មនុញ្ញរបស់ ប្រទេសកម្ពុជាបច្ចុប្បន្ន ក៏មានការបែងចែកអំណាចទាំងបី ដាច់ដោយឡែកពីគ្នាផងដែរ គឺចាប់ពីជំពូកទី៧ រហូតដល់ ជំពូកទី១២ថ្មី។

ពាក្យថា "**អង្គការនីតិប្បញ្ញត្តិ**" គឺសំដៅទៅលើស្ថាប័នសភា ដែលមាន **រដ្ឋសភា និងព្រឹទ្ធសភា**។ សភានេះគឺមានតួនាទី "**តាក់តែងច្បាប់ និងអនុម័តច្បាប់**"។

សូមកត់សម្គាល់ថា បើគេប្រើពាក្យថា **សភា** គឺសំដៅលើស្ថាប័ននីតិប្បញ្ញត្តិ ឬ ពាក្យទូទៅដែលគេកត់សម្គាល់នូវសភាទាំងពីរថ្នាក់គឺ **រដ្ឋសភា និងព្រឹទ្ធសភា**។ តែបើគេចង់និយាយឱ្យចំឈ្មោះនីមួយៗ គឺគេប្រើពាក្យថា រដ្ឋសភា ឬព្រឹទ្ធសភា។

ពាក្យថា "**អង្គការនីតិប្រតិបត្តិ**" គឺសំដៅទៅលើរដ្ឋាភិបាល ដែលមានសមាសភាពចាប់ពី នាយករដ្ឋមន្ត្រី សមាជិកគណៈរដ្ឋមន្ត្រី ក្រសួងនានា និងរដ្ឋលេខាធិការដ្ឋានមួយចំនួនទៀតផង។

អង្គការនីតិប្រតិបត្តិមានតួនាទីគឺ "**ប្រតិបត្តិច្បាប់ ឬអនុវត្តច្បាប់ និងគោលនយោបាយទាំងឡាយណាដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានផ្តល់ការយល់ព្រម**" ចប់សព្វគ្រប់។

ពាក្យថា "**តុលាការ**" គឺសំដៅទៅលើសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់គឺ "**តុលាការកំពូល សាលាឧទ្ធរណ៍ និងសាលាដំបូង**" ដែលមានតុលាការរាជធានី-ខេត្ត និងតុលាការយោធា។ សាលាជម្រះក្តី មានតួនាទីកាត់ក្តីលើគ្រប់រឿងក្តីទាំងអស់ រួមទាំងរឿងរដ្ឋបាល និងពាណិជ្ជកម្មផងដែរ[1]។

[1] និពន្ធដោយ ឯឧត្តម តន យឿន សៀវភៅ មូលដ្ឋានច្បាប់ និងស្ថាប័នច្បាប់ បោះពុម្ពលើកទី៣ ទំព័រ១៥

តាមការមកដល់របស់អ៊ុនតាក់ (UNTAC) នៅឆ្នាំ១៩៩២ បាននាំមកនូវការផ្លាស់ប្តូរដ៏សំខាន់នៅក្នុងប្រព័ន្ធតុលាការនៅកម្ពុជា។ សាលាឧទ្ធរណ៍ ត្រូវបានបង្កើតឡើង ដែលជាលទ្ធផលកើតជាប្រព័ន្ធតុលាការដែលមានពីរជាន់ (ជាន់ខ្ពស់ និងជាន់ទាប) ហើយចែកចេញជាបីថ្នាក់គឺ៖

ក.សាលាដំបូងរាជធានី-ខេត្ត (តុលាការថ្នាក់ទី១)

ខ.សាលាឧទ្ធរណ៍ និង (តុលាការថ្នាក់ទី២)

គ.តុលាការកំពូល (តុលាការថ្នាក់ទី៣ និងជាថ្នាក់ចុងក្រោយ)

ព័ត៌មានលម្អិតមានចែងនៅក្នុង **"ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី"** ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៣[2]។

### ១.១.អំពីសាលាដំបូងរាជធានី-ខេត្ត

សាលាដំបូង គឺជាតុលាការជាន់ទាប ដែលក្នុងនោះរួមមាន តុលាការរាជធានី-ខេត្ត និងតុលាការយោធា។ យុត្តាធិការ របស់តុលាការនីមួយៗ គ្របដណ្តប់លើតំបន់ភូមិសាស្ត្រជាក់លាក់ណាមួយ ដែលតុលាការស្ថិតនៅ។ លើកលែងតែតុលាការយោធាមួយប៉ុណ្ណោះ ដែលមានយុត្តាធិការគ្របដណ្តប់លើទឹកដី នៃព្រះរាជាណាចក្រកម្ពុជាទាំងមូល។

តុលាការនេះ គឺជាតុលាការជម្រះក្តីថ្នាក់ទាបបំផុត។ ជាគោលការណ៍ សាលាដំបូងរាជធានី ឬ សាលាដំបូងខេត្តមានពីរផ្នែកគឺ ផ្នែករដ្ឋប្បវេណី និងផ្នែកព្រហ្មទណ្ឌ។ ប៉ុន្តែនៅក្នុងការអនុវត្តន៍ ដោយសារចំនួនចៅក្រមនៅមានកម្រិតនៅឡើយ គេពុំទាន់ឃើញមានការបែងចែកឱ្យច្បាស់លាស់រវាង ផ្នែកទាំងពីរនេះនៅឡើយទេ។ ចៅក្រម អាចដោះស្រាយរឿងក្តីរដ្ឋប្បវេណី និងរឿងក្តីព្រហ្មទណ្ឌ។ ចៅក្រម តែងតែសម្រេចលើករណីទាំងអស់ក្នុងនាមជា ចៅក្រមតែមួយ[3]។

### ១.២.អំពីតុលាការយោធា

តុលាការយោធា មានទីតាំងនៅរាជធានីភ្នំពេញ។ តុលាការនេះ គឺជាតុលាការដំបូង ដែលមានយុត្តាធិការផ្តាច់មុខលើករណីទាំងឡាយ ដែលប្រព្រឹត្តឡើងដោយកងយោធា ដែលពាក់ព័ន្ធនឹង៖

-បទល្មើសយោធា (ការរំលោភករណីកិច្ចយោធា ការប្រព្រឹត្តខុសវិន័យយោធា)។ និង

-បទល្មើសណាមួយ ដែលប៉ះពាល់ដល់ទ្រព្យសម្បត្តិកងទ័ព។

---

[2] វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ សៀវភៅសិក្សាផ្នែកទី៣ ប្រព័ន្ធតុលាការ ទំព័រ៨

[3] វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ សៀវភៅសិក្សាផ្នែកទី៣ ប្រព័ន្ធតុលាការ ទំព័រ៨

បទល្មើសធម្មតាផ្សេងៗទៀត (ដូចជា ឃាតកម្ម មនុស្សឃាតដោយអចេតនា) ដែលបង្កើតឡើងដោយកងយោធិន គឺត្រូវនៅក្រោមយុត្តាធិការរបស់សាលាដំបូងរាជធានី-ខេត្ត។ តុលាការយោធាត្រូវ ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ក្រសួងការពារជាតិ ខាងផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និងផ្នែកបរិក្ខារ[4]។

## កថាខណ្ឌទី២៖ មូលហេតុនៃរឿងក្តីព្រហ្មទណ្ឌ

ដោយសារតែការរស់នៅមិនចុះសម្រុងគ្នា រវាងសត្វ និងសត្វ, សត្វ និងមនុស្ស, មនុស្ស និងមនុស្សដែលជាហេតុធ្វើឱ្យសង្គមមានភាពរីករវ ព្រោះតែមានការបៀតបៀន ការកាប់សម្លាប់ជិះជាន់ គ្នាទៅវិញទៅមក។ ព្រោះតែហេតុដូច្នេះហើយ បានជាលោក **ហ្សង់ហ្សាក់ រ៉ូស្សូ** (Jean Jacques Rousseau) ជាទស្សនវិទូបារាំង ជាអ្នកទ្រឹស្តីនយោបាយ និងអ្នកក្រមសីលធម៌ គឺបានវិភាគមិនប្លែក ពីអ្នកនិពន្ធដទៃទៀតនៅជំនាន់នោះទេ គឺការវិភាគដែលចេញពីសភាពធម្មជាតិជាមូលដ្ឋាន។ នៅក្នុងសភាពធម្មជាតិ អ្នកខ្លាំងមានជ័យជំនះលើអ្នកខ្សោយ ហើយមានតែជម្លោះ សង្គ្រាម ការប្រឆាំង និងចលាចល។ ដូច្នេះហើយមនុស្សមានផ្លូវតែមួយគត់ គឺការរត់ទៅជ្រកកោនក្រោមដំបូលរបស់រដ្ឋ ឱ្យជួយការពារខ្លួន។ លោកបានលើកឡើងថា **"នៅក្នុងសង្គមមនុស្សប្រៀបបីដូចជាហ្វូងឆ្កែចចក ដែលចាំតែហែកហួរខាំគ្នាទៅវិញទៅមក ដើម្បីចិញ្ចឹមជីវិតរបស់ខ្លួន"**។

នៅក្នុងទ្រឹស្តីនយោបាយ ស្នាដៃរបស់លោកដ៏សំខាន់មួយគឺ **"កិច្ចព្រមព្រៀងសង្គម"** ដែលបានសរសេរនៅឆ្នាំ១៧៦២។ មានន័យថា ដើម្បីឱ្យសង្គមមនុស្សរស់នៅសុខដុមរម្យនា និងឆន្ទៈរួមគ្នា គឺមនុស្សគ្រប់រូបត្រូវការច្បាប់ដើម្បីរារាំងទប់ស្កាត់ និងកុំឱ្យមានការរំលោភបំពានកើតឡើង។

ដើម្បីឱ្យមានការកើនឡើងនូវឆន្ទៈរួម លោកបានគិតថា ជាការចាំបាច់ត្រូវការនូវលក្ខន្តិកៈមួយចំនួន ហើយជាបឋម គឺសមភាពនៅក្នុងសម្បត្តិឯកជន គឺជា **"ច្បាប់សង្គម"**។

ទោះបីរដ្ឋបានបង្កើត និងចងក្រងនូវវិធានច្បាប់នានាដើម្បីការពារដល់សមាជិកសង្គមយ៉ាងណាក៏ដោយ ក៏នៅតែមានមនុស្សមួយចំនួន ដែលតែងតែប្រព្រឹត្តខុសច្បាប់ ហើយធ្វើការរំលោភបំពានទៅលើច្បាប់ដដែល។

ដើម្បីការពាររបបសង្គម សណ្តាប់ធ្នាប់សារធារណៈ និងរបៀបរៀបរយសង្គម រដ្ឋបានប្រើប្រាស់នូវវិធានការផ្សេងៗ ដែលមានចរិកកែលម្អផង និងមានលក្ខណៈបង្ខិតបង្ខំផង។ គ្រប់បទដ្ឋានគតិយុត្តដែលបានដាក់ចេញឱ្យប្រើប្រាស់ក្នុងគោលបំណងចាត់តាំង និងគ្រប់គ្រងសង្គម ដែលតែងតែមានលក្ខណៈបង្ខិតបង្ខំដើម្បីអនុវត្ត និងទប់ទល់ជាមួយនឹងអំពើរំលោភបំពាន។ បើអំពើរំលោភបំពានមានលក្ខណៈធ្ងន់ធ្ងរ បង្កឱ្យមានអន្តរាយធំធេងនោះ រដ្ឋត្រូវប្រើប្រាស់នូវវិធានការខ្លាំងក្លា និងមានលក្ខណៈបង្ខិតបង្ខំតាមច្បាប់ព្រហ្មទណ្ឌ ឬ លិខិតបទដ្ឋាន

[4] វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ សៀវភៅសិក្សាផ្នែកទី៣ ប្រព័ន្ធតុលាការ ទំព័រ៩

គតិយុត្តព្រហ្មទណ្ឌ ដែលបានកំណត់ អំពីការរំលោភបំពាននោះ ហើយនឹងផ្តន្ទាទោសទៅលើជនដែលបានប្រព្រឹត្តបទល្មើស[5]។

## ២.១.ដំណាក់កាលនៃនីតិវិធីព្រហ្មទណ្ឌ

នីតិវិធីព្រហ្មទណ្ឌ គឺជាច្បាប់ ដែលសិក្សាពីរបៀបរបបនៃការរៀបចំអំណាចតុលាការជាជាន់ជាថ្នាក់ ការរៀបចំជានីតិវិធីដើម្បីតម្រូវឱ្យសាលាជម្រះក្តី គោរពតាមគោលការណ៍ ដែលត្រូវគោរពសិទ្ធិ និងសេរីភាពបុគ្គលក្នុងការឃាត់ខ្លួន ឃុំខ្លួន និងនីតិវិធីផ្សេងៗទៀត ដើម្បីត្រួតពិនិត្យការអនុវត្តច្បាប់ដោយអង្គការតុលាការគ្រប់ជាន់ថ្នាក់។

រឿងក្តីព្រហ្មទណ្ឌ គឺជាបាតុកម្មតាមផ្លូវតុលាការរបស់សង្គម មានន័យថា នៅពេលណាដែលមានការរំលោភបំពានច្បាប់ ឬ វិធានដែលគ្រប់គ្រងសង្គម និងមានប្រតិកម្មតបមួយ និយាយឱ្យខ្លី ចាប់ពីបទល្មើសមួយត្រូវបានប្រព្រឹត្ត រហូតដល់ការដាក់ទណ្ឌកម្ម គឺមានទំនាក់ទំនងមួយ និងមាននីតិវិធីមួយត្រូវបានដំណើរការ ហៅថា **រឿងក្តីព្រហ្មទណ្ឌ**។ និយាយឱ្យងាយជាងនេះ រឿងក្តីព្រហ្មទណ្ឌ កើតមាននៅពេលដែលបទល្មើសមួយចាប់ផ្តើមកើតឡើង រហូតដល់ការដាក់ទណ្ឌកម្ម និងការអនុវត្តទណ្ឌកម្ម ហើយវិធានដែលទាក់ទងដល់ការរៀបចំ និងការបព្រឹត្តទៅ ការវិនិច្ឆ័យនៃរឿងក្តីព្រហ្មទណ្ឌនេះ បង្កើតបានជាសំណុំមួយហៅថា **នីតិវិធីព្រហ្មទណ្ឌ**។

រីឯ នីតិវិធីព្រហ្មទណ្ឌ ជាវិធានដែលគ្រប់គ្រងដល់ការរៀបចំ និងការប្រព្រឹត្តទៅនៃការវិនិច្ឆ័យរឿងក្តីព្រហ្មទណ្ឌ ដើម្បីធានាប្រសិទ្ធភាព នៃដំណើរការក្នុងការរកយុត្តិធម៌ជូនប្រជាពលរដ្ឋ។ ហើយនីតិវិធីព្រហ្មទណ្ឌនេះ ត្រូវបានរៀបចំឡើងនៅក្នុងគោលដៅសំខាន់ៗជាអាទិ៍ដូចជា ទាក់ទងនឹងការកំណត់សមត្ថកិច្ច ការប្រព្រឹត្តទៅរបស់យុត្តាធិការព្រហ្មទណ្ឌ ជាពិសេសដែលយើងហៅថាតុលាការព្រហ្មទណ្ឌ តាមរចនាសម្ព័ន្ធសព្វថ្ងៃមាន បីថ្នាក់។ នីតិវិធីព្រហ្មទណ្ឌនេះផងដែរ ក៏ទាក់ទងដល់បែបបទនីតិវិធីនៃការត្រួតពិនិត្យ ការចោទប្រកាន់បទល្មើស ការស្រាវជ្រាវរកជនល្មើស ការស្វែងរកភស្តុតាង ព្រមទាំងនីតិវិធីនៃការជំនុំជម្រះជនល្មើស ហើយក៏ទាក់ទង ផងដែរដល់ការរៀបចំផ្លូវនៃបណ្តឹងតវ៉ា ចំពោះការសម្រេចរបស់តុលាការព្រហ្មទណ្ឌ បែបបទនៃការអនុវត្តទោសព្រហ្មទណ្ឌ។

នីតិវិធីព្រហ្មទណ្ឌ នៃប្រទេសកម្ពុជា ត្រូវបានគ្រប់គ្រងដោយក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើនៅឆ្នាំ២០០៧ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ប្រកាសឱ្យប្រើនៅឆ្នាំ២០១៤ និងមានច្បាប់ពិសេសជាច្រើនទៀតផងដែរ[6]។

ចំពោះដំណាក់កាល នៃនីតិវិធីព្រហ្មទណ្ឌទាំងនោះ រួមមានដូចជា៖

ក.បណ្តឹងក្នុងរឿងក្តីព្រហ្មទណ្ឌ

[5] សាស្ត្រាចារ្យ ឆឹង ស៊ីនៀង សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ ទំព័រ៦ ឆ្នាំសិក្សា២០១៦-២០១៧

[6] សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត សៀវភៅ នីតិវិធីព្រហ្មទណ្ឌ ទំព័រ០១ ឆ្នាំ២០១៧-២០១៨

ខ.ភាគីក្នុងរឿងក្ដីព្រហ្មទណ្ឌ

គ.ភស្តុតាងក្នុងរឿងក្ដីព្រហ្មទណ្ឌ

ឃ.អំពីនគរបាលយុត្តិធម៌

ង.អំពីអង្គការអយ្យការ

ច.អំពីចៅក្រមស៊ើបសួរ

ឆ.អំពីចៅក្រមជំនុំជម្រះ និង

ជ.អំពីបណ្ដឹងតវ៉ា។

## ២.២.តួអង្គសំខាន់ៗក្នុងរឿងក្ដីព្រហ្មទណ្ឌ

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តនៅឆ្នាំ២០០៧ កំណត់អំពីតួនាទី និងការទទួលខុសត្រូវរបស់ភាគីផ្សេងៗ នៃដំណើរការរឿងក្ដីព្រហ្មទណ្ឌ។

យ៉ាងណាមិញ ចំពោះតួអង្គសំខាន់ៗ នៅក្នុងរឿងក្ដីព្រហ្មទណ្ឌរួមមានដូចជា៖

១. **អង្គការអយ្យការ** គឺជាម្ចាស់នៃបណ្ដឹងអាជ្ញា មាននៅគ្រប់ស្ថាប័នសាលាជម្រះក្ដី បំពេញតួនាទីការពារផលប្រយោជន៍ និងសណ្ដាប់ធ្នាប់សាធារណៈ។ នៅពេលពិនិត្យអង្គហេតុណាមួយ ដែលជាបទល្មើស អយ្យការត្រូវធ្វើការចោទប្រកាន់ និងសុំឱ្យអនុវត្តច្បាប់ចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ។

**២. ជនសង្ស័យ ជនល្មើស ជនត្រូវចោទ ពិរុទ្ធជន ឬ ទណ្ឌិត**

**ជនល្មើស** គឺជារូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលប្រព្រឹត្តនូវអំពើល្មើសច្បាប់ណាមួយ ដែលខ្លួនត្រូវទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនតាមកំណត់ច្បាប់។ ការប្រើប្រាស់វាក្យស័ព្ទចំពោះជនដែលប្រព្រឹត្តបទល្មើសនេះគឺប្រែប្រួលទៅតាមដំណាក់កាលនីមួយៗ នៃនីតិវិធីក្នុងរឿងព្រហ្មទណ្ឌដូចជា នៅដំណាក់កាលដំបូង នៃនីតិវិធីនៅពេល ជនម្នាក់ត្រូវបានឃាត់ខ្លួនដោយនគរបាលយុត្តិធម៌គេប្រើពាក្យ "**ជនសង្ស័យ ឬ ក៏ជនល្មើស**" តែម្ដង។ ក៏ប៉ុន្តែ ជនសង្ស័យ គឺប្រើសម្រាប់បទល្មើសមិនជាក់ស្ដែង រីឯ ជនល្មើស គឺប្រើសម្រាប់បទល្មើសជាក់ស្ដែង។

នៅដំណាក់កាលអយ្យការ បានចាប់ផ្ដើមធ្វើការចោទប្រកាន់ជនសង្ស័យប្រែក្លាយទៅជា "**ជនត្រូវចោទ**"។ "**ជនត្រូវចោទ**" ត្រូវប្រើរហូតដល់មានដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ ដោយត្រូវហៅថា "**ជនជាប់ចោទ**"។ ក្រោយពីមានសេចក្ដីសម្រេចផ្ដន្ទាទោស (សាលក្រម) លើជនជាប់ចោទហើយ គេហៅជនជាប់ចោទថា "**ពិរុទ្ធជន**"។ ហើយបន្ទាប់ពីសាលក្រម ឬ សាលដីដែលជាសេចក្ដីសម្រេចផ្ដន្ទាទោសពិរុទ្ធជនចូលជាស្ថាពរ ជននេះត្រូវ ហៅថា "**ទណ្ឌិត**" ដែលជាជនត្រូវអនុវត្តទោសក្នុងពន្ធនាគារ។

៣. **ជនរងគ្រោះ** គឺជាបុគ្គលដែលទទួលរងគ្រោះដោយផ្ទាល់ ពីអំពើល្មើសរបស់ជនដែលប្រព្រឹត្តបទល្មើស។ ការខូចខាតដែលជនរងគ្រោះទទួលរងអាចជា ព្យសនកម្មខាងរូបកាយ ផ្លូវចិត្ត ទ្រព្យសម្បត្តិជាដើម។

៤. **ដើមបណ្ដឹងរដ្ឋប្បវេណី** មានក្នុងរឿងក្ដីព្រហ្មទណ្ឌ នៅពេលដែលជនរងគ្រោះ នៃរឿងក្ដីនោះជាអនីតិជន ឬ ជនស្ថិតក្រោមរបបអាណាព្យាបាលទូទៅ ឬ ជនស្ថិតក្រោមហិតូបត្ថម្ភ ដែលតម្រូវឱ្យអ្នកមានសិទ្ធិគ្រប់គ្រងលើជនរងគ្រោះដែលជាអនីតិជន ជនស្ថិតក្រោមរបបអាណាព្យាបាលទូទៅ ឬ ជនស្ថិតក្រោមហិតូបត្ថម្ភ ឬ សិទ្ធិវន្តរបស់ជនរងគ្រោះ អាចតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីទាមទារសំណងរដ្ឋប្បវេណីពីជនល្មើស។ ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវធ្វើឡើងក្នុងនាមផលប្រយោជន៍របស់ជនរងគ្រោះ និងអាចធ្វើនៅពេលណាក៏បាន ដរាបណាចៅក្រមមិនទាន់សម្រេចលើអង្គហេតុទនោះ។

៥. **អ្នកទទួលខុសត្រូវរដ្ឋប្បវេណី** គឺជាជនទាំងឡាយណា ដែលច្បាប់តម្រូវឱ្យទទួលខុសត្រូវខាងសំណងរដ្ឋប្បវេណី ចំពោះទង្វើរបស់ជនល្មើស ដែលជននោះកំពុងស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកទទួល ខុសត្រូវរដ្ឋប្បវេណីដែលច្បាប់ទទួលស្គាល់។ ដែលអ្នកទទួលខុសត្រូវរដ្ឋប្បវេណីអាចជា៖

-ឪពុកម្ដាយ ឬ អាណាព្យាបាលរបស់ជនល្មើសដែលជាអនីតិជន

-អ្នកមានសិទ្ធិជាអាណាព្យាបាលទូទៅ ឬ ហិតូបត្ថម្ភកៈរបស់ជនល្មើស

-សិទ្ធិវន្តរបស់ជនល្មើស

-និយោជិករបស់ជនល្មើស និង

-ក្រុមហ៊ុនធានារ៉ាប់រង។

# ជំពូកទី២
# អំពីនគរបាលយុត្តិធម៌

# ជំពូកទី២
# អំពីនគរបាលយុត្តិធម៌

## ផ្នែកទី១៖ សមាសភាពនគរបាលយុត្តិធម៌

### កថាខណ្ឌទី១៖ មន្ត្រីនគរបាលយុត្តិធម៌

នគរបាលយុត្តិធម៌ គឺជាជំនួយរបស់អំណាចតុលាការ និងមានភារកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ កំណត់អត្តសញ្ញាណ និងចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាង[7]។

មន្ត្រីរាជការចំនួន បី ជំពូកដែលអាចទទួលបាននូវគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ជាអាទិ៍ដូចជា៖

- មន្ត្រីនគរបាល នៃនគរបាលជាតិ
- នាយទាហាន នៃកងរាជអាវុទ្ធហត្ថ និង
- មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតដែលច្បាប់ដោយឡែកប្រគល់អំណាចឱ្យ។

ដើម្បីអាចក្លាយទៅជាមន្ត្រីនរគបាលយុត្តិធម៌ គឺត្រូវតែទទួលគុណសម្បត្តិតាមរយៈ៖

#### ១.១.ការទទួលបានតាមរយៈឋានន្តរស័ក្ក

- នៅក្នុងក្របខ័ណ្ឌនគរបាលជាតិ អ្នកដែលមានឋានៈជាមន្ត្រីនគរបាលយុត្តិធម៌គឺ មន្ត្រីនគរបាលជាតិដែលមានឋានន្តរសក្តិចាប់ពីអនុសេនីយ៍ត្រីឡើងទៅ ដែលបានបម្រើការងារយ៉ាងតិចពីរឆ្នាំ ក្នុងនគរបាលជាតិ ហើយបន្ទាប់ពីបានទទួលសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌។ មន្ត្រីនគរបាល នៃនគរបាលជាតិ ដែលមានសញ្ញាបត្រនៃមន្ត្រីនរបាលតុលាការ មុនពេលក្រមនីតិវិធីព្រហ្មទណ្ឌនេះចូលជាធរមាន ត្រូវទទួលបានដោយស្វ័យប្រវត្តិ នូវសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌។

- នៅក្នុងកងរាជអាវុធហត្ថ អ្នកដែលមានឋានៈជានគរបាលយុត្តិធម៌ គឺនាយទាហាន នៃកងរាជអាវុធហត្ថដែលបានបម្រើការងារយ៉ាងតិចពីរឆ្នាំ ក្នុងកងរាជអាវុធហត្ថ ហើយបន្ទាប់ពីបានទទួលសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌។ នាយទាហាននៃកងរាជអាវុធហត្ថ ដែលមានសញ្ញាប័ត្រនៃមន្ត្រីនគរបាលតុលាការមុនក្រមនីតិវិធីព្រហ្មទណ្ឌនេះចូលជាធរមាន ត្រូវទទួលបានដោយស្វ័យប្រវត្តិ នូវសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌។

រដ្ឋមន្ត្រីអាណាព្យាបាលនៃមន្ត្រីនគរបាល ឬ ជាអាណាព្យាបាលនៃនាយទាហានកងរាជអាវុធហត្ថទាំងឡាយ ដែលមានចែងនៅក្នុងចំណុចខាងលើនេះ មានភារកិច្ចតែងតាំងមន្ត្រីនគរបាល ឬ នាយទាហាននៃកងរាជអាវុធហត្ថទាំងឡាយណា ដែលត្រូវបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ ដោយប្រកាសរួមជាមួយរដ្ឋ

---

[7] មាត្រា ៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

មន្ត្រីក្រសួងយុត្តិធម៌[8]។

### ១.២.ការទទួលបានតាមរយៈការប្រឡងប្រជែង

ចំពោះមន្ត្រីនគរបាលយុត្តិធម៌ក្នុង ពីរ ជំពូកដំបូងនេះ សញ្ញាប័ត្រជាន់ខ្ពស់នៃនគរបាលយុត្តិធម៌ ត្រូវផ្តល់ជូនបន្ទាប់ពីឆ្លងកាត់ការប្រឡងបែបវិជ្ជាជីវៈ ដែលរួមមានវិញ្ញាសាជាមូលដ្ឋាន ដូចខាងក្រោម៖

១- វិញ្ញសាស្តីពីនីតិព្រហ្មទណ្ឌខ្មែរ

២- វិញ្ញសាស្តីពីនីតិវិធីព្រហ្មទណ្ឌខ្មែរ និង

៣- វិញ្ញសាស្តីពីករណីកិច្ចសាស្រ្ត ដូចដែលមានចែងនៅក្នុងក្រមសីលធម៌ ដែលតាក់តែងដោយអង្គការសហប្រជាជាតិ។

គណៈមេប្រយោគនៃការប្រលង ស្ថិតក្រោមអធិបតីភាពរបស់ អគ្គព្រះរាជអាជ្ញា ឬ ចៅក្រមអយ្យការអមតុលាការកំពូលដែលទទួលមុខងារនេះ៖

១-ទាក់ទងនឹងមន្ត្រីនគរបាលជាតិ គណៈមេប្រយោគមានសមាសភាពដូចតទៅ៖

-ចៅក្រមស៊ើបសួរម្នាក់ ដែលតែងតាំងដោយប្រធានតុលាការកំពូល

-ចៅក្រមអយ្យការម្នាក់ ដែលតែងតាំងដោយអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

-តំណាងពីររូប របស់ក្រសួរមហាផ្ទៃ។

២-ទាក់ទងនឹងយោធិន នៃកងរាជអាវុទ្ធហត្ថ គណៈមេប្រយោគមានសមាសភាពដូចតទៅ៖

-ចៅក្រមស៊ើបសួរម្នាក់ ដែលតែងតាំងដោយប្រធានតុលាការកំពូល

-ចៅក្រមអយ្យការម្នាក់ ដែលតែងតាំងដោយអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

-តំណាងពីររូប របស់ក្រសួងការពារជាតិ។

បែបបទនៃការចេញសញ្ញាប័ត្រ ត្រូវកំណត់ដោយប្រកាសរួមមួយ រវាងរដ្ឋមន្ត្រីពាក់ព័ន្ធ។ សញ្ញាប័ត្រនេះត្រូវចុះហត្ថលេខារួមដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីសាមី ព្រមទាំងមានការបោះត្រាផង[9]។

### ១.៣.ការទទួលបានដោយស្វ័យប្រវត្តិ

អ្នកដែលមានឋានន្តរស័ក្ត និងមុនងារដូចខាងក្រោមត្រូវទទួលដោយស្វ័យប្រវត្តិ នូវគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌៖

ក. អភិបាល និងអភិបាលរង ខេត្ត ក្រុង អភិបាល និងអភិបាលរង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់។

---

[8] មាត្រា ៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[9] យោង មាត្រា ៦១ និងមាត្រា ៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ខ. ប្រធាន និងអនុប្រធាននាយកដ្ឋានកណ្ដាលនគរបាលយុត្តិធម៌ ប្រធាន និងអនុប្រធាននាយកដ្ឋានកណ្ដាលសន្តិសុខ និងប្រធាន និងអនុប្រធាននាយកដ្ឋានកណ្ដាលសណ្ដាប់ធ្នាប់សាធារណៈ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ។

គ. ប្រធាន និងអនុប្រធាននាយកដ្ឋាន ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែកដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ និងស្ថិតក្រោមឱវាទរបស់នាយកដ្ឋានកណ្ដាលនគរបាលយុត្តិធម៌ និងនាយកដ្ឋានកណ្ដាលសន្តិសុខ និងនាយកដ្ឋានកណ្ដាលសណ្ដាប់ធ្នាប់សាធារណៈ។

ឃ.ប្រធាន និងអនុប្រធាននាយកដ្ឋាន ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែកនៃ៖

- នាយកដ្ឋាននគរបាលព្រំដែន "ចំពោះបទល្មើសឆ្លងដែន"
- មន្ទីរប្រឆាំងគ្រឿងញៀន
- នាយកដ្ឋាននគរបាលទេសចរណ៍ និងស្នងការពិសេសការពារបេតិកភ័ណ្ឌ។

ង. ស្នងការ ស្នងការរងនគរបាលខេត្ត ក្រុង។

ច. ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែកដែលទទួលបន្ទុកការងារព្រហ្មទណ្ឌចំណុះស្នងការនគរបាលខេត្ត ក្រុងដូចជា៖

- ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតធ្ងន់ និងការិយាល័យព្រហ្មទណ្ឌកំរិតស្រាល
- ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន
- ការិយាល័យនគរបាលសេចដ្ឋកិច្ច
- ការិយាល័យបច្ចេកទេសវិទ្យាសាស្ត្រព្រហ្មទណ្ឌ
- ការិយាល័យប្រឆាំងគ្រឿងញៀន
- ការិយាល័យប្រឆាំងភេរវកម្ម និង
- ការិយាល័យជនបរទេស។

ឆ. អធិការ និងអធិការរង ប្រធាន និងអនុផ្នែកព្រហ្មទណ្ឌនៃអធិការដ្ឋាននគរបាល ស្រុក ខណ្ឌ។

ជ. ប្រធាន និងអនុប្រធានការិយាល័យនគរបាលចរាចរ ប្រធាន និងអនុផ្នែក នគរបាលចរាចរ "ចំពោះបទល្មើសចរាចរ"។ ប្រធាន និងអនុប្រធានការិយាលល័យគ្រប់គ្រងអាវុធជាតិផ្ទុះ ប្រធាន និងអនុប្រធានផ្នែកការិយាល័យ គ្រប់គ្រងអាវុធជាតិផ្ទុះ "ចំពោះបទល្មើសអាវុធជាតិផ្ទុះ"។ ប្រធាន និងអនុប្រធានអង្គភាព ប្រធាន និងអនុប្រធានការិយាល័យនគរបាលទេសចរណ៍ ប្រធាន និងអនុប្រធានផ្នែកនៃការិយាល័យនគរបាលទេសចរណ៍។

ឈ. ប្រធាន និងអនុប្រប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំសង្កាត់ "ចំពោះបទល្មើសព្រហ្មទណ្ឌ"។

ញ. មេបញ្ជាការ និងមេបញ្ជាការរង នៃកងរាជអាវុធហត្ថ ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

ដ. មេបញ្ជាការ និងមេបញ្ជារងកងរាជអាវុធហត្ថ ប្រចាំខេត្ត ក្រុង ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

ឋ. មេបញ្ជាការ និងមេបញ្ជាការរងកងរាជអាវុធហត្ថប្រចាំស្រុក ខណ្ឌ ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

ឌ. ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែកកងរាជាអាវុធ ទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

ឍ. ប្រធាន និងអនុប្រធាន អង្គភាពផ្នែកផ្សេងទៀតដែលទទួលបន្ទុកកិច្ចការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌដែលត្រូវបានបង្កើតឡើងក្នុងករណីចាំបាច់។

រដ្ឋមន្ត្រីអាណាព្យាបាលនៃមន្ត្រីនគរបាល ឬ ជាអាណាព្យាបាលនៃនាយទាហាននៃកងរាជអាវុធហត្ថទាំងឡាយ ដែលមានចែងនៅក្នុងចំណុចខាងលើនេះ មានភារកិច្ចតែងតាំងមន្ត្រីនគរបាល ឬ នាយទាហាននៃកងរាជអាវុធហត្ថទាំងឡាយណា ដែលត្រូវបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ ដោយប្រកាសរួមជាមួយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ជាចុងក្រោយ មន្ត្រីនគរបាលយុត្តិធម៌ម្នាក់ៗ ត្រូវស្បថថាខ្លួននឹងបំពេញដោយភក្តីភាពនូវមុខងាររបស់ខ្លួន ហើយសម្បថនេះត្រូវធ្វើនៅមុខសាលាឧទ្ធរណ៍។ សម្បថនេះមិនចាំបាច់ធ្វើជាថ្មីម្តងទៀតឡើយ នៅពេលដែលបានទទួលនីតិសម្បទានជាមន្ត្រីនគរបាលយុត្តិធម៌នាពេលក្រោយទៀត។ រូបមន្តនៃសម្បថត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រិក្រសួងយុត្តិធ៌ម[10]។

## កថាខណ្ឌទី២៖ ភ្នាក់ងារនគរបាលយុត្តិធម៌

ភ្នាក់ងារនគរបាលយុត្តិធម៌ គឺជាជំនួយដល់មន្ត្រីនគរបាលយុត្តិធម៌ ដើម្បីបំពេញភារកិច្ច។

ភ្នាក់ងារនគរបាលយុត្តិធម៌ មានអំណាចក្នុងការត្រួតពិនិត្យនូវបទល្មើស។ អត្ថបទច្បាប់បានបញ្ជាក់យ៉ាងច្បាស់ថាភ្នាក់ងារនគរបាលយុត្តិធម៌មានអំណាចពិនិត្យបទលហុជាដើម។

### ២.១.ការទទួលគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌

អ្នកដែលអាចទទួលបានគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌រួមមាន៖

- នាយនគរបាល និងនាយនគរបាលរង ដែលមិនមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌
- ភ្នាក់ងារនគរបាលជាតិផ្សេងទៀត
- នាយទាហាននៃកងរាជអាវុធហត្ថ ដែលមិនមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌

[10] យោង មាត្រា៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

- យោធិផ្សេងទៀតនៃកងរាជអាវុធហត្ថ[11]។

ភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវបានស្បថថា នឹងបំពេញមុខងាររបស់ខ្លួនដោយស្មោះត្រង់ ហើយសម្បថត្រូវធ្វើឡើងនៅចំពោះមុខសាលាដំបូង។ សម្បថនេះពុំចាំបាច់ធ្វើឡើងវិញឡើយ នៅពេលដែលបានទទួលនូវគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌។ រូបមន្តសម្បថត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌[12]។

### ២.២.បេសកកម្មរបស់ភ្នាក់ងារនគរបាលយុត្តិធម៌

ភ្នាក់ងារនគរបាលយុត្តិធម៌មានបេសកកម្មដូចតទៅ៖

- ពិនិត្យបទល្មើស ជាអាទិ៍ បទលហុ
- ជួយដល់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការបំពេញមុខងាររបស់គេ។

ចំពោះការពិនិត្យបទល្មើស ភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវធ្វើបាយការណ៍ ហើយរបាយការណ៍នេះមានតម្លៃត្រឹមតែជាព័ត៌មានធម្មតាតែប៉ុណ្ណោះ។ ក្នុងករណីណាក៏ដោយ ភ្នាក់ងារនគរបាលយុត្តិធម៌ពុំអាចបំពេញកិច្ចទាំងឡាយណាបានទេ គឺត្រូវរក្សាទុកជូនមន្ត្រីនគរបាលយុត្តិធម៌តែប៉ុណ្ណោះ។ កិច្ចទាំងឡាយណាដែលត្រូវបានបំពេញដោយបំពានលើការហាមឃាត់នេះ ត្រូវទុកជាមោឃៈ[13]។

### ២.៣.សមត្ថកិច្ចរបស់ភ្នាក់ងារនគរបាលយុត្តិធម៌

ភ្នាក់ងារនគរបាលយុត្តិធម៌ មានសមត្ថកិច្ចក្នុងព្រំប្រទល់ដែនដីដែលខ្លួនបំពេញមុខងារទៅតាមធម្មតា។ នៅពេលជំនួយដល់មន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ ភ្នាក់ងារនគរបាលយុត្តិធម៌មានសមត្ថកិច្ចក្នុងព្រំប្រទល់ដែនដីដែលមន្ត្រីនគរបាលយុត្តិធម៌នោះបំពេញមុខការរបស់ខ្លួន។ ភ្នាក់ងារនគរបាលយុត្តិធម៌មិនអាចពន្លាតសមត្ថកិច្ចដោយខ្លួនឯងនោះទេ ប៉ុន្តែខ្លួនអាចអមដំណើរមន្ត្រីនគរបាលយុត្តិធម៌ដែលបានធ្វើដំណើរទៅក្រៅដែនសមត្ថកិច្ចរបស់ខ្លួនតាមការអនុញ្ញាតឱ្យពន្លាតសមត្ថកិច្ច។

ក្របខ័ណ្ឌស៊ើបអង្កេត (ការស៊ើបអង្កេតបទល្មើសជាក់ស្តែង ការស៊ើបអង្កេតបឋម ការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស) មិនមានឥទ្ធិពលលើសមត្ថកិច្ចដែនដីដំបូងរបស់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ឡើយ។ ដើម្បីប្រយុទ្ធប្រឆាំងនឹងបទល្មើសមួយចំនួនឱ្យកាន់តែមានប្រសិទ្ធិភាព (ការជួញដូរគ្រឿងញៀន ភេរវកម្ម ចោរកម្មទ្រង់ទ្រាយធំ ការជួញដូរវត្ថុបុរាណ ការប្រយុទ្ធប្រឆាំងនឹងបទល្មើសផ្លូវភេទប្រព្រឹត្ត

[11] មាត្រា ៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[12] មាត្រា ៧៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[13] មាត្រា ៧៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ចំពោះកុមារ។ល។) អាជ្ញាធរ អាចសម្រេចបង្កើតអង្គភាពផ្សេងៗដែលមានសមត្ថកិច្ចថ្នាក់ជាតិ។ ដូចនេះមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ដែលអមដំណើរនគរបាលយុត្តិធម៌ ដែលតែងតាំងក្នុងអង្គភាពនេះ អាចធ្វើដំណើរលើវិសាលភាពដែនដីជាតិទាំងមូលដោយមិនចាំបាច់សុំការអនុញ្ញាតពន្លាតសមត្ថកិច្ចឡើយ។

## ២.៤.កំហុសដែលត្រូវបានប្រព្រឹត្តនៅពេលបំពេញមុខងារ

រាល់កំហុសទាំងឡាយដែលប្រព្រឹត្តដោយភ្នាក់ងារនគរបាលយុត្តិធម៌ នៅក្នុងពេលបំពេញមុខងាររបស់ខ្លួនត្រូវតែឱ្យដំណឹងដោយព្រះរាជអាជ្ញា ឬ ដោយចៅក្រមស៊ើបសួរ ជូនចំពោះអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

យោងតាមករណីនីមួយៗ អគ្គព្រះរាជអាជ្ញាប្រកាសប្រាប់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬ រដ្ឋមន្ត្រីក្រសួងការពារជាតិ ដើម្បីចាប់ផ្តើមនីតិវិធីខាងវិន័យ។ អគ្គព្រះរាជអាជ្ញា ត្រូវបានផ្តល់ដំណឹងអំពីចំណាត់ការបន្តនៃនីតិវិធីវិន័យ។

## កថាខណ្ឌទី៣៖ មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតដែលមាននីតិសម្បទា

មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ក៏មាននីតិសម្បទាជានគរបាលយុត្តិធម៌បានផងដែរតាមរយៈច្បាប់ពិសេសផ្សេងៗ ដែលចែងផ្តល់នីតិសម្បទា ដើម្បីត្រួតពិនិត្យ ឃ្លាំមើលបទល្មើស ដែលស្ថិតក្នុងដែនដី ឬ ដែនសមត្ថកិច្ចរបស់ខ្លួន។

### ៣.១.ការទទួលបាននូវនីតិសម្បទាតាមរយៈច្បាប់ដោយឡែកមួយចំនួន

ដោយមូលហេតុថាការទទួលបាននូវនីតិសម្បទាតាមរយៈ ច្បាប់ដោយឡែកមានចំនួនច្រើនប៉ុន្តែប្រធានបទយើងខ្ញុំពុំបានផ្តោតសំខាន់ទៅលើចំណុចនេះខ្លាំងពេកទេ។ អាស្រ័យហេតុនេះដើម្បីផ្តល់ជំនួយក្នុងការសិក្សាស្រាវជ្រាវទាក់ទងទៅនឹងចំណុចនេះខ្ញុំសូមលើកយកមកបង្ហាញតែច្បាប់ចំនួនពីរតែប៉ុណ្ណោះ។ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ(ទី១) និងច្បាប់ស្តីពីព្រៃឈើ(ទី២)។ ច្បាប់ទាំងពីរប្រភេទនេះ យើងខ្ញុំនឹងធ្វើការបង្ហាញជូនដូចខាងក្រោម៖

#### ៣.១.១.តាមរយៈច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ

មន្ត្រីនៃក្រសួងកិច្ចការនារី បម្រើការងារលើវិស័យដែលបញ្ញត្តិដោយច្បាប់ខាងលើនេះ ត្រូវទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ និងអាចធ្វើជាដើមបណ្តឹងជួសមុខឱ្យជនរងគ្រោះ ក្នុងគោលដៅទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះស្របតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន។ នៅក្នុងករណីដែលអវត្តមានមន្ត្រីដែលទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ នោះមន្ត្រីមានសមត្ថកិច្ចផ្សេងទៀតដែលរួមមានមន្ត្រីនគរបាល ភ្នាក់ងារនគរបាល កងរាជអាវុធហត្ថ អាជ្ញាធរមូលដ្ឋាន ឃុំ សង្កាត់ មេភូមិ រួមទាំងមន្ត្រីរបស់ក្រសួងកិច្ចការនារីដែលបានធ្វើការអន្តរាគមន៍ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការពារជនរងគ្រោះត្រូវបានច្បាប់នេះផ្តល់អំណាច

ដើម្បីធ្វើកំណត់ហេតុជូនទៅតុលាការ។ កំណត់ហេតុនេះ មានតម្លៃស្មើគ្នា ដូចកំណត់ហេតុដែលបំពេញដោយមន្ត្រីនគរបាលយុត្តិធម៌ដែរ[14]។

ដើម្បីទប់ស្កាត់អំពើហិង្សាដែលកំពុងតែកើតឡើង ឬ ជឿជាក់ថានឹងកើតឡើង អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើការអន្តរាគមន៍ជាបន្ទាន់ដោយៈ

-ឃាត់ទុកអាវុធ ឬ វត្ថុជាក់ស្តែងដែលជនមុខសញ្ញាបាន ឬ អាចប្រើប្រាស់

-បង្វែរយកចេញជនមុខសញ្ញាពីកន្លែងកើតហេតុ ឬ បង្វែរជនរងគ្រោះបើមានការស្នើសុំពីជនរងគ្រោះ ក្នុងករណីពិសេស ជនរគ្រោះអាចបង្វែរចេញបានដោយគ្មានការស្នើសុំ ប្រសិនបើមានហេតុផលចាំបាច់ត្រូវធ្វើ

-ផ្តល់ឱ្យជនរងគ្រោះនូវជំនួយសមស្របតាមកាលៈទេសៈ ជាពិសេសផ្តល់កន្លែងជម្រកបណ្តោះអាសន្ន ដែលអាចធានាសុវត្ថិភាព និងផ្តល់ជំនួយសុខាភិបាលជាបន្ទាប់

-ពន្យល់ អប់រំ និងសម្រុះសម្រួលគូភាគីទាំងសងខាងឱ្យបញ្ឈប់អំពើហិង្សា និងណែនាំជនរងគ្រោះអំពីសិទ្ធិរបស់ខ្លួនសម្រាប់ទប់ស្កាត់អំពើហិង្សាដែលមានចែងនៅក្នុងមាត្រា ២០ និងមាត្រា ២៦ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ[15]។

### ៣.១.២.តាមរយៈច្បាប់ស្តីពីព្រៃឈើ

មន្ត្រីនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺសំដៅទៅលើមន្ត្រីរដ្ឋបាលព្រៃឈើដែលមានសមត្ថកិច្ចជាមន្ត្រីនគរបាលយុត្តិធម៌ មានន័យថាត្រូវទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេតបទល្មើសព្រៃឈើ និងកសាងសំណុំរឿងបញ្ជូនទៅតុលាការ។ មន្ត្រីរដ្ឋបាលព្រៃឈើធ្វើសច្ចាប្រណិធានបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌បាន លុះត្រាតែសាមីខ្លួនបានទទួលនីតិសម្បទាពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ ការស្រាវជ្រាវ ទប់ស្កាត់ បង្ក្រាបបទល្មើសព្រៃឈើជាសមត្ថកិច្ចរបស់រដ្ឋបាលព្រៃឈើគ្រប់ថ្នាក់នៅក្នុងរង្វង់ដែនដីសមត្ថកិច្ចរៀងៗខ្លួន។ នៅពេលបំពេញបេសសកម្មស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ មន្ត្រីរដ្ឋបាលព្រៃឈើត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសំគាល់ ពាក់ឋានន្តរសក្តិ និងត្រូវមានលិខិតបញ្ជាបេសសកម្ម។ មន្ត្រីព្រៃឈើ ដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ត្រូវធ្វើ និងចុះហត្ថលេខាលើកំណត់ហេតុបទល្មើសព្រៃឈើតាមដែនសមត្ថកិច្ចរបស់ខ្លួន។ ប្រតិបត្តិការរបស់មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ត្រូវអនុវត្តស្របតាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ។ សំលៀកបំពាក់ឯកសណ្ឋាន ពាក់សញ្ញាសំគាល់ ពាក់ឋានន្តរសក្តិរបស់រដ្ឋបាលព្រៃឈើត្រូវកំណត់ដោយអនុក្រឹត្យ[16]។

---

[14] មាត្រា១០ និងមាត្រា ១១ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ចុះថ្ងៃទី២៤ តុលា ឆ្នាំ២០០៥

[15] មាត្រា ១៣ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ចុះថ្ងៃទី២៤ តុលា ឆ្នាំ២០០៥

នៅពេលបំពេញបេសសកម្មមន្ត្រីនរគបាលយុត្តិធម៌ នៃរដ្ឋបាលព្រៃឈើ មានសមត្ថកិច្ចស្នើសុំឱ្យអាជ្ញាធរដែនដីគ្រប់ថ្នាក់ ដែលពាក់ព័ន្ធជួយបង្កភាពងាយស្រួល និងជួយផ្តល់កម្លាំងសហការក្នុងការស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ ឬ ថែរក្សាវត្ថុតាងនៃបទល្មើសព្រៃឈើជាបណ្តោះអាសន្ន ក្នុងករណីមានការស្នើសុំពីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច[17]។

ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ មានសិទ្ធិ ដូចតទៅៈ

១-អាចឱ្យបុគ្គលណាម្នាក់ឆ្លើយតបសំណួរ និងផ្តល់ព័ត៌មានពាក់ព័ន្ធដល់ការប្រព្រឹត្តបទល្មើសព្រៃឈើ

២-ចូលធ្វើការត្រួតពិនិត្យ ឬ ឆែកឆេរគ្រប់ទីកន្លែងរួមទាំងក្នុងប្រលានយន្តហោះ កំពង់ផែសមុទ្រ កំពង់ផែទន្លេ ផែស្ងួត ច្រកព្រំដែន ចំណតរថយន្ត ស្ថានីយ៍រថភ្លើង ក្នុងករណីបទល្មើសជាក់ស្តែងដោយមានកិច្ចសហការជាមួយសមត្ថកិច្ចជាប់ពាក់ព័ន្ធ

៣-ដកហូតជាបណ្តោះអាសន្ននូវអាជ្ញាប័ណ្ណ ឬ លិខិតអនុញ្ញាតគ្រប់ប្រភេទដែលកំណត់ដោយច្បាប់ស្តីពីព្រៃឈើ បើសិនជាបុគ្គលទទួលអាជ្ញាប័ណ្ណ ឬ លិខិតអនុញ្ញាតនោះប្រព្រឹត្តល្មើសនឹងច្បាប់នេះ។

ក្នុងករណីបទល្មើសជាក់ស្តែង មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ មានសិទ្ធិចូលឆែកឆេរនៅ ក្នុងទីធ្លា អគារ ឬ ក្នុងលំនៅដ្ឋានស្របតាមនីតិវិធីព្រហ្មទណ្ឌ។ ការឆែកឆេរត្រូវចំពោះមុខជនល្មើស និងមានសាក្សីពីរនាក់ ដែលជាអ្នកជិតខាង ឬ ជាម្ចាស់ផ្ទះ។ ហើយចាប់ឃាត់ជាបណ្តោះអាសន្នៈ

- រាល់ផល អនុផលព្រៃឈើ ឬ ផលប្រម៉ាញ់ ដែលល្មើសនិងប្បញ្ញត្តិនៃច្បាប់
- សត្វពាហនៈដែលបានជួបប្រទះកំពុងបំផ្លិចបំផ្លាញដំណាំឈើ
- គ្រឿងចក្រ យានយន្ត ឧបករណ៍ និងសត្វពាហនៈដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើសព្រៃឈើ។

## ៣.២.ការតែងតាំងចំពោះមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត

បន្ទាប់ពីមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃផ្សេងទៀតនោះទទួលបាននូវនីតិសម្បទាពិសេសរួច ហើយពួកគេត្រូវទទួលបាននូវការតែងតាំងជាមុនសិន។ អាស្រ័យហេតុនេះទើបមានសំណួរចោទសួរថាតើបុគ្គលប្រភេទណាដែលមានសិទ្ធិអំណាចក្នុងការតែងតាំងពួកគាត់? តើមានសេចក្តីសម្រេចប្រភេទណាដែរក្នុងការតែងតាំងពួកគាត់? ដើម្បីឆ្លើយតបនឹងសំណួរទាំងនេះបានយើងត្រូវសិក្សាដូចតទៅៈ

[16] មាត្រា ៧៦ និងមាត្រា ៧៧ នៃច្បាប់ស្តីពីព្រៃឈើ

[17] មាត្រា ៧៨ និងមាត្រា ៧៧ នៃច្បាប់ស្តីពីព្រៃឈើ

### ៣.២.១.បុគ្គលដែលមានអំណាចក្នុងការតែងតាំង

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាមួយ និងរដ្ឋមន្ត្រីនៃក្រសួងពាក់ព័ន្ធជាអ្នកមានសិទ្ធិក្នុងការតែងតាំងមន្ត្រីដែលបម្រើការនៅតាមក្រសួងនីមួយៗ នេះបើយោងតាមមាត្រា៨២ វាក្យខណ្ឌ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថា "**បែបបទ និងនីតិវិធីនៃការផ្តល់នីតិសម្បទាត្រូវកំណត់រវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងក្រសួងពាក់ព័ន្ធ**"។ តួយ៉ាងប្រសិនបើមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតនោះ ធ្វើការនៅក្នុងក្រសួងកិច្ចការនារី ដូច្នេះពួកគាត់ត្រូវមានការតែងតាំងដោយមន្ត្រីក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី។ ចំណែកមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលធ្វើការនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូច្នេះពួកគាត់ត្រូវមានការតែងតាំងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

### ៣.២.២ សេចក្តីសម្រេចក្តីក្នុងការតែងតាំង

រដ្ឋមន្ត្រី នៃក្រសួងសាមីជាអ្នកមានសិទ្ធិចេញប្រកាស ដើម្បីតែងតាំងមន្ត្រីមួយចំនួនដែលនៅក្រោមឱវាទរបស់ខ្លួន តែរដ្ឋមន្ត្រីនៃក្រសួងពីរផ្សេងគ្នា សម្រេចតែងតាំងមន្ត្រីតែមួយដូចគ្នា ដូច្នេះសេចក្តីសម្រេចរួមគ្នានេះគេហៅថាប្រកាសរួម។ ជាក់ស្តែងដើម្បីផ្តល់នីតិសម្បទាជូនមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត នោះរដ្ឋមន្ត្រីនៃក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងសាមីត្រូវចេញប្រកាសរួមដើម្បីទុកជាសេចក្តីសម្រេចក្នុងការតែងតាំងពួកគាត់។

## ៣.៣.សម្បថរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត

នៅពេលដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាមួយនិងរដ្ឋមន្ត្រីក្រសួងសាមីបានចេញប្រកាសរួមតែងតាំងខ្លួនរួចហើយ មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតនោះមិនទាន់អាចទៅបំពេញមុខងារនេះបានភ្លាមនោះទេ គឺគាត់ត្រូវឆ្លងកាត់ដំណាក់កាលមួយផ្សេងទៀតដូចមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ដែលដំណាក់កាលនេះគេឱ្យឈ្មោះថា ការធ្វើសម្បថ។

### ៣.៣.១.ទីកន្លែងដែលត្រូវធ្វើសម្បថ

យោងតាមមាត្រា៨២ ត្រង់វាក្យខណ្ឌ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត អាចបំពេញមុខងារបានទាល់តែឆ្លងកាត់នូវសម្បថជាមុនសិន។ ប៉ុន្តែសម្បថរបស់គាត់មិនធ្វើនៅចំពោះមុខសាលាឧទ្ធរណ៍ដូចមន្ត្រីនគរបាលយុត្តិធម៌នោះទេ គឺគាត់ត្រូវធ្វើសម្បថនៅចំពោះមុខសាលាដំបូងដែលមានសមត្ថកិច្ចតាមរាជធានី-ខេត្តនីមួយៗដូចគ្នា និងភ្នាក់ងារនគរបាលយុត្តិធម៌ដែរ។ រូបមន្តនៃសម្បថត្រូវ (យោងសម្បថនេះត្រូវស្បថ បំពេញមុខងារដោយស្មោះត្រង់) កំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

#### ៣.៣.២.នត្ថិភាពនៃអញ្ញាត្រកម្មចំពោះសម្បថរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត

នត្ថិភាព នៃអញ្ញាត្រកម្មចំពោះសម្បថរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត គឺមានភាពខុសគ្នាពីមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ព្រោះសម្បថរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត (នត្ថិភាព គឺភាពគ្មាន ឬ ភាពនៃអ្វីៗដែលមិនមាន យោងតាមសន្ធានុក្រមរដ្ឋប្បវេណី)។ ចំពោះអញ្ញាត្រកម្មនៃសម្បថ មិនបានកំណត់នូវករណីលើកលែងចំពោះមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតឡើយ នៅពេលដែលបានទទួលនូវគុណសម្បត្តិរួចរាល់ជាមន្ត្រីនគរបាលយុត្តិធម៌ គឺតម្រូវឱ្យធ្វើសម្បថម្តងទៀត។ ចំណុចនេះហើយដែលធ្វើឱ្យឃើញពីភាពខុសគ្នារវាងមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ជាមួយនិងមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ព្រោះពួកគេមានករណីលើកលែងចំពោះសម្បថរបស់ខ្លួន (សម្បថនេះពុំចាំបាច់ធ្វើឡើងវិញឡើយនៅពេលដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ឬ នៅពេលដែលទទួលនូវគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌នាពេលក្រោយទៀត)។ ផ្ទុយទៅវិញចំពោះមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតទាំងនេះពុំមានប្បញ្ញត្តិណាមួយចែងច្បាស់លាស់អំពីចំណុចនេះឡើយ គឺត្រូវធ្វើសម្បថសារជាថ្មីម្តងទៀត។ នេះហើយដែលបង្ហាញឱ្យឃើញពីវិសមភាពគ្នារវាងមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ និងមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត។

### ៣.៤.កំហុសរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតក្នុងពេលបំពេញមុខងារ

ក្រោយពេលទទួលបាននូវប្រកាសរួមតែងតាំងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីនៃក្រសួងសាមីនិងក្រោយពីបានទៅធ្វើសម្បថនៅចំពោះមុខសាលាដំបូងរួចមក។ មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតត្រូវធ្វើការត្រួតពិនិត្យបទល្មើស ចំពោះការពិនិត្យលើបទល្មើសមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈទាំងនេះត្រូវធ្វើរបាយការណ៍ ហើយរបាយការណ៍នេះមានតម្លៃត្រឹមតែព័ត៌មានធម្មតាប៉ុណ្ណោះ។

ទណ្ឌកម្មរបស់ មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតដែលប្រព្រឹត្តកំហុសអំឡុងពេលកំពុងតែអនុវត្តមុខងារជាមន្ត្រីនគរបានយុត្តិធម៌របស់ខ្លួនរួមមាន៖

#### ៣.៤.១.នីតិវិធីខាងវិន័យ

រាល់កំហុសទាំងឡាយដែលបានប្រព្រឹត្តដោយមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតនៅក្នុងពេលបំពេញមុខងាររបស់ខ្លួនត្រូវតែឱ្យដំណឹងដោយព្រះរាជអាជ្ញា ឬ ចៅក្រមស៊ើបសួរជូនចំពោះអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ប្រកាសប្រាប់រដ្ឋមន្ត្រីដែលមន្ត្រី ឬភ្នាក់ងារនោះនៅក្រោមឱវាទដើម្បីចាប់ផ្តើមនីតិវិធីខាងវិន័យ។ អគ្គព្រះរាជាអាជ្ញាអមសាលាឧទ្ធរណ៍ត្រូវបានផ្តល់ដំណឹងអំពីចំណាត់ការ

បន្តនៃនីតិវិធីខាងវិន័យនេះ[18]។

### ៣.៤.២. ទណ្ឌកម្មចំពោះមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត

មិនខុសគ្នាទេចំពោះការដាក់ទណ្ឌកម្មខាងវិន័យសម្រាប់នាយទាហាននៃកងរាជអាវុធហត្ថ និងនាយនគរបាលជាតិ ដូច្នេះមិនមែនជាឧបសគ្គទៅដល់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈក្នុងការធ្វើបណ្តឹងនោះទេ ប្រសិនបើបទល្មើសត្រូវបានប្រព្រឹត្ត។ ដោយមូលហេតុមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតត្រូវបានច្បាប់នេះផ្តល់នូវនីតិសម្បទាឱ្យក្លាយជាមន្ត្រីនគរបាលយុត្តិធម៌ ដូច្នេះនៅពេលដែលពួកគាត់ប្រព្រឹត្តនូវកំហុសក្នុងពេលអនុវត្តមុខងាររបស់ខ្លួន នាំឱ្យបទបញ្ញត្តិនៃមាត្រា ៦៤ (នីតតវិធីខាងវិន័យ) ដល់មាត្រា ៦៦ (ការហាមឃាត់មិនឱ្យបំពេញមុខខាងជាមន្ត្រីនគរបាលយុត្តិធម៌) ត្រូវបានយកមកអនុវត្តដូចគ្នាផងដែរ។

## ផ្នែកទី២៖ សមត្ថកិច្ច និងអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌

### កថាខណ្ឌទី១៖ សមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌

មន្ត្រីនគរបាលមន្ត្រីយុត្តិធម៌ មានតួនាទីទទួលពាក្យបណ្តឹងតវ៉ា និងបណ្តឹងបរិហារ។ គ្រប់ការដាក់ពាក្យបណ្តឹងតម្រូវឱ្យមានការធ្វើកំណត់ហេតុ ដើម្បីអនុញ្ញាតឱ្យមានការស៊ើបអង្កេត ឬការបញ្ជូនទៅទៅឱ្យព្រះរាជអាជ្ញា។ ក្នុងករណីដែលបណ្តឹងបរិហារមានមូលហេតុត្រឹមត្រូវ មន្ត្រីនគរបាលយុត្តិធម៌មានកាតព្វកិច្ចជូនព័ត៌មានដល់ព្រះរាជអាជ្ញា និងសំការណែនាំ។ មន្ត្រីនគរបាលយុត្តិធម៌ ធ្វើការស៊ើបអង្កេតបទល្មើសចាក់ស្តែង និងស៊ើបអង្កេតបឋម ព្រមទាំងអនុវត្តដីកាចាត់ឱ្យសួរជំនួសរបស់ចៅក្រមស៊ើបសួរ។ ហេតុដូច្នេះ មន្ត្រីនគរបាលយុត្តិធម៌គឺជាអង្គគំនិតក្នុងការដឹងនាំ ការបញ្ជា និងជាអង្គនៃក្របខណ្ឌបេសកកម្ម នៃនគរបាលយុត្តិធម៌។

ចំពោះសមត្ថកិច្ចរបស់នគរបាលយុត្តិធម៌ ត្រូវបានចែកចេញជាពីរប្រភេទធំៗគឺ៖

#### ១.១.សមត្ថកិច្ចដែនដី

មន្ត្រីនគរបាលយុត្តិធម៌ មានសមត្ថកិច្ចនៅក្នុងព្រំប្រទល់ដែនដីអង្គភាព ដែលខ្លួនត្រូវបានចាត់តាំងឱ្យទៅបម្រើការងារ។ ការកំណត់ពីមណ្ឌលរដ្ឋបាលដែលជាដែនដីសមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ មានបញ្ជាក់នៅក្នុងសេចក្តីសម្រេចតែងតាំងមន្ត្រីនគរបាលយុត្តិធម៌នោះ។ ហេតុនេះ មន្ត្រីនគរបាលយុត្តិធម៌ ដែលត្រូវបានចាត់តាំងឱ្យទៅបម្រើការងារនៅស្រុកណាមួយ នៃខេត្តណាមួយ មានសមត្ថកិច្ចនៃដែនដីនោះតែប៉ុណ្ណោះ[19]។

[18] មាត្រា ៦៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[19] មាត្រា ៦៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

នៅទីក្រុងភ្នំពេញ មន្ត្រីនគរបាលយុត្តិធម៌ មានសមត្ថកិច្ចលើវិសាលភាពទីក្រុងទាំងមូល ដោយមិនគិតពីអង្គភាពចាត់តាំងដោយព្រះរាជអាជ្ញាក្នុងករណីបទឧក្រិដ្ឋ ឬ បទមជ្ឈឹមជាក់ស្តែង ឬ ក្នុងករណីបន្ទាន់។ ការអនុញ្ញាតឱ្យបំពេញប្រតិបត្តិការដោយព្រះរាជអាជ្ញាលើវិសាលភាពនៃដែនដីជាតិទាំងមូល ជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់ ក្នុងករណីបទល្មើសជាក់ស្តែង។ ចៅក្រមស៊ើបសួរ ក៏អាចពង្រីកសមត្ថកិច្ចដែនដី របស់មន្ត្រីនគរបាលយុត្តិធម៌នៅពេលចេញដីកាចាត់ឱ្យស៊ើបសួរជំនួស ដោយមានបញ្ជាក់ពីលក្ខណៈបន្ទាន់។ អន្តរាគមន៍របស់មន្ត្រីនគរបាលយុត្តិធម៌នៅក្រៅដែនសមត្ថកិច្ច ត្រូវធ្វើឡើងដោយមានកិច្ចសហការជាមួយមន្ត្រីនគរបាលយុត្តិធម៌ដែលមានសមត្ថកិច្ចក្នុងដែនដីនោះ។ ព្រះរាជអាជ្ញា ដែលមានសមត្ថកិច្ចខាងដែនដីក៏ត្រូវទទួលដំណឹងអំពីអន្តរាគមន៍នេះផងដែរ ពីចៅក្រមដែលបានពង្រីកសមត្ថកិច្ច របស់ខ្លួន។ គ្រប់អន្តរាគមន៍របស់មន្ត្រីនគរបាលយុត្តិធម៌ នៅក្រៅសមត្ថកិច្ចដែនដីរបស់ខ្លួន ដែលពុំទទួលបានការអនុញ្ញាតពីចៅក្រមស៊ើបសួរ ពុំមានសុពលភាពទេ ហើយការស៊ើបអង្កេតត្រូវចាត់ទុកជាមោឃៈ។

### ១.២.សមត្ថកិច្ចសម្ភារៈ

តាមក្រមនីតិវិធិព្រហ្មទណ្ឌ កងរាជអាវុធហត្ថ នគរបាលជាតិ មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតដែលច្បាប់ដោយឡែកប្រគល់អំណាចឱ្យ ក៏ជានគរបាលយុត្តិធម៌ដែរ។ ប៉ុន្តែចំពោះបទល្មើសយោធាមានតែកងរាជអាវុធហត្ថទេ ដែលមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌។ រីឯក្នុងករណីបទល្មើសព្រៃឈើមានតែមន្ត្រីរដ្ឋបាលការព្រៃឈើដែលទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ ជាអ្នកធ្វើការស៊ើបអង្កេតបទល្មើសព្រៃឈើមិនអាចស៊ើបអង្កេតបទល្មើសផ្សេងទៀត។ ម៉្យាងវិញទៀត មានតែមន្ត្រីនៃក្រសួងកិច្ចការនារី ដែលទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ ទើបមានសិទ្ធិក្នុងការធ្វើអន្តរាគមន៍ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការពារជនរងគ្រោះដែលជាស្ត្រី និងកុមារ ពីសំណាក់ការរំលោភបំពាន់ផ្សេងៗ។

## កថាខណ្ឌទី២៖ អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌

ក្រមនីតិវិធីព្រហ្មទណ្ឌបានឱ្យអំណាចដល់មន្ត្រីនគរបាលយុត្តិធមិ នៅក្នុងក្រមខណ្ឌនៃការស៊ើបអង្កេតស៊ើបអង្កេតករណីជាក់ស្តែង ឬ ការស៊ើបអង្កេតបឋម។

ការស៊ើបអង្កេត ត្រូវតែជាការសម្ងាត់។ បុគ្គលទាំងឡាយដែលចូលរួមក្នុងការស៊ើបអង្កេតជាពិសេសចៅក្រមខាងអយ្យការ មេធាវី ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ មន្ត្រីរាជកា អ្នកជំនាញ អ្នកបកប្រែ គ្រូពេទ្យ និងបុគ្គលដែលមានសមត្ថកិច្ច ត្រូវរក្សាការសម្ងាត់នៃវិជ្ជាជីវៈ[20]។

[20] មាត្រា ៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

## ២.១.ការស៊ើបអង្កេតបទល្មើសជាក់ស្តែង

ក្នុងន័យនេះ យើងអាចកំណត់បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងគឺ (មាត្រា៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)៖

- បទល្មើស ដែលកំពុងប្រព្រឹត្ត

-បទល្មើស ដែលទើបនឹងប្រព្រឹត្តរួចភ្លាម

- កាលណានៅក្រោយពេលមានបទល្មើសបន្តិច

- ជនដែលគេសង្ស័យត្រូវបានសាធារណៈជន ស្រែកដេញប្រផាប់ចាប់ប្រកីង

- បុគ្គលដែលត្រូវបានគេរកឃើញមានវត្ថុ ឬស្នាកស្នាម ឬតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់ផ្សេងទៀត។

នាំឱ្យគេសន្និដ្ឋានបានថា បុគ្គលនោះបានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទល្មើស[21]។

### ២.១.១.លក្ខខណ្ឌនៃការបើកការស៊ើបអង្កេតករណីជាក់ស្តែង

ការស៊ើបអង្កេតបទល្មើសជាក់ស្តែង ត្រូវបើកការស៊ើបអង្កេតក្នុងករណីមានបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង។ បទល្មើសជាក់ស្តែង ជាបទល្មើសដែលកំពុងប្រព្រឹត្ត បទល្មើសដែលទើបប្រព្រឹត្តរួចភ្លាម។ ចាត់ទុកជាបទល្មើសជាក់ស្តែងដែរ កាលណានៅក្រោយពេលមានបទល្មើសរួចបន្តិចមក ជនដែលគេសង្ស័យត្រូវ បានសាធារណៈជន ស្រែកដេញប្រផាត់ចាប់ប្រកីង ឬ បុគ្គលដែលត្រូវគេរកឃើញមានវត្ថុ ឬ មានស្លាកស្នាម ឬ តម្រុយច្បាស់ លាស់ និងស៊ីសង្វាក់ផ្សេងទៀត ដែលនាំឱ្យគេសន្និដ្ឋានបានថា បុគ្គលនោះបានប្រព្រឹត្ត ឬ បានចូលរួមប្រព្រឹត្តបទល្មើស[22]។

ចាត់ទុកដូចជាបទល្មើសជាក់ស្តែងដែរ បើទោះបីជាស្ថិតនៅក្រៅពីករណីដែលមានចែងនៅមាត្រា ៨៦ ក៏ដោយ គ្រប់បទឧក្រិដ្ឋ ឬមជ្ឈិមទាំងឡាយណាដែលត្រូវបានប្រព្រឹត្តនៅក្នុងទីកន្លែង ដែលអ្នកកាន់កាប់នៅទីនោះ គឺសុំឱ្យព្រះរាជអាជ្ញា ឬ មន្ត្រីនគរបាលយុត្តិធម៌ ចូលមកពិនិត្យ ឬ ភ្នាក់ងារនគរបាលយុត្តិធម៌ ក្នុងករណីដែលគ្មានមន្ត្រីនគរបាលយុត្តិធម៌នៅទីកន្លែងនោះ។

### ២.១.២.ដំណើរការស៊ើបអង្កេត

ទោះបីជាការស៊ើបអង្កេតត្រូវបានធ្វើឡើងក្រោមរូបភាពណាក៏ដោយ ទាំងបទល្មើសជាក់ស្តែង ការស៊ើបអង្កេត ឬ ដីកាចាត់ឱ្យស៊ើបសួរជំនួស កិច្ចស្រាវជ្រាវនានាដែលធ្វើឡើងដោយមន្ត្រីនគរនបាលយុត្តិធម៌ ក្នុងការស្វែងរកភស្តុតាងសម្រាប់ដំណើរការនៃរឿងព្រហ្មទណ្ឌគឺមានលក្ខណៈដូចគ្នាទាំងអស់។ ក្នុងនោះ កិច្ចទាំងឡាយដែលទាក់ទងនឹងបទល្មើសជាក់ស្តែងនេះមានចែងចាប់ពីមាត្រា ៨៥ (អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ នៅក្នុង

---

[21] សៀវភៅដំណាក់កាលក្នុងរឿងក្តីព្រហ្មទណ្ឌសម្រាប់មន្ត្រីនគរបាលយុត្តិធម៌ ឆ្នាំ២០០៩ ទំព័រ១៧

[22] មាត្រា ៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ការស៊ើបអង្កេតជាក់ស្តែង) ដល់មាត្រា ១១០ (អំណាចធ្វើមូលវិចារណ៍របស់ចៅក្រម) ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

### ២.១.៣.វិធាននៃការស្រាវជ្រាវរបស់មន្ត្រីនគរបាលយុត្តិធម៌

នៅក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា។ មន្ត្រីនគរបាលយុត្តិធម៌ចុះទៅកាន់ទីកន្លែងកើតហេតុដើម្បីធ្វើការពិនិត្យបទល្មើស។ មន្ត្រីនគរបាលយុត្តិធម៌ធានារ៉ាប់រងរក្សាទុកនូវ តម្រុយនៃភស្តុតាងទាំងឡាយណាដែលអាចបាត់បង់។ មន្ត្រីនគរបាលយុត្តិធម៌អាចហាមឃាត់បុគ្គលគ្រប់រូបកុំឱ្យទៅទីណាឆ្ងាយពីកន្លែងនៃបទល្មើស រហូតដល់ពេលបញ្ចប់កិច្ចប្រតិបត្តិការរបស់ខ្លួន។ ប្រសិនបើយល់ឃើញថាមានផលប្រយោជន៍ ព្រះរាជអាជ្ញាអាចចុះទៅកន្លែងកើតហេតុ និងដឹកនាំការស៊ើបអង្កេត។ ក្នុងករណីមានការបន្ទាន់ព្រះរាជអាជ្ញាអាចអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ណាមួយធ្វើប្រតិបត្តិការលើវិសាលភាពទាំងមូលលើដែនដីជាតិ ដោយគោរពតាមលក្ខខណ្ឌទាំងឡាយដែលមានចែងនៅក្នុងមាត្រា ៦៨ (ការពន្លាតសមត្ថកិច្ចដែនដី) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

### ២.១.៤.វិធានក្នុងការឃាត់ខ្លួន

ដើម្បីឆ្លើយតបនឹងតម្រូវការចាំបាច់នៃការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួន បុគ្គលដែលសង្ស័យថាបានចូលរួមក្នុងបទល្មើស។ មន្ត្រីនគរបាលយុត្តិធម៌ក៏អាចឃាត់ខ្លួនបុគ្គលដែលអាចផ្តល់ព័ត៌មានស្តីពីរឿងហេតុបានដែរ ប្រសិនបើបុគ្គលដែលអាចផ្តល់ព័ត៌មានប្រកែកមិនព្រមផ្តល់ព័ត៌មាន និងការយល់ព្រមជាលាយលក្ខណ៍អក្សរឱ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា ព្រមទាំងត្រូវបញ្ជូនគ្រប់ភស្តុតាងទាំងអស់ដែលតម្រូវឱ្យមានការឃាត់ខ្លួននេះ។ ការឃាត់ខ្លួនមានចិរវេលា ៤៨ ម៉ោង ហើយត្រូវចាត់គិតពីម៉ោងដែលសាមីខ្លួនមកដល់អង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ។

ចំពោះបទឧក្រិដ្ឋ កាលណាមានតម្រុយដែលបង្ហាញឱ្យឃើញថា មានពិរុទ្ធភាពលើបុគ្គលដែលឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌អាចបន្ទាពេលនៃការឃាត់ខ្លួនបានក្នុងរយៈពេលមិនលើសពី ២៤ ម៉ោង ដោយមិនគិតពីចិរវេលាចាំបាច់ក្នុងការដឹកជញ្ជូន តែត្រូវមានការអនុញ្ញាតពន្យាពេលពីព្រះរាជអាជ្ញា ជាលាយលាយលក្ខណ៍អក្សរ មានសំអាងហេតុ ហើយត្រូវដាក់បញ្ចូនទៅក្នុងសំណុំរឿង។

ចំពោះបទឧក្រិដ្ឋ រយៈពេលនៃការឃាត់ខ្លួនអនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ ១៦ ឆ្នាំ មិនត្រូវបានឃាត់ខ្លួនលើសពី ៣៦ ម៉ោង និងបទមជ្ឈិមការឃាត់ខ្លួនមិនត្រូវលើសពី ២៤ ម៉ោង។

ចំពោះបទឧក្រិដ្ឋ រយៈពេលនៃការឃាត់ខ្លួនអនីតិជនដែលមានអាយុចាប់ពី ១៦ ឆ្នាំ ដល់ ១៨ ឆ្នាំ មិនត្រូវបានឃាត់ខ្លួនលើសពី ៤៨ ម៉ោង និងបទមជ្ឈិមការឃាត់ខ្លួនមិនត្រូវលើសពី ៣៦ ម៉ោង។

អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ ពុំត្រូវបានធ្វើការឃាត់ខ្លួនឡើយ។ នៅក្នុងករណីដែលបុគ្គលដែលត្រូវបានឃាត់ខ្លួននេះជាអនីតិជន នោះច្បាប់មិនអនុញ្ញាតឱ្យពន្យាពេលឡើយ។

កាលណាមានការឃាត់ខ្លួនបុគ្គលណាមួយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវឱ្យដំណឹងជាបន្ទាន់អំពីសេចក្តីសម្រេចចិត្តរបស់ខ្លួនដល់បុគ្គលដែលត្រូវបានឃាត់ខ្លួននោះ ដោយប្រាប់ឱ្យដឹងអំពីមូលហេតុនៃសេចក្តីសម្រេចចិត្តឃាត់ខ្លួន។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវប្រាប់ដល់សាមីជនខ្លួនឱ្យបានដឹងផងដែរ អំពីសិទ្ធជំនួយផ្នែកច្បាប់ដែលមានចែងក្នុងមាត្រា ៩៨ (ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ចំពោះបុគ្គលដែលត្រូវបានឃាត់ខ្លួនដែលមិនចេះភាសាខ្មែរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវរកអ្នកបកប្រែឱ្យបុគ្គលនោះ។ មន្ត្រីនគរបាលយុត្តិធម៌ មានកិច្ចការមួយចាំបាច់ត្រូវតែធ្វើនោះគឺកំណត់ហេតុស្តីពីការឃាត់ខ្លួនជាបន្ទាន់ ដែលកំណត់ហេតុនេះត្រូវមានចុះសេចក្តីដូចជា ៖

- ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តធម៌ដែលបានបង្គាប់ឱ្យឃាត់ខ្លួន
- អត្តសញ្ញាណនៃបុគ្គលដែលត្រូវបានឃាត់ខ្លួន
- មូលហេតុ នៃការឃាត់ខ្លួន
- ការឱ្យដំណឹងអំពីសិទ្ធិដែលរកជំនួយមេធាវី (មាត្រា ៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)
- បែបបទនៃការជូនដំណឹងដោយអនុវត្តតាមមាត្រា ១០០ (អនីតិជនដែលត្រូវឃាត់ខ្លួន) នៃក្រមនីតិវិធីព្រហ្មទណ្ឌ
- ឈ្មោះរបស់គ្រូពេទ្យដែលបានពិនិត្យបុគ្គលឃាត់ខ្លួន
- អត្តសញ្ញាណរបស់ជនដែលបាន សន្ទនាជាមួយបុគ្គលឃាត់ខ្លួន
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែល ជាយថាហេតុបានអនុញ្ញាតឱ្យបន្តការឃាត់ខ្លួន
- ថិរវេលានៃការស្តាប់ចម្លើយនីមួយៗ និងថិរវេលានៃការសម្រាកចន្លោះការស្តាប់ចម្លើយនីមួយៗ
- ថ្ងៃ ខែ ឆ្នាំ និងម៉ោងនៃការឃាត់ខ្លួន
- ប្រភេទនៃសេចក្តីសម្រេចរបស់អាជ្ញាធរតុលាការនៅពេលបញ្ចប់ការឃាត់ខ្លួន
- លក្ខខណ្ឌនៃការប្រព្រឹត្តិទៅនៃការឃាត់ខ្លួនព្រមទាំង ឧប្បត្តិហេតុជាយថាហេតុ
- កំណត់ហេតុសរុបនៃការឃាត់ខ្លួនត្រូវភ្ជាប់ជាមួយសំណុំរឿង។

កំណត់ហេតុនេះត្រូវចុះហត្ថលេខា ឬ ផ្តិតម្រាមដៃរបស់ជនត្រូវបានឃាត់ខ្លួន ក្រោយពីសាមីខ្លួនបានអាន ឬ បើសាមីខ្លួនមិនចេះអក្សរមន្ត្រីនគរបាលយុត្តិធម៌ត្រូវអានកំណត់ហេតុឱ្យស្តាប់ ឬ ប្រើអ្នកបកប្រែបើសាមី

ខ្លួនមិនចេះភាសាខ្មែរ។ ប្រសិនបើជននេះប្រកែកមិនព្រមចុះហត្ថលេខា ឬ ផ្តិតស្រាមដៃទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេស។ កំណត់ហេតុត្រូវភ្ជាប់ជាមួយសំណុំរឿង។

### ២.១.៥.ទិដ្ឋានៃការបញ្ជូនជនដែលត្រូវបានឃាត់ខ្លួនដល់ព្រះរាជអាជ្ញា

ក្រោយពីការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនទៅព្រះរាជអាជ្ញា (ករណីជាក់ស្តែង និងការស៊ើបអង្កេតបឋម) នូវនីតិវិធីភ្ជាប់ជាមួយ កំណត់ហេតុ និងរបាយការណ៍។

នៅពេលផុតរយៈពេលនៃការឃាត់ខ្លួន បុគ្គលដែលត្រូវបានឃាត់ខ្លួននោះត្រូវ៖

-បញ្ជូនខ្លួនទៅព្រះរាជអាជ្ញា ឬ

-ដោះលែងឱ្យមានសេរីភាពឡើងវិញ។

សេចក្តីសម្រេចនេះធ្វើឡើយដោយព្រះរាជអាជ្ញា។

កាលណាបុគ្គលដែលត្រូវបានឃាត់ខ្លួន ត្រូវបញ្ជូនទៅព្រះរាជអាជ្ញា នោះបុគ្គលនេះត្រូវបានគេនាំខ្លួនភ្លាមយកទៅចំពោះមុខព្រះរាជអាជ្ញា។ ប្រសិនបើបង្ហាញខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន ពុំអាចធ្វើឡើងនៅថ្ងៃតែមួយបាន ដោយសារមានមូលហេតុពិសេសដែលបណ្តាលមកពីការលំបាកក្នុងការដឹងជញ្ជូន ឬ ចម្ងាយផ្លូវនៃការដឹងជញ្ជូននោះ រយៈពេលបន្ថែមអាចផ្តល់ឱ្យដោយព្រះរាជអាជ្ញាបាន។ នៅគ្រប់ករណីទាំងអស់ ការបង្ហាញខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន ត្រូវធ្វើឡើងក្នុងរយៈពេលដ៏ឆាប់បំផុតតាមការដែលអាចធ្វើទៅបាន។ ហើយមូលហេតុនៃការយឺតយ៉ាវ ត្រូវចុះក្នុងកំណត់ហេតុ ដែលត្រូវប្រគល់ជូនព្រះរាជអាជ្ញាដោយមន្ត្រីនគរបាលយុត្តិធម៌។

### ២.២.ការស៊ើបអង្កេតបឋម

ការស៊ើបអង្កេតបឋម អាចដំណើរការបានដោយការផ្តួចផ្តើមរបស់ព្រះរាជអាជ្ញា ឬ តាមការសុំរបស់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងករណីដែលមានបទល្មើសជាបទឧក្រិដ្ឋ បទមជ្ឈឹម ឬ បទលហុ។ ការស៊ើបសអង្កេតបឋមដំណើរការនៅក្នុងករណី ដែលបទក្រិដ្ឋ ឬ បទមជ្ឈិមមិនជាក់ស្តែង ឬ ក៏ក្នុងករណីដែលថិរវេលានៃការស៊ើបអង្កេតករណីជាក់ស្តែងបានកន្លងផុត។ មាត្រា ១០៦ នៃក្រមនីតិវិធីវិធីព្រហ្មទណ្ឌ កំណត់ថិរវេលានៃការស៊ើបអង្កេតករណីជាក់ស្តែងតែ ៧ ថ្ងៃប៉ុណ្ណោះ គិតចាប់ពីថ្ងៃ ដែលប្រព្រឹត្តបទល្មើស។

អំណាច និងកាតព្វកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងក្របខណ្ឌនៃការស៊ើបអង្កេតបឋមមានលក្ខណៈប្រហាក់ប្រហែល និងអំណាច និងកាតព្វកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ នៅក្នុងក្របខណ្ឌនៃការស៊ើបអង្កេតករណីជាក់ស្តែង ដោយគ្រាន់តែបទប្បញ្ញត្តិ យោងមានភាពខុសគ្នា។ វិធានទាក់ទិននឹងការស៊ើបអង្កេតបឋម មានចែងចាប់ពីមាត្រា ១១១ រហូតដល់មាត្រា ១១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ចំណុចដែលខុសប្លែកគ្នាខ្លាំងគឺទាក់ទិននឹងអំណាចនៃការឆែកឆេរ ដែលមានចែងនៅក្នុងមាត្រា ១១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ក្នុងករណីនេះ មន្ត្រីនគរបាលយុត្តិធម៌ គឺអាចធ្វការឆែកឆេរបាន ប៉ុន្តែត្រូវមាន៖

១- ការយល់ព្រមច្បាស់លាស់ និងពិតប្រាកដពីអ្នកកាន់កាប់ទីកន្លែង ជាលាយលក្ខណ៍អក្សរនិងសរសេរដោយផ្ទាល់ដៃរបស់អ្នកកាន់កាប់ទីកន្លែង។

### ២.២.១.វិធាននៃការស្រាវជ្រាវរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងបទល្មើសមិនជាក់ស្តែង

ការស៊ើបអង្កេតបឋម មន្ត្រីនគរបានយុត្តិធម៌អាចចុះឆែកឆេរបានដោយៈ

- អាចសុំម្ចាស់ទីកន្លែងចូលឆែកឆេរ និងចាប់យកវត្ថុតាងមកពិនិត្យបានដោយពុំទាន់ចាំសុំយោបល់ពីព្រះរាជអាជ្ញា ប្រសិនបើម្ចាស់ទីកន្លែងនោះយល់ព្រមអនុញ្ញាតឱ្យ ប៉ុន្តែការអនុញ្ញាតត្រូវតែមានជាលាយលក្ខណ៍អក្សរដោយស្មោះត្រង់ គ្មានការគាបសង្កត់ណាមួយជាដាច់ខាត។
- ប្រសិនបើអ្នកកាន់កាប់ទីកន្លែងអវត្តមាន ឬបដិសេធការឆែកឆេរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ទៅព្រះរាជអាជ្ញារួច ព្រះរាជអាជ្ញាសុំទៅប្រធានសាលាដំបូង ហើយលុះត្រាតែប្រធានសាលាដំបូងចេញដីកាឱ្យឆែកឆេរ តាមការស្នើសុំរបស់ព្រះរាជអាជ្ញា ទើបព្រះរាជអាជ្ញាត្រូវដឹកនាំឆែកឆេរផ្ទាល់បាន។
- ក្នុងការឆែកឆេរត្រូវធ្វើឡើងនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេត្រូវធ្វើនៅចំពោះមុខសាក្សី ០២នាក់ ហើយសាក្សីអាចត្រូវចាត់តាំងដោយព្រះរាជអាជ្ញា ក្រៅពីនគរបាល ឬកងរាជអាវុធហត្ថ ដែលជាកងកម្លាំងរួម។ ការឆែកឆេរមិនអាចផ្តើមមុនម៉ោង ០៦ព្រឹក និងក្រោយម៉ោង ០៦ល្ងាចឡើយ ប៉ុន្តែបើកិច្ចការបន្ត គឺអាចបន្តតាមពេលសមរម្យបាន។ ការឆែកឆេរត្រូវតែធ្វើកំណត់ហេតុ និងអនុវត្តតាមខ្លឹមសារមាត្រា ៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌជាដាច់ខាត។
- កាលណាការស៊ើបអង្កេតជាបឋមនោះទាក់ទងនឹងបទល្មើសឧក្រិដ្ឋ ឬបទមជ្ឈិម មន្ត្រីនគរបាលយុត្តិធម៌ អាចធ្វើការឆែកឆេរ និងចាប់យកវត្ថុតាង តែត្រូវទទួលការយល់ព្រមច្បាស់លាស់ និងពិតប្រាកដពីអ្នកកាន់កាប់ទីកន្លែង។ ការយល់ព្រមនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ សរសេរដោយផ្ទាល់ដៃរបស់អ្នកកាន់កាប់ទីកន្លែង[23]។

### ២.២.២.វិធានក្នុងការឃាត់ខ្លួន និងបញ្ជូនជនដែលត្រូវបានឃាត់ខ្លួន

មន្ត្រីនគរបាលយុត្តិធម៌អាចៈ

- ឃាត់ខ្លួនជនសង្ស័យ
- ជនដែលអាចផ្តល់ព័ត៌មានអំពីរឿងហេតុ តែជននោះប្រកែកមិនព្រមផ្តល់ព័ត៌មាន
- ការឃាត់ខ្លួនត្រូវមានការយល់ព្រមពីជាលាយលក្ខណ៍អក្សរពីព្រះរាជអាជ្ញា។

[23] សៀវភៅដំណាក់កាលក្នុងរឿងក្តីព្រហ្មទណ្ឌសម្រាប់មន្ត្រីនគរបាលយុត្តិធម៌ ឆ្នាំ២០០៩ ទំព័រ២៦

ការឃាត់ខ្លួនក្នុងករណីស៊ើបអង្កេតបឋម ក៏ដូចក្នុងករណីជាក់ស្តែងដែរ នៅពេលដែលមានតម្រុយពីអំពើល្មើសព្រហ្មទណ្ឌច្បាស់លាស់ ឬត្រូវអនុវត្តវិធានការបង្ខំណាមួយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវ រាយការណ៍ជូនព្រះរាជអាជ្ញាជាមុន មានន័យថា ប្រសិនបើក្រោយពីការស៊ើបអង្កេត ពិនិត្យឃើញច្បាស់ថា ពិតជាមានបទល្មើសព្រហ្មទណ្ឌច្បាស់លាស់ ហើយមានមូលហេតុចាំបាច់តម្រូវឱ្យឃាត់ខ្លួនខាងមិនបាន មន្ត្រីនគរបាលយុត្តិធម៌អាចស្នើសុំឃាត់ខ្លួនជនសង្ស័យទៅព្រះរាជអាជ្ញា។ ការស្នើសុំឃាត់ខ្លួនទៅព្រះរាជអាជ្ញានេះ គឺជាការផ្តើមគំនិតរបស់មន្ត្រីនគរបាលយុត្តិធម៌ ដូច្នេះមន្ត្រីនគរបាលយុត្តិធម៌ ត្រូវភ្ជាប់ទៅជាមួយនូវវត្ថុតាងដែលតម្រូវឱ្យមានការឃាត់ខ្លួនជាចាំបាច់នោះ ក្នុងការទទួលខុសត្រូវលើសំណើរបស់ខ្លួន ហើយត្រូវតែមានការយល់ព្រមពីព្រះរាជអាជ្ញាជាលាយលក្ខណ៍អក្សរ ទើបអាចធ្វើការឃាត់ខ្លួនបាន។

ក្នុងករណីស៊ើបអង្កេតបឋម ដែលមន្ត្រីនគរបាលយុត្តិធម៌បានហៅមកសាកសួរតាមសម្រួលហើយក្រោយពីការសាកសួររួចឃើញថា ពុំមានបទល្មើសព្រហ្មទណ្ឌ ឬពុំមានពិរុទ្ធធ្ងន់ធ្ងរដែលមិនចាំ បាច់ឃាត់មន្ត្រីនគរបាលយុត្តិធម៌ អាចអនុញ្ញាតឱ្យជននោះអាចត្រឡប់ទៅវិញ ហើយបញ្ជូនតែសំណុំរឿងមកព្រះរាជអាជ្ញាក្រោយក៏បាន។

ក្នុងករណីស៊ើបអង្កេតបឋមដែលទទួលបញ្ជាពីព្រះរាជអាជ្ញា ហើយក្រោយពីការស៊ើបអង្កេតពិនិត្យឃើញថា ពុំមានបទល្មើសព្រហ្មទណ្ឌ ឬពុំមានពិរុទ្ធធ្ងន់ធ្ងរដែលមិនចាំបាច់ឃាត់ខ្លួនទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវសុំការសម្រេចឃាត់ខ្លួន ឬមិនឃាត់ខ្លួនពីព្រះរាជអាជ្ញា ក្នុងករណីនេះប្រសិនបើព្រះរាជអាជ្ញាទទូចឱ្យឃាត់ខ្លួន និងបញ្ជាឱ្យឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌គ្រាន់តែសរសេរបញ្ជាក់ក្នុងរបាយការណ៍ថា ការឃាត់ខ្លួននោះតាមបញ្ជារបស់ព្រះរាជអាជ្ញា ជាការស្រេចដើម្បីផុតពីការទទួលខុសត្រូវ[24]។

+ រយៈពេលនៃការឃាត់ខ្លួន៖

ការឃាត់ខ្លួនមិនអាចឱ្យលើសពី ៤៨ ម៉ោង គិតចាប់ពីម៉ោងដែលសាមីខ្លួនមកដល់អង្គភាពរបស់មន្ត្រីនគរបាលយុត្តិធម៌។ ចំពោះបទល្មើសឧក្រិដ្ឋមន្ត្រីនគរបាលយុត្តិធម៌អាចបន្យាពេលឃាត់ខ្លួនបាន តែត្រូវសុំការយល់ព្រមព្រះរាជអាជ្ញា។

ការអនុញ្ញាតឱ្យពន្យាពេលឃាត់ខ្លួនត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ ត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង។ ការពន្យាពេលនេះ មិនអាចឱ្យលើសពី ២៤ម៉ោងឡើយ ដោយមិនគិតពីថេរវេលាចាំបាច់សម្រាប់ដឹកជញ្ជូន។ ហើយការពន្យាពេលនេះ មិនអាចធ្វើបានទេប្រសិនបើបុគ្គលដែលត្រូវឃាត់ខ្លួននោះជាអនីតិជន[25]។

---

[24] សៀវភៅដំណាក់កាលក្នុងរឿងក្តីព្រហ្មទណ្ឌសម្រាប់មន្ត្រីនគរបាលយុត្តិធម៌ ឆ្នាំ២០០៩ ទំព័រ២៨

[25] សៀវភៅដំណាក់កាលក្នុងរឿងក្តីព្រហ្មទណ្ឌសម្រាប់មន្ត្រីនគរបាលយុត្តិធម៌ ឆ្នាំ២០០៩ ទំព័រ២៩

+ រយៈពេលឃាត់ខ្លួនសម្រាប់អនីតិជនៈ

ចំពោះបទឧក្រិដ្ឋ រយៈពេលនៃការឃាត់ខ្លួនអនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ ១៦ ឆ្នាំ មិនត្រូវបានឃាត់ខ្លួនលើសពី ៣៦ ម៉ោង និងបទមជ្ឈិមការឃាត់ខ្លួនមិនត្រូវលើសពី ២៤ ម៉ោង។

ចំពោះបទឧក្រិដ្ឋ រយៈពេលនៃការឃាត់ខ្លួនអនីតិជនដែលមានអាយុចាប់ពី ១៦ ឆ្នាំ ដល់ ១៨ ឆ្នាំ មិនត្រូវបានឃាត់ខ្លួនលើសពី ៤៨ ម៉ោង និងបទមជ្ឈិមការឃាត់ខ្លួនមិនត្រូវលើសពី ៣៦ ម៉ោង។

អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ ពុំត្រូវបានធ្វើការឃាត់ខ្លួនឡើយ។ នៅក្នុងករណីដែលបុគ្គលដែលត្រូវបានឃាត់ខ្លួននេះជាអនីតិជន នោះច្បាប់មិនអនុញ្ញាតឱ្យពន្យាពេលឡើយ។

+ បែបបទនៃការឃាត់ខ្លួនៈ

ពេលដែលបានទទួលបញ្ជាឱ្យឃាត់ខ្លួនពីព្រះរាជអាជ្ញា មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើៈ

- ត្រូវធ្វើកំណត់ហេតុស្តីពីការឃាត់ខ្លួន (មាត្រា ៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)
- ឱ្យដំណឹងអំពីការសម្រេចឃាត់ខ្លួន ដល់បុគ្គលនោះ
- ប្រាប់ពីមូលហេតុនៃការឃាត់ខ្លួន (មាត្រា ៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)
- ការឱ្យដំណឹងអំពីសិទ្ធិដែលរកជំនួយមេធាវី (មាត្រា ៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)
- មន្ត្រីនគរបាលយុត្តិធម៌ ជាអ្នកស្វែងរកអ្នកបកប្រែក្នុងករណីចាំបាច់
- មន្ត្រីនគរបាលយុត្តិធម៌ ជាអ្នកស្វែងរកអ្នកជំនាញវាយតម្លៃ ឬធ្វើការសន្និដ្ឋាន ក្នុងករណីចាំបាច់ កំណត់ហេតុស្តីពីការឃាត់ខ្លួនមានចុះសេចក្តីដូចតទៅៈ
  - ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តធម៌ដែលបានបង្គាប់ឱ្យឃាត់ខ្លួន
  - អត្តសញ្ញាណនៃបុគ្គលដែលត្រូវបានឃាត់ខ្លួន
  - មូលហេតុ នៃការឃាត់ខ្លួន
  - បែបបទនៃការជូនដំណឹងតាមរយៈមាត្រា ១០០ (អនីតិជនដែលត្រូវឃាត់ខ្លួន) នៃក្រមនីតិវិធីព្រហ្មទណ្ឌ
  - ឈ្មោះរបស់គ្រូពេទ្យដែលបានពិនិត្យបុគ្គលឃាត់ខ្លួន
  - អត្តសញ្ញាណរបស់ដែលត្រូវបានបុគ្គលឃាត់ខ្លួន
  - ឈ្មោះ និងឋានៈរបស់ចៅក្រមដែល ជាយថាហេតុបានអនុញ្ញាតឱ្យបន្តការឃាត់ខ្លួន
  - ថ្ងៃ ខែ ឆ្នាំ និងម៉ោងនៃការផ្តើមឃាត់ខ្លួន
  - ត្រូវឱ្យដឹងអំពីសិទ្ធិដែលរកជំនួយមេធាវី

- ត្រូវប្រាប់ពីឈ្មោះអ្នកបកប្រែ

កំណត់ហេតុហេតុនេះ ត្រូវមានចុះហត្ថលេខា ឬផ្តិតម្រាមដៃរបស់ជនដែលត្រូវបានឃាត់ខ្លួន ក្រោយពីអានកំណត់ហេតុរួច ឬបើសាមីខ្លួនមិនចេះអក្សរមន្ត្រីនគរបាលយុត្តិធម៌ត្រូវអានកំណត់ហេតុឱ្យស្តាប់។ ប្រសិនបើជននេះប្រកែកមិនព្រមចុះហត្ថលេខា ឬផ្តិតម្រាមដៃទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេស។ កំណត់ហេតុត្រូវភ្ជាប់ជាមួយសំណុំរឿង។

## ផ្នែកទី៣៖ ភាពចំណុះនៃនគរបាលយុត្តិធម៌

គោលបំណង នៃការបង្កើតឱ្យមានមន្ត្រីនគរបាលយុត្តិធម៌ គឺដើម្បីធានានូវប្រសិទ្ធភាពនៃបណ្តឹងអាជ្ញា និងជួយសម្របសម្រួលដល់ដំណើរការរឿងក្តីព្រហ្មទណ្ឌ។ មន្ត្រីនគរបាលយុត្តិធម៌បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងដំណាក់កាលស៊ើបអង្កេត និងស៊ើបសួរ។

### កថាខណ្ឌទី១៖ដំណាក់កាលស៊ើបអង្កេត

នៅក្នុងដំណាក់នេះ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវស្ថិតនៅក្រោមការដឹកនាំដោយព្រះរាជអាជ្ញាមានន័យថា ប្រសិនបើជាមន្ត្រីណាមួយប្រព្រឹត្តខុសក្នុងពេលបំពេញបេសកកម្មរបស់ខ្លួន ក្នុងករណីនេះគឺជាតួនាទី និងសិទ្ធិអំណាចរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ក្នុងការដាក់ទណ្ឌកម្មខាងវិន័យ។

នៅក្នុងដំណាក់កាលស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌បានដើរតួនាទីយ៉ាងសំខាន់ក្នុងការធានានូវប្រសិទ្ធភាពនៃបណ្តឹងអាជ្ញា និងស្វែងរកភស្តុតាងដើម្បីចាប់ជនល្មើស។

ព្រះរាជអាជ្ញាដឹកនាំ និងសម្របសម្រួលសកម្មភាពការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់ នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។

ព្រះរាជអាជ្ញា មានអំណាចទៅលើមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលចែងនៅក្នុងមាត្រា ៨២ (ការផ្តល់នីតិសម្បទាចំពោះមន្ត្រីរាជការ និងភហនាក់ងារសាធារណៈដទៃទៀត) នៃក្រមនីតិវិធីព្រហ្មទណ្ឌ កាលណាមន្ត្រីរាជការ ឬ ភ្នាក់ងារសាធារណៈនោះ បំពេញមុខងាររបស់ខ្លួនជាមន្ត្រីនគរបាលយុត្តិធម៌។

តាមរយៈការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស គឺមន្ត្រីនគរបាលយុត្តិធម៌ត្រូវស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ[26]។

### កថាខណ្ឌទី២៖ ដំណាក់កាលស៊ើបសួរ

ដំណាក់កាលមួយ ដែលសំណុំរឿងស្ថិតនៅក្រោមការសម្របសម្រួលរបស់ចៅក្រមស៊ើបសួរ នោះនាំឱ្យចៅក្រមស៊ើបសួរជាអ្នកមានសិទ្ធិអំណាចដល់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងករណីមានដីកាចាត់ឱ្យស៊ើបសួរជំនួស។

---

[26] ឯកឧត្តម កើត រិទ្ធ សៀវភៅ នីតិវិធីព្រហ្មទណ្ឌ ទំព័រ១៤ ឆ្នាំ២០១៦

យ៉ាងណាក៏ដោយ ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ មិនមានសមត្ថកិច្ចដាក់ទណ្ឌកម្ម ចំពោះមន្ត្រីនគរបាលយុត្តិធម៌នោះទេ គឺគាត់ត្រូវតែធ្វើសេចក្តីរាយការណ៍ដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ ហើយទើបអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ប្រកាសជូនដំណឹងដល់មន្ត្រីក្រសួងមហាផ្ទៃ ឬ រដ្ឋមន្ត្រីក្រសួងការពារជាតិពីចំណាត់ការ នៃនីតិវិធីវិន័យ។ ការដាក់ទណ្ឌកម្មមានដូចជា៖

- ការហាមមិនឱ្យបំពេញការងាររយៈពេល ៥ឆ្នាំ យ៉ាងច្រើនបំផុត
- ហាមមិនឱ្យបំពេញការងារជាស្ថាពរ ប៉ុន្តែមុខងារជាមន្ត្រី នៃស្ថាប័នដើមនៅរក្សាដដែល[27]។

### កថាខណ្ឌទី៣៖ បេសកកម្មរបស់នគរបាលយុត្តិធម៌

មន្ត្រីនគរបាលយុត្តិធម៌ គឺមានបេសកកម្មចំនួន ៣ ធំៗគឺ៖

១.ទទួលពាក្យបណ្តឹង អាចជាបណ្តឹងបរិហារ ឬ បណ្តឹងទាមទារ

២.ស្វែងរកបទល្មើសដោយខ្លួនឯង

៣.ស៊ើបអង្កេត ទាំងករណីបទល្មើសជាក់ស្តែង និងមិនជាក់ស្តែង[28]។

## ផ្នែកទី៤៖ ករណីការអនុវត្តជាក់ស្តែង និងការបាត់បង់សមាជិកភាពនៃនគរបាលយុត្តិធម៌

### កថាខណ្ឌទី១៖ ករណីការអនុវត្តជាក់ស្តែង

នៅក្នុងប្រទេសនីតិរដ្ឋ ការអនុវត្តគោលការណ៍ច្បាប់ គឺជាមូលដ្ឋានគ្រឹះនៃការគោរពសិទ្ធិមនុស្ស ដូច្នេះគ្រប់បទល្មើសដែលបានកើតឡើង ត្រូវតែបើការស៊ើបអង្កេតដោយហ្មត់ចត់ ដើម្បីស្វែងរកជនដែលប្រព្រឹត្តបទល្មើសយកមកផ្តន្ទាទោសតាមច្បាប់ បើពុំនោះទេនឹងធ្វើឱ្យសង្គមច្របូកច្របល់ គ្មានយុត្តិធម៌ ក្លាយជាសង្គមអនាធិបតេយ្យ គ្មានច្បាប់ទម្លាប់។ គ្រប់ការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ដើម្បីធ្វើការត្រួតពិនិត្យបទល្មើស កំណត់អត្តសញ្ញាណ ចាប់ខ្លួនជនល្មើស ព្រមទាំងធ្វើការប្រមូលភស្តុតាង។

បន្ទាប់ពីបានធ្វើការសិក្សាអំពីតួនាទី ភារកិច្ច មុខងារ បេសកកម្ម ក៏ដូចជានីតិវិធីនានារបស់នគរបាលចប់សព្វគ្រប់ហើយ យើងសង្កេតឃើញថា នៅក្នុងដំណាក់កាលនៃនគរបាលយុត្តិធម៌គឺពិតជាមានការមមាញឹកខ្លាំងណាស់ ចំពោះការបំពេញការងាររបស់ខ្លួន។ ហើយអ្វីដែលកាន់តែមានភាពស្មុគស្មាញថែមទៀតនោះ គឺនគរបាលយុត្តិធម៌ ត្រូវប្រឈមជាមួយបញ្ហានានាជាច្រើនដូចជា ការដោះស្រាយបញ្ហាជាមួយជនរងគ្រោះ ការ

---

[27] ឯកឧត្តម កើត រិទ្ធ សៀវភៅ នីតិវិធីព្រហ្មទណ្ឌ ទំព័រ១៥ ឆ្នាំ២០១៦

[28] ឯកឧត្តម កើត រិទ្ធ សៀវភៅនីតិវិធីព្រហ្មទណ្ឌ ទំព័រទី១៥ ឆ្នាំ២០១៦

ប្រថុយប្រថានជាមួយនឹងជនល្មើស ឬ ការចងគំនុំសងសឹកពីជនល្មើស ឬ ញាតិនៃជនល្មើស ឬ ការស៊ើបអង្កេតមានភាពលំបាកជាដើម ជាហេតុនាំឱ្យមានកត្តារាំងស្ទះក្នុងការអនុវត្តការងាររបស់ខ្លួន។

### ១.១.បញ្ហាដែលកើតមានចំពោះមន្ត្រីនគរបាលយុត្តិធម៌

ដោយយល់ឃើញថា មន្ត្រីនគរបាលយុត្តិធម៌មានតួនាទី និងភារកិច្ចយ៉ាងសំខាន់ ដែលមិនអាចខ្វះបានក្នុងការចូលរួមអន្តរាគមន៍គ្រប់បទល្មើសព្រហ្មទណ្ឌ ហេតុដូច្នេះហើយ ទើបមន្ត្រីនគរបាលចួនប្រទះនឹងបញ្ហាប្រឈមជាច្រើន។

ចំពោះបញ្ហាប្រឈមដែលកើតមានចំពោះមន្ត្រីនគរបាលយុត្តិធម៌រួមមានដូចជា៖

**ក.ការធ្វេសប្រហែសគួបផ្សំនឹងការខ្វះសម្ភារៈមធ្យោបាយ**

- ការងារមួយចំនួនអសកម្ម ដោយសារកង្វះខាតនៃការចុះផ្ទាល់ដល់មូលដ្ឋាន និងគោលដៅឈរជើង បានធ្វើឱ្យមានភាពចន្លោះប្រហោងក្នុងការអន្តរាគមន៍នៅពេលមានបទល្មើសកើតមានឡើង។
- ការចាត់តាំងអនុវត្តរបស់អង្គភាពការងាររបស់មន្ត្រីថ្នាក់ក្រោមឱ្យបានត្រឹមត្រូវ គួបផ្សំនឹងការមិនបានត្រួតពិនិត្យសកម្មភាពការងាររបស់មន្ត្រីថ្នាក់ក្រោមឱ្យបានត្រឹមត្រូវផងនោះ ធ្វើឱ្យប្រសិទ្ធភាពនៃការអនុវត្តផែនការ មិនទាន់ទទួលបានលទ្ធផលល្អប្រសើរនៅឡើយ។
- ការងារស៊ើបអង្កេត និងការបង្ក្រាបបទល្មើសព្រហ្មទណ្ឌវិញ មិនទាន់បានឆ្លើយតបទៅតាមសំណូមពរ និងទិសដៅផែនការការងារនៅឡើយ ជាពិសេស គឺការគ្រប់គ្រងមុខសញ្ញានៅក្នុងមូលដ្ឋាន ដូចជាមុខសញ្ញាក្មេងទំនើង ការប្រើប្រាស់គ្រឿងញៀន មុខសញ្ញាមានដីការចាប់ខ្លួន មុខសញ្ញាសេសសល់ មុខសញ្ញាករណីតស៊ូ និងមុខសញ្ញាដោះលែងចេញពីពន្ធនាគារ។
- ខ្វះមធ្យោបាយ សម្ភារៈ ថវិកា ដើម្បីបម្រើឱ្យកិច្ចប្រតិបត្តិការស្រាវជ្រាវ ធ្វើឱ្យការងារបង្ក្រាបបទល្មើសព្រហ្មទណ្ឌមិនបានទាន់ពេលវេលា ពេលខ្លះមានមធ្យោបាយខ្វះប្រេងសាំង យានជំនិះ អាគុយ អគ្គិសនីជាដើម[29]។

**ខ.មន្ត្រីនគរបាលយុត្តិធម៌មានអាណាព្យាបាលពីរ**

នៅក្នុងកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសព្រហ្មទណ្ឌ មន្ត្រីនគរបាលយុត្តិធម៌ ស្ថិតក្រោមអំណាចរបស់ព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរ(តាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួស)។ នៅក្នុងការបំពេញបេសកកម្ម មន្ត្រីនគរបាលយុត្តិធម៌ទទួលបញ្ជា ឬសុំបញ្ជាពីអាជ្ញាធរតុលាការរហូតដល់ចប់កិច្ចប្រតិបត្តិការរបស់ខ្លួន។ ទន្ទឹមនឹង

[29] លោក សុខ ដី បេក្ខជនបណ្ឌិតជំនាន់ទី១ សមត្ថកិច្ចនគរបាលយុត្តិធម៌នៅកម្ពុជា ទំព័រ៧

នេះ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវរាយការណ៍តាមឋានានុក្រមដល់មេកើយខ្លួន អំពីរឿងហេតុកើតឡើង និងសុំយោបល់ដឹកនាំ។ ដូច្នេះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវមានអាណាព្យាបាលពីរតាមឋានានុក្រមការងាររដ្ឋបាលស្ថិតក្រោមការត្រួតពិនិត្យរបស់ស្នងការនគរបាលរាជធានីភ្នំពេញ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ និងការងារនីតិវិធីព្រហ្មទណ្ឌ ស្ថិតក្រោមការសម្របសម្រួលរបស់ព្រះរាជអាជ្ញា។

តាមគោលការណ៍ច្បាប់ មន្ត្រីនគរបាលយុត្តិធម៌ មិនអាចតម្កល់រឿងព្រហ្មទណ្ឌណាមួយទុកឥតចាត់ការបានទេ ទោះបីជាក្រោយពីមានការសម្រុះសម្រួលគ្នារវាងជនល្មើស និងជនរងគ្រោះ ឬក៏មានការដកពាក្យប្តឹងក៏ដោយ។ មន្ត្រីនគរបាលយុត្តិធម៌ ដែលរក្សាទុកកំណត់ហេតុ ឬវត្ថុតាងដោយចេតនា ឬលាក់បាំងដល់អាជ្ញាធរតុលាការ អំពីអត្ថិភាពនៃកំណត់ហេតុ ឬវត្ថុតាង ត្រូវចាត់ទុកថា មន្ត្រីនគរបាលយុត្តិធម៌នោះបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ដែលត្រូវផ្តន្ទាទោសតាមក្រមព្រហ្មទណ្ឌឆ្នាំ២០០៩។

នៅក្នុងការអនុវត្តជាក់ស្តែង ជាបទពិសោធន៍ មានរឿងមួយបានកើតឡើងចំពោះមន្ត្រីនគរបាលយុត្តិធម៌ ក្រោយពីទទួលបញ្ជាពីថ្នាក់ដឹកនាំឱ្យធ្វើការសម្របសម្រួលបញ្ចប់រឿងទំនាស់នេះ ដោយមានការឯកភាពរវាងជនល្មើស និងជនរងគ្រោះ។ មន្ត្រីនគរបាលយុត្តិធម៌ ក៏បានសុំយោបល់ពីព្រះរាជអាជ្ញាដែរ ចំពោះករណីដែលគាត់បានទទួលបញ្ជាពីមេកើយឱ្យសម្របសម្រួល។ ពេលនោះ ព្រះរាជអាជ្ញា យល់ព្រមតាមការស្នើសុំ តែត្រូវបញ្ជូនសុំណុំរឿងមកកាន់អយ្យការ ដើម្បីឱ្យគាត់ពិនិត្យមើលអង្គហេតុ។ មន្ត្រីនគរបាលយុត្តិធម៌ បានរៀបចំសំណុំរឿងបញ្ជូនទៅឱ្យព្រះរាជអាជ្ញា នៅពេលដែលព្រះរាជអាជ្ញា ទទួលបានសំណុំរឿងរួចហើយ គាត់ក៏បានពិនិត្យមើលអង្គហេតុ និងអង្គច្បាប់ ចប់សព្វគ្រប់ហើយ គាត់យល់ឃើញថា មានភស្តុងតាងគ្រប់គ្រាន់សម្រាប់ធ្វើការចោទប្រកាន់។ ព្រះរាជអាជ្ញា ក៏សម្រេចធ្វើការចោទប្រកាន់បញ្ជូនសំណុំរឿងទៅចៅក្រមស៊ើបសួរ។ ជាលទ្ធផលចុងក្រោយសំណុំរឿងនេះ ត្រូវបានបញ្ចប់ជាស្ថាពរនៅតុលាការ ប៉ុន្តែមន្ត្រីនគរបាលយុត្តិធម៌រូបនោះ ត្រូវបានថ្នាក់ដឹកនាំធ្វើការស្តីបន្ទោសជាលាយលក្ខអក្សរ និងទម្លាក់ដំណែងទៅជាភ្នាក់ងារនគរបាលយុត្តិធម៌វិញ។

-សមត្ថកិច្ចជាន់គ្នារវាងនគរបាលជាតិ និងកងរាជអាវុធហត្ថ

ជាគោលការណ៍ មាត្រា៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ បានផ្តល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ដល់មន្ត្រីនៃនគរបាលជាតិ និងមន្ត្រីនៃកងរាជអាវុធហត្ថ មានភារកិច្ចធ្វើការត្រួតពិនិត្យ បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ កំណត់អត្តសញ្ញាណ ចាប់ជនល្មើស ព្រមទាំងការប្រមូលភស្តុតាង។ មន្ត្រីនគរបាល និងមន្ត្រីកងរាជអាវុធហត្ថ គឺចុះដល់កន្លែងកើតហេតុដូចគ្នា មានសិទ្ធិពិនិត្យទីកន្លែងកើតហេតុ សម្ភាសន៍សាក្សី ជនរងគ្រោះ ស្រង់ចម្លើយជនសង្ស័យ និងធ្វើការដែកឆេររហូតដល់ចប់កិច្ចប្រតិបត្តិការរៀងៗខ្លួន។ គ្រប់បេសកកម្មរបស់អង្គភាពទាំងពីរ មានគោលដៅរួម មានគោលបំណងតែមួយ ដើម្បីការពារផលប្រយោជន៍សាធារណៈ ទ្រព្យសម្បត្តិ អាយុជីវិតរបស់ប្រជាពលរដ្ឋបទូទៅ។

មាត្រា ៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ក៏បានចង្អុលបង្ហាញពីការកំណត់សមត្ថកិច្ចរបស់នគរបាលជាតិ និងកងរាជអាវុធ នៅក្នុងវិស័យនគរបាលយុត្តិធម៌។ ទោះបីជាក្រមនេះ បានចង្អុលបង្ហាញទៅលើអនុក្រឹត្យស្តីពីអំពីការបែងចែកភារកិច្ចមន្ត្រីនគរបាលជាតិ និងមន្ត្រីកងរាជអាវុធហត្ថក៏ដោយ ប៉ុន្តែរហូតមកដល់ពេលនេះ នៅតែពុំទាន់ឃើញមានអនុក្រឹត្យ ស្តីពីការកំណត់សមត្ថកិច្ចក្នុងការបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌នៅឡើយទេ[30]។

## ១.២.ដំណោះស្រាយចំពោះបញ្ហាប្រឈម

### ក.យន្តការបណ្តុះបណ្តាលជំនាញ និងច្បាប់

គោលនយោបាយកំណែទម្រង់កងកម្លាំងប្រដាប់អាវុធរបស់រាជរដ្ឋាភិបាល ដោយផ្តោតការយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍធនធានមនុស្ស និងការបង្កើតសមត្ថភាពខាងវិជ្ជាជីវៈនៃកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទតាមរយៈនៃបណ្តុះបណ្តាលប្រកបដោយគុណភាព និងប្រសិទ្ធភាព។

ក្រសួងមហាផ្ទៃបានដាក់ចេញនូវយន្តការកំណែទម្រង់កងកម្លាំងនគរបាលជាតិឱ្យក្លាយទៅជាកងកម្លាំងមួយ ដែលមានវិជ្ជាជីវៈពិតប្រាកដ បំពាក់ដោយបច្ចេកទេសទំនើប មានអត្តចរិតសុភាពរាបសារ មានសមត្ថភាពបំពេញភារកិច្ច មានស្មារតីទទួលខុសត្រូវខ្ពស់ គោរពប្រតិបត្តិច្បាប់ គោរពសិទ្ធិមនុស្ស រក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ការពារអាយុជីវិត និងទ្រព្យសម្បត្តិនានារបស់ប្រជាពលរដ្ឋ។ ដើម្បីអនុវត្តយន្តការនេះ ក្រសួងមហាផ្ទៃ បានប្រគល់ភារកិច្ចទៅឱ្យបណ្ឌិត្យសភាននគរបាលកម្ពុជា ធ្វើជាសេនាធិកាក្នុងការបណ្តុះបណ្តាលកងកម្លាំងនគរបាលជាតិទូទាំងប្រទេស។ ដើម្បីឱ្យបណ្ឌិត្យសភានគរបាលកម្ពុជា អនុវត្តបានតាមផែនការបណ្តុះបណ្តាលកងកម្លាំងនគរបាលជាតិទទួលបានជោគជ័យ ត្រូវមានការគាំទ្រពីរាជរដ្ឋាភិបាល ពីក្រសួងមហាផ្ទៃ និងការចូលរួមសហការគ្រប់អង្គភាព គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេស នាយកដ្ឋានបុគ្គលិក នៃអគ្គស្នងការដ្ឋាននគរបាលជាតិ មានការគាំទ្រ និងមានយន្តការតាមដានចំពោះនិស្សិត សិក្ខាកាម ដែលបណ្ឌិត្យសភានគរបាលកម្ពុជាបានដាក់វិន័យ ឬបណ្តេញចេញពីការសិក្សា។

### ខ.យន្តការពង្រឹងការអនុវត្តច្បាប់

-**ការលុបបំបាត់អំពើពុករលួយ៖** ជាគោលការណ៍នគរបាលយុត្តិធម៌ មិនត្រូវយកតួនាទីខ្លួនទៅការពារបនល្បែងស៊ីសង បនស្រីពេស្យាចារ ឬកន្លែងប្រព្រឹត្តិអមពើអបាយមុខ អំពើពាលា ដែលផ្ទុយពីច្បាប់ឡើយ។ មិនត្រូវយកតួនាទីខ្លួន ទៅការពារជនល្មើស ឬក្រុមប្រព្រឹត្តបទល្មើស ជនប្រព្រឹត្តសកម្មភាពចាប់ជំរិត លួច ឆក់ ប្លន់ កេងប្រវ័ញ្ចសម្បត្តិជាតិ ឬកេងប្រវ័ញ្ចកម្មសិទ្ធិអ្នកដទៃដែលស្របច្បាប់។ មិនត្រូវប្រើអំណាចគំរាមគំហែងប្រជាពល

[30] លោក សុខ ដី បេក្ខជនបណ្ឌិតជនបណ្ឌិតជំនាន់ទី១ សមត្ថកិច្ចនគរបាលយុត្តិធម៌នៅកម្ពុជា ទំព័រ៧ ៩

រដ្ឋ ដើម្បីធ្វើសំណូកការពារជនល្មើស និងប្រើប្រាស់សម្ភារៈរបស់រដ្ឋ បម្រើផលប្រយោជន៍ខ្លួន ព្រមទាំងហ៊ានប្រព្រឹត្តនូវបទល្មើសផ្សេងៗដែលផ្ទុយនឹងច្បាប់។ មិនត្រូវលាក់បាំងនូវសំណុំរឿង ឬវត្ថុតាង ឬធ្វើការដោះដូរវត្ថុតាង ដើម្បីប្រយោជន៍បុគ្គល។

**-ការលុបបំបាត់វប្បធម៌អន្តរាគមន៍៖** បរិបទនៃសង្គមខ្មែរនាបច្ចុប្បន្ន តែងតែកើតមាននូវបញ្ហាអន្តរាគមន៍ជាញឹកញាប់ វាគឺជាទម្លាប់ពលរដ្ឋខ្មែរ ក្នុងការទំនាក់ទំនងគ្នានៅក្នុងសង្គម ប៉ុន្តែបញ្ហាទាំងនេះ បានក្លាយជាទម្លាក់មិនអាចកែប្រែបាន សូម្បីតែអ្នករត់ម៉ូតូឌុបម្នាក់ ក៏អាចស្គាល់នគរបាលម្នាក់ដែរ ក្នុងការជួយអន្តរាគមន៍ពេលខ្លួនត្រូវការជាយថាហេតុ មិនថាមានរឿងរ៉ាវតូច ឬធំនោះទេ តែងតែចូលខ្លួនមកដោះស្រាយបញ្ចប់បញ្ហាដោយមិនទុកឱ្យសមត្ថកិច្ចចាត់ការតាមនីតិវិធី និងច្បាប់ឡើយ។ អ្នកដែលមានអំណាច មានឋានៈតួនាទីនៅក្នុងសង្គមមួយចំនួន តែងតែលូកលាន់នៅក្នុងកិច្ចការរបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលធ្វើឱ្យការបំពេញតួនាទីមិនទាន់បានល្អ មិនបានប្រកាន់ភ្ជាប់ក្នុងការអនុវត្តច្បាប់ និងមិនមានយុត្តិធម៌នៅក្នុងសង្គម។ ដើម្បីលុបបំបាត់នូវបញ្ហាទាំងនេះ ចាំបាច់ត្រូវពង្រឹងទូនាទី ភារកិច្ចមន្ត្រីនគរបាលយុត្តិធម៌ក្នុងការអនុវត្តច្បាប់ និងត្រូវយកគោលការណ៍ច្បាប់ជាមូលដ្ឋានគ្រឹះ។ បើមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ ដែលមិនបានប្រតិបត្តិតាមច្បាប់ត្រូវតែទទួលខាងវិន័យ និងទណ្ឌកម្មជាដាច់ខាត មិនត្រូវលើកលែងចំពោះមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ ដែលធ្វើឱ្យមានកមហុសឆ្គងក្នុងការបំពេញតួនាទីនោះទេ។

**-ការលុបបំបាត់វប្បធម៌និទណ្ឌភាព៖** កាលណាគ្មានយុត្តិធម៌ វានឹងមាននូវនិទណ្ឌភាព បើមាននិទណ្ឌភាព គឺគ្មានភាពស្មើគ្នាចំពោះមុខច្បាប់ឡើយ។ និទណ្ឌភាព គឺគ្មានការចាប់ខ្លួន និងនាំខ្លួន និងនាំខ្លួនជនប្រព្រឹត្តបទល្មើសមកធ្វើការវិនិច្ឆ័យទោស ពីព្រោះតែមុខតំណែង ឥទ្ធិពល ឬទ្រព្យធនរបស់ពួកគេ។ ដើម្បីចៀសវាងនូវរាល់បញ្ហាអស់ទាំងនេះ នគរបាលជាតិត្រូវមានភក្តីភាពចំពោះ ជាតិ សាសនា ព្រះមហាក្សត្រជានិច្ច។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើការស៊ើបអង្កេតភ្លាមៗ នូវខណៈពេលដែលខ្លួនបានដឹងពីការប្រព្រឹត្តបទល្មើស មិនត្រូវរង់ចាំឱ្យនរណាម្នាក់ ធ្វើពាក្យបណ្ដឹងជាមុននោះទេ មុខពេលដែលខ្លួនចាប់ផ្ដើមស៊ើបអង្កេត។

ជាគោលការណ៍ បើមានបទល្មើសព្រហ្មទណ្ឌ បទឧក្រិដ្ឋ ឬបទមជ្ឈឹម កើតឡើង ទោះបីជាគ្មានបណ្ដឹងក៏ដោយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែបើការស៊ើបអង្កេត ស្រាវជ្រាវស្វែងរកជនល្មើសដើម្បីកសាងសំណុំរឿងបញ្ជូនទៅតុលាការ។ បើមិនដូច្នោះទេ បញ្ហានិទណ្ឌភាព និងសកម្មភាពល្មើសច្បាប់កាន់តែមានច្រើនឡើងៗ ធ្វើឱ្យសង្គមច្របូកច្របល់ គ្មានសណ្ដាប់ធ្នាប់ គ្មានសុវត្ថិភាពក្លាយទៅជាសង្គមមួយអនាធិបតេយ្យ[31]។

[31] លោកសុខ ង៉ី បេក្ខជនបណ្ឌិតជំនាន់ទី១ សមត្ថកិច្ចនគរបាលយុត្តិធម៌នៅកម្ពុជា ទំព័រ៩-១០

## កថាខណ្ឌទី២៖ ការបាត់បង់សមាជិកភាព

ចំពោះការបាត់បង់ជាសមាជិកភាព នៃនគរបាលយុត្តិធម៌ គឺដោយសារតែនគរបាលយុត្តិធម៌នោះបាន ប្រព្រឹត្តខុសឆ្គងទៅលើវិន័យបញ្ញត្តិ ក៏ដូចជាការដល់អាយុដែលត្រូវចូលនិវត្តន៍ ហើយការបាត់បង់នេះទៀតសោត គឺអាស្រ័យទៅតាមមុខងាររបស់នគរបាលយុត្តិធម៌នោះផងដែរ។

### ២.១.តាមរយៈការពិន័យ

រាល់ការប្រព្រឹត្តកំហុសទាំងឡាយ ដែលបានប្រព្រឹត្តដោយមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាល យុត្តិធម៌ មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត នៅក្នុងពេលបំពេញមុខងាររបស់ខ្លួន ត្រូវតែឱ្យដំណឹង ដោយព្រះរាជអាជ្ញា ឬដោយចៅក្រមស៊ើបសួរ ជូនចំពោះអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញា ប្រកាសប្រាប់ដំណឹងដល់មន្ត្រី (រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិ ចំពោះមន្ត្រីនគរបាល យុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌) ឬភ្នាក់ងារនោះ នៅក្រោមឱវាទ ដើម្បីចាប់ផ្តើមនីតិវិធីខាងវិន័យ។ អគ្គ ព្រះរាជអាជ្ញា ត្រូវបានផ្តល់ដំណឹងអំពីចំណាត់ ការបន្តនៃនីតិវិធីខាងវិន័យ។ ទណ្ឌកម្មខាងវិន័យ មិនមែនជា ឧបសគ្គដល់ការធ្វើបណ្តឹងអាជ្ញាទេ ប្រសិនបើមានបទល្មើសត្រូវបានប្រព្រឹត្តឡើង[32]។

ការសម្រេចដាក់ទណ្ឌនេះ អាចធ្វើឡើងតាមរយៈការស្តីបន្ទោស ការផាកពិន័យ ការព្យួរការងារ ឬការការ បណ្តេញចេញពីក្របខណ្ឌនៃមុខងារជាដើម ដែលជាហេតុធ្វើឱ្យបាត់បង់ជាសមាជិកភាពនៃនគរបាលយុត្តិធម៌។

### ២.២.តាមរយៈការចូលនិវត្តន៍

ដូចដែលបានលើកឡើងហើយថា នគរបាលយុត្តិធម៌ គឺត្រូវបានចែកចេញជាបី ដែលរួមមាន មន្ត្រី នគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ និងមន្ត្រីរាជការសាធារណៈដទៃទៀតដែលច្បាប់បានផ្តល់ឱ្យ ដូច្នេះការចូលនិវត្តន៍របស់ពួកគាត់ គឺត្រូវបានកំណត់ទៅតាមច្បាប់ដោយឡែកពីគ្នា។ តួយ៉ាងដូចជា មន្ត្រីនគរបាល យុត្តិធម៌ ត្រូវបានចូលនិវត្តន៍ទៅតាមច្បាប់ដែលបានបញ្ញត្តិរបស់ខ្លួន ហើយនគរបាល និងភ្នាក់ងារសាធារណៈ ដទៃទៀត គឺតាមការផុតអាណត្តិ ឬ ដល់អាយុក្នុងការចូលនិវត្តន៍។

[32] មាត្រា ៦៤, មាត្រា ៧៩ និងមាត្រា ៨២ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

# ជំពូកទី៣

# អង្គការអយ្យការ

# ជំពូកទី៣

# អង្គការអយ្យការ

## ផ្នែកទី១៖ សញ្ញាណទូទៅនៃអង្គការអយ្យការ

អង្គការអយ្យការ គឺជាស្ថាប័នមួយតំណាងឱ្យអង្គការនីតិប្រតិបត្តិ ដែលនៅអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ហើយមានតួនាទីក្នុងការការពារថែរក្សាសណ្តាប់ធ្នាប់សាធារណៈ។ អង្គការអយ្យការមានតួនាទីធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ[33]។ បានសេចក្តីថា អង្គការអយ្យការមានសិទ្ធិក្នុងការបង្ក្រាបរាល់បទល្មើសទាំងឡាយណា ដែលជាបទល្មើសព្រហ្មទណ្ឌ ដើម្បីការពារផលប្រយោជន៍សាធារណៈ ក៏ដូចជាផលប្រយោជន៍សង្គមជាតិផងដែរ។ អង្គការអយ្យការធានារ៉ាប់រងការអនុវត្តសេចក្តីសម្រេចខាងបទល្មើសព្រហ្មទណ្ឌ ព្រមទាំងធានាយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួន។ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន អង្គការអយ្យការ មានសិទ្ធិកេណ្ឌកម្លាំងសាធារណៈដោយផ្ទាល់ជាជំនួយរបស់ខ្លួន។

អង្គការអយ្យការ គឺជាអង្គឯករាជ្យ ដែលមិនស្ថិតក្រោមអំណាចនៃសាលាជម្រះក្តីដែលខ្លួននៅអមនោះទេ ហើយសាលាជម្រះក្តីទៀតសោតគ្មានអំណាចត្រួតពិនិត្យកិច្ចការរបស់ព្រះរាជអាជ្ញាឡើយ ក្នុងករណីដែលព្រះរាជអាជ្ញាមានកំហុសឆ្គងក្នុងពេលបំពេញមុខងារក៏ដោយ ក៏សាលាជម្រះក្តីមិនត្រូវចុះសេចក្តីសម្រេចរបស់ខ្លួនយកការស្តីបន្ទោសអ្វីចំពោះព្រះរាជអាជ្ញាឡើយ។ ការហាមឃាត់នេះត្រូវអនុវត្តទាំងក្នុងរឿងព្រហ្មទណ្ឌ និងទាំងក្នុងរឿងក្តីផ្សេងៗទៀត។

### កថាខណ្ឌទី១៖ រចនាសម្ព័ន្ធរបស់អង្គការអយ្យការ

អង្គការអយ្យការត្រូវបានបែងចែងជាពីរ (២) ប្រភេទគឺ អយ្យការ និងមហាអយ្យការៈ

#### ១.១. អង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្ត

អង្គការអយ្យការអមសាលាដំបូងរាជធានី ខេត្ត គឺជាស្ថាប័នមួយសម្រាប់ធ្វើការចោទប្រកាន់រាល់រឿងក្តីដែលបានកើតមានឡើងនៅគ្រប់រាជធានី ខេត្តក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ អង្គការអយ្យការនេះត្រូវបានដឹកនាំដោយព្រះរាជអាជ្ញា និង ព្រះរាជអាជ្ញារងជាតំណាងឱ្យស្ថាប័ននេះ។

##### ១.១.១.ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញា ជាប្រធានក្នុងការដឹកនាំកិច្ចដំណើរការប្រព្រឹត្តទៅរបស់អង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្ត។ ព្រះរាជអាជ្ញា ជាភាគីនៅក្នុងរឿងក្តីព្រហ្មទណ្ឌបានសេចក្តីថា ព្រះរាជអាជ្ញាជាអ្នកធ្វើការចោទ

[33] មាត្រា៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ២

ប្រកាន់លើរឿងក្តីទាំងឡាយណាជារឿងព្រហ្មទណ្ឌ។

### ១.១.២. ព្រះរាជអាជ្ញារង

ព្រះរាជអាជ្ញារង ជាសេនាធិការស្ថិតក្រោមការដឹកនាំ និងការទទួលខុសត្រូវរបស់ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ហើយបានប្រើប្រាស់អំណាចទាំងអស់ ដែលព្រះរាជអាជ្ញាមានក្នុងការស្រាវជ្រាវ និងធ្វើការចោទប្រកាន់ទៅលើបទល្មើសព្រហ្មទណ្ឌ[34]។

### ១.២. អង្គការមហាអយ្យការ

អង្គការមហាអយ្យការ គឺជាអង្គការដែលនៅអមសាលាជម្រះក្តីជាន់ខ្ពស់ ដែលគេហៅថា មហាអយ្យការអមសាលាឧទ្ធរណ៍ និងមហាអយ្យការអមតុលាការកំពូល។ ម្យ៉ាងវិញទៀតអង្គការនេះក៏បានដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្រួលដល់កិច្ចដំណើរការរបស់សាលាដំបូងរាជធានីផងដែរ ក្នុងការប្តឹងឧទ្ធរណ៍ជាដើម។

### ១.២.១. មហាអយ្យការអមសាលាឧទ្ធរណ៍

មហាអយ្យការអមសាលាឧទ្ធរណ៍ត្រូវបានដឹកនាំដោយ អគ្គព្រះរាជអាជ្ញា អមដោយអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាក្នុងការជួយសម្រួលដល់កិច្ចដំណើរការក្នុងសាលាឧទ្ធរណ៍[35]។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មានអំណាចក្នុងការគ្រប់គ្រងទៅលើអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញាមានសិទ្ធិអំណាចក្នុងការចាត់តាំងអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាក្នុងកិច្ចដំណើរការផ្សេងៗ ព្រមទាំងអង្គជំនុំជម្រះ។ រាល់សេចក្តីសន្និដ្ឋានដែលបានធ្វើឡើងដោយអគ្គព្រះរាជអាជ្ញារង ឬ ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវដាក់ឱ្យអគ្គព្រះរាជអាជ្ញាត្រួតពិនិត្យជាមុនសិនមុនពេលសវនាការ។

អគ្គព្រះរាជអាជ្ញា មានសិទ្ធិធ្វើអធិបញ្ញាលើព្រះរាជអាជ្ញាអមសាលាដំបូង ឱ្យធ្វើការចោទប្រកាន់ ឬ ចាត់ឱ្យចោទប្រកាន់ ឬ ក៏ធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាដែលខ្លួនយល់ឃើញថាជាការគួរ[36]។ ម្យ៉ាងវិញទៀត អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចធ្វើអធិការកិច្ចនៅអង្គការអយ្យការទាំងឡាយដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន[37]។ ជាមួយគ្នានេះដែរ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឃ្លាំមើលការអនុវត្តច្បាប់ នៅក្នុងសមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍ផងដែរ។

---

[34] មាត្រា៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ១១

[35] មាត្រា៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ៩

[36] មាត្រា២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ៨

[37] មាត្រា៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ៩

#### ១.២.២. មហាអយ្យការអមតុលាការកំពូល

អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល គឺជាតំណាងនៃមហាអយ្យការអមតុលាការកំពូល[38]។

អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ចូលរួមក្នុងការសុំឱ្យមានការគោរពច្បាប់ នៅពេលដែលមានបណ្តឹងសារទុក្ខ បណ្តឹងសើរើ និងបណ្តឹងតវ៉ាផ្សេងៗទៀត ដែលដាក់ជូនតុលាការកំពូលពិនិត្យ[39]។

ដើម្បីបញ្ចៀសវិវាទសមត្ថកិច្ចរវាងព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ដូច្នេះត្រូវកំណត់ដែនសមត្ថកិច្ច ភារកិច្ច សិទ្ធិអំណាច និងតួនាទីរបស់ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងឱ្យបានជាក់លាក់។

## កថាខណ្ឌទី២៖ សមត្ថកិច្ច ភារកិច្ច សិទ្ធិអំណាច និងតួនាទីរបស់អង្គការអយ្យការ

### ២.១. សមត្ថកិច្ចរបស់ព្រះរាជអាជ្ញា

ក្នុងករណីដែលមានបទល្មើសមួយកើតមានឡើង តាមការស្រាវជ្រាវលើបទល្មើសមួយអាចនឹងធ្វើឡើងជាច្រើនទីកន្លែងតាមការកំណត់ ដែលពាក់ព័ន្ធនឹងបទល្មើសនោះមានជាអាទិ៍ ទីតាំងប្រព្រឹត្តបទល្មើស ទីតាំងជនសង្ស័យរស់នៅ និងទីតាំងចាប់ខ្លួនជនសង្ស័យ។ ដូចនេះហើយ ដើម្បីកំណត់ថាតើបទល្មើសមួយដែលកើតមានឡើង ព្រះរាជអាជ្ញាណាមានសមត្ថកិច្ចក្នុងការដោះស្រាយបទល្មើសនោះ? ចំពោះដែនសមត្ថកិច្ចរបស់ព្រះរាជអាជ្ញាត្រូវបានកំណត់ដូចខាងក្រោម៖

- ព្រះរាជអាជ្ញានៃទីកន្លែងដែលមានការប្រព្រឹត្តបទល្មើស
- ព្រះរាជអាជ្ញានៃលំនៅស្ថានរបស់ជនដែលគេសង្ស័យថាបានប្រព្រឹត្តបទល្មើស
- ព្រះរាជអាជ្ញានៃទីកន្លែងចាប់ខ្លួនជនដែលត្រូវបានសង្ស័យថា បានប្រព្រឹត្តបទល្មើស[40]។

### ២.២. ភារកិច្ចរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញា មានភារកិច្ចដើរតួយ៉ាងសំខាន់ជាអ្នកធ្វើការចោទប្រកាន់រាល់បទល្មើសទាំងឡាយណាជាបទល្មើសព្រហ្មទណ្ឌ។ ដោយតួនាទីនេះ ត្រូវគោរពគោលការណ៍នៃការអនុវត្តការងាររបស់ខ្លួន ដោយមិនលម្អៀង និងលុបបំបាត់ចោលនូវការរើសអើងពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា និន្នាការនយោបាយ សញ្ជាតិ និងការរើសអើងផ្សេងៗទៀត។

---

[38] មាត្រា៣១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ៩

[39] មាត្រា៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ៩

[40] មាត្រា៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ១១

ព្រះរាជអាជ្ញា ត្រូវទទួលធានាក្នុងការការពារផលប្រយោជន៍ ដោយយកចិត្តទុកដាក់ចំពោះជនសង្ស័យ និងជនរងគ្រោះ ដោយមិនលម្អៀងព្រមទាំងមានការប្រុងប្រយ័ត្នខ្ពស់ទៅលើការគ្រប់គ្រងស្ថានភាពដែលមានការពាក់ព័ន្ធទូទៅនឹងជនសង្ស័យទាំងអស់ ទោះបីជាស្ថានភាពនោះមានប្រយោជន៍ ឬ គ្មានប្រយោជន៍សម្រាប់ជនសង្ស័យក៏ដោយ[41]។

ព្រះរាជអាជ្ញា ត្រូវរក្សារឿងក្តីដែលមាននៅក្នុងសមត្ថកិច្ចជាការសម្ងាត់ ដើម្បីបញ្ជាក់ពីភាពយុត្តិធម៌នៃតុលាការ។ ម្យ៉ាងវិញទៀត ជាការការពារផលប្រយោជន៍របស់ជនរងគ្រោះ និងត្រូវធានាថាមិនមានការរំលោភអំណាចផ្សេងៗ ដែលនាំឱ្យជាក្តីបារម្ភរបស់ជនរងគ្រោះ។

### ២.៣. សិទ្ធិអំណាចរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាប្រើប្រាស់សិទ្ធិអំណាចដែលច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗដែលបានប្រគល់ឱ្យប្រើប្រាស់តាមការកំណត់។

ព្រះរាជអាជ្ញាមានសិទ្ធិអំណាចជាគោលការណ៍ ក្នុងការទទួលបានគ្រប់ព័ត៌មានទាំងអស់ដែលជាប្រយោជន៍ក្នុងបណ្តឹង។ ក្នុងករណីដែលព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ដោយផ្អែកលើការវិនិច្ឆ័យជា ០៣ ទម្រង់គឺៈ ការបើកការស៊ើបសួរ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម[42]។

ព្រះរាជអាជ្ញាក្នុងដំណាក់កាលចោទប្រកាន់នេះអាចធ្វើការបែងចែកជា ០៣ គឺ អំណាចលើនគរបាលយុត្តិធម៌ អំណាចក្នុងការស៊ើបអង្កេត និងអំណាចក្នុងការចោទប្រកាន់។

អំណាចលើមន្ត្រីនគរបាលយុត្តិធម៌ៈ ព្រះរាជអាជ្ញាដឹកនាំ និងសម្របសម្រួលសកម្មភាពមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់ នៅក្នុងដែលសមត្ថកិច្ចរបស់ខ្លួន។ ហើយក្នុងករណីដែលមន្ត្រីនគរបាលយុត្តិធម៌បានអនុវត្តដីកាសម្រេចចាត់ឱ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្ថិតក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ។ ព្រះរាជអាជ្ញាអាចចុះទៅកន្លែងកើតហេតុដើម្បីធ្វើការស៊ើបអង្កេត និងធ្វើការណែនាំដល់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ក្នុងការបំពេញភារកិច្ចរបស់ខ្លួន។ ជាពិសេសព្រះរាជអាជ្ញាអាចដកសិទ្ធិស៊ើបអង្កេតពីមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ ហើយរៀបចំជំនួសសមាសភាពមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ថ្មី។ ជាមួយគ្នានេះផងដែរ ព្រះរាជអាជ្ញាអាចធ្វើអធិការកិច្ចបានគ្រប់ពេលវេលា នៅអង្គភាពនគរបាលយុត្តិធម៌ ដើម្បីត្រួតពិនិត្យពីកិច្ចដំណើរការលើសំណុំរឿង[43]។

---

[41] ចំណុច ១៣ (ក) (ខ) នៃគោលការណ៍ណែនាំស្តីពី "តួនាទីព្រះរាជអាជ្ញា" អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទី៧ ចាប់ពីថ្ងៃទី២៧ ខែសីហា ដល់ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩០ នៅប្រទេសគុយបា ទីក្រុងហាវ៉ាណា

[42] មាត្រា៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ១២

[43] មាត្រា៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ១០

អំណាចក្នុងការស៊ើបអង្កេត៖ ដើម្បីធ្វើការចោទប្រកាន់ ថាជាបទល្មើសចំពោះអំពើណាមួយនោះ ព្រះរាជអាជ្ញា ត្រូវបើកការស៊ើបអង្កេត ដោយពិនិត្យលើអង្គហេតុនោះជាបទល្មើសព្រហ្មទណ្ឌដែរឬទេ? និងមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ក្នុងការធ្វើការចោទប្រកាន់ដែរឬទេ? ដោយការស៊ើបអង្កេតនេះ ព្រះរាជអាជ្ញាមានសិទ្ធិអំណាចក្នុងការបើកស៊ើបអង្កេតជាក់ស្តែង និងការស៊ើបអង្កេតបឋម មានជាអាទិ៍ដូចជា ការឃាត់ខ្លួន ការឆែកឆេរ ការចាប់យកវត្ថុតាង ការស្តាប់ចម្លើយ ការធ្វើកំណត់ហេតុ ការធ្វើកោសល្យវិច្ច័យ និងការស្តាប់ការសន្ទនា។

អំណាចក្នុងការធ្វើការចោទប្រកាន់៖ ក្នុងដំណាក់កាលចោទប្រកាន់ ព្រះរាជអាជ្ញាមានសមត្ថកិច្ច និងទទួលបន្ទុកក្នុងការធ្វើចំណាត់ការលើសំណុំរឿង ដោយព្រះរាជអាជ្ញាមានសិទ្ធិក្នុងការតម្កល់រឿងទុកឥតចាត់ការ បើទោះបីជាមានបទល្មើសព្រហ្មទណ្ឌក៏ដោយ ឬ ក៏ធ្វើការចោទប្រកាន់ដែលហៅថា គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់។

### ២.៤. តួនាទីរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញា បានដើរតួនាទីយ៉ាងសំខាន់ក្នុងចំណាត់ការរឿងក្តីព្រហ្មទណ្ឌ និងស្ថាប័នអយ្យការផងដែរ ដោយច្បាប់អនុញ្ញាត ឬ ស្របតាមការអនុវត្តក្នុងស្រុក ដោយធ្វើការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ ពិនិត្យមើលសេចក្តីសម្រេចរបស់តុលាការ ពិនិត្យមើលនីត្យានុកូលភាពនៃបទល្មើស និងការបំពេញតួនាទីសំខាន់ផ្សេងៗទៀតដែលជាប្រយោជន៍របស់សាធារណៈ។

ព្រះរាជអាជ្ញាត្រូវតែបំពេញតួនាទីរបស់ខ្លួនឱ្យបានម៉ឺងម៉ាត់ ត្រឹមត្រូវ និងឱ្យទាន់ពេលវេលាដោយគោរពសេចក្តីថ្លៃថ្នូររបស់មនុស្ស និងលើកកម្ពស់សិទ្ធិមនុស្សផងដែរ។ ជារួមព្រះរាជអាជ្ញាត្រូវបានចូលរួមក្នុងកិច្ចដំណើរការដ៏ត្រឹមត្រូវនៃការប្រព្រឹត្តទៅរបស់ប្រព័ន្ធយុត្តិធម៌ លើផ្នែកព្រហ្មទណ្ឌ ដោយរលូន[44]។

## កថាខណ្ឌទី៣៖ គោលការណ៍សំខាន់ៗរបស់អង្គការអយ្យការ

### ៣.១. គោលការណ៍អវិភាគ

គោលការណ៍អវិភាគ បានសេចក្តីថាគឺជាគោលការណ៍មួយដែលកំណត់ឱ្យព្រះរាជអាជ្ញាមានភារកិច្ចបំពេញក្នុងអង្គការអយ្យការអមសាលាជម្រះក្តីណាមួយ ត្រូវមានកាតព្វកិច្ចរួមក្នុងមុខងារនោះ និងអាចជំនួសគ្នាទៅវិញទៅមកបានដូចជាក្នុងករណីមានធុរៈ ឬមានជម្ងឺ ឬអវត្តមាន ព្រះរាជអាជ្ញាត្រូវបានចាត់តាំង ព្រះរាជអាជ្ញារងណាម្នាក់ដើម្បីជំនួសបាន។ តាមគោលការណ៍នេះតំណាងអយ្យការ អាចបន្តការងារគ្នាបាននៅក្នុងសំណុំរឿងតែមួយតាមការចាត់តាំងរបស់នាយហ៊ានានុក្រម។

[44] ចំណុច ១២ នៃគោលការណ៍ណែនាំស្តីពី "តួនាទីព្រះរាជអាជ្ញា" អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទី៧ ចាប់ពីថ្ងៃទី២៧ ខែសីហា ដល់ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩០ នៅប្រទេសគុយបា ទីក្រុងហាវ៉ាណា

ករណីដែលព្រះរាជអាជ្ញាស្ថិតក្នុងស្ថានភាពមិនអាចបំពេញការងារបាន ឬ ក្នុងករណីតំណែងព្រះរាជអាជ្ញាស្ថិតក្នុងភាពទំនេរ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចាត់តាំងព្រះរាជអាជ្ញារងណាម្នាក់ឱ្យធ្វើជាព្រះរាជអាជ្ញាស្ដីទីជំនួសបាន ដើម្បីធានាដំណើរការរបស់អយ្យការអមសាលាដំបូងរហូតដល់មានការតែងតាំងព្រះរាជអាជ្ញាជាផ្លូវការ។

### ៣.២. គោលការណ៍ឯកភាព

គោលការណ៍នេះ គឺជាគោលការណ៍មួយដែលឱ្យតំណាងអយ្យការទាំងអស់អនុវត្តការងាររបស់ខ្លួនដោយតម្រូវស្ថិតក្រោម ការដឹកនាំ និងការត្រួតពិនិត្យតាមឋានានុក្រមរបស់ខ្លួន។ ឋានានុក្រមនេះត្រូវកំណត់ក្នុងមាត្រា ២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧៖

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌៖ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ គឺជាឋានានុក្រមខ្ពស់នៃអង្គការអយ្យការ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នៃអង្គការអយ្យការអាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរទៅអង្គការអយ្យការគ្រប់ជាន់ថ្នាក់មានដូចជា អង្គការអយ្យការអមសាលាឧទ្ធរណ៍ និងអង្គការអយ្យការអមសាលាដំបូង។ អគ្គនាយកដ្ឋាន កិច្ចការអយ្យការ និងព្រហ្មទណ្ឌនៃក្រសួងយុត្តិធម៌ ជាសេនាធិការឱ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌លើកិច្ចការនេះ។

អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល៖ គឺជានាយឋានានុក្រមនៃមហាអយ្យការអមតុលាការកំពូល។ អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូលត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួន។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍៖ គឺជានាយឋានានុក្រមនៃមហាអយ្យការអមសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញា នៃមហាអយ្យការអមសាលាឧទ្ធរណ៍ត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួន។

ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី-ខេត្ត៖ គឺជានាយឋានានុក្រមនៃអយ្យការអមសាលាដំបូងរាជធានី-ខេត្ត។ ព្រះរាជអាជ្ញារងទាំងអស់នៃអយ្យការអមសាលាដំបូងត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់ព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួន។

### ៣.៣. គោលការណ៍ឯករាជ្យ

អង្គការអយ្យការ ដែលបង្កើតឡើងនៅអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ គឺមានឯករាជ្យភាពពីអំណាចតុលាការដោយមិនស្ថិតក្រោមអំណាចសាលាជម្រះក្តីដែលខ្លួនបានអមនោះទេ និងជាស្ថាប័នឯករាជ្យមិនចំណុះឱ្យសាលាជម្រះក្តីទេ។ ពោល គឺតុលាការមិនអាចធ្វើអធិបញ្ញាលើតំណាងអយ្យការទេ ហើយសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់មិនអាចធ្វើការត្រួតពិនិត្យលើកិច្ចដំណើរការ របស់ព្រះរាជអាជ្ញាបានឡើយ ព្រោះវាជាការបំពានគោលការណ៍នៃការបែងចែកមុខងារ និងអំណាចរបស់ស្ថាប័នទាំងបី។ ព្រះរាជអាជ្ញាមានសេរីភាព ក្នុងការ

និយាយបានដោយសេរីទៅលើអង្គហេតុ នៃការសាកសួរដេញដោល ដើម្បីរកភស្តុតាងមកធ្វើការដាក់បន្ទុកក្នុងការចោទប្រកាន់លើជនជាប់ចោទនៅពេលមានសវនាការ។ ក្នុងករណីដែលមានការប្រព្រឹត្តកំហុសឆ្គងកើតឡើងក្នុងពេលបំពេញមុខងាររបស់ព្រះរាជអាជ្ញា សាលាជម្រះក្តីមិនអាចធ្វើការស្តីបន្ទោស ឬ សេចក្តីសម្រេចរបស់ខ្លួនទៅលើព្រះរាជអាជ្ញាបានឡើយ។ ដោយសាលាជម្រះក្តីអាចលើកសំណើរទៅកាន់នាយឋានានុក្រមរបស់ព្រះរាជអាជ្ញាដើម្បីធ្វើចំណាត់ការអំពីកំហុសឆ្គងរបស់ព្រះរាជអាជ្ញានោះ។

### ៣.៤. គោលការណ៍មិនអាចប្តឹងជិតចិត្ត

អង្គការអយ្យការដែលមានព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងដែលស្ថិតក្នុងតំណាងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត មិនត្រូវបានពាក់ព័ន្ធទៅនឹងការប្តឹងជិតចិត្តបានទេ ព្រោះថាព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ក្នុងនាមជាអ្នកតំណាងឱ្យរដ្ឋ ហើយព្រះរាជអាជ្ញាមិនតំណាងឱ្យខ្លួនឯងនោះទេ បើទោះបីជាព្រះរាជអាជ្ញាមានការជាប់ពាក់ព័ន្ធនឹងសាច់ញាតិ ឬ មានផលប្រយោជន៍ក្នុងបណ្តឹងក៏ដោយ។ម្យ៉ាងវិញទៀត ទោះបីជាមានការចោទប្រកាន់របស់ព្រះរាជអាជ្ញាក៏ដោយ ក៏មិនមែនបានន័យថាបុគ្គលនោះជាជនដែលបានប្រព្រឹត្តបទល្មើសនោះដែរ។

### ៣.៥. គោលការណ៍នៃការមិនទទួលខុសត្រូវ

ព្រះរាជអាជ្ញាក្នុងនាមជាអ្នកតំណាងឱ្យរដ្ឋ ក្នុងការចោទប្រកាន់ចំពោះអង្គហេតុទាំងឡាយណាដែលគិតថាជាបទល្មើសព្រហ្មទណ្ឌ។ ក្នុងករណីខ្លះ អង្គហេតុដែលព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់អាចនឹងត្រូវច្រានចោលដោយចៅក្រមស៊ើបសួរ នៅក្នុងដំណាក់កាលនៃការស៊ើបសួរ ឬ ដោយចៅក្រមជំនុំជម្រះ ប្រសិនបើអង្គហេតុនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌ ឬ មិនមានភស្តុតាងក្នុងការដាក់បន្ទុកគ្រប់គ្រាន់ដើម្បីកំណត់ធាតុផ្សំនៃបទល្មើស។ ប្រសិនបើមានករណីនេះកើតមានឡើង ព្រះរាជអាជ្ញាមិនអាចត្រូវទទួលខុសត្រូវរាល់ការខូតខាតទាំងឡាយដែលកើតចេញពីការសម្រេចចិត្តរបស់ព្រះរាជអាជ្ញាទៅលើរឿងក្តីដែលខ្លួនទទួលខុសត្រូវ ជាពិសេសជនត្រូវចោទ ឬ ជនជាប់ចោទនៅក្នុងសំណុំរឿងនោះទេ។ ផ្ទុយមកវិញ គោលការណ៍នៃការមិនទទួលខុសត្រូវនៃអង្គការអយ្យការនៅក្នុងការចោទប្រកាន់មិនមែនបានន័យថា ព្រះរាជអាជ្ញាអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌនៅពេលដែលខ្លួនបានប្រព្រឹត្តកំហុសជាបទល្មើសព្រហ្មទណ្ឌ ដោយកើតចេញពីឆន្ទៈទុច្ចរិតនៅពេលបំពេញងាររបស់ខ្លួននោះទេ។ ហេតុនេះ ប្រសិនបើមានករណីដែលព្រះរាជអាជ្ញាបានប្រព្រឹត្តកំហុសដែលជាបទល្មើសព្រហ្មទណ្ឌណាមួយនោះ នាំឱ្យព្រះរាជអាជ្ញាត្រូវតែទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌដែលខ្លួនបានប្រព្រឹត្ត។

## ផ្នែកទី២៖ ការរៀបចំអង្គការអយ្យការ

ការគ្រប់គ្រងអង្គការអយ្យការត្រូវស្ថិតនៅក្រោមឋានានុក្រម ហើយឋានានុក្រមនេះពិសេសដាច់ដោយឡែកទៅតាមសមត្ថកិច្ចដែនដីរបស់ខ្លួន។ ឋានានុក្រមពិសេសនេះ ជាទូទៅប្រើទាំងផ្នែករដ្ឋបាល និងចំណាត់ការ

សំណុំរឿង ដែលគេឱ្យឈ្មោះថា "**អធិបញ្ញា**"។

ចំពោះអធិបញ្ញា គឺត្រូវធ្វើឡើងក្រោមទម្រង់ ០៣ យ៉ាងគឺ៖

១.ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ

២.ក្នុងទិសដៅនៃការចោទប្រកាន់ ហើយមិនអាចក្នុងទិសដៅតម្កល់រឿងទុកឥតចាត់ការទេ

៣.អ្នកទទួលអធិបញ្ញា ត្រូវតែអនុវត្តតាមជាដាច់ខាត។

អ្នកដែលអាចចេញអធិបញ្ញាបានរួមមាន៖

- ព្រះរាជអាជ្ញានៃសាលាដំបូង អាចចេញអធិបញ្ញាទៅលើព្រះរាជអាជ្ញារងទាំងអស់
- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចចេញអធិបញ្ញាទៅព្រះរាជអាជ្ញា ដែលឋិតនៅក្នុងដែនដីរបស់ខ្លួន
- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មានសិទ្ធិចេញអធិបញ្ញា ទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញាអមសាលាដំបូងទាំងអស់ លើកលែងតែអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល។

## កថាខណ្ឌទី១៖ ការជ្រើសរើសព្រះរាជអាជ្ញា

ការជ្រើសរើស និងការបណ្តុះបណ្តាលព្រះរាជអាជ្ញា ត្រូវអនុវត្តរួមគ្នាជាមួយការជ្រើសរើស និងការបណ្តុះបណ្តាលចៅក្រម តាមបញ្ញត្តិនៃជំពូកទី២ (ចៅក្រម) ផ្នែកទី៥ (ការជ្រើសរើសចៅក្រម) នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា[45]។

សិស្សព្រះរាជអាជ្ញា ដែលបានបញ្ចប់ការបណ្តុះបណ្តាលវិជ្ជាជីវៈដោយជោគជ័យ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ជាព្រះរាជអាជ្ញាកម្មសិក្សា ក្នុងឋានន្តរសក្តិជាអនុព្រះរាជអាជ្ញាថ្នាក់ដំបូងគេ។ ព្រះរាជអាជ្ញាកម្មសិក្សាត្រូវធ្វើកម្មសិក្សារយៈពេល០១ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការតែងតាំង។

ការធ្វើកម្មសិក្សារបស់ព្រះរាជអាជ្ញាកម្មសិក្សា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសមាជិកទាំងអស់នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ការតែងតាំងជាព្រះរាជអាជ្ញាកម្មសិក្សា មានអានុភាពដល់ការរៀបចំប្រាក់បៀវត្ស និងការគិតអំពីអតីតភាពការងារ[46]។

ព្រះរាជអាជ្ញាកម្មសិក្សា ដែលបានបំពេញកម្មសិក្សាចប់ដោយជោយជ័យ ត្រូវតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញា និងមានឋានន្តរសក្តិជាអនុព្រះរាជអាជ្ញាថ្នាក់ដំបូងគេ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមលើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រ អំពីការតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញានេះ តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

[45] មាត្រា៨២ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និង ព្រះរាជអាជ្ញា ឆ្នាំ២០១៤ ទំព័រ ២៥

[46] មាត្រា៨៣ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និង ព្រះរាជអាជ្ញា ឆ្នាំ២០១៤ ទំព័រ ២៦

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចសម្រេចឱ្យព្រះរាជអាជ្ញាកម្មសិក្សា បន្តធ្វើកម្មសិក្សា០១ឆ្នាំ បន្ថែមទៀត កាលបើព្រះរាជអាជ្ញាកម្មសិក្សានោះ ពុំទទួលបានជោគជ័យក្នុងការធ្វើកម្មសិក្សា ឬ មានការអាក់ខានមិនបានធ្វើកម្មសិក្សាសរុបទាំងអស់លើសពី ៣០ ថ្ងៃ។ ក្នុងករណីដែលព្រះរាជអាជ្ញាកម្មសិក្សាឈប់រហូតលើសពី ៣០ថ្ងៃ ដោយគ្មានការអនុញ្ញាតច្បាប់ ឬ ព្រះរាជអាជ្ញាកម្មសិក្សា ដែលមិនបានទទួលជោគជ័យជាថ្មីម្តងទៀត ក្នុងការធ្វើកម្មសិក្សាបន្ថែម ត្រូវលុបឈ្មោះចេញពីក្របខណ្ឌព្រះរាជអាជ្ញា ដោយអនុវត្តទៅតាមបញ្ញត្តិមាត្រា ៨៤ នៃច្បាប់នេះ[47]។

ព្រះរាជអាជ្ញាកម្មសិក្សា ដែលមិនមានសម្បទាគ្រប់គ្រាន់ ឬ មានសុខភាពមិនគ្រប់គ្រាន់ដើម្បីបំពេញមុខងាររបស់ខ្លួនតាមលក្ខខណ្ឌ ដែលច្បាប់បានកំណត់ ឬ មានការខុសឆ្គងនៅក្នុងការបម្រើការងារមិនបានពេញលេញអាចត្រូវលុបឈ្មោះចេញពីក្របខណ្ឌព្រះរាជអាជ្ញា បានគ្រប់ពេលវេលាដោយអនុវត្តតាមបញ្ញត្តិនៃមាត្រា ៨៩ នៃច្បាប់នេះ។

ការលុបឈ្មោះចេញ ឬ ការតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញា ត្រូវធ្វើក្នុងរយៈពេល ០៣ ខែយ៉ាងតិច ក្រោយពីការបញ្ចប់កម្មសិក្សា[48]។

## កថាខណ្ឌទី២៖ សមាសភាពរបស់អង្គការអយ្យការ

ចំពោះសមាសភាព នៃអង្គការអយ្យការ គឺត្រូវបានចែកចេញជា ០៣ ផ្នែកផ្សេងៗពីគ្នា ដោយចំណុចទី១ និងទី២ គឺមិនបានលើកយកមកសរសេរពិស្តារនោះទេ រីឯចំណុចទី៣ គឺជាចំណុចដែលសំខាន់ ដែលត្រូវយកមកសរសេរយ៉ាងពិស្តារ អំពីសមាសភាពនៃអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ដែលរួមមានដូចតទៅ៖

**ចំណុចទី១៖** មហាអយ្យការអមតុលាការកំពូល

ពាក្យថា មហាអយ្យការ គឺសំដៅលើឈ្មោះស្ថាប័នមួយដែលជាស្ថាប័នអវិភាគ ហើយនៅអមតុលាការកំពូល។ ចំពោះអ្នកដែលធ្វើការនៅក្នុងមហាអយ្យការអមតុលាការកំពូលគឺ មានសមាសភាពដូចខាងក្រោម៖

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង
- ព្រះរាជអាជ្ញា
- ក្រឡាបញ្ជី និង
- មន្ត្រីរដ្ឋបាល និង អាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត។

**ចំណុចទី២៖** មហាអយ្យការអមសាលាឧទ្ធរណ៍

[47] មាត្រា៨៤ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤ ទំព័រ២៦

[48] មាត្រា៨៥ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤ ទំព័រ២៦

ដូចដែលបានបញ្ជាក់ខាងលើរួចមកហើយ ថានៅអមតុលាការកំពូល មានមហាអយ្យការអមតុលាការកំពូល។ ដោយឡែកនៅសាលាឧទ្ធរណ៍វិញ ក៏មានស្ថាប័នមួយនៅអមដែរ ដែលគេហៅថា មហាអយ្យការអមសាលាឧទ្ធរណ៍។

សមាសភាពដែលបម្រើការងារនៅមហាអយ្យការអមសាលាឧទ្ធរណ៍មានដូចតទៅៈ

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង
- ព្រះរាជអាជ្ញា
- ក្រឡាបញ្ជី និង
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត។

**ចំណុចទី៣ៈ** អយ្យការអមសាលាដំបូងរាជធានី-ខេត្ត

នៅតាមសាលាដំបូងរាជធានី-ខេត្ត គឺមានស្ថាប័នមួយនៅអមដូចនៅសាលាឧទ្ធរណ៍ និងនៅតុលាការកំពូលដែរ។ ស្ថាប័ននោះហៅថា អយ្យការអមសាលាដំបូង។

អយ្យការអមសាលាដំបូង មានសមាសភាពដូចតទៅៈ

- ព្រះរាជអាជ្ញា
- ព្រះរាជអាជ្ញារង
- ក្រឡាបញ្ជី និង
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត[49]។

## កថាខណ្ឌទី៣ៈ ភារកិច្ចព្រះរាជអាជ្ញា

ព្រះរាជអាជ្ញា ត្រូវមានភារកិច្ចទទួលខុសត្រូវចំពោះកិច្ចការដែលបានប្រគល់ឱ្យ និងគោរពបទបញ្ជាយ៉ាងម៉ឺងម៉ាត់នូវក្រមសីលធម៌របស់ខ្លួន។

ក្នុងជីវភាពរស់នៅផ្ទាល់ខ្លួនព្រះរាជអាជ្ញា មិនត្រូវប្រព្រឹត្តអំពើណាមួយដែលនាំឱ្យអាប់ឱនដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ខ្លួន និងដល់កិត្យានុភាព នៃអង្គការអយ្យការឡើយ។

ព្រះរាជអាជ្ញា ដែលកំពុងបំពេញមុខងារនៅតាមអយ្យការអមសាលាជម្រះក្តី គ្រប់ជាន់ថ្នាក់ត្រូវសុំការអនុញ្ញាតជាមុនពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មុននឹងផ្សាយ ឬ សុំឱ្យផ្សាយតាមគ្រប់មធ្យោបាយទាំងអស់នូវអត្ថបទ ឬការសរសេរសំណៅព្រមទាំងមតិផ្សេងៗ ដែលអាចធ្វើឱ្យប៉ះពាល់ដល់កិត្យានុភាពនៃស្ថាប័នអយ្យការ ឬស្ថាប័ន

[49] មាត្រា២៩ នៃច្បាប់ស្តីពី "ការរៀបចំអង្គការតុលាការ" ឆ្នាំ២០១៤ ទំព័រ១១

តុលាការ។ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះការធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់ព្រះរាជអាជ្ញា ដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ។

ក្នុងវិស័យនយោបាយ ព្រះរាជអាជ្ញា ត្រូវប្រកាន់ជាដាច់ខាតនូវឥរិយាបថអព្យាក្រឹត។

ការរំលោភលើបញ្ញត្តិនៃកថាខណ្ឌទី២ និងទី៣ នៃមាត្រានេះ ត្រូវទទួលទោសវិន័យដោយមិនគិតដល់ការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌទេ ប្រសិនបើមាន[50]។

ព្រះរាជអាជ្ញាទាំងអស់មិនត្រូវបោះបង់ការងាររបស់ខ្លួន ឬ អវត្តមានដោយគ្មានការអនុញ្ញាតពីថ្នាក់លើផ្ទាល់របស់ខ្លួនជាមុនឡើយ។ សំណើរសុំអនុញ្ញាតអវត្តមានរបស់ព្រះរាជអាជ្ញាអមសាលាដំបូង អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌[51]។

ការបោះបង់ការងារ ឬអវត្តមានឥតច្បាប់ ដោយពុំមានមូលហេតុចាប់ពី១៥ថ្ងៃឡើងទៅ ត្រូវទទួលវិន័យផ្អាកមិនឱ្យបើកប្រាក់បៀវត្ស ឬ ដាក់ឱ្យទំនេរគ្មានបៀវត្ស ដោយពុំមានមូលហេតុលើសពី៣០ថ្ងៃ ហើយព្រះរាជអាជ្ញានោះ នៅតែមិនត្រឡប់មកបំពេញការងារវិញ ក្រោយការដាក់កំហិតចំនួនពីរដងនោះត្រូវលុបឈ្មោះពីក្របខណ្ឌ[52]។

## ផ្នែកទី៣៖ ចំណាត់ការលើសំណុំរឿងរបស់អយ្យការ

### កថាខណ្ឌទី១៖ បណ្តឹងព្រហ្មទណ្ឌ និងបញ្ជីឈ្មោះសៀវភៅនៃសំណុំរឿងព្រហ្មទណ្ឌ

បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណីជាបណ្តឹងពីរផ្សេងគ្នា។ បណ្តឹងអាជ្ញាមានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឱ្យឃើញពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជនដែលប្រព្រឹត្តនោះតាមច្បាប់កំណត់។ រីឯបណ្តឹងរដ្ឋប្បវេណីវិញ មានគោលបំណងតែធ្វើឱ្យមានការជួសជុលការខូចខាត និង ជម្ងឺចិត្ត ដែលបណ្តាលមកពីបទល្មើសដល់ជនរងគ្រោះតែប៉ុណ្ណោះ[53]។ បណ្តឹងទាំងពីរនេះត្រូវផ្តើមឡើងដោយបុគ្គលពីរផ្សេងគ្នា គឺនៅពេលមានបទល្មើសកើតឡើង តំណាងអយ្យការមានភារកិច្ចចម្បងធ្វើបណ្តឹងអាជ្ញា។ រីឯជនរងគ្រោះ ឬ សិទ្ធិវន្តរបស់គេ ឬ បុគ្គលផ្សេងទៀតដែលច្បាប់ទទួលស្គាល់មានសិទ្ធិតាមច្បាប់ធ្វើបណ្តឹងរដ្ឋប្បវេណី។ ក៏ប៉ុន្តែជនរងគ្រោះ ឬ មេធាវីរបស់ខ្លួនក៏អាចធ្វើឱ្យបណ្តឹងព្រហ្មទណ្ឌមានចលនាតាមរយៈការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានដែរ[54]។

---

[50] មាត្រា៩៦ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤ ទំព័រ៣០

[51] មាត្រា៩៧ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤ ទំព័រ៣០

[52] មាត្រា៩៨ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤ ទំព័រ៣១

[53] មាត្រា ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ១

[54] មាត្រា ១៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ៤៨

ព្រះរាជអាជ្ញាដែលតំណាងឱ្យស្ថាប័នអយ្យការទាំងមូល ដែលក្នុងនាមផលប្រយោជន៍ទូទៅនៅពេលបានដឹងអំពីបទល្មើស ឬ បានទទួលសំណុំរឿងនីតិវិធីដែលបញ្ជូនមកពីមន្ត្រីនគរបាល ឬ ដោយមធ្យោបាយផ្សេងទៀតមានភារកិច្ចតាំងខ្លួនជាភាគីនៃបណ្តឹង។ ហើយថ្លឹងថ្លែងអំពីចំណាត់ការរបស់ខ្លួនក្នុងការធ្វើបណ្តឹងអាជ្ញា ឬ ធ្វើការតម្កល់រឿងទុកឥតចាត់ការ។ ក្នុងករណីតំណាងអយ្យការយល់ថាអំពើនោះជាបទល្មើសព្រហ្មទណ្ឌ តំណាងអយ្យការមានជម្រើសជាច្រើនដើម្បីធ្វើបណ្តឹងអាជ្ញា។ ការជ្រើសរើសជម្រើសណាមួយអាស្រ័យទៅលើស្ថានភាពនៃសំណុំរឿង និងនីតិវិធីដែលច្បាប់តម្រូវឱ្យធ្វើ។ តំណាងអយ្យការត្រូវតែប្តឹងសុំទៅយុត្តាធិការស៊ើបសួរ ឱ្យបើកការស៊ើបសួរចំពោះបទល្មើសឧក្រិដ្ឋ ឬ បទមជ្ឈិមដែលស្មុគស្មាញ ឬ អាចប្តឹងសុំឱ្យធ្វើការជំនុំជម្រះតែម្តងចំពោះបទលហុ ឬ បទមជ្ឈិមតូចតាចមួយចំនួន ដែលបានបំពេញលក្ខខ័ណ្ឌដែលកំណត់ដោយច្បាប់ ឬ ធ្វើការជំនុំជម្រះចំពោះបទមជ្ឈិមតូចតាច។

### ១.១. នីតិវិធីទទួលបណ្តឹងព្រហ្មទណ្ឌ

ព្រះរាជអាជ្ញា មានតួនាទីរក្សាសណ្តាប់ធ្នាប់សាធារណៈមានភារកិច្ចឃ្លាំមើលការអនុវត្តច្បាប់ និងបណ្តឹងចោទប្រកាន់គ្រប់បុគ្គលដែលបង្កឱ្យមានអសន្តិសុខសង្គមទៅសាលាជម្រះក្តី។ តំណាងអយ្យការត្រូវបានមាត្រា ១៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាផ្តល់អំណាចឱ្យធ្វើជាម្ចាស់បណ្តឹងអាជ្ញាអាចធ្វើបណ្តឹងចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌ នៅពេលដែលខ្លួនបានដឹងអំពីការកើតឡើងនៃបទល្មើស។ តំណាងអយ្យការអាចទទួលដំណឹងអំពីបទល្មើសតាមមធ្យោបាយផ្សេងៗ ហើយថ្លឹងថ្លែងអំពីអត្ថិភាពនៃបទល្មើសចំពោះរឿងហេតុដែលខ្លួនបានដឹង នៅមុនពេលចាប់ផ្តើមធ្វើបណ្តឹងចោទប្រកាន់ចំពោះអំពើល្មើសទាំងនោះទៅយុត្តាធិការស៊ើបសួរ ឬ ទៅយុត្តាធិការជំនុំជម្រះក្នុងគោលបំណងដើម្បីស្វែងរកការពិត ហើយផ្តន្ទាទោសជនដែលខ្លួនបានសង្ស័យថាបានប្រព្រឹត្តបទល្មើសតាមច្បាប់។

តើតំណាងអយ្យការអាចតាំងខ្លួនជាម្ចាស់បណ្តឹងព្រហ្មទណ្ឌតាមមធ្យោបាយណាខ្លះ?

#### ១.១.១. ពាក្យបណ្តឹងទាមទារ និងពាក្យបណ្តឹងបរិហារដែលមន្ត្រីនគរបាលយុត្តធម៌បញ្ជូនមក

**ក. ពាក្យបណ្តឹងទាមទារ**

ជនរងគ្រោះ ឬ សិទ្ធិវន្តនៃជនរងគ្រោះ ឬ អង្គការសមាគមន៍ដែលច្បាប់ទទួលស្គាល់ហើយបានប្រកាសដោយត្រឹមត្រូវយ៉ាងតិចបំផុត ០៣ឆ្នាំ នៅមុនកាលបរិច្ឆេទនៃការកើតបទល្មើសអាចដាក់ពាក្យបណ្តឹងទាមទារក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ចូលមកមន្ត្រីនគរបានយុត្តិធម៌ដែលមានសមត្ថកិច្ចត្រួតពិនិត្យអត្ថិភាពនៃបទល្មើស។ ពាក្យបណ្តឹងទាមទារ ត្រូវមានបញ្ជាក់អំពីអង្គហេតុ និង កម្មវត្ថុនៃការទាមទារឱ្យបានច្បាស់លាស់។

បណ្តឹងទាមទារដែលធ្វើឡើងដោយបុគ្គលជាដើមបណ្តឹងរដ្ឋប្បវេណីនេះ គឺជាបណ្តឹងសាមញ្ញប៉ុណ្ណោះ គ្មានអានុភាពនាំឱ្យមានការចោទប្រកាន់ខាងបទល្មើសព្រហ្មទណ្ឌឡើយ[55]។ មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបានពាក្យបណ្តឹងទាមទារ ត្រូវតែធ្វើកំណត់ហេតុស្តីពីការដាក់ពាក្យបណ្តឹងនេះ។ បន្ទាប់ពីធ្វើកំណត់ហេតុបណ្តឹង មន្ត្រីនគរបាលយុត្តិធម៌ ចាប់ផ្តើមធ្វើការស៊ើបអង្កេតបឋមដោយឯកឯង ឬ សុំការអនុញ្ញាតពីព្រះរាជអាជ្ញាដើម្បីបើកការស៊ើបអង្កេតបឋម។ ក្នុងករណីខ្លះ មន្ត្រីនគរបាលយុត្តិធម៌មិនបើកការស៊ើបអង្កេតដោយខ្លួនឯងទេ។

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវតែបញ្ជូនកំណត់ហេតុស្តីពីការដាក់ពាក្យបណ្តឹងនោះ ទៅឱ្យព្រះរាជអាជ្ញាដើម្បីចាត់ការបន្ត។ ក្នុងករណីមន្ត្រីនគរបាលយុត្តិធម៌ ដែលទទួលបន្ទុកចាត់ការពាក្យបណ្តឹងបានពិនិត្យឃើញថា អង្គហេតុដែលគេប្តឹងនោះ ជាបទល្មើសព្រហ្មទណ្ឌ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែកសាងសំណុំរឿងហើយបញ្ជូនមកអយ្យការអមសាលាដំបូង នាទីកន្លែងដែលមន្ត្រីនគរបាលយុត្តិធម៌នោះស្ថិតនៅ មន្ត្រីនគរបាលយុត្តិធម៌មិនអាចតម្កល់រឿងព្រហ្មទណ្ឌទុកឥតចាត់ការបានទេ ទោះបីជាមានការសម្របសម្រួលគ្នារវាងជនល្មើស និងជនរងគ្រោះក្តី[56]។

**ខ. ពាក្យបណ្តឹងបរិហារ**

ដើម្បីចូលរួមបង្ក្រាបបទល្មើស ដែលតែងតែបង្កឱ្យមានអសន្តិសុខដល់សណ្តាប់ធ្នាប់សាធារណៈ សាធារណៈជន ឬ អាជ្ញាធរសាធារណៈ ឬ មន្ត្រីរាជការគ្រប់រូបនៅពេលបានដឹងអំពីបទល្មើសឧក្រិដ្ឋ ឬ បទមជ្ឈិមត្រូវតែជូនដំណឹងទៅឱ្យអាជ្ញាធរមានសមត្ថកិច្ច(មន្ត្រីនគរបាលយុត្តិធម៌)បានដឹងអំពីរឿងហេតុដែលជាបទល្មើសនោះ។ ការជូនដំណឹងអំពីបទល្មើសឧក្រិដ្ឋ ឬ បទមជ្ឈិមនេះត្រូវបានច្បាប់ឱ្យឈ្មោះថាជា ពាក្យបរិហារ។ មាត្រា ៤២ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិ ថាជាកាតព្វកិច្ចអាជ្ញាធរសាធារណៈ ឬ មន្ត្រីរាជការគ្រប់រូបត្រូវតែជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា ឬ មន្ត្រីនគរបាលយុត្តិធម៌។ អ្នកប្តឹងត្រូវផ្តល់ព័ត៌មានអំពីរឿងហេតុដែលខ្លួនដឹង ឬ ត្រូវនាំយកមកជាមួយនូវសម្ភារៈដែលជនល្មើសប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើស ឬ ឯកសារដែលពាក់ព័ន្ធផ្សេងៗទៀតដែលមានទាក់ទងទៅនឹងការប្រព្រឹត្តបទល្មើសដល់មន្ត្រីនគរបាលយុត្តិធម៌។

មន្ត្រីនគរបាលយុត្តិធម៌ ដែលទទួលដំណឹងអំពីប្តឹងបរិហារ ត្រូវធ្វើកំណត់ហេតុបណ្តឹងហើយត្រូវបើកការស៊ើបអង្កេតបឋមដើម្បីកំណត់អំពីអត្តសញ្ញាណជនល្មើស ឬ ធ្វើការផ្ទៀងផ្ទាត់សេចក្តីរាយការណ៍ដែលធ្វើឡើងជាបណ្តឹងបរិហារនោះ ការបើកការស៊ើបអង្កេតនេះ គឺជាការផ្ទៀងផ្ទាត់ជំហានដំបូងទៅលើករណីនៃការរាយការណ៍នេះ។ ប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌បានពិនិត្យឃើញថាពិតជាមានអត្ថិភាពនៃបទល្មើសដូចការរាយការណ៍ពិតប្រាកដមែន មន្ត្រីនគរបាលយុត្តិធម៌បើកការស៊ើបអង្កេត និងប្រមូលភស្តុតាងហើយរៀបចំជាសំណុំរឿងបញ្ជូនមកព្រះរាជអាជ្ញាដើម្បីចាត់ការបន្ត។

---

[55] មាត្រា៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ២

[56] មាត្រា៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ ២៥

### ១.១.២. ពាក្យបណ្តឹងទាមទារ និងពាក្យបណ្តឹងបរិហារដែលព្រះរាជអាជ្ញាទទួលដោយផ្ទាល់

#### ក. ពាក្យបណ្តឹងទាមទារ

បុគ្គលគ្រប់រូបដែលប្រកាសថាខ្លួនជាអ្នករងគ្រោះនៃបទល្មើស ឬ សិទ្ធិវន្តនៃជនរងគ្រោះ ឬ អង្គការសមាគមន៍ ដែលច្បាប់ទទួលស្គាល់ហើយបានប្រកាសដោយត្រឹមត្រូវ យ៉ាងតិចបំផុត០៣ឆ្នាំ នៅមុនពេលកើតបទល្មើស អាចដាក់ពាក្យបណ្តឹងទាមទារក្នុងឋានៈជាភាគីដើមបណ្តឹងរដ្ឋប្បវេណីចូលមកព្រះរាជអាជ្ញាដោយផ្ទាល់បាន។ ពាក្យបណ្តឹងទាមទារដែលព្រះរាជអាជ្ញាទទួលបានពីបុគ្គលខាងលើនោះគ្រាន់តែ ជាបណ្តឹងទាមទារឱ្យសងការខូចខាតផ្នែករដ្ឋប្បវេណីដែលកើតចេញពីព្យសនកម្មនៃបទល្មើសព្រហ្មទណ្ឌតែប៉ុណ្ណោះ។ ពាក្យបណ្តឹងទាមទារ គឺជាពាក្យបណ្តឹងសាមញ្ញគ្មានអានុភាព នាំឱ្យធ្វើការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌបានឡើយ[57]។

បន្ទាប់ពីទទួលបានពាក្យបណ្តឹងទាមទារ ព្រះរាជអាជ្ញាអាចធ្វើការស៊ើបអង្កេតបឋម ឬ បង្គាប់ឱ្យធ្វើការស្រាវជ្រាវបន្ថែម។ បន្ទាប់ពីកិច្ចស៊ើបអង្កេត ឬ ការស្រាវជ្រាវបានបញ្ចប់ចប់សព្វគ្រប់ព្រះរាជអាជ្ញាថ្លឹងថ្លែងអំពីចំណាត់ការរបស់ខ្លួនចំពោះការប្តឹងទាមទារនោះ។ ក្នុងករណីព្រះរាជអាជ្ញាយល់ឃើញថាបណ្តឹងទាមទារមានមូលហេតុត្រឹមត្រូវ ហើយមានតម្រុយដែលបង្ហាញឱ្យឃើញថាអំពើនោះជាបទល្មើសព្រហ្មទណ្ឌ នោះព្រះរាជអាជ្ញាត្រូវធ្វើការចោទប្រកាន់ ហើយបញ្ជូនសំណុំរឿងទៅឱ្យយុត្តាធិការស៊ើបសួរ ឬ ទៅឱ្យយុត្តាធិការជំនុំជម្រះ ដើម្បីស្វែងរកការពិត និងផ្តន្ទាទោសជនល្មើសតាមច្បាប់។

ផ្ទុយទៅវិញនៅក្នុងករណីដែលពាក្យបណ្តឹងទាមទារស្ថិតនៅដោយគ្មានចម្លើយ ឬ ពាក្យបណ្តឹងដែលទទួលបាននោះត្រូវបានតម្កល់ទុកឥតចាត់ការដោយព្រះរាជអាជ្ញា នោះជនរងគ្រោះនៃបទល្មើស ឬ សិទ្ធិវន្តនៃជនរងគ្រោះ ឬ បុគ្គលពាក់ព័ន្ធដទៃទៀតអាចប្តឹងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ឱ្យចេញអធិបញ្ជាដល់ព្រះរាជអាជ្ញាអមសាលាដំបូងឱ្យធ្វើការចោទប្រកាន់បាន[58]។

#### ខ. ពាក្យបណ្តឹងបរិហារ

ព្រះរាជអាជ្ញា អាចតាំងខ្លួនជាម្ចាស់បណ្តឹងព្រហ្មទណ្ឌ នៅពេលទទួលបានពាក្យបរិហារពីសាធារណៈជនពីអាជ្ញាធរសាធារណៈ ឬ មន្ត្រីគ្រប់រូបដែលបានដឹងអំពីការកើតឡើងនូវបទល្មើសឧក្រិដ្ឋ ឬ បទមជ្ឈិមបន្ទាប់ពីបើកការស៊ើបអង្កេតបឋមរួចរាល់ហើយ។

---

[57] មាត្រា៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ២

[58] មាត្រា ៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ២

យោងតាមមាត្រា ៤២ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិជាកាតព្វកិច្ចថា អាជ្ញាធរដែលខ្លួនកំពុងបំពេញមុខងារបានដឹងអំពីការកើតឡើងបទឧក្រិដ្ឋ ឬ បទមជ្ឈិម។ ពាក្យប្តឹងបរិហារនេះគ្រាន់តែជាពាក្យប្តឹងសាមញ្ញប៉ុណ្ណោះមិនមានអានុភាពបង្ខំឱ្យព្រះរាជអាជ្ញាត្រូវតែធ្វើការចោទប្រកាន់ជាបទព្រហ្មទណ្ឌឡើយ។

### ១.១.៣. ការបញ្ជូនពាក្យបណ្តឹងដោយចៅក្រមស៊ើបសួរ

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៧ កំណត់យ៉ាងជាក់លាក់ថានៅក្នុងករណីមានបណ្តឹងសាមញ្ញចៅក្រមស៊ើបសួរត្រូវតែបញ្ជូនបណ្តឹងនោះទៅព្រះរាជអាជ្ញា[59]។

ក្នុងស្ថានភាពបែបនេះ គឺក្រមនីតិវិធីព្រហ្មទណ្ឌកំពុងតែគោរពតាមរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ ដែលបានកំណត់ថាមានតែអង្គការអយ្យការប៉ុណ្ណោះ គឺជាម្ចាស់បណ្តឹងអាជ្ញា[60]។

### ១.១.៤. ការបញ្ជូនពាក្យបណ្តឹងដោយចៅក្រមជំនុំជម្រះ

ចំពោះវិធីមួយទៀតដែលបើកសិទ្ធិឱ្យមានការបញ្ជូនពាក្យបណ្តឹងទៅព្រះរាជអាជ្ញា គឺក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា ៣៤៨ បានកំណត់ថាតុលាការអាចធ្វើការសម្រេចសេចក្តីបានតែទៅលើអំពើទាំងឡាយណា ដែលមានបង្ហាញនៅក្នុងសាលដីកាបញ្ជូន ដីកាបញ្ជូន ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬកំណត់ហេតុនៃការបង្ហាញខ្លួនភ្លាម។

ក្នុងករណីដែលតុលាការសម្រេចរួមជាក្រុមហើយយល់ឃើញថា អង្គហេតុដែលត្រូវបានប្តឹងនោះបង្កើតជាបទមជ្ឈិម ឬ បទលហុ តុលាការនោះនៅតែមានសមត្ថកិច្ចដើម្បីជម្រះសេចក្តីដដែល។

ប៉ុន្តែនៅក្នុងកថាខណ្ឌទី៣ មាត្រាដដែលបានកំណត់ថាក្នុងករណីដែលតុលាការសម្រេចដោយចៅក្រមតែម្នាក់គត់ហើយយល់ឃើញថាអង្គហេតុដែលត្រូវបានប្តឹងនោះ បង្កើតជាបទឧក្រិដ្ឋតុលាការនោះបង្វិលសំណុំរឿងជូនព្រះរាជអាជ្ញាវិញដើម្បីបើកការស៊ើបសួរ[61]។

### ១.១.៥. ពាក្យបណ្តឹងដែលមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

នីតិវិធីនៃការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរនេះ គឺជានីតិវិធីថ្មីដែលបង្កើតឡើងតាមរយៈក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧។ នីតិវិធីនេះ បើកសិទ្ធិឱ្យតែជនរងគ្រោះ ឬ មេធាវីតំណាងឱ្យជនរងគ្រោះនៃបទល្មើសឧក្រិដ្ឋ ឬ បទមជ្ឈិមតែប៉ុណ្ណោះ ទើបអាចដាក់ពាក្យបណ្តឹងតាមរយៈការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះយុត្តាធិការស៊ើបសួរបាន[62]។

---

[59] មាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ៤៤

[60] មាត្រា ១៣១(ថ្មី) នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ទំព័រ៤៦

[61] មាត្រា ៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ១១២

[62] មាត្រា ១៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ៤៨

នៅពេលទទួលបានពាក្យបណ្តឹង តាមរយៈការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះចៅក្រមស៊ើបសួរធ្វើការកត់សម្គាល់នូវការដាក់ពាក្យបណ្តឹងនេះដោយដីកាហើយជូនដំណឹងទៅព្រះរាជអាជ្ញាដើម្បីឱ្យបើកការចោទប្រកាន់ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ បន្ទាប់ពីពិនិត្យពាក្យបណ្តឹងដែលបញ្ជូនមកឱ្យខ្លួនហើយ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថា អំពើនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌទេ ឬ ប្រសិនបើបណ្តឹងអាជ្ញាត្រូវបានផុតរលត់ដោយយោងតាមមាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ព្រះរាជអាជ្ញាអាចសុំដល់ចៅក្រមស៊ើបសួរកុំឱ្យបើកការស៊ើបសួរបាន។ កិច្ចស្នើសុំកុំឱ្យបើកការស៊ើបសួររបស់ព្រះរាជអាជ្ញានេះ មិនមែនជាកាតព្វកិច្ចដែលចៅក្រមស៊ើបសួរត្រូវតែគោរពតាមនោះទេ។ ក្នុងករណីដែលចៅក្រមស៊ើបសួរ នៅតែសម្រេចបើកការស៊ើបសួរ ចៅក្រមស៊ើបសួររូបនោះ ត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ហើយជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា អំពីកិច្ចនៃការចាប់ផ្តើមបើកការស៊ើបសួររបស់ខ្លួន[63]។ បទបញ្ញត្តិនៃមាត្រា១៣៨ និងមាត្រា១៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មិនបញ្ញត្តិឱ្យច្បាស់ថាតើកិច្ចស៊ើបសួរចំពោះករណីការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចាំបាច់ត្រូវតែមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពីព្រះរាជអាជ្ញានោះទេ។ ហេតុដូចនេះហើយទើបមានការបកស្រាយឡើងថា ទោះបីជាព្រះរាជអាជ្ញាមិនយល់ព្រមធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក៏ដោយ ក៏ចៅក្រមស៊ើបសួរនៅតែមានអំណាចបើកការស៊ើបសួរដោយឯកឯងបានដែរ។ ព្រោះចៅក្រមស៊ើបសួរអាចសំអាងលើកថាខណ្ឌទី៥ នៃមាត្រា ១៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលបញ្ញត្តិថាចៅក្រមស៊ើបសួរគ្រាន់តែចេញដីកាសម្រេចស៊ើបសួរហើយជូនដំណឹងអំពីដីការសម្រេចនេះទៅឱ្យព្រះរាជអាជ្ញាតែប៉ុណ្ណោះ។

នីតិវិធីនៃការបើកការស៊ើបសួរតាមរយៈការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរនេះត្រូវបានមតិមួយចំនួនលើកឡើងថា បានចែងផ្ទុយទៅនឹងគោលបំណងនៃមាត្រា ១៣១(ថ្មី) នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលចែងថា "**មានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា**" ដូចនេះមានន័យថា ខ្លឹមសារកថាខណ្ឌទី៥ នៃមាត្រា ១៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌនោះ អធម្មនុញ្ញភាព។ ជាអាទិ៍យើងឃើញថា សូម្បីតែមាត្រាមួយចំនួននៃក្រមនីតិវិធីព្រហ្មទណ្ឌខ្លួនឯង ក៏បានចែងបដិបញ្ញត្តិនៃមាត្រា ១៣៨ និងមាត្រា ១៣៩ ស្តីពីការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះផងដែរ។ ដូចជានៅក្នុងកថាខណ្ឌទី១ នៃមាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិថា "ការស៊ើបសួរត្រូវបានបើកដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា" ហើយបញ្ញត្តិនៃកថាខណ្ឌទី៣នៃមាត្រាដដែលនោះ បានបំពេញបន្ថែមថា "ចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរណាមួយបាន ដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាទេនោះ"។

[63] មាត្រា ១៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ៤៨

### ១.២. បញ្ជីរាយឈ្មោះសៀវភៅនៃសំណុំរឿងព្រហ្មទណ្ឌ

នៅក្នុងចំណាត់ការលើរឿងក្តីព្រហ្មទណ្ឌ នៅអយ្យការអមសាលាដំបូងរាជធានី-ខេត្តមានដាក់ឱ្យដំណើរការសៀវភៅមួយចំនួន ដូចមានរាយឈ្មោះខាងក្រោមៈ

- សៀវភៅចុះបណ្តឹងសំណុំរឿងព្រហ្មទណ្ឌ
- សៀវភៅចុះបណ្តឹងអនុវត្ត
- សៀវភៅពិសេស
- សៀវភៅពិសេសកិច្ចការអនុវត្ត
- សៀវភៅចុះលេខលិខិត ចេញ ចូល
- សៀវភៅតាមដានការអនុវត្តទោសរបស់ទណ្ឌិត
- សៀវភៅទទួលយកភស្តុតាង និង ការបញ្ជាឱ្យចូលខ្លួន
- សៀវភៅចុះលេខដីកាកោះសវនាការ
- សៀវភៅតាមដានការឃាត់ខ្លួន
- សៀវភៅចាត់តាំងតំណាងអយ្យការ
- សៀវភៅដោះលែងទណ្ឌិត
- សៀវភៅចុះលេខឃុំខ្លួន មិនឃុំខ្លួន អនុញ្ញាតឱ្យនៅក្រៅឃុំ មិននៅក្រៅឃុំ លើកលែងចោទប្រកាន់
- សៀវភៅបញ្ជូនឯកសារ
- សៀវភៅសុំប្តឹងតវ៉ា
- សៀវភៅបញ្ជូនសំណុំរឿង
- សៀវភៅដាក់គុកបង្ខំរូបរាងកាយ។

### កថាខណ្ឌទី២៖ ជម្រើសនៃការចោទប្រកាន់

ព្រះរាជអាជ្ញាមានសិទ្ធិជាគោលការណ៍ក្នុងការផ្តើមធ្វើបណ្តឹងអាជ្ញា ចាប់តាំងពីពេលដែលខ្លួនបានដឹងអំពីបទល្មើស។ ជាអាទិ៍ព្រះរាជអាជ្ញាប្រើប្រាស់គោលការណ៍កាលានុវត្តភាពនៅក្នុងជម្រើសនៃការចោទប្រកាន់របស់ខ្លួន។ គោលការណ៍កាលានុវត្តភាពនេះផ្តល់ឱ្យព្រះរាជអាជ្ញានូវសេរីក្នុងការវាយតម្លៃថាគួរតែធ្វើបណ្តឹងអាជ្ញា ឬតម្កល់រឿងទុកឥតចាត់ការ ដោយផ្អែកទៅលើស្ថានទម្ងន់ទោសនៃបទល្មើស កាលៈទេសៈនៃការប្រព្រឹត្តបទល្មើស ភាពរឹករវដល់សណ្តាប់ធ្នាប់សាធារណៈ និង ភស្តុតាងផ្សេងៗទៀតដែលប្រមូលបានក្នុងពេលស៊ើបអង្កេត។

គោលការណ៍នេះអនុញ្ញាតឱ្យព្រះរាជអាជ្ញាតម្កល់រឿងទុកឥតចាត់ការ ហើយទោះបីជាច្បាប់បានចែងទុកថាអំពើនោះ គឺជាបទល្មើសដែលត្រូវតែផ្តន្ទាទោសក៏ដោយ។ អាចនិយាយបានម្យ៉ាងទៀតថាគោលការណ៍កាលានុវត្តភាពរបស់ព្រះរាជអាជ្ញា បានបំពានទៅលើបទបញ្ញត្តិស្តីពីគោលការណ៍នីត្យានុកូលភាពនៃមាត្រា ៣ នៃក្រមព្រហ្មទណ្ឌ ដែលចែងឱ្យប្រកាសអំពីទោសចំពោះអំពើដែលច្បាប់ចាត់ទុកថាជាបទល្មើស។

## ២.១. ការតម្កល់រឿងទុកឥតចាត់ការ

### ២.១.១. សញ្ញាណទូទៅនៃការតម្កល់រឿងទុកឥតចាត់ការ

អង្គការអយ្យការ ជាអ្នកដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។ មានន័យថា អង្គការអយ្យការជាម្ចាស់នៃបណ្តឹងដើម្បីធ្វើការចោទប្រកាន់ពីបទល្មើសណាមួយដែលកើតមានឡើងក្រោយពីពេលដែលខ្លួនបានទទួលពាក្យប្តឹង ឬពាក្យបរិហារដោយផ្ទាល់ ឬ ដោយមន្ត្រីនគរបាលយុត្តិធម៌។ តាមរយៈបណ្តឹងដែលទទួលបាន ព្រះរាជអាជ្ញានឹងធ្វើការចោទប្រកាន់ទៅលើអំពើដែលបង្កឱ្យមានព្យសនកម្ម។

ប៉ុន្តែបើតម្រូវឱ្យព្រះរាជអាជ្ញាធ្វើការចោទប្រកាន់នូវរាល់បទល្មើស ដើម្បីយកជនល្មើសមកផ្តន្ទាទោសនោះប្រាកដណាស់នឹងកើតមាននូវចំណុចអវិជ្ជមានច្រើនជាងវិជ្ជមាន សម្រាប់ប្រទេសកម្ពុជាដែលជាប្រទេសកំពុងអភិវឌ្ឍន៍។ ដោយហេតុថារាល់ការចោទប្រកាន់ហើយមានការផ្តន្ទាទោសដាក់ពន្ធនាគារ នាំឱ្យមានតម្រូវការពន្ធនាគារច្រើនសម្រាប់ទទួលបន្ទុករបស់ទណ្ឌិត ជាកត្តាដែលនាំឱ្យធនធានជាច្រើនត្រូវបានខាតបង់ និងនាំប្រទេសទៅជួបនឹងហានិភ័យដែលមិនអាចរំពឹងទុក។

ដូចនេះការចោទប្រកាន់នឹងកើតមាននូវផលវិបាកពីរ គឺការរក្សាសណ្តាប់ធ្នាប់សាធារណៈឱ្យមានរបៀបរៀបរយល្អ និងការចំណាយធនធានដ៏ខ្ជះខ្ជាយ។ នេះជាហេតុដែលនាំឱ្យព្រះរាជអាជ្ញាមានអំណាចឆន្ទានុសិទ្ធិដោយមិនធ្វើការចោទប្រកាន់ តែតម្កល់រឿងទុកឥតចាត់ការ។ តើអ្វីទៅជាការតម្កល់រឿងទុកឥតចាត់ការ ហើយមូលហេតុយ៉ាងណាទើបនាំឱ្យមានការតម្កល់រឿងទុកឥតចាត់ការ?

#### ក. អត្ថន័យនៃការតម្កល់រឿងទុកឥតចាត់ការ

នៅក្នុងរឿងក្តីព្រហ្មទណ្ឌដែលស្ថិតក្នុងចំណាត់ការរបស់អង្គការអយ្យការ គឺជាដំណាក់កាលមួយក្នុងការចោទប្រកាន់ ព្រោះថាមានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។ ប៉ុន្តែដោយក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់សេរីភាពដល់ព្រះរាជអាជ្ញាដោយសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬ ធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ[64]។ ដូចនេះនាំឱ្យមានការបកស្រាយថាក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាន់យកនូវគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ មានន័យថាទោះបីជាអំពើមួយជាបទល្មើសក៏ដោយ បើពុំមានផលប្រយោជន៍ក្នុងការ

[64] មាត្រា៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ១១

ចោទប្រកាន់នោះទេអាចនាំឱ្យព្រះរាជអាជ្ញាធ្វើការតម្កល់រឿងទុកឥតចាត់ការ ដែលនេះខុសពីគោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ដែលព្រះរាជអាជ្ញាពុំអាចធ្វើការតម្កល់រឿងទុកឥតចាត់ការបានឡើយ គឺឱ្យតែមានបទល្មើសព្រហ្មទណ្ឌណាមួយកើតឡើង នោះព្រះរាជអាជ្ញាត្រូវធ្វើការចោទប្រកាន់ជាដាច់ខាត។

**ខ. អាជ្ញាធរទទួលបន្ទុកក្នុងការតម្កល់រឿងទុកឥតចាត់ការ**

ដូចដែលបានធ្វើការបកស្រាយពីខាងលើ សមាសភាពរបស់ចៅក្រមក្នុងអង្គការអយ្យការអមសាលាដំបូងមានព្រះរាជអាជ្ញា ព្រមទាំងព្រះរាជអាជ្ញារង ដូចនេះអាជ្ញាធរដែលទទួលបន្ទុកក្នុងការតម្កល់រឿងទុកឥតចាត់ការមានព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង (គោលការណ៍អវិភាគ)។

## ២.១.២. លក្ខខណ្ឌតម្កល់រឿងទុកឥតចាត់ការ

តំណាងអយ្យការគ្មានអំណាចធ្វើការតម្កល់រឿងទុកឥតចាត់ការ ចំពោះសំណុំរឿងក្តីព្រហ្មទណ្ឌដែលខ្លួនមិនទាន់បានបើកការស៊ើបអង្កេតបឋម ឬ បានធ្វើការស្រាវជ្រាវបន្ថែមឡើយ[65]។

សេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់តំណាងអយ្យការ ត្រូវតែផ្អែកលើសំអាងហេតុយ៉ាងច្បាស់លាស់ និងមានចង្អុលអំពីបទបញ្ញត្តិច្បាប់ដែលអនុញ្ញាតឱ្យតំណាងអយ្យការអាចតម្កល់រឿងទុកឥតចាត់ការផងដែរ។ សេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ ត្រូវធ្វើឡើងដោយដីកាសម្រេចដែលមានទម្រង់ជាលាយលក្ខណ៍អក្សរ។ ព្រោះដីកាសម្រេចនេះត្រូវធ្វើការជូនដំណឹងទៅឱ្យអ្នកប្តឹង។ ការជូនដំណឹងអំពីដីកាសម្រេចត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងខ្លីបំផុត និងយ៉ាងយូរបំផុតត្រឹមរយៈពេល ០២ ខែ គិតចាប់ពីថ្ងៃចុះពាក្យប្តឹងក្នុងបញ្ជីពាក្យបណ្តឹងរបស់អយ្យការ[66]។

## ២.១.៣. មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ

ជាគោលការណ៍ មុនពេលធ្វើសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬ ធ្វើការចោទប្រកាន់តំណាងអយ្យការត្រូវបើកការស៊ើបអង្កេតបឋម ឬ ធ្វើការបង្គាប់ឱ្យមន្ត្រីនគរបាលយុត្តិធម៌ស្រាវជ្រាវបន្ថែម។ ក្នុងករណីដែលសម្រេចតម្កល់រឿងទុកឥតចាត់ការតំណាងអយ្យការត្រូវថ្លឹងថ្លែងទៅលើស្ថានភាព និងកាលៈទេសៈទាំងឡាយនៃការប្រព្រឹត្តបទល្មើសរបស់ជនល្មើស។

ក្នុងនាមជាអ្នកការពារផលប្រយោជន៍ទូទៅ និងជាអ្នកសម្របសម្រួលក្នុងសង្គម តំណាងអយ្យការត្រូវបានប្រគល់នូវអំណាចអាចសម្រេចមិនចោទប្រកាន់ ចំពោះបទល្មើសព្រហ្មទណ្ឌដែលខ្លួនបានទទួល ឬ បានដឹងវាគឺជាសិទ្ធិអំណាចដែលអាចប្រើនូវគោលការណ៍កាលានុវត្តភាពមិនចោទប្រកាន់ចំពោះបទល្មើស មានន័យ

[65] មាត្រា៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ១១

[66] មាត្រា៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ១១

ថាបើបទល្មើសជាបទល្មើសមជ្ឈិមតូចតាចហើយគ្មានព្យសនកម្ម ឬ មានព្យសនកម្មតិចតួចពេកនោះតំណាងអយ្យការអាចតម្កល់រឿងទុកឥតចាត់ការបាន។

ជាទូទៅការតម្កល់រឿងទុកឥតចាត់ការ ត្រូវផ្អែកលើមូលហេតុដែលមានបញ្ញត្តិនៅក្នុងច្បាប់ជាធរមាន។ ក្នុងករណីនេះ ប្រសិនបើជនរងគ្រោះដាក់ពាក្យបណ្តឹងយឺតយ៉ាវដែលធ្វើឱ្យផុតរយៈពេលនៃអាជ្ញាយុកាលនោះតំណាងអយ្យការត្រូវតែសម្រេចតម្កល់រឿងទុកឥតចាត់ការ។

**ក. ខ្វះធាតុផ្សំបទល្មើស**

បន្ទាប់ពីទទួលបានពាក្យបណ្តឹងតវ៉ា ឬ ពាក្យបណ្តឹងបរិហារ តំណាងអយ្យការត្រូវតែបើកការស៊ើបអង្កេតបឋម ឬ ស៊ើបអង្កេតបន្ថែមដើម្បីស្រាវជ្រាវស្វែងរកធាតុផ្សំនៃបទល្មើស។ ធាតុផ្សំនៃបទល្មើសមានធាតុនីត្យានុកូល ធាតុសន្យានុម័ត និងធាតុអត្តនោម័ត។ ក្នុងករណីអវត្តមានធាតុផ្សំណាមួយតំណាងអយ្យការគ្មានអំណាចបើកការចោទប្រកាន់បានឡើយ តំណាងអយ្យការត្រូវតែសម្រេចតម្កល់រឿងទុកឥតចាត់ការ។

**ខ. សំណុំរឿងរដ្ឋប្បវេណី**

បណ្តឹងរដ្ឋប្បវេណី និង បណ្តឹងអាជ្ញាគឺជាបណ្តឹងពីរផ្សេងគ្នា។ បណ្តឹងអាជ្ញាដែលធ្វើឡើងដោយតំណាងអយ្យការមានគោលបំណងឱ្យពិនិត្យអំពីអត្ថិភាពនៃបទល្មើស បង្ហាញឱ្យឃើញអំពីពិរុទ្ធភាពរបស់ជនល្មើស និងផ្តន្ទាទោសជនដែលប្រព្រឹត្តល្មើសតាមច្បាប់។ ចំណែកឯបណ្តឹងរដ្ឋប្បវេណីវិញមានគោលបំណងឱ្យទទួលបានការជួសជុលការខូចខាតទទួលបានសំណងជម្ងឺចិត្ត។

ជនរងគ្រោះនៃអំពីល្មើស ក៏អាចធ្វើបណ្តឹងរដ្ឋប្បវេណីនៅក្នុងពេលជាមួយគ្នា និងបណ្តឹងអាជ្ញានៅចំពោះមុខសាលាជម្រះក្តីព្រហ្មទណ្ឌបានដែរ ក៏ប៉ុន្តែមានលក្ខខណ្ឌថាលុះត្រាតែសំណងរដ្ឋប្បវេណីនោះកើតចេញពីព្យសនកម្មនៃអំពើល្មើស។ តំណាងអយ្យការមិនចោទប្រកាន់ចំពោះអំពើណាដែលមិនមែនជាបទល្មើសព្រហ្មទណ្ឌឡើយ[67]។ តំណាងអយ្យការត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការចំពោះបណ្តឹងរដ្ឋប្បវេណី។

**គ. មូលហេតុមានចែងក្នុងច្បាប់**

ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ មិនបានបញ្ញត្តិអំពីមូលហេតុគតិយុត្តណាខ្លះ ដែលអនុញ្ញាតឱ្យតំណាងអយ្យការអាចតម្កល់រឿងទុកឥតចាត់ការឡើយ។ ក្រមនេះមានបញ្ញត្តិតែករណីនៃការរលត់បណ្តឹងអាជ្ញាប៉ុណ្ណោះ។ ជាភស្តុតាង យើងបានមើលឃើញនៅក្នុងមាត្រា៧ (ការរលត់នៃបណ្តឹងអាជ្ញា) និងមាត្រា៨ (មូលហេតុផ្សេងទៀតនៃការរលត់បណ្តឹងអាជ្ញា) ជាអាទិ៍។ បណ្តឹងអាជ្ញានឹងត្រូវរលត់ដោយមូលហេតុដូចខាងក្រោម៖

---

[67] មាត្រា ២២ និងមាត្រា ១៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ៤៨

១- ការដកពាក្យបណ្ដឹងៈ

នៅក្នុងចំណុចទី២ មាត្រា៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ បានបញ្ញត្តិថាបណ្ដឹងអាជ្ញាក៏អាចផុតរលត់ផងដែរដោយសារមូលហេតុនៃការដកពាក្យបណ្ដឹង នៅក្នុងករណីដែលពាក្យប្ដឹងនេះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទព្រហ្មទណ្ឌ។

រីឯមាត្រា៨ នៃច្បាប់ស្ដីពីឯកពន្ធភាពចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៦ បានបញ្ញត្តិថា ព្រះរាជអាជ្ញាអាចសម្រេចមិនធ្វើបណ្ដឹងអាជ្ញាបានប្រសិនបើមានបណ្ដឹងរបស់សហព័ទ្ធណាមួយ ស្នើសុំកុំឱ្យចោទប្រកាន់។

មាត្រាទាំងពីរនេះមានទំនាក់ទំនងគ្នា។ មាត្រា៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ បានបំពេញបន្ថែមទៅលើមាត្រា៨ នៃច្បាប់ស្ដីពីឯកពន្ធភាពថាតំណាងអយ្យការអាចមិនធ្វើបណ្ដឹងអាជ្ញា ប្រសិនបើសហព័ទ្ធណាមួយប្ដឹងសុំកុំឱ្យចោទប្រកាន់។ ហើយតំណាងអយ្យការត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការព្រោះមូលហេតុការរលត់បណ្ដឹងអាជ្ញា។

២- ការលើកលែងទោសជាទូទៅៈ

ចំណុចទី៣ នៃមាត្រា៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧បានបញ្ញត្តិថា ការលើកលែងទោសជាទូទៅក៏ជាមូលហេតុនៃការរលត់បណ្ដឹងអាជ្ញាផងដែរ។

៣- មរណភាពនៃជនល្មើសៈ

ចំណុចទី១ នៃមាត្រា៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧បានបញ្ញត្តិថា បណ្ដឹងអាជ្ញាត្រូវរលត់ប្រសិនបើជនល្មើសបានទទួលមរណភាពទៅហើយ។

ដូច្នេះតំណាងអយ្យការត្រូវតែសម្រេចតម្កល់រឿងក្ដីព្រហ្មទណ្ឌនោះទុកឥតចាត់ការ។ ហើយណែនាំឱ្យជនរងគ្រោះនៃអំពើល្មើសប្ដឹងទៅតុលាការរដ្ឋប្បវេណីដើម្បីទាមទារសំណងការខូចខាត និងសំណងជម្ងឺចិត្តវិញ។

៤- ការផុតអាជ្ញាយុកាលៈ

ចំណុចទី២ មាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ បានបញ្ញត្តិថា បណ្ដឹងអាជ្ញាត្រូវរលត់ប្រសិនបើផុតអាជ្ញាយុកាលនៃបទល្មើសទៅហើយ។

លើកលែងតែមានចែងពិសេសនៅក្នុងច្បាប់ផ្សេង ចិរវេលានៃអាជ្ញាយុកាលនៃបណ្ដឹងអាជ្ញាមាន១៥ឆ្នាំចំពោះបទឧក្រិដ្ឋ មាន០៥ឆ្នាំចំពោះបទមជ្ឈិម និង០១ឆ្នាំចំពោះបទលហុ[68]។ ចិរវេលានៃអាជ្ញាយុកាលត្រូវចាប់ផ្ដើមគិតពីពេលប្រព្រឹត្តបទល្មើស។ ប៉ុន្តែចិរវេលានេះត្រូវបានកាត់ផ្ដាច់ដោយគ្រប់កិច្ចនៃការចោទប្រកាន់ ឬ កិច្ចស៊ើបសួរ។ ចិរវេលានៃអាជ្ញាយុកាលត្រូវផ្ដើមគិតជាថ្មីនៅពេលដែលកិចចនីតិវិធីនីមួយៗត្រូវបានបញ្ចប់[69]។

[68] មាត្រា១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ៣

៥- និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ៖

ចំណុចទី៤ មាត្រា៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ បានបញ្ញត្តិថាបណ្តឹងអាជ្ញាត្រូវរលត់ ប្រសិនបើបទប្បញ្ញត្តិដែលមានចែងឱ្យផ្តន្ទាទោសចំពោះបទល្មើសនោះ ត្រូវបានប្រកាសឱ្យនិរាករណ៍ហើយ។ ក្នុងករណីនេះជាសត្យានុម័តតំណាងអយ្យការត្រូវតែសម្រេចតម្កល់រឿងទុកឥតចាត់ការ។

ចំណុចទី៥ មាត្រា៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧បានបញ្ញត្តិថាបណ្តឹងអាជ្ញាត្រូវរលត់ប្រសិនបើ អាជ្ញាអស់ជំនុំ។ អាជ្ញាអស់ជំនុំត្រូវបានឱ្យនិយមន័យថានៅពេលតុលាការសម្រេចឱ្យជនណារួចខ្លួន(លើកលែង ចោទ) ជាស្ថាពរហើយ ជននោះមិនអាចត្រូវចោទប្រកានជាថ្មីទៀតទេចំពោះបទល្មើសដដែលនោះទោះបីជា ក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងទៀតក៏ដោយ[70]។

វាមានន័យថាតំណាងអយ្យការត្រូវតែសម្រេចតម្កល់រឿងទុកឥតចាត់ការ ប្រសិនបើជនដដែលនោះធ្លាប់ ត្រូវបានតុលាការប្រកាសឱ្យរួចពីបទចោទប្រកាន់ពីដំបូងហើយ ចំពោះបទល្មើសដដែលដែលគេប្តឹងសុំមក តំណាងអយ្យការឱ្យបើកការចោទប្រកាន់នោះ។

៦- ការសម្របសម្រួលជាមួយរដ្ឋ៖

ចំណុចទី១ មាត្រា៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧បានបញ្ញត្តិថា បណ្តឹងអាជ្ញាត្រូវរលត់ប្រសិនបើ មានករណីមានការសម្របសម្រួលជាមួយរដ្ឋ។

មានបទល្មើសមួយចំនួន អាចត្រូវបញ្ចប់ដោយសារតែមូលហេតុនៃការសម្របសម្រួលជាមួយរដ្ឋផងដែរ។

៧- ការបង់ប្រាក់ពិន័យសរុប ឬ ប្រាក់ពិន័យសម្របសម្រួល៖

ចំណុចទី៣ មាត្រា៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧បានបញ្ញត្តិថា បណ្តឹងអាជ្ញាត្រូវរលត់ ប្រសិនបើមានការបង់ប្រាក់ពិន័យសរុប ឬ ប្រាក់ពិន័យសម្របសម្រួល។

មានបទល្មើសមួយចំនួន ត្រូវបានច្បាប់អនុញ្ញាតឱ្យធ្វើការបញ្ចប់សំណុំរឿងដោយគ្រាន់តែធ្វើការពិន័យ។ តំណាងអយ្យការត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការដោយបកស្រាយលើមូលហេតុនៃការរលត់បណ្តឹងអាជ្ញា។

៨- ការមានអភ័យឯកសិទ្ធិ៖

មាត្រា ៨០ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ បានបញ្ញត្តិថា "តំណាងរាស្ត្រមាន អភ័យឯកសិទ្ធិ តំណាងរាស្ត្រណាក៏ដោយមិនអាចត្រូវបានចោទប្រកាន់ចាប់ខ្លួន ឃាត់ខ្លួន ឬ ឃុំខ្លួនឡើយ លុះ ត្រាតែមានការយល់ព្រមពីរដ្ឋសភានៅក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា"។

---

[69] មាត្រ១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ៣

[70] មាត្រា១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ៣

ចំពោះករណីមិនចោទប្រកាន់ចំពោះបុគ្គលដែលមានអភ័យឯកសិទ្ធិនេះ យើងអាចយល់ឃើញថាវាមិនមែនស្ថិតនៅក្នុងមូលហេតុនៃការរលត់បណ្តឹងអាជ្ញាឡើយ គឺវាគ្រាន់តែជាមូលហេតុគតិយុត្តផ្សេងទៀតដែលអនុញ្ញាតឱ្យតំណាងអយ្យការអាចសម្រេចតម្កល់រឿងទុកឥតចាត់ការប៉ុណ្ណោះ។

៩- ការរួចផុតពីការទទួលខុសត្រូវរបស់ជនល្មើសៈ

មានមាត្រាមួយចំនួនដូចជាៈ មាត្រា៣១ មាត្រា៣២ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ និងមាត្រា៣៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ដែលបញ្ញត្តិអំពីអំពើមួយចំនួនដែលមិនអនុញ្ញាតឱ្យតំណាងអយ្យការអាចបើកការចោទប្រកាន់ចំពោះអំពើនោះឡើយ បើទោះបីជាសកម្មភាពនៃអំពើនោះត្រូវបានចាត់ទុកថាជាបទល្មើសក៏ដោយ។ ប៉ុន្តែការអនុញ្ញាតឱ្យរួចផុតពីការចោទប្រកាន់នេះមិនមែនជាមូលហេតុនៃការរលត់បណ្តឹងអាជ្ញាឡើយ។

**ឃ. មូលហេតុដទៃទៀត**

ព្រះរាជអាជ្ញាក៏អាចតម្កល់រឿងទុកឥតចាត់ការ ដោយផ្អែកលើមូលហេតុជាក់ស្តែងក្នុងសង្គមផ្សេងៗទៀតក្រៅពីការបញ្ញត្តិនៅក្នុងច្បាប់ផងដែរ។ មូលហេតុទាំងនោះមានដូចជាៈ

១- ការចោទប្រកាន់មិនផ្តល់អត្ថប្រយោជន៍ៈ

តំណាងអយ្យការ ប្រើប្រាស់គោលការណ៍កាលានុវត្តភាពរបស់ខ្លួនចំពោះករណីនេះ។ គោលការណ៍នេះអនុញ្ញាតឱ្យតំណាងអយ្យការ មានជម្រើសមិនចោទប្រកាន់ចំពោះបទល្មើសដែលខ្លួនទទួលចាត់ការ គឺនៅពេលដែលតំណាងអយ្យការបានមើលឃើញថា ការចោទប្រកាន់មិនទទួលបានអត្ថប្រយោជន៍អ្វីឡើយ ហើយពេលខ្លះជនរងគ្រោះនៃអំពើនោះមិនបានអើពើនឹងការចោទប្រកាន់របស់តំណាងអយ្យការថែមទៀតផង។

២- ជម្រើសនៃការអប់រំណែនាំៈ

មានបទល្មើសមួយចំនួនតំណាងអយ្យការមិនគួរចោទប្រកាន់បញ្ជូនឱ្យស៊ើបសួរ ឬ បញ្ជូនទៅជំនុំជម្រះឡើយ។ មុនពេលចោទប្រកាន់តំណាងអយ្យការ គប្បីពិនិត្យទៅលើកាលៈទេសៈនៃការប្រព្រឹត្តបទល្មើស ស្ថានភាពសង្គម ឬ ស្ថានភាពនៃអាយុ និងការយល់ដឹងរបស់ជនល្មើសផងដែរ។ ព្រោះថាពេលខ្លះជនល្មើសគ្មានបំណងទៅប្រព្រឹត្តបទល្មើសនោះទេ ជួនកាលដោយសារការអូសទាញពីអ្នកដទៃ ឬ កើតចេញពីបរិយកាសសង្គមមិនល្អ ដែលបានជម្រុញឱ្យគេទៅប្រព្រឹត្តបទល្មើសទាំងនោះ។

## ២.១.៤. នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ

ក្នុងករណីតំណាងអយ្យការសម្រេចតម្កល់រឿងទុកឥតចាត់ការ តំណាងអយ្យការត្រូវបញ្ជាក់អំពីសំអាងហេតុ និងសំអាងច្បាប់ជាលាយលក្ខណ៍អក្សរនៅក្នុងដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់ខ្លួនហើយជូនដំណឹងអំពីដីកាសម្រេចនោះទៅឱ្យអ្នកប្តឹង នៅក្នុងរយៈពេលខ្លីបំផុតហើយយ៉ាងយូរបំផុតរយៈពេល ០២ខែ គិតពីថ្ងៃចុះបញ្ជីពាក្យបណ្តឹង។

មុនពេលចេញដីកាសសម្រេចតម្កល់រឿងទុកឥតចាត់ការ តំណាងអយ្យការត្រូវតែបើកការស៊ើបអង្កេតបឋម ឬ បង្គាប់ឱ្យធ្វើការស្រាវជ្រាវបន្ថែម។

### ២.១.៥. នីតិវិធី និងសេចក្តីសម្រេចនៃបណ្តឹងតវ៉ា

បន្ទាប់ពីទទួលដំណឹងអំពីដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ ប្រសិនបើអ្នកប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចនោះទេ អ្នកប្តឹងអាចធ្វើបណ្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសលាឧទ្ធរណ៍ដែលជានាយឋានានុក្រមរបស់ព្រះរាជអាជ្ញានោះបាន។

ក្នុងករណីតំណាងអយ្យការទទួលបានពាក្យប្តឹងតវ៉ា ចំពោះសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់ខ្លួន តំណាងអយ្យការត្រូវធ្វើលិខិតជូនដំណឹងមួយទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ឱ្យបានដឹងអំពីការប្តឹងតវ៉ានេះដោយមានរៀបរាប់អំពីសំអាងហេតុ និងសំអាងច្បាប់ដែលខ្លួនសម្រេចតម្កល់រឿងទុកឥតចាត់ការ។

ការតវ៉ាត្រូវធ្វើនៅក្នុងរយៈពេល០២ខែ គិតពីថ្ងៃទទួលដំណឹង អំពីសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ។ ការតវ៉ានេះត្រូវធ្វើតាមបណ្តឹងសាមញ្ញនៅអង្គការអយ្យការដែលពាក់ព័ន្ធ។ បន្ទាប់មកសំណុំរឿងត្រូវបញ្ជូនភ្លាមទៅឱ្យសាលាឧទ្ធរណ៍ ដែលមានសមត្ថកិច្ចដែនដីលើអយ្យការអមសាលាដំបូងនោះ។

ប្រសិនបើយល់ឃើញថា ការតវ៉ានោះមានមូលហេតុត្រឹមត្រូវអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចចេញអធិបញ្ញាដល់ព្រះរាជអាជ្ញាអមសាលាដំបូងឱ្យធ្វើការចោទប្រកាន់។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរ។

ផ្ទុយទៅវិញ ប្រសិនបើអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍សម្រេចតម្កល់សេចក្តីសម្រេចរបស់ព្រះរាជអាជ្ញាអមសាលាដំបូងទុកជាបានការហើយជូនដំណឹងអំពីសេចក្តីសម្រេចនេះដល់អ្នកប្តឹងតវ៉ា។

## ២.២. ការចោទប្រកាន់

មាត្រា ១៣១(ថ្មី) នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ញត្តិថាមានតែអង្គការអយ្យការតែមួយគត់ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។ បណ្តឹងអាជ្ញាមានគោលបំណងឱ្យពិនិត្យអត្ថិភាពនៃបទល្មើសបង្ហាញឱ្យឃើញអំពីពិរុទ្ធភាពចំពោះជនល្មើស និងផ្តន្ទាទោសជនល្មើសតាមច្បាប់។ ក្នុងនាមជាបុគ្គលដែលតំណាងឱ្យផលប្រយោជន៍ទូទៅ ជាអ្នកធានារក្សាឱ្យបាននូវសណ្តាប់ធ្នាប់សាធារណៈ និងជាបុគ្គលតំណាងឱ្យស្ថាប័នអយ្យការទាំងមូល ក្នុងការឃ្លាំមើលការអនុវត្តច្បាប់នៅក្នុងសង្គមទើបតំណាងអយ្យការត្រូវបានផ្តល់ឱ្យនូវបុព្វសិទ្ធិអាចធ្វើបុរេវិនិច្ឆ័យដោយសន្មត់ទុកជាមុនថាជនទាំងឡាយដែលខ្លួនសង្ស័យថាបានប្រព្រឹត្តបទល្មើសពិតជាបានប្រព្រឹត្តបទល្មើស។ ហើយប្តឹងសុំទៅយុត្តាធិការស៊ើបសួរ ឬ យុត្តាធិការជំនុំជម្រះឱ្យធ្វើការស្រាវជ្រាវ និងផ្តន្ទា ទោសជននោះតាមច្បាប់។

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់មធ្យោបាយបីដល់តំណាងអយ្យការនៅក្នុងនីតិវិធីនៃការប្តឹងសុំឱ្យមានការផ្តន្ទាទោសជនល្មើស។ តំណាងអយ្យការថ្លឹងថ្លែងអំពីជម្រើសរបស់ខ្លួនដោយពិចារណាទៅលើលក្ខខណ្ឌចាំបាច់នៃកិច្ចនីតិវិធីដែលត្រូវធ្វើ អាស្រ័យទៅតាមប្រភេទនៃបទល្មើស និងអាស្រ័យទៅតាមស្ថានភាពជាក់ស្តែងនៃបទល្មើសជាអាទិ៍។

### ២.២.១. ការបើកការស៊ើបសួរ

តំណាងអយ្យការ អាចប្តឹងសុំទៅយុត្តាធិការស៊ើបសួរឱ្យធ្វើការស្រាវជ្រាវចំពោះអំពើដែលខ្លួនសង្ស័យថាគឺជាបទល្មើសតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះ គឺជានីតិវិធីមួយដែលតំណាងអយ្យការអាចធ្វើដើម្បីបើកការស៊ើបសួរប្រឆាំងទៅលើបុគ្គលម្នាក់ ឬ ច្រើននាក់ដោយមានចង្អុលប្រាប់ឈ្មោះ ឬ ប្រឆាំងទៅលើអញ្ញាតជន[71]។

ចៅក្រមស៊ើបសួរ ដែលទទួលបណ្តឹងអំពីអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់តំណាងអយ្យការនេះ អាចធ្វើការស៊ើបសួរតែចំពោះអង្គហេតុដែលបញ្ជូនមកឱ្យខ្លួនពិនិត្យតែប៉ុណ្ណោះ។ នៅពេលបំពេញកិច្ចស៊ើបសួរត្រូវជូនព័ត៌មានអំពីអង្គហេតុថ្មីនោះ ទៅតំណាងអយ្យការដើម្បីឱ្យតំណាងអយ្យការអាចប្តឹងសុំឱ្យចៅក្រមស៊ើបសួរ ធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនោះតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ ចៅក្រមស៊ើបសួរគ្មានអំណាចស៊ើបសួរអំពីអង្គហេតុថ្មីណាមួយឡើយ បើមិនទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពីតំណាងអយ្យការនោះទេ[72]។

ក្នុងករណីនេះ មានចំណោទគតិយុត្តមួយបានចោទឡើងថា៖ ស្ថិតនៅក្នុងពេលកំពុងស៊ើបសួរហើយមានលេចចេញអង្គហេតុថ្មី ដែលចៅក្រមស៊ើបសួរយល់ឃើញថាជាបទល្មើសព្រហ្មទណ្ឌតែបែរជាតំណាងអយ្យការមិនព្រមប្តឹងសុំចោទប្រកាន់ឱ្យស៊ើបសួរបន្ថែមទេ ទោះបីជាចៅក្រមស៊ើបសួរបានជូនដំណឹងអំពីការលេចចេញនូវអង្គហេតុថ្មីរួចហើយក៏ដោយ។ ចំពោះករណីនេះតើចៅក្រមស៊ើបសួរអាចធ្វើការស៊ើបសួរបន្ថែមទៅលើអង្គហេតុថ្មីដោយគ្រាន់តែយោងតាមបទបញ្ញត្តិនៃមាត្រា ១៣៨ និងមាត្រា ១៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌស្តីពីការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរបានដែរឬទេ?

ចម្លើយគឺឆ្លើយថាបានដោយគ្រាន់តែមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរ ដោយធ្វើសេចក្តីបញ្ជាក់ពីការលេចចេញនូវអង្គហេតុថ្មីដែលជាបទល្មើសព្រហ្មទណ្ឌនោះតែប៉ុណ្ណោះ។

[71] មាត្រា៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ១៣

[72] មាត្រា១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ៤៤

ចៅក្រមស៊ើបសួរ មិនចាំបាច់មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពីតំណាងអយ្យការឡើយ ប្រសិនបើអង្គហេតុថ្មីនោះ គ្រាន់តែជាស្ថានទម្ងន់ទោសទៅលើអង្គហេតុដែលព្រះរាជអាជ្ញាបានរៀបរាប់នៅក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដំបូងប៉ុណ្ណោះ[73]។

គ្រប់បុគ្គលដែលត្រូវបានតំណាងអយ្យការ ដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរត្រូវបានផ្លាស់ប្តូរឋានៈរបស់ខ្លួនទៅជាជនត្រូវចោទ។

ជនត្រូវចោទអាចត្រូវបានចៅក្រមស៊ើបសួរដកហូតសិទ្ធិសេរីភាពខ្លះ ដូចជាហាមឃាត់មិនឱ្យផ្លាស់ប្តូរលំនៅឋាន ឬ ត្រូវមកបង្ហាញខ្លួនតាមការណែនាំរបស់ចៅក្រមស៊ើបសួរ មិនឱ្យធ្វើដំណើរក្រៅព្រំប្រទល់ដែនដីកំណត់ដោយចៅក្រមស៊ើបសួរជាអាទិ៍ ឬ ចៅក្រមស៊ើបសួរ អាចសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្នថែមទៀតផង[74]។ ព្រោះតែអានុភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះនាំឱ្យមានការកំណត់ឋានៈ ជាមធ្យោបាយសម្រាប់ដកហូតសិទ្ធិសេរីភាពចំពោះពលរដ្ឋ ដូចនេះហើយទើបនៅក្នុងបទបញ្ញត្តិនៃមាត្រា៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងអំពីទម្រង់ចាំបាច់មួយចំនួនដែលតម្រូវឱ្យតំណាងអយ្យការ ដែលជាម្ចាស់បណ្តឹងអាជ្ញាត្រូវតែគោរពជាដាច់ខាតនៅមុនពេលចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅឱ្យចៅក្រមស៊ើបសួរ។

ក្នុងករណីតំណាងអយ្យការចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដោយបំពានទៅលើទម្រង់ដែលកំណត់ជាកាតព្វកិច្ចនៅក្នុងមាត្រា៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌនាំឱ្យការបើកការស៊ើបសួររបស់តំណាងអយ្យការត្រូវចាត់ទុកជាមោឃៈ ហើយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះគ្មានអានុភាពអ្វីដល់បុគ្គលដែលមានឈ្មោះនៅក្នុងដីកានោះឡើយ[75]។

### ក.ប្រភពដែលនាំឱ្យព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

+ ពាក្យបណ្តឹង ឬ ពាក្យបរិហារទទួលដោយផ្ទាល់ ឬ បញ្ជូនពីមន្ត្រីនគរបាលយុត្តិធម៌

ដោយយោងតាមមាត្រា១៣១(ថ្មី)នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាបានប្រគល់អំណាចឱ្យតែអង្គការអយ្យការប៉ុណ្ណោះដែលអាចមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។ ដូច្នេះគ្រប់បុគ្គល ឬ គ្រប់ស្ថាប័នទាំងអស់នៅពេលដឹងថាមានការកើតឡើងនូវបទល្មើសត្រូវជូនដំណឹងមកស្ថាប័ន អយ្យការ ឬ ប្តឹងចូលមកស្ថាប័នអយ្យការ ឬ កសាងសំណុំរឿងបញ្ជូនមកឱ្យស្ថាប័នអយ្យការដើម្បីផ្តើមធ្វើបណ្តឹងអាជ្ញា។

---

[73] មាត្រា១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ៤៤

[74] មាត្រា១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ៤៤

[75] មាត្រា៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ១៣

ជនរងគ្រោះនៃសំណុំរឿងព្រហ្មទណ្ឌក៏អាចដាក់ពាក្យប្ដឹងមកតំណាងអយ្យការបានដែរ[76]។ រីឯអ្នកតំណាងរបស់ជនរងគ្រោះ ដែលជាអនីតិជន ឬ ជានីតិជនស្ថិតនៅក្រោមរបបច្បាប់ការពារ ក៏អាចដាក់ពាក្យប្ដឹងមកតំណាងអយ្យការបានដែរ[77]។

ក្នុងករណីផ្សេងទៀតបើសិនជាជនរងគ្រោះទទួលមរណភាព ឬ គ្មានអ្នកតំណាងឱ្យខ្លួនទេសិទ្ធិវ័ន្តនៃជនរងគ្រោះ ករណីជនរងគ្រោះទទួលមរណភាពអាចដាក់ពាក្យប្ដឹងមកតំណាងអយ្យការបាន[78] ឬ ក្នុងករណីជនរងគ្រោះគ្មានអ្នកតំណាងឱ្យខ្លួនទេ ក្រមនីតិវិធីព្រហ្មទណ្ឌដដែលនេះ ក៏បានចែងជាកាតព្វកិច្ចចំពោះអាជ្ញាធរសាធារណៈ ឬ មន្ត្រី(មន្ត្រីរាជការ)គ្រប់រូប នៅពេលបំពេញការងាររបស់ខ្លួនហើយបានដឹងអំពីការកើតឡើងនូវបទល្មើសត្រូវតែធ្វើបណ្ដឹងបរិហារអំពីបទល្មើសដែលខ្លួនបានដឹងនោះមកតំណាងអយ្យការ[79]។

តំណាងអយ្យការថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យប្ដឹង និងពាក្យបរិហារដែលខ្លួនបានទទួល ដោយផ្ទាល់ ឬ ដែលមន្ត្រីនគរបាលបានបញ្ជូនមក បន្ទាប់ពីតំណាងអយ្យការបើកការស៊ើបអង្កេតបឋម ឬ បង្គាប់ឱ្យធ្វើការស្រាវជ្រាវបន្ថែមទៀតមក ឬ អាចនិយាយបានថាពាក្យប្ដឹងទាមទារ និងបរិហារដែលខ្លួនទទួលបាននោះគ្រាន់តែជាពាក្យបណ្ដឹងសាមញ្ញប៉ុណ្ណោះ គ្មានអានុភាពចាប់បង្ខំឱ្យតំណាងអយ្យការត្រូវតែធ្វើបណ្ដឹងអាជ្ញាឡើយ។

បណ្ដឹងអាជ្ញានេះអាចធ្វើបានបន្ទាប់ពីតំណាងអយ្យការបានបើកការស៊ើបអង្កេតបឋម ឬ បានធ្វើការស្រាវជ្រាវបន្ថែមរួចរាល់ហើយ។ ក្នុងករណីតំណាងអយ្យការសម្រេចធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ តំណាងអយ្យការសុំឱ្យចៅក្រមស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[80]។

+ ការជូនដំណឹងអំពីការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី

ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬ បទមជ្ឈិមអាចដាក់ពាក្យប្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅដំណាក់កាលចៅក្រមស៊ើបសួរបាន។ ពាក្យបណ្ដឹងនេះមានអានុភាពប្ដឹងដល់ចៅក្រមស៊ើបសួរអំពីរឿងហេតុដែលជាបទល្មើសព្រហ្មទណ្ឌ ហើយមានកម្មវត្ថុឱ្យចៅក្រមស៊ើបសួរពិនិត្យអំពីអត្ថិភាពចំពោះបទល្មើសនោះក្នុងគោលបំណងទទួលបានសំណងការខូចខាតជម្ងឺចិត្ត និងផ្ដន្ទាទោសជននោះតាមច្បាប់។

នៅពេលចៅក្រមស៊ើបសួរទទួលបានពាក្យបណ្ដឹង ដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរធ្វើការកត់សម្គាល់អំពីការដាក់ពាក្យបណ្ដឹងនោះ ហើយបញ្ជូនបណ្ដឹងទៅឱ្យតំណាងអយ្យការ

---

76 មាត្រា៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ២

77 មាត្រា១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ៤

78 មាត្រា១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ៤

79 មាត្រា៤២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ១២

80 មាត្រា៤០ និងមាត្រា១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ១១ និងទំព័រ៤៤

ដើម្បីពិនិត្យ ក្រោយពីបានឃើញពាក្យបណ្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនេះ តំណាងអយ្យការអាចប្ដឹងសុំទៅចៅក្រមស៊ើបសួរ ឱ្យបើកការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[81]។

+ អធិបញ្ញារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

កំណត់សម្គាល់៖ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌មានអំណាចអាចធ្វើអធិបញ្ញាឱ្យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬ ព្រះរាជអាជ្ញាអមសលាដំបូងធ្វើការចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌ ប៉ុន្តែគ្មានអំណាចធ្វើអធិបញ្ញាឱ្យអគ្គព្រះរាជអាជ្ញា ឬ ព្រះរាជអាជ្ញាតម្កល់រឿងទុកឥតចាត់ការ នូវរឿងក្ដីព្រហ្មទណ្ឌណាមួយបានឡើយ។

មាត្រា៧៥ នៃច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និង ព្រះរាជអាជ្ញាបានបញ្ញត្តិថា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ គឺជានាយឋានានុក្រមនៃអង្គការអយ្យការ ហើយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរទៅអង្គការអយ្យការគ្រប់ជាន់ថ្នាក់។ នៅក្នុងចំណាត់ការទៅលើសំណុំរឿងក្ដីព្រហ្មទណ្ឌវិញ យើងបានមើលឃើញថារដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចប្ដឹងបរិហារទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬ ទៅព្រះរាជអាជ្ញាអមសាលាដំបូងអំពីបទល្មើសដែលខ្លួនបានដឹង ឬ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរ ឱ្យអគ្គព្រះរាជអាជ្ញា ឬ ព្រះរាជអាជ្ញាអមសាលាដំបូង ធ្វើការចោទប្រកាន់ចំពោះរឿងក្ដីព្រហ្មទណ្ឌ ដែលខ្លួនយល់ថា គឺជាបទល្មើសព្រហ្មទណ្ឌបាន[82]។ ក្នុងករណីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ធ្វើអធិបញ្ញាឱ្យចោទប្រកាន់តំណាងអយ្យការត្រូវតែប្ដឹងទៅយុត្តាធិការស៊ើបសួរ ឱ្យបើកការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

+ ការធ្វើអធិបញ្ញារបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានអំណាចលើចៅក្រមអយ្យការទាំងអស់ដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន (សមត្ថកិច្ចដែនដីនាពេលបច្ចុប្បន្នគឺ គ្រប់អយ្យការអមសាលាដំបូងនៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងអស់។ ក៏ប៉ុន្តែនៅពេលច្បាប់ស្ដីពីការរៀបចំអង្គការតុលាការដំណើរការបានអយ្យការអមសាលាឧទ្ធរណ៍ ត្រូវបបានបង្កើតឡើងច្រើនជាងមួយ គឺមានអយ្យការអមសាលាឧទ្ធរណ៍នៅរាជធានីភ្នំពេញ និងអយ្យការអមសាលាឧទ្ធរណ៍នៅតាមតំបន់)[83]។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចធ្វើអធិបញ្ញាឱ្យព្រះរាជអាជ្ញាអមសាលាដំបូងធ្វើការចោទប្រកាន់។ ព្រះរាជអាជ្ញាដែលមានកាតព្វកិច្ចត្រូវគោរពតាមអធិបញ្ញានេះ ត្រូវបើកការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅចៅក្រមស៊ើបសួរ។

---

[81] មាត្រា១៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ៤៨

[82] មាត្រា២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ៨

[83] មាត្រា៤០ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤ ទំព័រ១៦

+ ការស្នើសុំឱ្យបើកការស៊ើបសួរបន្ថែម

នៅពេលបំពេញកិច្ចស៊ើបសួរ ប្រសិនបើមានលេចនូវអង្គហេតុថ្មីដែលអាចជាបទល្មើសព្រហ្មទណ្ឌផ្សេងតទៀត ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានអំពីអង្គហេតុនេះទៅតំណាងអយ្យការដោយដីកា ប៉ុន្តែមិនមែនជាដីកាសម្រេចទេ។ តំណាងអយ្យការអាចប្តឹងសុំឱ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរចំពោះអង្គហេតុថ្មីនោះតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ ក្នុងករណីចៅក្រមស៊ើបសួរមិនទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ ចៅក្រមស៊ើបសួរគ្មានអំណាចស៊ើបសួរអំពីអង្គហេតុថ្មីនោះឡើយ[84]។

+ ការបញ្ជូនរឿងឱ្យបើកការស៊ើបសួរដោយចៅក្រមជំនុំជម្រះ

តំណាងអយ្យការអាចបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទចូលទៅបង្ហាញខ្លួនភ្លាម នៅមុខតុលាការជាន់ដំបូងប្រសិនបើមានគ្រប់លក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ប៉ុន្តែប្រសិនបើតុលាការដែលបានទទួលបណ្តឹង តាមនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាមយល់ឃើញថាលក្ខខណ្ឌនៃមាត្រា ៤៧ នៃក្រមនេះមិនបានបំពេញទេ ឬ ក៏ដោយភាពស្មុគស្មាញនៃសំណុំរឿងដែលតម្រូវជាចាំបាច់ឱ្យធ្វើការស្រាវជ្រាវឱ្យបានស៊ីជម្រៅបន្ថែមទៀត តុលាការជំនុំជម្រះនៃនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាមត្រូវបញ្ជូនសំណុំរឿងទៅតំណាងអយ្យការ ដើម្បីបើកការស៊ើបសួរវិញតំណាងអយ្យការប្តឹងសុំដើម្បីបើកការស៊ើបសួរតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅចៅក្រមស៊ើបសួរហើយ ជនជាប់ចោទត្រូវតែនាំទៅបង្ហាញខ្លួនចំពោះមុខចៅក្រមស៊ើបសួរនៅថ្ងៃនោះតែម្តង បើមិនដូច្នោះទេជនជាប់ចោទត្រូវតែដោះលែងឱ្យមានសេរីភាពវិញដោយឯកឯង[85]។

**ខ. លក្ខខណ្ឌចាំបាច់ដែលតម្រូវឱ្យព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបអង្កេត**

+ ករណីបទឧក្រិដ្ឋ

យោងតាមមាត្រា៤៦ នៃក្រមព្រហ្មទណ្ឌបានឱ្យនិយមន័យថាបទឧក្រិដ្ឋ គឺជាបទល្មើសដែលនៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារ ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ឬ ជាទោសដាក់ពន្ធនាគារមានរយៈពេលលើសពី០៥ឆ្នាំ និង ក្រោម ឬ ស្មើនឹង៣០ឆ្នាំ និងទោសដាក់ពន្ធនាគារអាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។ មាត្រានេះបញ្ជាក់ឱ្យឃើញថាបទឧក្រិដ្ឋគឺជាបទល្មើសដែលមានស្ថានភាពធ្ងន់ធ្ងរមានផលប៉ះពាល់ខ្លាំងដល់សង្គម និង មានរយៈពេលវែងក្នុងការដកហូតសិទ្ធិសេរីភាពរបស់បុគ្គល ដូច្នេះតម្រូវឱ្យត្រូវពិនិត្យឱ្យបានល្អិតល្អន់បំផុត មុននឹងធ្វើការសម្រេចអំពីទោស។ ព្រោះតែស្ថានភាពធ្ងន់ធ្ងរដែលកើតឡើងពី

[84] មាត្រា១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ៤៤

[85] មាត្រា៤៨ និង មាត្រា៣០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ១៤ និង ទំព័រ៩៩

បទល្មើសនោះទើបក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិជាកាតព្វកិច្ចជាចាំបាច់ថា ក្នុងករណីបទល្មើសជាបទឧក្រិដ្ឋ តំណាងអយ្យការត្រូវតែបើកការស៊ើបសួរ[86]។

+ ករណីបទមជ្ឈិម

ចំណែកឯបទមជ្ឈិមវិញ មិនមែនជាលក្ខខណ្ឌចាំបាច់ដែលតម្រូវឱ្យព្រះរាជអាជ្ញាត្រូវតែប្ដឹងសុំចោទប្រកាន់ឱ្យបើកការស៊ើបសួរឡើយ[87]។ ព្រះរាជអាជ្ញាមានជម្រើសផ្សេងៗដូចជាប្រើនីតិវិធីប្ដឹងសុំទៅយុត្តាធិកាជំនុំជម្រះដោយបញ្ជូនជនសង្ស័យទៅជំនុំជម្រះតែម្ដង ឬ ធ្វើការតម្កល់រឿងទុកឥតចាត់ការ។

ករណីដែលបទមជ្ឈិមតម្រូវឱ្យបើកការស៊ើបសួរ គឺលុះត្រាតែភស្តុតាងដែលប្រមូលបាននោះពុំទាន់គ្រប់គ្រាន់ដើម្បីប្ដឹងទៅយុត្តាធិកាជំនុំជម្រះបាន ហើយភស្តុតាងដែលខ្វះខាតមិនអាចប្រមូលបាន ដោយការស៊ើបអង្កេតបឋម ប៉ុន្តែអាចប្រមូលបានក្នុងករណីដែលត្រូវប្រើអំណាចដោយបង្ខំ ឬក្នុងករណីដែលបទមជ្ឈិមនោះមានលក្ខណៈស្មុគស្មាញ ដែលតម្រូវឱ្យមានការស្រាវជ្រាវយូរ និង មានការលំបាកក្នុងការស្រាវជ្រាវ។

**គ. អានុភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ**

អានុភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ គឺជាការប្ដឹងសុំទៅយុត្តាធិកាស៊ើបសួរឱ្យដាក់ស្ថិតក្រោមការពិនិត្យចំពោះបុគ្គលម្នាក់ ឬ ច្រើននាក់ដោយមានចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ បានដាក់ឱ្យស្ថិតក្រោមការពិនិត្យចំពោះអញ្ញាតជនដែលតំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋានថាបានប្រព្រឹត្តបទល្មើសដោយផ្ទាល់ ឬ បានចូលរួមប្រព្រឹត្តបទល្មើស[88]។

ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ គឺជាមូលដ្ឋានដែលផ្ដល់អំណាចដល់ចៅក្រមស៊ើបសួរនៅក្នុងបេសកកម្មស្វែងរកយុត្តិធម៌ ឬ ម្យ៉ាងទៀតថាជាអំណាចក្នុងការពិនិត្យអំពីអត្ថិភាពនៃបទល្មើស។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បានផ្ដល់អំណាចឱ្យចៅក្រមស៊ើបសួរអាចដកហូតសិទ្ធិសេរីភាពមួយចំនួនចំពោះបុគ្គលដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

ការដកហូតសិទ្ធិសេរីភាពនោះមានជាអាទិ៍ដូចជា ការឃុំខ្លួនបណ្ដោះអាសន្នដោយឈរលើមូលហេតុដែលមានបញ្ញត្តិក្នុងមាត្រា២០៥នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងសិទ្ធិអំណាចក្នុងការដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការពិនិត្យតាមផ្លូវតុលាការ ដែលមានបញ្ញត្តិក្នុងមាត្រា២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ[89]។

---

[86] មាត្រា៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ១៣

[87] មាត្រា៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ១៣

[88] មាត្រា១២៤ និង មាត្រា១៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ៤៤ និង ទំព័រ៤៩

[89] មាត្រា ២០៤ មាត្រា ២០៥ និងមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ៦៧ និង ទំព័រ៧២

### ២.២.២. ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

នីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ក៏ជាជម្រើសមួយរបស់តំណាងអយ្យការក្នុងការចោទប្រកាន់ខាងបទល្មើសព្រហ្មទណ្ឌផងដែរ។ នីតិវិធីថ្មីនេះទើបតែបង្កើតឡើងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌថ្មីឆ្នាំ២០០៧នេះ តែប៉ុណ្ណោះ ក្រមនីតិវិធីនេះ ធ្វើការណែនាំឱ្យតំណាងអយ្យការត្រូវតែប្រើនីតិវិធីបញ្ជូនទៅជម្រះផ្ទាល់ចំពោះបទលហុ ឬ អាចប្រើនីតិវិធីបញ្ជូនទៅជម្រះផ្ទាល់ចំពោះបទមជ្ឈិមដែលមានភស្តុតាងគ្រប់គ្រាន់ហើយមិនមែនជាសំណុំរឿងមជ្ឈិមស្មុគស្មាញ[៩០]។

#### ក. លក្ខខណ្ឌទម្រង់ និងរយៈពេល

ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺជាការបញ្ជាឱ្យជនជាប់ចោទចូលទៅបង្ហាញខ្លួននៅមុខតុលាការជាន់ដំបូង ហើយដើម្បីអាចចេញដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់បាន លុះត្រាតែបានបំពេញនូវលក្ខខណ្ឌពីរ គឺ លក្ខខណ្ឌទម្រង់ និង លក្ខខណ្ឌនៃរយៈពេលដែលត្រូវគោរពរវាងការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ និង រយៈពេលដែលបង្គាប់ឱ្យចូលមកបង្ហាញខ្លួនចំពោះមុខតុលាការ។

- លក្ខខណ្ឌទម្រង់ នៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់រួមមាន៖
    - អត្តសញ្ញាណនៃជនជាប់ចោទ
    - សេចក្តីសង្ខេបនៃអង្គហេតុ
    - ឈ្មោះបទល្មើស
    - អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស
    - ការចង្អុលប្រាប់ពីតុលាការ ព្រមទាំងទីកន្លែង កាលបរិច្ឆេទ និង ម៉ោងពេលនៃសវនាការ[៩១]។
- លក្ខខណ្ឌ នៃរយៈពេលដែលត្រូវគោរពក្នុងការចេញដីកា៖
    - រយៈពេលដែលត្រូវគោរពរវាងការប្រគល់ដីកាកោះហៅបញ្ជូនទៅជម្រះផ្ទាល់ឱ្យដល់ជនជាប់ចោទ និងថ្ងៃ កំណត់ឱ្យចូលបង្ហាញខ្លួននៅមុខតុលាការត្រូវកំណត់ដូចតទៅ៖
        - ១៥ (ដប់ប្រាំ)ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃទីស្នាក់ការរបស់តុលាការ
        - ២០ (ម្ភៃ)ថ្ងៃ ប្រសិនបើជនជាប់ចោទ រស់នៅក្នុងទីកន្លែងផ្សេងក្នុងដែនដីជាតិ
        - ០២ (ពីរ)ខែ ប្រសិនបើជនជាប់ចោទ រស់នៅក្នុងរដ្ឋមួយជាប់ព្រំដែនព្រះរាជាណាចក្រកម្ពុជា
        - ០៣ (បី)ខែ ប្រសិនបើជនជាប់ចោទ រស់នៅក្នុងទីកន្លែងដទៃផ្សេងទៀត[៩២]។

---

[90] មាត្រា ៤៥ និងមាត្រា ៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ១៣

[91] មាត្រា ៤៦ និងមាត្រា ៤៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ១៣ និង ទំព័រ១៤០

- ដីកាកោះហៅបញ្ជូនទៅជម្រះផ្ទាល់ អាចត្រូវប្រគល់ឱ្យជនជាប់ចោទដោយៈ

- ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ក៏អាចត្រូវប្រគល់ឱ្យជនជាប់ចោទដោយអាជ្ញាសាលាផងដែរ។ អាជ្ញាសាលាត្រូវប្រើប្រាស់គ្រប់មធ្យោបាយដើម្បីប្រគល់ដីកានេះឱ្យជនជាប់ចោទដោយផ្ទាល់ដៃ[93]។ អាជ្ញាសាលាប្រគល់ចុងដីកាកោះទៅឱ្យជនជាប់ចោទ ហើយអាជ្ញាសាលាចារសេចក្តីលើដើមដីកាថាបានប្រគល់ចុងដីកាដល់ជនជាប់ចោទដោយផ្ទាល់ដៃ ហើយចុះនិទ្ទេសស្តីពីកាលបរិច្ឆេទ ទីកន្លែងប្រគល់ដីកា និងមានចុះហត្ថលេខាលើដើមដីកានោះ។ ដើមដីកាត្រូវបញ្ជូនវិលត្រឡប់ទៅតំណាងអយ្យការវិញភ្លាម[94]។

ក្នុងករណីជនជាប់ចោទអវត្តមានពីលំនៅឋានរបស់ខ្លួន អាជ្ញាសាលាត្រូវប្រគល់ចុងដីកាឱ្យដល់គ្រប់បុគ្គលទាំងឡាយណាជានីតិជនដែលមានវត្តមាននៅក្នុងលំនៅឋានរបស់ជនជាប់ចោទនោះ។ បុគ្គលដែលទទួលដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ត្រូវសន្យាថានឹងប្រគល់ដីកានោះក្នុងរយៈពេលខ្លីបំផុតដល់ជនជាប់ចោទ។ អាជ្ញាសាលាចុះនិទ្ទេសស្តីពីអត្តសញ្ញាណនៃបុគ្គលដែលទទួលចុងដីកាកោះចុះនិទ្ទេសស្តីពីកាលបរិច្ឆេទ និង ទីកន្លែងប្រគល់ដីកាហើយមានចុះហត្ថលេខានៅលើដើមដីកានោះ ហើយដើមដីកាត្រូវបញ្ជូនវិលត្រឡប់ទៅតំណាងអយ្យការវិញភ្លាម[95]។

អាជ្ញាសាលាត្រូវប្រគល់ចុងដីកាកោះឱ្យដល់មេឃុំ ឬ ចៅសង្កាត់ ឬ ជំទប់ ឬ ចៅសង្កាត់រង ក្នុងករណីផ្សេងទៀតដូចជាៈ

+ ជនជាប់ចោទមិនព្រមទទួលដីកាកោះហៅបញ្ជូនទៅជម្រះផ្ទាល់

+ គ្មានវត្តមានបុគ្គលណាម្នាក់ជានីតិជននៅក្នុងលំនៅឋានរបស់ជនជាប់ចោទទេ

+គ្មានបុគ្គលណាម្នាក់ជានីតិជន ដែលមានវត្តមាននៅក្នុងលំនៅឋានរបស់ជនជាប់ចោទព្រមទទួលដីកាកោះនោះទេ[96]។

- ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ អាចត្រូវប្រគល់ឱ្យជនជាប់ចោទដោយផ្ទាល់ដៃដោយតំណាងអយ្យការ។ តំណាងអយ្យការប្រគល់ចុងដីកាទៅឱ្យជនជាប់ចោទហើយតំណាងអយ្យការចុះនិទ្ទេសស្តីពីកាលបរិច្ឆេទ ទីកន្លែងប្រគល់ដីកា និង មានចុះហត្ថលេខានៅលើដើមដីកានោះ[97]។

- មានមធ្យោបាយផ្សេងទៀតទាក់ទងនឹងការកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺមានដូចជាៈ

---

[92] មាត្រា៤៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ១៤០

[93] មាត្រា៤៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ១៤១

[94] មាត្រា៤៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ១៤១

[95] មាត្រា៤៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ១៤១

[96] មាត្រា៤៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ១៤១

[97] មាត្រា៤៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ១៤០

+ ការបញ្ជូនតាមផ្លូវរដ្ឋបាល

+ ការបញ្ជូនតាមរយៈក្រឡាបញ្ជី

+ ការបញ្ជូនតាមរយៈអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ[98]។

+ ការបញ្ជូនតាមរយៈប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ប្រសិនបើជនជាប់ចោទត្រូវឃុំខ្លួនពីបទល្មើសផ្សេងទៀត។

**ខ. មូលហេតុនៃការប្រើនីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់**

- បទលហុ

បទលហុ គឺជាបទល្មើសដែលអតិបរមានៃការផ្តន្ទាទោសដាក់ពន្ធនាគារមានរយៈពេលក្រោម ឬ ស្មើ០៦ ថ្ងៃ ឬ ជាប្រភេទបទល្មើសដែលគ្រាន់តែត្រូវផ្តន្ទាទោសពិន័យជាប្រាក់តែប៉ុណ្ណោះ[99]។ ព្រោះតែបទល្មើសលហុត្រូវបានចាត់ទុកថាជាប្រភេទបទល្មើសស្រាលបំផុត ដែលមិនបង្កឱ្យប៉ះពាល់ដល់សន្តិសុខសង្គមហើយដើម្បីកាត់បន្ថយបន្ទុកចំណាយរបស់រដ្ឋនិងភាគី និងដើម្បីចំណេញពេលវេលាទើបច្បាប់បានបញ្ញត្តិជាកំហិតថា ក្នុងករណីទទួលបានសំណុំរឿងដែលជាបទលហុ តំណាងអយ្យការត្រូវតែប្រើនីតិវិធីកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់[100]។

- បទមជ្ឈិម

តំណាងអយ្យការមានកាតព្វកិច្ចត្រូវតែគោរព តែចំពោះលក្ខខណ្ឌតែ០២ (ពីរ)ប៉ុណ្ណោះ គឺមាត្រា៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលបញ្ញត្តិថា ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរចំពោះបទឧក្រិដ្ឋ និងមាត្រា៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលបញ្ញត្តិថា ព្រះរាជអាជ្ញាត្រូវតែប្រើនីតិវិធីកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ចំពោះបទលហុ។

ចំណែកឯការបញ្ជូនទៅជំនុំជម្រះផ្ទាល់ចំពោះបទមជ្ឈិម ច្បាប់មិនបានតម្រូវថាត្រូវតែធ្វើបែបណានោះទេ។ ចំពោះករណីបទល្មើសមជ្ឈិមក៏បានដែរទោះបីជាបទល្មើសនោះជាបទមជ្ឈិមជាក់ស្តែង ឬ មិនជាក់ស្តែងក៏ដោយ។

ដូច្នេះតំណាងអយ្យការមានជម្រើសអាចប្រើនីតិវិធីកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់បាន។

**គ. អានុភាពនៃដីកាកោះហៅទៅជំនុំជម្រះ**

ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ មានអានុភាពជាការប្តឹងសុំទៅយុត្តាធិកាជំនុំជម្រះឱ្យបើកសវនាការទៅតាមកាលបរិច្ឆេទដែលកំណត់ នៅក្នុងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ដើម្បីជំនុះជម្រះលើអង្គសេចក្តីចំពោះបទលហុ ឬ បទមជ្ឈិមដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ។ យោងតាមមាត្រា៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ កាលបរិច្ឆេទ និងម៉ោងពេលនៃសវនាការត្រូវកំណត់ឡើងដោយតំណាងអយ្យការនៅក្នុងដីកាកោះ

[98] មាត្រា៤៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ១៤២

[99] មាត្រា៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ១៤

[100] មាត្រា៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ១៥

ហៅបញ្ជូនទៅជម្រះផ្ទាល់តែម្តង។ ដោយសារផ្អែកលើមូលហេតុដូច្នេះហើយ ទើបយើងយល់ថាអានុភាពនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់នេះបានបំពានទៅលើសិទ្ធិអំណាចរបស់ប្រធានសាលាដំបូង ដែលពីដំបូងជាបុគ្គលតែម្នាក់គត់ដែលមានអំណាចកំណត់អំពីកាលបរិច្ឆេទនៃសវនាការ។

ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ មានអានុភាពកែប្រែឋានៈរបស់បុគ្គលធម្មតាម្នាក់ឱ្យក្លាយទៅជាជនជាប់ចោទ។ មិនតែប៉ុណ្ណោះដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់នេះថែមទាំងមានអានុភាពជាសេចក្តីបញ្ជាដល់ជនជាប់ចោទនោះ ឱ្យចូលទៅបង្ហាញខ្លួននៅចំពោះមុខតុលាការជាន់ដំបូងដែលចេញដីកាកោះនោះថែមទៀតផង។

## ២.២.៣. កំណត់ហេតុស្តីពីនីតិវិធីបង្ហាញខ្លួនភ្លាម

ក្រមនីតិវិធីព្រហ្មទណ្ឌថ្មី នៃព្រះរាជាណាចក្រកម្ពុជាបានបង្កើតមធ្យោបាយថ្មីមួយទៀតហៅថា នីតិវិធីបង្ហាញខ្លួនភ្លាម ដែលផ្តល់សិទ្ធិអំណាចឱ្យតំណាងអយ្យការអាចប្តឹងសុំចោទប្រកាន់ទៅឱ្យយុត្តាធិកាជំនុំជម្រះធ្វើការជំនុំជម្រះចំពោះអំពើដែលតំណាងអយ្យការយល់ថាជាបទល្មើសតែម្តង។

កាលណាតំណាងអយ្យការសម្រេចប្រើនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម សេចក្តីសម្រេចនោះមានអានុភាពបញ្ជាទៅដល់កម្លាំងសាធារណៈ ដែលមានសមត្ថកិច្ចឱ្យនាំខ្លួនជនជាប់ចោទចូលបង្ហាញនៅមុខតុលាការជាន់ដំបូងភ្លាម បន្ទាប់ពីផ្ទៀងផ្ទាត់អត្តសញ្ញាណជនជាប់ចោទរួចរាល់ហើយតុលាការដែលទទួលបន្ទុកជំនុំជម្រះត្រូវបើកសវនាការនៅថ្ងៃនោះតែម្តង។

នីតិវិធីបង្ហាញខ្លួនភ្លាមនេះគឺជានីតិវិធីថ្មី ដែលស្តែងឱ្យឃើញអំពីការបង្កើនល្បឿនចំពោះចំណាត់ការរឿងក្តីរបស់ស្ថាប័នតុលាការ ដែលជម្រុញឱ្យការស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋបានឆាប់រហ័ស។ ប៉ុន្តែពេលខ្លះមានការយល់ឃើញថា ការធ្វើឱ្យឆាប់រហ័សពេកក៏បានប៉ះពាល់ដល់សិទ្ធិរបស់ភាគីនៃរឿងក្តីផងដែរ។ ហេតុដូច្នេះហើយទើបច្បាប់បានបញ្ញត្តិអំពីលក្ខខណ្ឌមួយចំនួន ដែលតម្រូវឱ្យអ្នកអនុវត្តត្រូវតែគោរពផងដែរ។

### ក. លក្ខខណ្ឌដើម្បីប្រើនីតិវិធីបង្ហាញខ្លួនភ្លាម

តំណាងអយ្យការ អាចប្រើនីតិវិធីបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទចូលបង្ហាញខ្លួនភ្លាមបាន លុះត្រាតែសំណុំរឿងក្តីដែលខ្លួនទទួលបាននោះ បំពេញតាមលក្ខខណ្ឌទាំងបួនដែលបញ្ញត្តិនៅក្នុងមាត្រា ៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

+ លក្ខខណ្ឌបទល្មើស

តំណាងអយ្យការអាចប្រើនីតិវិធីបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទទៅបង្ហាញខ្លួនបាន លុះត្រាតែអំពើដែលប្រព្រឹត្តនោះគឺជាបទល្មើសជាក់ស្តែង[101] ។ បទល្មើសជាក់ស្តែងមានប្រភេទជាបទមជ្ឈិមដែលអប្បបរមានៃការផ្តន្ទាទោសយ៉ាងតិច០១ឆ្នាំ ឬ អតិបរមានៃការផ្តន្ទាទោសយ៉ាងច្រើនក្រោម ឬ ស្មើ ០៥ ឆ្នាំ។ បទល្មើសជាក់ស្តែងដែលបំពេញលក្ខខណ្ឌមានបញ្ញត្តិក្នុងមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលផ្តល់សិទ្ធិអំណាចឱ្យតុលាការជំនុំជម្រះអាចចេញ ដីកាបង្គាប់ឱ្យឃុំខ្លួនជាបណ្តោះអាសន្នចំពោះជនជាប់ចោទនៅក្នុងសវនាការបាន។

នីតិវិធីបង្ហាញខ្លួនភ្លាមនេះអាច ប្រើបានតែចំពោះករណីជាបទល្មើសជាក់ស្តែងហើយដែលជនជាប់ចោទកំពុងស្ថិតនៅក្នុងការឃាត់ខ្លួនចំពោះបទល្មើសនោះតែប៉ុណ្ណោះ។ ក្នុងករណីផ្សេងទៀតដែលក្រៅពីករណីខាងលើនេះ តំណាងអយ្យការអាចធ្វើនីតិវិធីប្តឹងសុំឱ្យបើកការស៊ើបសួរតាមរយៈនីតិវិធីធម្មតា ឬ នីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់។

+ លក្ខខណ្ឌចំពោះការផ្តន្ទាទោស

លក្ខខណ្ឌចាំបាច់ទីពីរដែលតម្រូវឱ្យមាន គឺត្រូវតែជាបទល្មើសមជ្ឈិមដែលអតិបរមានៃការផ្តន្ទាទោសចំពោះបទល្មើសនោះត្រូវដាក់ពន្ធនាគារយ៉ាងតិច០១(មួយ)ឆ្នាំ និងអតិបរមានៃការផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងច្រើន ០៥(ប្រាំ)ឆ្នាំ[102]។

មូលទោសនៃមាត្រា៣៨៤នៃក្រមព្រហ្មទណ្ឌ "បទបន្លំ" បញ្ញត្តិឱ្យផ្តន្ទាទោសដាក់ពន្ធនាគារពី០៦ថ្ងៃ ទៅ ០៣ខែ និងពិន័យជាប្រាក់ពី១០០.០០០ (មួយសែន)រៀលទៅ ៥០០.០០០(ប្រាំសែន)រៀល។ មានសំណួរសួរថា៖ ក្នុងករណីទទួលបានសំណុំរឿង "បទបន្លំ" តើតំណាងអយ្យការអាចប្រើនីតិវិធីបង្ហាញខ្លួនភ្លាមបានដែរឬទេ?

អតិបរមានៃការផ្តន្ទាទោសដាក់ពន្ធនាគារនៃបទបន្លំ មានរយៈពេលត្រឹមតែ០៣ខែប៉ុណ្ណោះហេតុដូច្នេះតំណាងអយ្យការមិនអាចប្រើនីតិវិធីបង្ហាញខ្លួនភ្លាមចំពោះករណីនេះឡើយ។ ព្រោះលក្ខខណ្ឌចាំបាច់ដែលតម្រូវឱ្យតំណាងអយ្យការ អាចប្រើនីតិវិធីបង្ហាញខ្លួនភ្លាមបានលុះត្រាតែអតិបរមានៃការផ្តន្ទាទោសចំពោះបទល្មើសយ៉ាងតិចមានរយៈពេល ០១ឆ្នាំ។

+ លក្ខខណ្ឌអាយុ

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដែលបានពន្យល់ថា បុគ្គលដែលអាចទទួលខុសត្រូវព្រហ្មទណ្ឌបានលុះត្រាតែជននោះដល់នីតិភាព។ ហើយនីតិភាពដែលកំណត់យកនៅក្នុងក្រមព្រហ្មទណ្ឌគឺមានអាយុចាប់

---

[101] មាត្រា៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ១៤

[102] មាត្រា៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ ១៤

ពី១៨ឆ្នាំឡើងទៅ[103]។ ក៏ប៉ុន្តែក្រមនេះក៏បានបញ្ញត្តិផងដែរថាតុលាការព្រហ្មទណ្ឌនៅតែអាចប្រកាសអំពីទណ្ឌកម្មទៅលើអនីតិជននោះបានដែរ ក្នុងករណីដែលគេមានអាយុដល់១៤ឆ្នាំហើយ ប្រសិនបើគេបានទៅប្រព្រឹត្តបទល្មើស។ ការប្រកាសអំពីទណ្ឌកម្មទៅលើអនីតិជន ត្រូវតែផ្អែកទៅលើកាលៈទេសៈនៃបទល្មើស ឬ បុគ្គលិកលក្ខណៈរបស់ អនីតិជននោះតម្រូវ។ ចំពោះការអនុវត្តជាក់ស្តែងតុលាការតែងតែប្រើវិធានការអប់រំណែនាំចំពោះការប្រព្រឹត្តបទល្មើសតូចតាចរបស់អនីតិជន[104]។

ចំណុចទី៣ មាត្រា ៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិថាតំណាងអយ្យការអាចបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទចូលទៅបង្ហាញខ្លួនភ្លាម នៅចំពោះមុខតុលាការជាន់ដំបូងឱ្យធ្វើការជំនុំជម្រះភ្លាមៗបានប្រសិនបើជនជាប់ចោទនោះគឺជានីតិជន។

+ លក្ខខណ្ឌសំណុំរឿង

លក្ខខណ្ឌមួយទៀតដែលតម្រូវឱ្យមានដើម្បីបើកផ្លូវឱ្យតំណាងអយ្យការ អាចប្រើនីតិវិធីបង្ហាញខ្លួនភ្លាមបាន គឺជាលក្ខខណ្ឌនៃសំណុំរឿងមានន័យថាលុះត្រាតែសំណុំរឿងនោះមានលក្ខណៈគ្រប់គ្រាន់ល្មមអាចជំនុំជម្រះបានទើប តំណាងអយ្យការអាចបញ្ជូនសំណុំរឿងនោះទៅជំនុំជម្រះភ្លាមបាន[105]។

### ខ. នីតិវិធីនៃការបង្ហាញខ្លួនភ្លាម

នៅពេលមន្ត្រីនគរបាលយុត្តិធម៌បានបញ្ជូនសំណុំរឿង និង បញ្ជូនខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួនមកឱ្យតំណាងអយ្យការ តំណាងអយ្យការអាចបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទចូលទៅបង្ហាញខ្លួននៅមុខតុលាការជាន់ដំបូងបាន បន្ទាប់ពីបានពិនិត្យឃើញថាសំណុំរឿងក្តីព្រហ្មទណ្ឌនោះបានបំពេញគ្រប់លក្ខខណ្ឌដែលមានបញ្ញត្តិនៅក្នុងមាត្រា៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

កាលណាសម្រេចថាត្រូវប្រើនីតិវិធីបង្គាប់ឱ្យបង្ហាញខ្លួនភ្លាម តំណាងអយ្យការត្រូវពិនិត្យអត្តសញ្ញាណបុគ្គលដែលគេបញ្ជូនមកឱ្យខ្លួន ឱ្យដំណឹងដល់ជននោះអំពីរឿងរ៉ាវ និងបទល្មើសដែលចោទប្រកាន់ និងប្រាប់អំពីសិទ្ធិដល់ជននោះថាខ្លួនអាចពឹងមេធាវីការពារខ្លួនបាន។ តំណាងអយ្យការទទួលស្តាប់ចម្លើយ ក្នុងករណីបុគ្គលដែលនឹងត្រូវនាំទៅបង្ហាញខ្លួនភ្លាមនោះចង់និយាយ។ តំណាងអយ្យការគ្រាន់តែធ្វើការកត់សម្គាល់ ចំពោះចម្លើយដែលជននោះបានរៀបរាប់តែប៉ុណ្ណោះ។

តំណាងអយ្យការ ធ្វើបណ្តឹងសុំឱ្យជំនុំជម្រះទៅយុត្តាធិការជំនុំជម្រះនៃតុលាការជាន់ដំបូងតាមរយៈកំណត់ហេតុស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម។ ក្នុងករណីសម្រេចថាត្រូវប្រើនីតិវិធីបង្ហាញខ្លួនភ្លាម តំណាង

---

[103] មាត្រា៣៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ ទំព័រ១១

[104] មាត្រា៣៩ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ ទំព័រ១២

[105] មាត្រា៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ១៤

អយ្យការកំណត់កាលបរិច្ឆេទនៃសវនាការ នៅក្នុងកំណត់ហេតុស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាមនោះតែម្តង។ បន្ទាប់មកទៀតតំណាងអយ្យការត្រូវកោះហៅជនរងគ្រោះ សាក្សី អ្នកបកប្រែ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ដើមបណ្តឹងរដ្ឋប្បវេណីឱ្យចូលរួមសវនាការផងដែរ[106]។

នីតិវិធីបង្ហាញខ្លួនភ្លាមនេះ បានផ្លាស់ប្តូរឋានៈបុគ្គលដែលបញ្ជូនមកនោះទៅជាជនជាប់ចោទ។ ជនជាប់ចោទត្រូវបង្ខាំងទុកដោយមានកងកម្លាំងការពារ រហូតដល់សាមីខ្លួនចូលទៅបង្ហាញខ្លួននៅចំពោះមុខតុលាការជាន់ដំបូង។ តុលាការដែលទទួលបានបណ្តឹងតាមនីតិវិធីបង្ហាញខ្លួនភ្លាមនេះត្រូវបើកសវនាការជំនុំជម្រះលើអង្គសេចក្តីនៅក្នុងថ្ងៃនោះតែម្តង។ លើកលែងតែជនជាប់ចោទសុំរយៈពេល ឬ ប្រសិនបើតុលាការយល់ឃើញថារឿងក្តីមិនទាន់អាចជំនុំជម្រះភ្លាមៗបាន។

នៅមុនពេលចាប់ផ្តើមដំណើរការជំនុំជម្រះ តុលាការជាន់ដំបូងត្រូវធ្វើរបាយការណ៍សង្ខេបអំពីរឿងរ៉ាវដែលតំណាងអយ្យការបានចោទប្រកាន់ ហើយប្រាប់ជនជាប់ចោទអំពីសិទ្ធិរបស់ខ្លួនដែលអាចមានមេធាវីការពារ និងប្រាប់អំពីសិទ្ធិអាចស្នើសុំរយៈពេល ដើម្បីរៀបចំខ្លួនមុនពេលទទួលបានការជំនុំជម្រះ។ តុលាការជំនុំជម្រះអាចចេញសាលក្រមមុនអង្គសេចក្តី ដើម្បីផ្តល់រយៈពេលឱ្យជនជាប់ចោទចំនួន០២(ពីរ) សប្តាហ៍ដើម្បីរៀបចំខ្លួន។ សាលក្រមមុនអង្គសេចក្តីនេះ ក៏ត្រូវសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្នចំពោះជនជាប់ចោទ ដោយផ្អែកតាមមូលហេតុដែលមានបញ្ញត្តិនៅក្នុងមាត្រា២០៥នៃក្រមនីតិវិធីព្រហ្មទណ្ឌផងដែរ។

សាលក្រមលើអង្គសេចក្តីត្រូវប្រកាសភ្លាម បន្ទាប់ពីបញ្ចប់ការពិភាក្សាដេញដោលនៅក្នុងសវនាការ ឬត្រូវតែប្រកាសក្នុងរយៈមិនលើសពី០២(ពីរ)សប្តាហ៍ គិតចាប់ពីថ្ងៃដែលជនជាប់ចោទចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ។ ក្នុងករណីជនជាប់ចោទដែលស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្នមិនទទួលបានការសម្រេចលើអង្គសេចក្តីក្នុងរយៈពេលនោះទេ ជនជាប់ចោទត្រូវតែមានសេរីភាពដោយពេញច្បាប់[107]។

ប្រសិនបើតុលាការដែលបានទទួលបណ្តឹងតាមនីតិវិធីបង្គាប់ឱ្យបង្ហាញខ្លួនភ្លាម យល់ឃើញថាលក្ខខណ្ឌនៃមាត្រា៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌមិនបានបំពេញទេ ឬ ក៏ដោយសារភាពសាំញ៉ាំនៃរឿងក្តីតម្រូវជាចាំបាច់ឱ្យធ្វើការស្រាវជ្រាវបន្ថែមទៀត តុលាការត្រូវបញ្ជូនសំណុំរឿងទៅតំណាងអយ្យការឱ្យបើកការស៊ើបសួរវិញ។ តំណាងអយ្យការប្តឹងសុំទៅចៅក្រមស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ហើយជនជាប់ចោទត្រូវតែនាំទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរនៅថ្ងៃនោះតែម្តង បើមិនដូច្នោះទេជនជាប់ចោទត្រូវតែទទួលបានការដោះលែងនៅថ្ងៃនោះតែម្តង។

---

[106] មាត្រា២៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ៩៦

[107] មាត្រា៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ១៤

**គ. អានុភាពនៃកំណត់ហេតុបង្ហាញខ្លួនភ្លាម**

+ ឱ្យតុលាការបើកសវនាការនៅថ្ងៃនោះតែម្តង

តុលាការជាន់ដំបូង ដែលបានទទួលបណ្តឹងតាមរយៈកំណត់ហេតុស្តីពីការបង្ហាញខ្លួនភ្លាមត្រូវតែបើកសវនាការជំនុំជម្រះនៅថ្ងៃនោះតែម្តង។ ចំពោះកំណត់ហេតុស្តីពីការបង្ហាញខ្លួនភ្លាមអាចធ្វើទៅបានលុះត្រាតែបទល្មើសនោះ ជាបទលល្មើសឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង ហើយជននោះជានីតិជន និងបទល្មើសមានធាតុផ្សំព្រមទាំងលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបាន។

+ ត្រូវតែចេញសាលក្រមនៅថ្ងៃនោះតែម្តង

តុលាការជាន់ដំបូងនោះត្រូវតែចេញសាលក្រមលើអង្គសេចក្តីនៅថ្ងៃនោះតែម្តង លើកលែងតែជនជាប់ចោទសុំរយៈពេលដើម្បីរៀបចំការពារខ្លួន ឬ បើតុលាការយល់ថាសំណុំរឿងក្តីមិនទាន់អាចជំនុំជម្រះភ្លាមៗបានទេ ទើបតុលាការអាចចេញសាលក្រមមុនអង្គសេចក្តី ហើយលើកសវនាការទៅពេលក្រោយវិញបាន[108]។

+ អានុភាពដែលនាំឱ្យព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបអង្កេត

ប្រសិនបើតុលាការដែលបានទទួលបណ្តឹង តាមនីតិវិធីបង្គាប់ឱ្យបង្ហាញខ្លួនភ្លាមយល់ថាលក្ខខណ្ឌនៃមាត្រា៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌមិនបានបំពេញទេ ឬ ដោយសារតែភាពស្មុគស្មាញនៃរឿងក្តីដែលទាមទារជាចាំបាច់ត្រូវធ្វើការស្រាវជ្រាវបន្ថែម តុលាការត្រូវបញ្ជូនសំណុំរឿងទៅឱ្យព្រះរាជអាជ្ញាដើម្បីប្តឹងសុំឱ្យបើកការស៊ើបអង្កេត។

ជនជាប់ចោទត្រូវនាំទៅបង្ហាញខ្លួន នៅចំពោះមុខចៅក្រមស៊ើបសួរនៅក្នុងថ្ងៃនោះតែម្តង។ ផ្អែកតាមករណីនេះ ព្រះរាជអាជ្ញាគ្មានជម្រើសអ្វីក្រៅពីការចោទប្រកាន់បញ្ជូនសំណុំរឿងឱ្យបើកការស៊ើបសួរនោះឡើយ[109]។

+ អានុភាពអាចឱ្យឃុំខ្លួនបណ្តោះអាសន្ន

ក្នុងករណីជនជាប់ចោទសុំរយៈពេលដើម្បីរៀបចំការពារខ្លួន ឬ បើតុលាការយល់ថាសំណុំរឿងក្តីមិនទាន់អាចជំនុំជម្រះភ្លាមៗបានទេ នោះតុលាការត្រូវលើកពេលសវនាការទៅពេលក្រោយទៀត។ ហើយតុលាការអាចបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្នតាមសាលក្រមដែលមានសំអាងហេតុ[110]។

## ផ្នែកទី៤៖ ការបញ្ចប់មុខងារជាព្រះរាជអាជ្ញា និង ករណីការអនុវត្តជាក់ស្តែង

### កថាខណ្ឌទី១៖ ករណីការអនុវត្តជាក់ស្តែង

នៅក្នុងការអនុវត្តជាក់ស្តែងរបស់ព្រះរាជអាជ្ញា ចំពោះការចោទប្រកាន់ជនល្មើស ក៏ដូចជានៅក្នុងរឿងក្តី

[108] មាត្រា៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ១៤

[109] មាត្រា៣០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័រ៩៩

[110] មាត្រា៣០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ទំព័៩៩

នីមួយៗ គឺពិតជាមានភាពប្រែប្រួល និងបត់បែនទៅតាមកាលៈទេសៈ ដែលពេលខ្លះអាចនឹងប្រាសចាកអំពីបទប្បញ្ញត្តិ ក៏ដូចជាទៅតាមនីតិវិធីច្បាប់។ ចំពោះការអនុវត្តជាក់ស្តែងរបស់ព្រះរាជអាជ្ញា យើងសង្កេតឃើញតែងតែមានកត្តាពីរកើតឡើងចំពោះពួកគាត់គឺៈ

### ១.១. បញ្ហាដែលកើតមានចំពោះព្រះរាជអាជ្ញា

ដូចដែលបានរៀបរាប់ពីខាងលើរួចមកស្តីអំពី តួនាទី ភារកិច្ច មុខងារ របស់ព្រះរាជអាជ្ញាក្នុងរឿងក្តីព្រហ្មទណ្ឌ ដែលព្រះរាជអាជ្ញា គឺដើរតួនាទីជាអ្នកធ្វើការចោទប្រកាន់ចំពោះជនណាម្នាក់ នៅក្នុងបទល្មើសប្រភេទណាមួយក្នុងបទល្មើសព្រហ្មទណ្ឌ។ ហើយបញ្ហាប្រឈម ដែលតែងតែកើតមានចំពោះព្រះរាជអាជ្ញា គឺរួមមានដូចជាៈ

- **ការចុះទៅដល់ទីតាំងផ្ទាល់ៈ** នៅពេលមានបទល្មើសកើតឡើង ព្រះរាជអាជ្ញា តែងតែចុះទៅកាន់ទីតាំងកើតហេតុដោយផ្ទាល់ ដើម្បីធ្វើការឃាត់ខ្លួន និងចាប់ខ្លួនជនល្មើស ដើម្បីដំណើរការនីតិវិធីនៃការចោទប្រកាន់ក្នុងអំឡុងពេលនោះហើយដែលព្រះរាជអាជ្ញា អាចនឹងជួបហានិភ័យដល់ខ្លួន ក៏ដូចជាត្រូវជួបប្រទះបញ្ហាជាមួយនឹងជនល្មើស ឬ ក៏អ្នកដែលពាក់ព័ន្ធ ជាហេតុធ្វើឱ្យព្រះរាជអាជ្ញាមានការលំបាកជាខ្លាំងក្នុងការចាប់ខ្លួនជនប្រព្រឹត្តបទល្មើសយកមកចោទប្រកាន់។

- **ការសហការជាមួយមន្ត្រីនគរបាលយុត្តិធម៌ៈ** ដូចដែលបានដឹងហើយថា បទល្មើសមួយតែងតែកើតឡើងក្នុងដែនដីណាមួយជាក់ជាពុំខាន ដូច្នេះព្រះរាជអាជ្ញា ត្រូវការអាជ្ញាធរដែនដីនោះសហការជាមួយ ដើម្បីបំពេញការងារ។ តែផ្ទុយទៅវិញ ប្រសិនបើអាជ្ញាធរនៃដែនដីនោះ ធ្វើព្រងើយកន្តើយ មិនព្រមសហការ ហើយមិនយកចិត្តទុកដាក់ចំពោះការតាមចាប់ខ្លួនជនល្មើសនោះទេ គឺពិតជាច្បាស់ណាស់ថា ព្រះរាជអាជ្ញា ប្រាកដជាពិបាកក្នុងការបំពេញការងាររបស់ខ្លួន។

- **វប្បធម៌នៃការអន្តរាគមន៍ៈ** ចំពោះវប្បធម៌អន្តរាគមន៍ គឺតែងតែកើតមានជារឿយៗ ចំពោះប្រជាពលរដ្ឋខ្មែរយើង ជាពិសេសចំពោះអ្នកដែលមានលុយ មានអំណាច មុខងារ តួនាទីធំៗ ដែលតែងតែប្រព្រឹត្តិបទល្មើសហើយ តែបែរជាមិនត្រូវបានទទួលការចោទប្រកាន់ ឬ ចោទប្រកាន់មិនស្មើភាពជាមួយនឹងជនល្មើសធម្មតា។ កត្តានេះហើយ ដែលធ្វើឱ្យព្រះរាជអាជ្ញា ជួបប្រទះការលំបាកអាស្រ័យដោយមានការជ្រៀតជ្រែក ឬ ការស្នើសុំពីជនអ្នកមានអំណាចជាដើម។

- **បញ្ហាសន្តិសុខផ្ទាល់ខ្លួនៈ** បញ្ហាសន្តិសុខផ្ទាល់ខ្លួន ក៏ដូចជាសន្តិសុខគ្រួសារ វាជារឿងសំខាន់ ព្រោះថាព្រះរាជអាជ្ញា ជាអ្នកធ្វើការចោទប្រកាន់ជនណាម្នាក់ ដែលជាហេតុធ្វើឱ្យជននោះមានការខឹងសម្បា ចងគំនុំគុំគួន និងបក្សពួកសាច់ញាតិរបស់គេមានការស្អប់ខ្ពើម តាមសងសឹកជាដើម ដែលអាចធ្វើឱ្យព្រះរាជអាជ្ញា មានការភ័យខ្លាចចំពោះសុវត្ថិភាពផ្ទាល់ខ្លួនរបស់ពួកគាត់ ក៏ដូចជាគ្រួសារផងដែរ។

### ១.២. ដំណោះស្រាយចំពោះបញ្ហាប្រឈមរបស់រាជអាជ្ញា

ចំពោះបញ្ហា ដែលតែងតែកើតមានក្នុងសង្គមជាតិយើង ជាពិសេសដែលកើតមានចំពោះព្រះរាជអាជ្ញា នៅតាមសាលាដំបូងរាជធានី-ខេត្ត ក្នុងប្រទេសកម្ពុជា គឺពិតជាមានការលំបាកណាស់ សម្រាប់ធ្វើការដោះស្រាយ។ ដើម្បីបានជាដំណោះស្រាយខ្លះក្នុងការជួយសម្រួលដល់បញ្ហាដែលកើតមានចំពោះព្រះរាជអាជ្ញា គឺយើងទាំងអស់គ្នាត្រូវគោរពទៅតាមនីតិវិធីច្បាប់ដែលមានចែងជាធរមាន ក៏ដូចជាបន្តខិតខំប្រឹងប្រែអនុវត្តច្បាប់ ឱ្យបានល្អទាំងអស់គ្នា។ ដែលកត្តាទាំងនេះ គឺត្រូវការ ការចូលរួមយ៉ាងចិត្តទុកដាក់អំពីសំណាក់ស្ថាប័នពាក់ព័ន្ធ ដែលមានដូចជា៖

**-ការយកចិត្តទុកពីសំណាក់ស្ថាប័នសាមី៖** ស្ថាប័នសាមី គឺជាអ្នកមើលការខុសត្រូវដោយផ្ទាល់ទៅលើការបំពេញការងាររបស់មន្ត្រីក្រោមឱវាទ ដូច្នេះប្រសិនបើមានបញ្ហាអ្វីកើតឡើង គឺត្រូវតែជួយរកដំណោះស្រាយ ក៏ដូចជាជួយរកវិធីទប់ស្កាត់ កុំឱ្យបញ្ហានោះកើតមានឡើងបន្តទៀត។

**-ការរួមសហការគ្នារវាងនគរបាលយុត្តិធម៌ជាមួយនឹងព្រះរាជអាជ្ញា៖** ដូចដែលបានដឹងហើយថាមន្ត្រីនគរបាលយុត្តិធម៌ គឺជាជំនួយដល់ព្រះរាជអាជ្ញា ក្នុងការបង្ក្រាបបទល្មើស ស៊ើបអង្កេតបទល្មើសក៏ដូចជាតាមចាប់ជនល្មើស យកមកផ្តន្ទាទោសទៅតាមច្បាប់ដែលបានកំណត់។ ដូច្នេះហើយ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើការយ៉ាងស្អិតល្មួតជាមួយព្រះរាជអាជ្ញា ហើយនៅក្នុងករណីដែលមន្ត្រីនគរបាលពុំបានយកចិត្តទុកដាក់នោះទេ នឹងធ្វើឱ្យមានការពិបាកដល់ព្រះរាជអាជ្ញា ជាពិសេសប្រសិនបើ មានការឃុបឃិតជាមួយនឹងមន្ត្រីនគរបាលណាមួយទៀតនោះ ច្បាស់ជាកាន់តែពិបាកទៀតហើយអាស្រ័យហេតុនេះ គឺត្រូវការការរួមសហការគ្នាយ៉ាងល្អប្រសើរ។

**-ការលុបបំបាត់នូវវប្បធម៌អន្តរាគមន៍៖** បញ្ហាដែលកើតមានចម្បងចំពោះព្រះរាជអាជ្ញា គឺអាស្រ័យដោយមានវប្បធម៌អន្តរាគមន៍ពីសំណាក់អ្នកមានអំណាច មានបុណ្យសក្តិ មានខ្នងបង្អែកក៏ដូចជា អ្នកមានលុយជាដើម ដែលជាហេតុធ្វើមានការរាំងស្ទះដល់ការបំពេញការងាររបស់ព្រះរាជអាជ្ញាជាដើម។

យ៉ាងណាមិញ ដើម្បីឱ្យមានយុត្តិធម៌ដល់ការអនុវត្តច្បាប់ និងមិនឱ្យកកស្ទះនូវសំណុំរឿងព្រះរាជអាជ្ញាខ្លួនឯង ក៏មិនត្រូវមើលឃើញតែអំពីផលប្រយោជន៍ដល់ខ្លួននោះទេ។ ជាចុងក្រោយ ដើម្បីធ្វើឱ្យស្ថាប័នអយ្យការមានភាពងាយស្រួលក្នុងការបំពេញការងារ គឺគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវចូលរួមសហការគ្នាឱ្យបានល្អ ដើម្បីលុបបំបាក់នូវអំពើអាក្រក់នានាដែលតែងតែកើតមានក្នុងស្ថាប័ន តុលាការ ក៏ដូចជាក្នុងសង្គមជាតិទាំងមូល។

## កថាខណ្ឌទី២៖ ការបញ្ចប់មុខងារជាព្រះរាជអាជ្ញា

### ២.១. ការដាក់ទណ្ឌកម្ម

នៅក្នុងបញ្ញត្តិនៃជំពូកទី២ (ក្រមចៅ) ផ្នែកទី១០ (ទណ្ឌកម្មវិន័យ) នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការដែលអនុវត្តចំពោះចៅក្រម ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះព្រះរាជអាជ្ញា។ ដោយក្នុងនោះដែរ មាត្រា៥៤ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និង ព្រះរាជអាជ្ញាបានចែងដូច្នេះថា៖

កំហុសរបស់ព្រះរាជអាជ្ញា ក្នុងការបំពេញកាតព្វកិច្ចវិជ្ជាជីវៈ និងការធ្វើឱ្យប៉ះពាល់ដល់កិត្តិយស សីលធម៌ ស្អាតស្អំ និងសេចក្ដីថ្លៃថ្នូរប្រាសចាកពីក្រមសីលធម៌របស់ចៅក្រម និងព្រះរាជអាជ្ញានាំឱ្យមានទណ្ឌកម្មខាងវិន័យ តាមបទប្បញ្ញត្តិនៃច្បាប់នេះ។ ប៉ុន្តែ ការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ចៅក្រម និងព្រះរាជអាជ្ញាក្នុងការអនុវត្តច្បាប់ មិនត្រូវចាត់ទុកថាជាកំហុសខាងវិន័យឡើយ។

ទណ្ឌកម្មខាងវិន័យ មិនមែនជាឧបសគ្គដល់ការធ្វើបណ្ដឹងអាជ្ញាទេ ប្រសិនបើមានបទល្មើសណាមួយត្រូវបានប្រព្រឹត្ត។

ទណ្ឌកម្មខាងវិន័យមាន ២ ថ្នាក់គឺៈ

- **ទណ្ឌកម្មថ្នាក់ទី១**

  ក. ការស្ដីបន្ទោសដោយផ្ទាល់មាត់

  ខ. ការស្ដីបន្ទោសដោយចុះក្នុងសំណុំលិខិតផ្ទាល់ខ្លួន

  គ. ការផ្អាកមិនឱ្យចុះឈ្មោះក្នុងតារាងដំឡើងថ្នាក់ ឬ ឋានន្តរសក្តិមួយរយៈ តែមិនត្រូវឱ្យលើសពី០២ឆ្នាំទេ ឬ លុបឈ្មោះចេញពីតារាងដំឡើងថ្នាក់ ឬ ឋានន្តរសក្តិវិញ ក្នុងករណីដែលមានចុះឈ្មោះរួចហើយ។

- **ទណ្ឌកម្មថ្នាក់ទី២**

  ក. ការផ្លាស់ដោយបង្ខំ អាចតម្រូវឱ្យទទួលការបណ្ដុះបណ្ដាលបន្ថែម

  ខ. ការព្យួរពីការងារមិនឱ្យមានបៀវត្ស ក្នុងរយៈពេលមិនឱ្យលើសពី០១ឆ្នាំ

  គ. ការបន្ថយមួយថ្នាក់ ឬ ច្រើនថ្នាក់ ឬ បន្ថយឋានន្តរសក្តិ

  ឃ. ការដាក់ឱ្យចូលនិវត្តន៍ដោយបង្ខំ

  ង. ការបញ្ឈប់ពីមុខងារដោយបង្ខំ

  ច. ការបណ្ដេញចេញពីក្របខណ្ឌ។

ទណ្ឌកម្មថ្នាក់ទី២ ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ បន្ទាប់ពីមានការសម្រេចពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម[111]។

ក្នុងករណី មានការបញ្ឈប់ពីមុខងារដោយបង្ខំ ឬ ការបណ្ដេញចេញពីក្របខណ្ឌដោយអនុលោមតាមបញ្ញត្តិនៃច្បាប់នេះ សាមីខ្លួនមានសិទ្ធិទទួលយកប្រាក់ទាំងអស់ ដែលបេឡាសោធននិវត្តន៍បានកាត់លើប្រាក់បៀវត្សរបស់ខ្លួនរួចមកហើយ តាមច្បាប់ ឬ បទបញ្ជានៃបេឡាសោធននិវត្តន៍[112]។

[111] មាត្រា៥៥ នៃច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និង ព្រះរាជអាជ្ញា ឆ្នាំ២០១៤ ទំព័រ១៧

### ២.២. ការចូលនិវត្តន៍

ព្រះរាជអាជ្ញាទាំងពីរភេទ ត្រូវចូលនិវត្តន៍នៅពេលគ្រប់អាយុ ៦០ ឆ្នាំ។ ដោយឡែក ព្រះរាជអាជ្ញាទាំងអស់នៃមហាអយ្យការអមតុលាការកំពូល ដែលមានអាយុចាប់ពី ៦០ ឆ្នាំឡើងទៅ ត្រូវចូលនិវត្តន៍តាមការស្នើសុំរបស់សាមីខ្លួន។ ប៉ុន្តែនៅពេលដែលដល់អាយុ ៦៥ ឆ្នាំ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវសម្រេចអំពីការបន្តការងាររបស់ព្រះរាជអាជ្ញាទាំងអស់នៃមហាអយ្យការអមតុលាការកំពូល តាមការស្នើសុំរបស់សាមីខ្លួន។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ លើកសេចក្តីព្រាងព្រះរាជក្រឹត្យថ្វាយព្រះមហាក្សត្រអំពីកិច្ចការខាងលើនេះ[113]៕

[112] មាត្រា៥៦ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និង ព្រះរាជអាជ្ញា ឆ្នាំ២០១៤ ទំព័រ១៧

[113] មាត្រា១០១ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និង ព្រះរាជអាជ្ញា ឆ្នាំ២០១៤ ទំព័រ៣១

# សេចក្តីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

តាមរយៈលទ្ធផលនៃការស្រាវជ្រាវលើទ្រឹស្ដីគតិយុត្ត ចំពោះប្រធានបទ "**អំពីនគរបាលយុត្តិធម៌ និងអង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្ត**" នេះរួចមកបានបង្ហាញឱ្យយើងមើលឃើញថា មន្ត្រីនគរបាលយុត្តិធម៌ ពិតជាផ្នែកមួយដ៏សំខាន់មិនអាចខ្វះបាននៃស្ថាប័នតុលាការ ព្រោះថាមន្ត្រីនគរបាលយុត្តិធម៌បានដើរតួនាទីយ៉ាងសំខាន់ក្នុងការទប់ស្កាត់បទល្មើស បង្ក្រាបបទល្មើស បង្ការបទល្មើសកុំឱ្យកើតជាថ្មី ស្វែងរកជនល្មើស ថែរក្សាតម្រុយ វត្ថុតាងដែលមាន ឃាត់ខ្លួនជនល្មើស ធ្វើការសាកសួរជនល្មើស សាក្សី និងធ្វើកំណត់ហេតុ ព្រមទាំងបញ្ជូនវត្ថុតាង និងជនល្មើសទៅកាន់តំណាងអយ្យការ ហើយក៏ជាជំនួយសម្រាប់ចៅក្រមស៊ើបសួរផងដែរ។

រីឯអង្គការអយ្យការដែលស្ថិតនៅអមសាលាជម្រះក្ដីគ្រប់ជាន់ថ្នាក់វិញ ក៏បានដើរតួនាទីសំខាន់មិនអាចខ្វះបានដែរ ដែលមានភារកិច្ចការពារផលប្រយោជន៍សាធារណៈ ថែរក្សាសណ្ដាប់ធ្នាប់របៀបរៀបរយសង្គម ធានាសុំឱ្យមានការអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ ជាពិសេសគឺធ្វើការចោទប្រកាន់ជនល្មើសនៃបទល្មើសព្រហ្មទណ្ឌដោយតំណាងអយ្យការ ដែលអនុលោមទៅតាមមាត្រា ១៣១ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តិថា "មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្ដឹងអាជ្ញា" ក៏ដូចជាមាត្រា ៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌក៏បានបញ្ញត្តិដែលថា "បណ្ដឹងអាជ្ញាត្រូវអនុវត្តក្នុងនាមនៃផលប្រយោជន៍ទូទៅដោយអយ្យការ" ដែលបានបង្ហាញឱ្យឃើញកាន់តែច្បាស់ថាអង្គការ អយ្យការពិតជាដើរតួនាទីយ៉ាងសំខាន់មិនអាចខ្វះបាន ហើយថាទាំងជាអ្នកមានសិទ្ធិធ្វើបណ្ដឹងអាជ្ញា ក្នុងការចោទប្រកាន់ដើម្បីធ្វើការការពារផលប្រយោជន៍ទូទៅ។

យ៉ាងណាមិញ ទាំងស្ថាប័ននគរបាលយុត្តិធម៌ និងស្ថាប័នអយ្យការគឺជាស្ថាប័នដែលមិនអាចខ្វះបាននៅក្នុងវិស័យយុត្តិធម៌ និងសាលាជម្រះក្ដីគ្រប់ជាន់ថ្នាក់ ជាផ្នែកមួយនៃការស្វែងរកយុត្តិធម៌ជនសាធារណៈជន និងជាផ្នែកមួយអនុញ្ញាតឱ្យរឿងក្ដីព្រហ្មទណ្ឌអនុវត្តទៅបានរលូន និងយុត្តិធម៌គ្មានលំអៀង។

ជាពិសេស ដើម្បីឱ្យប្រទេសជាមួយរីកចម្រើនទៅបានលុះត្រាតែចំនួនធនជាមនុស្សកាន់តែរីកចម្រើន ហើយដើម្បីឱ្យសង្គមនោះមានធនធានមនុស្សច្រើនលុះត្រាតែសង្គមនោះមានការអភិវឌ្ឍន៍ ដើម្បីឱ្យសង្គមនោះមានការអភិវឌ្ឍន៍នោះគឺត្រូវតែឱ្យប្រជាពលរដ្ឋមានជំនឿទៅលើច្បាប់ជាមុនសិន ហើយដើម្បីឱ្យប្រជនពលរដ្ឋមានជំនឿទៅលើច្បាប់ លុះត្រាតែច្បាប់នោះបានបង្ហាញនូវភាពយុត្តិធម៌ មិនប្រកាន់វណ្ណៈ ធនធាន ទ្រព្យសម្បត្តិ ពូជសាសន៍ និន្នាការនយោបាយផ្សេងៗ ហើយច្បាប់នោះទៀតសោតត្រូវតែអនុវត្តទៅតាមគោលការណ៍នៃភាពស្មើគ្នាចំពោះមុខច្បាប់ ដែលស្របទៅនិងកតិកាសញ្ញាអន្តរជាតិស្តីពី "សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ" របស់អង្គការសហប្រជាជាតិ។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានធ្វើការស្រាវជ្រាវយ៉ាងលម្អិ ក៏ដូចជាការធ្វើសេចក្តីសន្និដ្ឋានរួចមក យើងខ្ញុំយល់ឃើញថា ការអនុវត្តច្បាប់ ក៏ដូចជាកិច្ចនៃនីតិវិធីក្នុងដំណើររឿងក្តីព្រហ្មទណ្ឌ ចាប់ពីដំណាក់កាល នគរបាលយុត្តិធម៌ រហូតដល់ដំណាក់កាល អយ្យការ ក៏ដូចជាដំណាក់កាលផ្សេងទៀត គឺប្រព្រឹត្តទៅដោយរលូន និងមានភាពប្រទាក់ក្រឡាគ្នារហូតដល់ចប់នីតិវិធី។ ក៏ប៉ុន្តែ នៅក្នុងនោះផងដែរ ចំពោះបញ្ហាមួយចំនួនក្នុងកិច្ចនីតិវិធី ក៏ដូចជាការអនុវត្តជាក់ស្តែង នៅមានចំណុចអសកម្មពាក់ព័ន្ធនឹងបញ្ហាបច្ចេកទេស ស្ថាប័ន និងការរួមសហការ ដែលជាហេតុធ្វើឱ្យមានចន្លោះប្រហោង និងយឺតយ៉ាវក្នុងការបំពេញការងារ។ ដើម្បីជាការរួមចំណែក ក្នុងការធ្វើឱ្យកាន់តែប្រសើរឡើង ក្នុងវិស័យយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា យើងខ្ញុំ ជានិស្សិតសរសេរសារណាបញ្ចប់ការសិក្សា សូមចូលរួមជាគំនិតខ្លះៗ ដើម្បីបានផ្តល់ជាអនុសាសន៍បន្ថែមទៅលើចំណុចខ្វះខាតទាំងនោះដូចជា៖

**ក. ត្រូវបំពេញកង្វះខាតឧបករណ៍ បច្ចេកទេស មធ្យោបាយប្រើប្រាស់**

- ការងារមួយចំនួនអសកម្ម ដោយសារកង្វះខាងនៃការចុះផ្ទាល់ដល់មូលដ្ឋាន និងគោលដៅឈរជើង បានធ្វើឱ្យមានភាពចន្លោះប្រហោងក្នុងការអន្តរាគមន៍នៅពេលមានបទល្មើសកើតឡើង។

- ការស៊ើបអង្កេត និងការបង្ក្រាបបទល្មើសព្រហ្មទណ្ឌវិញ មិនទាន់បានឆ្លើយតបទៅតាមសំណូមពរ និងទិសដៅផែនការការងារនៅឡើយ ជាពិសេស គឺការគ្រប់គ្រងមុខសញ្ញាក្នុងមូលដ្ឋានដូចជាមុខសញ្ញាក្មេងទំនើង ការប្រើប្រាស់គ្រឿងញៀន មុខសញ្ញាមានដីកាចាប់ខ្លួន មុខសញ្ញាសេសសល់ និងមុខសញ្ញាដោះលែងចេញពីពន្ធនាគារ។

- ខ្វះមធ្យោបាយ សម្ភារៈ ថវិកា ដើម្បីបម្រើឱ្យកិច្ចប្រតិបត្តិការស្រាវជ្រាវ ធ្វើឱ្យការងារបង្ក្រាបបទល្មើសព្រហ្មទណ្ឌមិនបានទាន់ពេលវេលា ពេលខ្លះមានមធ្យោបាយតែខ្វះប្រេង សាំង យានជំនិះ អាគុយ ភ្លើង ជាដើម។

**ខ. យន្តការពង្រឹងការអនុវត្តច្បាប់**

**- ការលុបបំបាត់អំពើពុករលួយ៖** ជាគោលការណ៍ មន្ត្រីមានសមត្ថកិច្ច មិនត្រូវយកតួនាទីរបស់ខ្លួនដែលមានទៅធ្វើការការពារបនល្បែងស៊ីសង បនស្រីពេស្យាចារ ឬកន្លែងប្រព្រឹត្តអំពើអបាយមុខ អំពើពាលា ដែលផ្ទុយនឹងច្បាប់ជាធរមានឡើយ។ មិនត្រូវយកតួនាទីទៅការពារជនល្មើស ឬក្រុមប្រព្រឹត្តបទល្មើស ឬជនប្រព្រឹត្តសកម្មភាពចាប់ជំរិត លួច ឆក់ ប្លន់ កេងសម្បត្តិជាតិ ឬកេងប្រវ័ញ្ចកម្មសិទ្ធិអ្នកដទៃ ដែលបានកាន់កាប់ស្របច្បាប់។ មិនត្រូវប្រើអំណាចគំរាមកំហែងប្រជាពលរដ្ឋ ដើម្បីការពារជនល្មើស និងប្រើប្រាស់សម្ភារៈរបស់រដ្ឋដើម្បីបម្រើផលប្រយោជន៍ខ្លួន ព្រមទាំងប្រព្រឹត្តបទល្មើសផ្សេងៗ ដែលផ្ទុយនឹងច្បាប់។ មិនត្រូវលាក់បំបាំងសំណុំរឿង ឬវត្ថុតាង ឬធ្វើការដោះដូរវត្ថុតាង ដើម្បីប្រយោជន៍បុគ្គលឡើយ។

- **ការលុបបំបាត់វប្បធម៌អន្តរាគមន៍៖** បរិបទនៃសង្គមខ្មែរបច្ចុប្បន្ន គឺតែងតែកើតមាននូវបញ្ហាអន្តរាគមន៍ជាញឹកញាប់ វាជាទម្លាប់របស់ពលរដ្ឋខ្មែរ។ អ្នកដែលមានអំណាច មានឋានៈ តួនាទីនៅក្នុងសង្គមមួយចំនួនតែងតែលូកលាន់ នៅក្នុងកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ ក៏ដូចជាតុលាការ ដែលធ្វើឱ្យការបំពេញតួនាទីមិនទាន់បានល្អប្រសើរ។ ដើម្បីលុបបំបាត់នូវបញ្ហាទាំងនេះ ចាំបាច់ត្រូវតែពង្រឹង តួនាទី ភារកិច្ច មន្ត្រីពាក់ព័ន្ធ ក្នុងការអនុវត្តច្បាប់ និងត្រូវយកគោលការណ៍ច្បាប់ជាមូលដ្ឋានគ្រឹះ។ បើមន្ត្រីណាម្នាក់ ដែលមិនបានប្រព្រឹត្តតាមច្បាប់ ត្រូវទទួលខុសត្រូវខាងវិន័យ និងដាក់ទណ្ឌកម្មជាដាច់ខាត ដោយមិនត្រូវលើលលែងឡើយ។

- **ការថលុបបំបាត់វប្បធម៌និទណ្ឌភាព៖** ការណាគ្មានយុត្តិធម៌ វានឹងមាននូវនិទណ្ឌភាព បើមាននិទណ្ឌភាពគឺគ្មានទេ ភាពស្មើគ្នាចំពោះមុខច្បាប់។

**គ. ត្រូវបណ្តុះបណ្តាលជំនាញបច្ចេកទេស និងច្បាប់**

- **ការជ្រើសរើសមន្ត្រីតុលាការ៖** ត្រូវជ្រើសរើសមន្ត្រីរាជការ ក្រឡាបញ្ជី ព្រះរាជអាជ្ញា ចៅក្រម ដើម្បីឱ្យ បង្រើការងារនៅតាមស្ថាប័នតុលាការឱ្យបានគ្រប់ចំនួន ព្រោះយើងសង្កេតឃើញថា សព្វថ្ងៃនេះ គឺមានការខ្វះខាតមន្ត្រីផ្នែកតុលាការជាច្រើន។

- **បង្កើតតុលាការតាមជំនាញ៖** នាពេលបច្ចុប្បន្ន តុលាការនៃព្រះរាជាណាចក្រកម្ពុជា គឺមិនទាន់គ្រប់តម្រូវការ និងជំនាញឯកទេសរបស់ខ្លួននោះទេ ដូចជា តុលាការពាណិជ្ជកម្ម តុលាការរដ្ឋបាលជាដើម ដែលជាហេតុធ្វើឱ្យមានភាពមមាញឹកខ្លាំងក្នុងការដោះស្រាយរឿងក្តីនីមួយៗ។

- **ការផ្សព្វផ្សាយវិស័យយុត្តិធម៌ឱ្យកាន់តែទូលំទូលាយ៖** កត្តាបណ្តុះបណ្តាល និងធ្វើការផ្សព្វផ្សាយពាក់ព័ន្ធទៅនឹងវិស័យយុត្តិធម៌ គឺមានភាពចង្អៀតនៅឡើយ មិនទាន់បានទូលំទូលាញនោះទេ ដូច្នេះត្រូវការ ការចូលរួមយ៉ាងសកម្ម អំពីសំណាក់ស្រសួងស្ថាប័ន ក៏ដូចបុគ្គលដែលមានសមត្ថកិច្ច ធ្វើយ៉ាងណា បណ្តុះបណ្តាលផ្សព្វផ្សាយច្បាប់ឱ្យដល់ប្រជាពលរដ្ឋទូទៅ ដើម្បីបានយល់ដឹងអំពីច្បាប់ជាធរមាន។

# គន្ថនិទេស

# គន្ថនិទេស

## I. អំពីរដ្ឋធម្មនុញ្ញ

ក. រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

## II. អំពីក្រម

ខ. ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

គ. ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

## III. អំពីច្បាប់

ឃ. ច្បាប់ស្តីពីព្រៃឈើ

ង. ច្បាប់ស្តីពីលក្ខខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

ច. ច្បាប់ស្តីពី ការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

ឆ. ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ចុះថ្ងៃទី២៤ តុលា ឆ្នាំ២០០៥

## IV. អំពីអនុក្រឹត្យ

ជ. អនុក្រឹត្យលេខ ៧៧ អនក្រ. ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៤ ស្តីពីភារកិច្ច និងរចនាសម្ព័ន្ធទូទៅរបស់កងរាជអាវុធហត្ថ។

ឈ. អនុក្រឹត្យលេខ ១៣៦ អនក្រ.ប.ក ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩ ស្តីពីការបង្កើតស្នងការដ្ឋានដាក់ចំណុះបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

ញ. អនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលរៀបចំឡើងវិញរចនាសម្ព័ន្ធក្របខណ្ឌចាត់តាំងបញ្ជាការដ្ឋានកងរាជអាវុធហត្ថ

ដ. អនុក្រឹត្យលេខ ២៥ អនក្រ. ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៤ ស្តីពីភារកិច្ច និងរចនាសម្ព័ន្ធទូទៅរបស់កងរាជអាវុធហត្ថ។

## V. អំពីឯកសារជាសៀវភៅ និងអត្ថបទ

ឋ. នីតិវិធីក្នុងការធ្វើសម្បថ និងពាក្យសច្ចាប្រណិធាន

ឌ. បទបញ្ជាផ្ទៃក្នុងនៃកងរាជអាវុធហត្ថ

ឍ. សារណាបញ្ចប់ការសិក្សាស្តីពី "ចំណាត់ការលើរឿងក្តីព្រហ្មទណ្ឌរបស់អង្គការអយ្យការអមសាលាដំបូង" របស់និស្សិតឈ្មោះ ផល តារាឧត្តម និង លី គីមឆាយ ជំនាន់២២ ឆ្នាំ២០១៧

ណ. សារណាបញ្ចប់ការសិក្សាស្តីពី "ដំណាក់កាលទាំង៤ នៃរឿងក្តីព្រហ្មទណ្ឌនៅសាលាដំបូងរាជធានី-ខេត្ត ករណីអនុវត្តជាក់ស្តែង និងបញ្ហាប្រឈម" របស់និស្សិតឈ្មោះ រិន ថា និង ផាត វណ្ឌ ជំនាន់១៩ ឆ្នាំ២០១៩

ត. សារណាបញ្ចប់ការសិក្សាស្តីពី "អង្គការអយ្យការ" របស់និស្សិតឈ្មោះ ផៃ ចេងសេង ជំនាន់១៦ ឆ្នាំ២០១៧

ថ. សារណាបញ្ចប់ការសិក្សាស្តីពី "អង្គការអយ្យការ" របស់និស្សិតឈ្មោះ ជា គីមសៀ និង ភិន្ទ ច័ន្ទរីណែត ជំនាន់១៧ ឆ្នាំ២០១៧

ទ. សារណាបញ្ចប់ការសិក្សាស្តីពី "ចំណាត់ការសំណុំរឿងព្រហ្មទណ្ឌរបស់អង្គការអយ្យការ" របស់និស្សិតឈ្មោះ ឈុំ លីហួរ និង កែវ គីមស៊ីង ជំនាន់១៨ ឆ្នាំ២០១៨

ធ. គោលការណ៍ណែនាំស្តីពី តួនាទីព្រះរាជអាជ្ញា អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទី៧ ចាប់ពីថ្ងៃទី២៧ ខែសីហា ដល់ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩៩ នៅប្រទេសគុយបា ទីក្រុងហាវ៉ាណា

ធ. សៀវភៅ មូលដ្ឋានច្បាប់ និងស្ថាប័នច្បាប់ របស់ឯឧត្តម ឥន យឿន បោះពុម្ពលើកទី៣

ន. សាស្ត្រាចារ្យ ឆឹង ស៊ីនៀង សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ របស់លោកសាស្ត្រាចារ្យ ឆឹង ស៊ីនៀង ឆ្នាំ ២០១៦

ប. សៀវភៅស្តីពី ប្រព័ន្ធតុលាការ របស់វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ

ផ. សៀវភៅ នីតិវីធីព្រហ្មទណ្ឌ របស់លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត ឆ្នាំ២០១៧-២០១៨

ព. សៀវភៅដំណាក់កាលក្នុងរឿងក្តីព្រហ្មទណ្ឌសម្រាប់មន្រ្តីនគរបាលយុត្តិធម៌ ឆ្នាំ២០០៩

ភ. សៀវភៅ នីតិវិធីព្រហ្មទណ្ឌ របស់ឯកឧត្តម កើត រិទ្ធ ឆ្នាំ២០១៦

ម. សៀវភៅ សមត្ថកិច្ចនគរបាលយុត្តិធម៌នៅកម្ពុជា របស់លោក សុខ ងី បេក្ខជនបណ្ឌិតជនបណ្ឌិតជំនាន់ទី១។

# ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៣

អយ្យការអម

សាលាដំបូងខេត្ត

*បន្ទាយមានជ័យ*

*លេខ៖*

# ដីកាបង្គាប់ឲ្យស៊ើបអង្កេតបឋម

✦✦✦✦✦

យើង ... ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្ត បន្ទាយមានជ័យ ។

-បានឃើញរបាយការណ៍លេខៈ .../១១ តពទ.បជ ចុះថ្ងៃទី ... ខែ ... ឆ្នាំ ២០១១ របស់សាខាកាំកុងត្រូលខេត្តបន្ទាយមានជ័យ ។

-បានឃើញសុំណុំរឿងព្រហ្មទណ្ឌលេខៈ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ២០១១ ។

-បានឃើញមាត្រា ១១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាលឲ្យប្រើតាមព្រះរាជក្រម លេខៈ នស/រកម ០៨០៧/០២៤ ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧។

**សម្រេច**

**១**-បង្គាប់ឲ្យសាខាកាំកុងត្រូលខេត្តបន្ទាយមានជ័យ បើកការស៊ើបអង្កេតបឋម លើករណីឈ្មោះ ... ហើយឲ្យឈ្មោះ ... បង់ប្រាក់ពិន័យអន្តរកាលទៅតាមនីតិវិធី។

**២**-ពេលស៊ើបអង្កេតចប់បញ្ជូនសំណុំរឿងមកអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យវិញ។

ធ្វើនៅបន្ទាយមានជ័យ ថ្ងៃទី ខែ ... ឆ្នាំ ២០១៣

ព្រះរាជអាជ្ញារង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការ**
អមសាលាដំបូង
ខេត្តបន្ទាយមានជ័យ

# កំណត់ហេតុទទួលវត្ថុតាង

ឆ្នាំពីរពាន់ដប់បី ខែ ... ថ្ងៃទី ពីរ វេលាម៉ោង ដប់ និង សូន្យ នាទី ។
យើង ...ក្រឡាបញ្ជីនៃអយ្យការ អមសាលាដំបូងខេត្តបន្ទាយមានជ័យ ។
លោក ... ជាមន្ត្រីនគរបាលយុត្តិធម៌នៃស្នងការនគរបាលខេត្តបន្ទាយមានជ័យ
ជាអ្នកប្រគល់រួមជាមួយនិងឈ្មោះ ....ឈ្មោះ ....ឈ្មោះ ...ពីបទៈជួញដូរនិងប្រើប្រាស់ដោយខុសច្បាប់នូវសាធាតុញៀន

បានពិនិត្យភិនភាគវត្ថុតាង ដែលទាក់ទងក្នុងសំណុំរឿងលេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... ឃើញដូចខាងក្រោមៈ

១-កញ្ចប់ពណ៌សបិទជិតមានស្នាមមេដៃឈ្មោះ ....ឈ្មោះ ...និងហត្ថលេខាលោក ...លោក ...និងលោក ... ។

២-ទូរស័ព្ទចំនួន ០៦ គ្រឿង មួយគ្រឿងម៉ាក់ SAMSUNG ពណ៌ខ្មៅស៊ីមពីរ(ចិន) .មួយគ្រឿងម៉ាក់NOKIA E99I ពណខ្មៅស៊ីមពីរ(ចិន) .មួយគ្រឿងម៉ាក់ NOKIA X1 ពណ៌ខ្មៅ(ចិន) .មួយគ្រឿងទៀតម៉ាក់ NOKIA ចុចពិលពណ៌ផ្កាឈូកលាយពណ៌ស (ចាស់) .មួយគ្រឿងម៉ាក់ NOKIA ចុចពិលពណ៌ខ្មៅបិទស្តុតពណ៌ទឹកប្រាក់ និងមួយគ្រឿងទៀតម៉ាក់ HUAWEI ពណ៌ខ្មៅលាយពណ៌ស។

៣-កាបូបលុយចំនួនមួយពណ៌ខៀវ(គ្មានលុយ).ដែកកេះចំនួនពីរ.កាបូបស្ពាយតូចចំនួនមួយពណ៌ប្រផេះ.សំបកប្រអប់ស្រោមអនាម័យOKចំនួនមួយ.ចង់តូចពណ៌សមួយចំនួន.បំពុងទុយយចំនួនពីរ.កំរបដបទឹកចោះដាក់ទុយយមួយ។

៤-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរចំនួនពីរ.មួយមានលេខៈ...របស់ឈ្មោះ...និងមួយទៀតមានលេខៈ... របស់ឈ្មោះ ...។

៥-លុយខ្មែរចំនួន ៥០០០០ រៀល និងលុយដុល្លារចំនួន ១០ ដុល្លារ។

៦-ម៉ូតូមួយគ្រឿងម៉ាក់ VIVA ពណ៌ខ្មៅសេរីឆ្នាំ ២០១០ គ្មានកញ្ចក់ .គ្មានកន្ទ្រក ពាក់ផ្លាក់លេខៈ ...លេខម៉ាស៊ីន ...។

បញ្ឈប់កំណត់ហេតុនេះនៅវេលាម៉ោង ដប់និងសែសិប នាទី នាថ្ងៃ ខែឆ្នាំដដែល ។

អ្នកប្រគល់ ក្រឡាបញ្ជី ជនជាប់សង្ស័យ

បានឃើញ
បន្ទាយមានជ័យ.ថ្ងៃទី ... ខែ ...ឆ្នាំ ២០១៣
**ព្រះរាជអាជ្ញារង**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

អយ្យការអម
សាលាដំបូងខេត្តពោធិ៍សាត់
*សំណុំរឿង៧ហ្មទណ្ឌ*
*លេខ...........*
*ចុះថ្ងៃទី ... ខែ... ឆ្នាំ២០១៦*

# កំណត់ហេតុស្តាប់ចម្លើយ

ឆ្នាំ ពីរពាន់ដប់ប្រាំមួយ ខែធ្នូ ថ្ងៃទីពីរ វេលាម៉ោង ដប់ និងសូន្យ នាទី។

យើង ...ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តពោធិ៍សាត់ អមដោយលោកជាក្រឡាបញ្ជី ។

យើងបានស្តាប់ចម្លើយឈ្មោះ...ជាជនសង្ស័យដោយមានលោក...ជាមេធាវីការពរ។

បានមកបង្ហាញខ្លួន នៅចំពោះមុខយើង ដែលមានអត្តសញ្ញាដូចខាងក្រោម:

នាមត្រកូល ៖ ... នាមខ្លួន ៖ ...

ភេទ: ប្រុស

កើតថ្ងៃទី ៖ អាយុ ... ឆ្នាំ

ទីកន្លែងកំណើត ៖ភូមិ...ខេត្តពោធិ៍សាត់

អាសយដ្ឋាន ៖ភូមិ...ខេត្តពោធិ៍សាត់

មុខរបរ ៖ ...

សាសនា: ព្រះពុទ្ធ

☐ នៅលីវ ឬរៀបការ ☐ ឈ្មោះប្តី ៖

សញ្ជាតិ ៖ ខ្មែរ

ឪពុកឈ្មោះ ៖ ... "រ" ម្តាយឈ្មោះ ៖ ... "រ"

អនីតិជន ☐ ឬ នីតិជន ☐

ប្រវត្តិនៃការផ្តន្ទាទោសពីមុនគ្មាន

ជននេះ ៖ ☐ ចេះនិយាយ ☐ ចេះអាន ☐ ចេះសរសេរអក្សរខ្មែរ

ជននេះ ៖ ☐ មិនចេះនិយាយ ☐ មិនចេះអាន ☐ មិនចេះសរសេរអក្សរខ្មែរ

**សួរ-ឆ្លើយ៖** នៅថ្ងៃទី... ខែ... ឆ្នាំ២០១៦ វេលាម៉ោងប្រហែលជា២១ជាង មិត្តភក្តិរបស់ខ្ញុំមានគ្នាបីនាក់ ១.ឈ្មោះ ...២.... ៣.ឈ្មោះ ... ជិះម៉ូតូ០២គ្រឿងមកបបួលខ្ញុំនៅផ្ទះ

នៅភូមិ...ខេត្តពោធិ៍សាត់ ថាទៅដុតត្រីហូប ពេលនោះខ្ញុំនិងមិត្តភក្តិរៀបចេញដំណើរ ស្រាប់តែសមត្ថកិច្ចមកដល់ ហើយបានហៅពួកខ្ញុំទាំងបួននាក់ មកអធិការដ្ឋាននគរបាល ក្រុងពោធិ៍សាត់ សមត្ថកិច្ចបានឆែកឆេរក្នុងម៉ូតូ របស់ខ្ញុំ ឃើញមានក្រដាសអាលុយមីញ៉ូម ហើយទុយយូមួយដើម និងពិនិត្យទឹកនោមខ្ញុំ ឃើញមានសារធាតុញៀន ។

**សួរ.ឆ្លើយ៖** ខ្ញុំធ្លាប់ប្រើប្រាស់ថ្នាំញៀន ហើយប្រើប្រាស់លើកចុងក្រោយមុនថ្ងៃចាប់ខ្លួនពីរឬបីថ្ងៃ ប្រើម្នាក់ឯងក្នុងផ្ទះរបស់ខ្ញុំ។ថ្នាំញៀនដែលខ្ញុំប្រើប្រាស់នេះ ទិញពីឈ្មោះ ... ណាត់យកមកឲ្យនៅផ្លូវ...ខេត្តពោធិ៍សាត់ ទិញតំលៃ៣ម៉ឺនរៀល។

**សួរ.ឆ្លើយ៖** ពួកម៉ាកបីនាក់ទៀត សមត្ថកិច្ចបានឆែកឆេរអត់ឃើញមានអីពាក់ ពន្ធ័បានឲ្យទៅផ្ទះវិញ ។

**សួរ.ឆ្លើយ៖** ខ្ញុំមិនដែលរកស៊ីជួញដូរ និងចែកចាយថ្នាំញៀនទេ។

**សួរ.ឆ្លើយ៖** នៅក្នុងថ្ងៃខែមិនចាំ ក្នុងឆ្នាំ... ពេលយប់មិនចាំម៉ោង ខ្ញុំបានជិះម៉ូតូម៉ាកស៊ីរូស អត់មានផ្លាកលេខ ចេញពីផ្ទះដើម្បីទៅទិញមីនិងបារីជក់ ពេលជិះមកដល់ស្ពានដែក (ផ្លូវរថភ្លើង) តាមផ្លូវមាត់ស្ទឹង ស្រាប់តែមានរថយន្តតូចមួយគ្រឿង បានជិះមកគៀរម៉ូតូរបស់ខ្ញុំបណ្តាលឲ្យដួល ហើយឃើញគេចុះពីលើឡានរួចស្រែកឲ្យខ្ញុំឈប់ ឃើញដូច្នេះខ្ញុំក៏រត់ចោលម៉ូតូ មកដេកផ្ទះ ។

**សួរ.ឆ្លើយ៖** ពេលបាត់ម៉ូតូខ្ញុំមិនបានប្តឹងសមត្ថកិច្ចទេ ក្រោយមកលឺដំណឹងថាម៉ូតូរបស់ខ្ញុំ នៅប៉េអឹមហើយពាក់ពន្ធ័និងថ្នាំញៀន លឺដូចឆ្នេះខ្ញុំមិនហ៊ានទៅសុំម៉ូតូវិញទេ ព្រោះខ្លាចគេចោទ ថាជួញដូរថ្នាំញៀន ។

**សួរ.ឆ្លើយ៖** ពេលខ្ញុំរត់ចោលម៉ូតូ ខ្ញុំមិនមានថ្នាំញៀនទេហើយថ្នាំញៀនដែលសមត្ថកិច្ចដកហូតបាន ខ្ញុំមិនដឹងថាជារបស់អ្នកណាឡើយ ។

*បញ្ចប់កំណត់ហេតុវេលាម៉ោង ដប់ និង សែសិបប្រាំនាទី នាថ្ងៃ ខែ ឆ្នាំ ដដែល។*

យើងបានប្រាប់ជននេះឱ្យអានឡើងវិញនូវចម្លើយទាំងអស់របស់ខ្លួន ដែលយើងបានកត់ចម្លងចូលក្នុង កំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេ ផ្តិតម្រាមដៃលើកំណត់ហេតុនេះ ។

បានអានចប់សព្វគ្រប់ ហើយជននេះមិនមានបដិសេធចំណុចណាទេ និង ចុះហត្ថលេខា ឬ ផ្តិតម្រាម ដៃជាមួយយើង ។

**អ្នកឆ្លើយ** **ក្រឡាបញ្ជី** **ព្រះរាជអាជ្ញារង**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

**សាលាដំបូង ខេត្តពោធិ៍សាត់**

**ដីកាកោះ**

*សំណុំរឿងព្រហ្មទណ្ឌលេខ ...*

*ចុះថ្ងៃទី ... ខែ ... ឆ្នាំ...*

*យើង ... តំណាងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់*

*បង្គាប់មកឈ្មោះ ...ភេទប្រុស អាយុ ... ឆ្នាំ ជាសាក្សី ។*

*ទីលំនៅបច្ចុប្បន្ននៅភូមិ...ខេត្តពោធិ៍សាត់ ។*

*ឱ្យចូលទៅកាន់អយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់*

*នៅវេលាម៉ោង២.០០រសៀល ថ្ងៃទី ... ខែ... ឆ្នាំ... ។*

*ដើម្បី* ***សួរយកចម្លើយ***

*ពីដំណើររឿង* ***បង្ក្រាបបទល្មើសព្រៃឈើ កាលពីថ្ងៃទី ... ខែ... ឆ្នាំ ... នៅចំណុច...ភូមិ...ខេត្តពោធិ៍សាត់។***

*សាមីខ្លួនត្រូវអញ្ជើញទៅឱ្យទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងនិងរឿង ខាងលើ មកជាមួយផងប្រសិនបើមាន។*

*ធ្វើនៅពោធិ៍សាត់, ថ្ងៃទី ... ខែ ... ឆ្នាំ ...*

**ព្រះរាជអាជ្ញារង**

យើង........................................................................បានប្រគល់ដីកាកោះនេះដល់

ឈ្មោះ...................................ទីលំនៅបច្ចុប្បន្ននៅភូមិ.................... ឃុំ/សង្កាត់ .......................................... ស្រុក/ខណ្ឌ................ខេត្ត/ក្រុង..........................នៅថ្ងៃទី .........ខែ..................ឆ្នាំ.....................................ហើយយើងបានប្រាប់ថា ឱ្យយកចុង ដីកានេះទៅ ប្រគល់ដល់ក្រឡាបញ្ជី នៅពេលដែលខ្លួនចូលទៅចំពោះ មុខសាលា ដំបូងខេត្តពោធិ៍សាត់។

**អ្នកទទួល** **អ្នកប្រគល់**

**ហត្ថលេខា ឬ ស្នាមមេដៃ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

********

អយ្យការអម

*សាលាដំបូងខេត្ត*

**បន្ទាយមានជ័យ**

**********

លេខ:                    អក.បជ

# ដីកាបញ្ជាស្វែងរកចាប់ខ្លួន

យើង ... ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្ត **បន្ទាយមានជ័យ**

បានឃើញ: មាត្រា ៥១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ: នស/រ កម ០៨ ០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

បានឃើញ:របាយការណ៍លេខ: ... ព.គ ចុះថ្ងៃទី... ខែ... ឆ្នាំ២០១២ ស្តីពីទណ្ឌិតឈ្មោះ ... ភេទប្រុស អាយុ ... ឆ្នាំ ពុំមានឃុំខ្លួននៅក្នុងពន្ធនាគារ (រត់គេចខ្លួន)។

## យល់ឃើញថា:

-ទណ្ឌិតឈ្មោះ ...ភេទប្រុស អាយុ... ឆ្នាំ ជាប់ចោទពីបទ: ជួញដូរគ្រឿងញៀនខុស ច្បាប់ ហើយត្រូវបានសាលាដំបូងខេត្តបន្ទាយមានជ័យ សម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ: ... ចុះថ្ងៃទី... ខែ... ឆ្នាំ២០០៣ ។

-តាមរបាយការណ៍របស់ពន្ធនាគារបានបញ្ជាក់ថា: ទណ្ឌិតរូបនេះមិនបានជាប់ឃុំនៅក្នុងពន្ធនាគារខេត្តបន្ទាយមានជ័យ (រត់គេចខ្លួន) ។

-តាមកំណត់ហេតុស្តីពីការចុះត្រួតពិនិត្យពន្ធនាគារ ចុះថ្ងៃទី... ខែ...ឆ្នាំ២០១១ បញ្ជាក់ថា ទណ្ឌិតឈ្មោះ ...នៅព្យាបាលជម្ងឺនៅប្រទេសវៀតណាម តែពុំមានកំលាំងពន្ធនាគារការពារ នោះទេ ។

-តាមមាត្រា ៥១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ជាក់ថា: ក្នុងករណីដែលអ្នកទោសរត់ចេញពីពន្ធនាគារ ឬមណ្ឌលឃុំខ្លួននោះ ព្រះរាជអាជ្ញាចេញបញ្ជាស្វែងរកចាប់ខ្លួន និងចាត់វិធានការជាបន្ទាន់ដើម្បីអនុវត្តបញ្ជាស្វែងរកចាប់ខ្លួន ។

## ហេតុដូច្នេះសម្រេច

-បង្គាប់ឲ្យមន្រ្តីនគរបាលយុត្តិធម៌ និងកងកំលាំងសាធារណៈស្រាវជ្រាវរកចាប់ខ្លួន និងនាំខ្លួនទណ្ឌិតខាងលើនេះទៅក្នុងពន្ធនាគារខេត្តបន្ទាយមានជ័យ ក្នុងរយៈពេលយ៉ាងខ្លីបំផុតដើម្បីធ្វើការឃុំខ្លួន ។

បន្ទាយមានជ័យ ថ្ងៃទី          ខែ... ឆ្នាំ២០១២

**ព្រះរាជអាជ្ញារង**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងខេត្តពោធិ៍សាត់**
លេខ.....................អយ/១៧

**លិខិតអញ្ជើញ**

**យើង** ... **តំណាងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត**

អញ្ជើញ លោក ... ភេទប្រុស ជានាយកមន្ទី... ។

ឱ្យចូលទៅកាន់អយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់

នៅវេលាម៉ោង ២.០០ រសៀល ថ្ងៃទី ... ខែ ... ឆ្នាំ ២០១៧ ។

ដើម្បី បំភ្លឺ ពីដំណើររឿង **បង្ក្រាបបទល្មើសព្រៃឈើ កាលពីថ្ងៃទី... ខែ... ឆ្នាំ ២០១៦ នៅចំណុច... ភូមិ... ឃុំ... ស្រុក... ខេត្តពោធិ៍សាត់ ។**

សាម៉ីខ្លួនត្រូវអញ្ជើញទៅឱ្យទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងនិងរឿង ខាងលើ មកជាមួយផងប្រសិនបើមាន។

ធ្វើនៅពោធិ៍សាត់, ថ្ងៃទី ... ខែ ....ឆ្នាំ ២០១៧

**ព្រះរាជអាជ្ញារង**

យើង.........................................................................បានប្រគល់ដីកាអញ្ជើញនេះដល់

ឈ្មោះ....................................ទីលំនៅបច្ចុប្បន្ននៅភូមិ.................... ឃុំ/សង្កាត់ ........................................... ស្រុក/ខណ្ឌ................ខេត្ត/ក្រុង..........................នៅថ្ងៃទី .........ខែ..................ឆ្នាំ.....................................ហើយយើងបានប្រាប់ថា ឱ្យយកចុងដីកានេះទៅ ប្រគល់ដល់ក្រឡាបញ្ជី នៅពេលដែលខ្លួនចូលទៅចំពោះ មុខសាលាដំបូងខេត្តពោធិ៍សាត់។

**អ្នកទទួល** **អ្នកប្រគល់**

**ហត្ថលេខា ឬ ស្នាមមេដៃ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

អយ្យការ អម

សាលាដំបូងខេត្ត ពោធិ៍សាត់

លេខ..................

# លិខិតជូនដំណឹង

យើង ... តំណាងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់

សូមជូនដំណឹងលោក ... អាយុ ... ឆ្នាំ មានទីលំនៅ ភូមិ.... ឃុំ... ស្រុក... ខេត្តបាត់ដំបង អោយបានជ្រាបថា:

ពាក្យបណ្តឹងរបស់លោក ... ចុះថ្ងៃទី... ខែ... ឆ្នាំ២០១៣ ដែលបាន ប្តឹងលោក ... អាយុ...ឆ្នាំមានទីលំនៅភូមិ... ឃុំ... ស្រុក... ខេត្តកំពង់ឆ្នាំង ថា: **បានបង្កគ្រោះថ្នាក់ចរាចរណ៍** ប្រព្រឹត្តនៅភូមិ... ឃុំ... ស្រុក... ខេត្តពោធិ៍សាត់ ដែលមានសំណុំរឿងព្រហ្មទណ្ឌ លេខ:... ចុះថ្ងៃទី... ខែ... ឆ្នាំ២០១៣ នោះត្រូវបានតំណាងអយ្យការតម្កល់រឿងទុកឥតចាត់ការ តាមដីការតម្កល់រឿងទុកឥតចាត់ការ លេខ:... អយ/១៦ ចុះថ្ងៃទី... ខែ... ឆ្នាំ២០១៦ ហើយ សូមលោកជ្រាប។

លោកមានសិទ្ធិប្តឹងតវ៉ារយៈពេលពីរខែគិតចាប់ពីថ្ងៃលោកបានទទួលដំណឹងនេះ។

ពោធិ៍សាត់, ថ្ងៃទី... ខែ... ឆ្នាំ ២០១៦

**តំណាងអយ្យការ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
លេខ.........................

# ដីកាតម្កល់រឿងទុកឥតចាត់ការ

យើង ...........តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ:..................ចុះថ្ងៃទី........ខែ.........ឆ្នាំ២០១.....របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងសំណុំលិខិតភ្ជាប់មកជាមួយព្រមទាំងភស្តុតាងនានា។

**១- អវត្តមានបទល្មើស**

☐ ១.១. អវត្តមានបទល្មើស

**២- ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់**

☐ ២.១. ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

**៣- មូលហេតុគតិយុត្ត**

☐ ៣.១. ការដកពាក្យបណ្តឹង

☐ ៣.២. ការលើកលែងទោសជាទូទៅ

☐ ៣.៣. មរណភាពជនល្មើស

☐ ៣.៤. ផុតអាជ្ញាយុកាល

☐ ៣.៥. និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ

☐ ៣.៦. អាជ្ញាអស់ជំនុំ

☐ ៣.៧. ការសម្របសម្រួលជាមួយរដ្ឋ

☐ ៣.៨. ការបង់ប្រាក់ពិន័យសរុប ឬពិន័យសម្របសម្រួល

☐ ៣.៩. អភ័យឯកសិទ្ធ

☐ ៣.១០. អនិយ័តភាពនៃនីតិវិធី

☐ ៣.១១. ការរួចផុតពីការទទួលខុសត្រូវរបស់ជនល្មើស[1]

**៤- ការចោទប្រកាន់មិនផ្តល់ប្រយោជន៍**

☐ ៤.១. ការស្វែងរកមិនបានផល

☐ ៤.២. ការបោះបង់ពាក្យបណ្តឹងរបស់ដើមបណ្តឹង[2]

☐ ៤.៣ ស្ថានភាពវិបល្លាសស្មារតីដែលបន្ថយនូវការដឹងខុសត្រូវ

☐ ៤-៤ ការខកខានរបស់ដើមបណ្តឹង

☐ ៤.៥. អាកប្បកិរិយារបស់ជនរងគ្រោះ

☐ ៤.៦. ជនរងគ្រោះមិនចាប់អារម្មណ៍ នឹងបទល្មើស

☐ ៤.៧. និយ័តកម្មដោយឯកឯង[3]

☐ ៤.៨. ព្យសនកម្ម ឫការរំខានតិចតួចបង្កដោយបទល្មើស

**៥- នីតិវិធីជាជម្រើសអនុវត្តដោយព្រះរាជអាជ្ញា**

☐ ៥.១. ការជួសជុលការខូចខាតដោយ/ដល់អនីតិជន

☐ ៥.២. សន្ធានកម្ម[4]

☐ ៥.៣. អចិបញ្ញាផ្តល់ការព្យាបាល

☐ ៥.៤. ជនរងគ្រោះ/ដើមបណ្តឹងបោះបង់បណ្តឹង តាមការស្នើសុំរបស់ព្រះរាជអាជ្ញា

☐ ៥.៥. និយ័តកម្មតាមសំណើររបស់ព្រះរាជអាជ្ញា

☐ ៥.៦. ការរំលឹកពីអត្ថបទច្បាប់/ការព្រមាន[5]

☐ ៥.៧. ការកំណត់ទិសដៅចំពោះរចនាសម្ព័ន្ធនៃសុខភាព នៃសង្គម ឬវិជ្ជាជីវៈ

☐ ៥.៨. ការសម្រុះសម្រួលព្រហ្មទណ្ឌ[6]

**៦- នីតិវិធីជាជម្រើសអនុវត្តដោយអាជ្ញាធរផ្សេងៗ**

---

[1]) ដូចជាមូលហេតុ វិកលចរិត ការការពារស្របច្បាប់ ការបង្ខំ ស្ថានភាពចាំបាច់

[2]) ដើមបណ្តឹងឈប់ប្តឹង

[3]) សកម្មភាពដែលជនល្មើសបានបញ្ឈប់បទល្មើស និង ស្តារស្ថានភាពឡើងវិញ

[4]) ករណីចែងដោយច្បាប់

[5]) ព្រះរាជអាជ្ញាប្រាប់អំពីអំពើដែលជាបទល្មើស តាមកំណត់ច្បាប់ និងធ្វើការព្រមានឲ្យឈប់ប្រព្រឹត្ត

[6]) ករណីចែងដោយច្បាប់

☐ ៦.១. ការចោទប្រកាន់ ឫទណ្ឌកម្មផ្សេងទៀតមិនមែនព្រហ្មទណ្ឌ

**៧-ជនល្មើសមិនត្រូវបានស្គាល់**

☐ ៧.១. ជនល្មើសមិនត្រូវបានស្គាល់

**៨-ជំនួយការអប់រំ**

☐ ៨.១. ការផ្ដល់ជំនួយការអប់រំជំនួសការចោទប្រកាន់

**ការអង្កេតផ្សេងៗ ៖**កាលពីថ្ងៃទី.......................................................................................
...................................................................................................................................................
...................................................................................................................................

**បានឃើញ:**

-កំណត់ហេតុស្ដាប់ចម្លើយដើមបណ្ដឹងឈ្មោះ

-កំណត់ហេតុស្ដាប់ចម្លើយជនសង្ស័យឈ្មោះ ។

-ពាក្យស្នើសុំដកបណ្ដឹងរបស់ឈ្មោះ ចុះថ្ងៃទី ............ខែ ............ ឆ្នាំ ............។

**យល់ឃើញថា:**

-តាមចម្លើយរបស់ដើមបណ្ដឹងឈ្មោះ

**ហេតុដូច្នេះ សម្រេច**

-តម្កល់រឿងព្រហ្មទណ្ឌលេខ ............ ថ្ងៃទី ..... ខែ ............ ឆ្នាំ ............ ទុកឥតចាត់ការតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី... ខែ....... ឆ្នាំ........

**ព្រះរាជអាជ្ញារង**

អយ្យការអម

សាលាដំបូងខេត្ត

*ពោធិ៍សាត់*

*លេខ៖*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់

យើង ............ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តពោធិ៍សាត់

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី ខែ ឆ្នាំ ២០ ។

បានឃើញមាត្រា ៤៣ និង ៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើតាមព្រះរាជ ក្រមលេខ: នស/រ កម ០៨ ០៧/០២៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

**ឃើញថា ៖**

១-នាមត្រកូលនាមខ្លួន ៖ ភេទ សញ្ជាតិ ៖ ខ្មែរ

កើតថ្ងៃទីខែឆ្នាំ ៖

ទីកន្លែងកំណើត ៖ភូមិ ឃុំ ស្រុក ខេត្ត

អាស័យដ្ឋានសព្វថ្ងៃ:ភូមិ ឃុំ ស្រុក ខេត្ត

មុខរបរ ៖ ប្ដីឬប្រពន្ធឈ្មោះ ៖ កសិករ

ឪពុកឈ្មោះ ៖ "រ" ម្ដាយឈ្មោះ ៖ "រ"

អនីតិជន☐ ឬ ☐ នីតិជន

**ឃើញថា:**

កាលពីថ្ងៃទី ខែ ឆ្នាំ ២០១៤

ពីបទ: ដែលល្មើសមាត្រា នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក ។

-ឯកសារនានាទាក់ទងសំណុំរឿង លេខ: ចុះថ្ងៃទី ខែ ឆ្នាំ ២០១៤ ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ

-តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ

-តាមរបាយការលេខ:

**យល់ឃើញថា:**

-

-អង្គហេតុខាងលើ មានលក្ខណៈមូលសព្វគ្រប់ និងភស្តុតាងដែលប្រមូលបានអាច កំណាត់អំពីធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ហេតុ ដូច្នេះគប្បីសម្រេចបញ្ជូនសំណុំរឿងនេះ ដោយផ្ទាល់ទៅសាលាដំបូង ខេត្ត បន្ទាយមានជ័យ ដើម្បីជំនុំជម្រះតាមច្បាប់ជាធរមាន។

**ហេតុដូច្នេះសម្រេច ៖**

**បញ្ជូនជនជាប់ចោទ** ឈ្មោះ ភេទ អាយុ ឆ្នាំ ពីបទៈ ដែលល្មើសមាត្រា ប្រព្រឹត្ត នៅភូមិឫស្សីក្រោក ឃុំឫស្សីក្រោក ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី ខែ ឆ្នាំ ២០១៤។**ទៅសាលាដំបូងខេត្ត បន្ទាយមានជ័យ ដើម្បីជំនុំជម្រះ តាមនីតិវិធីកោះហៅ បញ្ជូនទៅជំនុំជំម្រះផ្ទាល់ ចំពោះអង្គហេតុខាងលើ ។**

បន្ទាយមានជ័យ ថ្ងៃទី ខែ ឆ្នាំ ២០១

**តំណាងអយ្យការ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្ត
*ពោធិ៍សាត់*
*លេខ៖..........*

# ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

យើង ........... តំណាងអយ្យការអម សាលាដំបូងខេត្ត ពោធិ៍សាត់
បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ .... ចុះថ្ងៃទី... ខែ... ឆ្នាំ២០១...
បានឃើញរបាយការណ៍របស់អធិការដ្ឋាននគរបាលស្រុកក្រគរ លេខ: ...
ចុះថ្ងៃទី... ខែ... ឆ្នាំ២០១... ។

ក្រោយពីបានពិនិត្យឯកសារខាងលើ

**ឃើញថា មានតម្រុយសន្មតបានថា:**

**១**-នាមត្រកូល ៖ ... នាមខ្លួន ...........ហៅគា ភេទ...
អាយុ ៖ ....ឆ្នាំ
ទីកន្លែងកំណើត៖ ..............................................................
អាសយដ្ឋាន ៖ ..............................................................
មុខរបរ ៖ ...
☐ នៅលីវ ឬរៀបការ ☐ ឈ្មោះប្រពន្ធ ៖ ..............
សញ្ជាតិ ៖ ខ្មែរ
ឪពុកឈ្មោះ ៖........... "ស" ម្ដាយឈ្មោះ ៖ ........... "ស"
អនីតិជន ☐ ឬ នីតិជន ☐

**២**-នាមត្រកូល ៖........... នាមខ្លួន ........... ភេទ...........
អាយុ ៖ ...........ឆ្នាំ
ទីកន្លែងកំណើត៖ ..............................................................
អាសយដ្ឋាន៖ ..............................................................
មុខរបរ ៖ ...........
☐ នៅលីវ ឬរៀបការ ☐ ឈ្មោះប្រពន្ធ ៖ ...........

សញ្ជាតិ ៖ ខ្មែរ

ឪពុកឈ្មោះ ៖ ........... "ស" ម្ដាយឈ្មោះ ៖ ........... "ស"

អនីតិជន ☐ ឬ នីតិជន ☐

៣-នាមត្រកូល ៖ ........... នាមខ្លួន ........... ភេទ...........

អាយុ ៖ ...........ឆ្នាំ

ទីកន្លែងកំណើត៖ ...........................................................................

អាសយដ្ឋាន ៖ ...........................................................................

មុខរបរ ៖ ...........

☐ នៅលីវ ឬរៀបការ ☐ ឈ្មោះប្រពន្ធ ៖ ...........

សញ្ជាតិ ៖ ខ្មែរ

ឪពុកឈ្មោះ ៖ ........... "ស" ម្ដាយឈ្មោះ ៖ ........... "ស"

អនីតិជន ☐ ឬ នីតិជន ☐

## បានប្រព្រឹត្តអំពើដូចតទៅ ៖

កាលពីថ្ងៃទី........... ខែ...........ឆ្នាំ........... វេលាម៉ោង...........និង...........នាទី មានបទល្មើស........... ........... ...........នៅតំបន់........... ........... ស្ថិតនៅភូមិ...........ឃុំ...........ស្រុក........... ខេត្តពោធិ៍សាត់ បង្កឡើងដោយជនសង្ស័យចំនួន០៧នាក់ ១.ឈ្មោះ...........ភេទ........... អាយុ ...........ឆ្នាំ ជា...........២.ឈ្មោះ ........... ភេទ........... ហៅ........... ភេទ........... អាយុ ...........ឆ្នាំ ៣.ឈ្មោះ ...........ភេទ........... អាយុ ...........ឆ្នាំ ៤.ឈ្មោះ ........... ភេទ........... អាយុ ...........ឆ្នាំ ៥.ឈ្មោះ ........... ភេទ........... អាយុ...........ឆ្នាំ ៦.ឈ្មោះ ........... ភេទ........... អាយុ ...........ឆ្នាំ ៧.ឈ្មោះ ........... ភេទ........... អាយុ ...........ឆ្នាំ។ ពេលទទួលបានបណ្ដឹងពីប្រជាពលរដ្ឋ លោកអធិការបានបញ្ជាឲ្យលោកអធិការរងទទួលផែនការយុត្តិធម៍ ដឹកនាំផ្នែកជំនាញ ដោយសហការជាមួយប៉ុស្ដិ៍........... ចុះទៅកន្លែងកើតហេតុដើម្បីធ្វើការស្រាវជ្រាវ បន្ទាប់ពីទៅដល់កន្លែងកើតហេតុលោកអធិការរងទទួលផែនការយុត្តិធម៍ ដឹកនាំផ្នែកជំនាញ និងប៉ុស្ដិ៍........... ធ្វើការស្រាវជ្រាវកំណត់មុខសញ្ញា ។លុះដល់ថ្ងៃទី........... ខែ........... ឆ្នាំ........... កំលាំងអធិការដ្ឋាននគរបាលស្រុក........... ធ្វើការឃាត់ខ្លួន ១.ឈ្មោះ........... ភេទ........... អាយុ ...........

ឆ្នាំ ជាប្រធានអង្គការ........... ២.ឈ្មោះ ...........ភេទ........... ហៅ...........ភេទ........... អាយុ ...........ឆ្នាំ ៣.ឈ្មោះ ........... ភេទ........... អាយុ...........ឆ្នាំ ៤.ឈ្មោះ ........... ភេទ ........... អាយុ ...........ឆ្នាំ ៥.ឈ្មោះ ...........ភេទ........... អាយុ ...........ឆ្នាំ ៦.ឈ្មោះ ........... ភេទ........... អាយុ ...........ឆ្នាំ ៧.ឈ្មោះ ...........ភេទ........... អាយុ ...........ឆ្នាំ ០៦នាក់ជាសមាជិក...........។

អំពើខាងលើជាបទល្មើសៈ កំហែងយក តាមមាត្រា ៣៦៣,៣៦៤ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅ........... ស្ថិតនៅភូមិ...........ឃុំ...........ស្រុក........... ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី...........ខែ........... ឆ្នាំ...........។

បានឃើញមាត្រា ៤៤ និងមាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**សម្រេច ៖**

បើកការស៊ើបសួរលើអង្គហេតុខាងលើ និង:

1.ដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យលើ ៖

ក. ឈ្មោះ ...........ហៅ........... អាយុ ...........ឆ្នាំ

ខ.ឈ្មោះ ...........ភេទ........... អាយុ ...........ឆ្នាំ

គ.ឈ្មោះ ...........ភេទ........... អាយុ ...........ឆ្នាំ

ឃ.ឈ្មោះ ...........ភេទ........... អាយុ ...........ឆ្នាំ

ង.ឈ្មោះ ...........ភេទ........... អាយុ ...........ឆ្នាំ

ច.ឈ្មោះ ...........ភេទ........... អាយុ ...........ឆ្នាំ

ឆ.ឈ្មោះ ...........ភេទ........... អាយុ ...........ឆ្នាំ

ពីបទៈ កំហែងយក តាមមាត្រា ៣៦៣,៣៦៤ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅ ....................... ស្ថិតនៅភូមិ.......... ........... ........... ........... ........... ............កាលពីថ្ងៃទី ........... ខែ........... ឆ្នាំ...........។

☐ ដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ធ្វើនៅពោធិ៍សាត់,ថ្ងៃទី....... ខែ ....... ឆ្នាំ ...........

**តំណាងអយ្យការ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្ត
*ពោធិ៍សាត់*
*លេខ៖*

# ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបទល្មើសថ្មីបន្ថែម

យើង ... ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តពោធិ៍សាត់

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ: ... ចុះថ្ងៃទី... ខែ... ឆ្នាំ២០១៦ របស់អយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរលេខ ... ចុះថ្ងៃទី... ខែ... ឆ្នាំ២០១៦ ។

-បានឃើញនីតិវិធីស៊ើបសួរលើឈ្មោះ ... ឈ្មោះ... និង ឈ្មោះ...ជាជនត្រូវចោទពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិ... ខេត្តពោធិ៍សាត់ និង នៅខណ្ឌ... ក្រុង ... កាលពីថ្ងៃទី... ខែ ... ឆ្នាំ ២០១៦។

**ឃើញថាអង្គហេតុ:** តាមចម្លើយរបស់ជនត្រូវចោទឈ្មោះ... បានឆ្លើយសារភាពថា ៖ កាលពីអំឡុង ខែ... ឆ្នាំ២០១៥ខ្លួនធ្លាប់បានទៅទិញថ្នាំញៀនពីឈ្មោះ ... ហៅ ... ចំនួនពាក់កណ្តាលកន្លះជ្រុង តម្លៃ១២០០០០០រៀល(មួយលានពីរសែនរៀល) ហើយឈ្មោះ...យកថ្នាំមកចនៅភូមិរលាប សង្កាត់... ក្រុង... ខេត្តពោធិ៍សាត់ ។ នៅអំឡុង ខែ... ឆ្នាំ២០១៥ ខ្លួនបានទិញថ្នាំញៀនពីឈ្មោះ ... ចំនួនកន្លះហ៊ុន នៅភូមិ... សង្កាត់... ក្រុង... ខេត្តពោធិ៍សាត់ ។ នៅអំឡុងខែ... ឆ្នាំ២០១៥ខ្លួនបានទៅទិញថ្នាំញៀនពីឈ្មោះ... ចំនួនមួយហ៊ុន ហើយឈ្មោះ...យកថ្នាំមកចនៅភូមិ ... សង្កាត់... ក្រុង... ខេត្តពោធិ៍សាត់។ នៅចុងខែ... ឆ្នាំ២០១៥ ខ្លួនបានទិញថ្នាំញៀនពីឈ្មោះ ... ចំនួនមួយជ្រុង តម្លៃ៧០០ដុល្លា (ប្រាំពីររយ) ទិញនៅភូមិ... សង្កាត់.... ក្រុង... ខេត្តពោធិ៍សាត់។

☐ ដែលត្រូវបានចៅក្រមស៊ើបសួររកឃើញ ហើយបានជូនដំណឹងតាមលិខិតលេខ... ចុះថ្ងៃទី ... ខែ... ឆ្នាំ ២០១៦ របស់ចៅក្រមស៊ើបសួរ និងសំណុំលិខិតភ្ជាប់មកជាមួយព្រមទាំងភស្តុតាងនានា។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខៈ ... ចុះថ្ងៃទី... ខែ... ឆ្នាំ២០១៦ របស់អយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរលេខ ... ចុះថ្ងៃទី... ខែ... ឆ្នាំ២០១៦ ។

-បានឃើញលិខិតជូនដំណឹងលេខ... ចុះថ្ងៃទី ...ខែ... ឆ្នាំ ២០១៦ របស់ចៅក្រមស៊ើបសួរ ស្តីពីលេចចេញនូវអង្គហេតុថ្មី។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

**ឃើញថា មានតម្រុយសន្មតបានថាៈ**

**១**-នាមត្រកូល ៖... នាមខ្លួន ៖ ហៅ ... ភេទ ប្រុស

កើតថ្ងៃទី ៖

ទីកន្លែងកំណើត ៖

អាសយដ្ឋាន ៖ ភូមិ... សង្កាត់... ក្រុង... ខេត្តពោធិ៍សាត់

មុខរបរ ៖

☐ នៅលីវ ឬរៀបការ ☐ ឈ្មោះប្តី ឬប្រពន្ធ ៖

សញ្ជាតិ ៖ ខ

ឪពុកឈ្មោះ ៖ "រ" ម្តាយឈ្មោះ ៖

អនីតិជន☐ ឬ នីតិជន ☐

**២**-នាមត្រកូល ៖ ... នាមខ្លួន ៖ ភេទ ប្រុស

កើតថ្ងៃទី ៖

ទីកន្លែងកំណើត ៖

អាសយដ្ឋាន ៖ ភូមិ

មុខរបរ ៖

☐ នៅលីវ ឬរៀបការ ☐ ឈ្មោះប្តី ឬប្រពន្ធ ៖

សញ្ជាតិ ៖ ខ្មែរ

ឪពុកឈ្មោះ ៖ "រ" ម្តាយឈ្មោះ ៖

អនីតិជន☐ ឬ នីតិជន ☐

**៣**-នាមត្រកូល ៖ ... នាមខ្លួន ៖ ភេទ ប្រុស

កើតថ្ងៃទី ៖

ទីកន្លែងកំណើត ៖

អាសយដ្ឋាន ៖ សង្កាត់... ក្រុង.... ខេត្តពោធិ៍សាត់

មុខរបរ ៖

☐ នៅលីវ ឬរៀបការ ☐ ឈ្មោះប្តី ឬប្រពន្ធ ៖

សញ្ជាតិ ៖ ខ្មែរ

ឪពុកឈ្មោះ ៖ "រ" ម្តាយឈ្មោះ ៖

អនីតិជន☐ ឬ នីតិជន ☐

៤-នាមត្រកូល ៖ ... នាមខ្លួន ៖ ភេទ ប្រុស

កើតថ្ងៃទី ៖

ទីកន្លែងកំណើត ៖

អាសយដ្ឋាន ៖ ភូមិ ... សង្កាត់... ក្រុង... ខេត្តពោធិ៍សាត់

មុខរបរ ៖

☐ នៅលីវ ឬរៀបការ ☐ ឈ្មោះប្តី ឬប្រពន្ធ ៖

សញ្ជាតិ ៖ ខ្មែរ

ឪពុកឈ្មោះ ៖ "រ" ម្តាយឈ្មោះ ៖

អនីតិជន☐ ឬ នីតិជន ☐

## បានប្រព្រឹត្តអំពើដូចតទៅ ៖

តាមចម្លើយរបស់ជនត្រូវចោទឈ្មោះ.... បានឆ្លើយសារភាពថា ៖ កាលពីអំឡុង ខែ... ឆ្នាំ២០១៥ខ្លួនធ្លាប់បានទៅទិញថ្នាំញៀនពីឈ្មោះ... ហៅ ... ចំនួនពាក់កណ្តាលកន្លះជ្រុង តម្លៃ១២០០០០០រៀល(មួយលានពីរសែនរៀល) ហើយឈ្មោះ...យកថ្នាំមកចនៅភូមិ... សង្កាត់... ក្រុង... ខេត្តពោធិ៍សាត់ ។ នៅអំឡុង ខែ... ឆ្នាំ២០១៥ ខ្លួនបានទិញថ្នាំញៀនពីឈ្មោះ ... ចំនួនកន្លះហ៊ុន នៅភូមិ... សង្កាត់... ក្រុង... ខេត្តពោធិ៍សាត់ ។ នៅអំឡុងខែ... ឆ្នាំ២០១៥ខ្លួនបានទៅទិញថ្នាំញៀនពីឈ្មោះ... ចំនួនមួយហ៊ុន ហើយឈ្មោះ...យកថ្នាំមកចនៅភូមិ ... សង្កាត់... ក្រុង... ខេត្តពោធិ៍សាត់។ នៅចុងខែ... ឆ្នាំ២០១៥ ខ្លួនបានទិញថ្នាំញៀនពីឈ្មោះ ... ចំនួនមួយជ្រុង តម្លៃ៧០០ដុល្លា (ប្រាំពីររយ) ទិញនៅភូមិ... សង្កាត់... ក្រុង... ខេត្តពោធិ៍សាត់។

- អំពើខាងលើជាបទល្មើស៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** តាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅ ក្រុង... ខេត្តពោធិ៍សាត់ កាលពីអំឡុង ខែ... ខែ... ខែ... ខែ.... ឆ្នាំ ២០១៥។

**យល់ឃើញថា**

-តាមចម្លើយសារភាពរបស់ជនត្រូវចោទឈ្មោះ.... ឃើញថា លេចចេញនូវអង្គហេតុថ្មី ហើយអង្គហេតុថ្មីនេះតំណាងអយ្យការមិនទាន់បានបើកការស៊ើបសួរនៅឡើយ។

បានឃើញមាត្រា ៤៤ និងមាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

**សម្រេច៖**

បើកការស៊ើបសួរលើអង្គហេតុខាងលើ និង:

☐ ដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យលើ ៖

១-ឈ្មោះ ... ហៅ...ភេទ ប្រុស

ពីបទ ៖ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្ត កាលពីអំឡុង ខែ... ឆ្នាំ២០១៥ នៅភូមិ... សង្កាត់... ក្រុង... ខេត្តពោធិ៍សាត់ ។

២-ឈ្មោះ ... ភេទ ប្រុស

ពីបទ ៖ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅអំឡុង ខែ... ឆ្នាំ២០១៥ នៅភូមិ... សង្កាត់... ក្រុង ... ខេត្តពោធិ៍សាត់ ។

៣-ឈ្មោះ ... ភេទ ប្រុស

ពីបទ ៖ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តកាលពីអំឡុងខែ... ឆ្នាំ២០១៥ នៅភូមិ ... សង្កាត់... ក្រុង... ខេត្តពោធិ៍សាត់

☐ ដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

☐ ដាក់ឱ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្ន ៖ ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការ ចាត់ការតាមនីតិវិធី។

ធ្វើនៅ,ពោធិ៍សាត់ថ្ងៃទី ... ខែ ... ឆ្នាំ ២០១៦

**តំណាងអយ្យការ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

អយ្យការអម
សាលាដំបូងខេត្ត*ពោធិ៍សាត់*
*លេខ៖*

**ដីកាស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែម**

យើង **...** តំណាងអយ្យការអមសាលាដំបូងខេត្ត ពោធិ៍សាត់។

-បានឃើញមាត្រា ២៤៦ និង ១៣២នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលប្រកាសអោយប្រើ

-តាមព្រះរាជក្រមលេខ នស. រកម . ០៨០៧.០២៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ... ចុះថ្ងៃទី... ខែ ... ឆ្នាំ ២០១៥។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរលេខ ... ចុះថ្ងៃទី... ខែ... ឆ្នាំ ២០១៥។

**ដែលបានបើកការស៊ើបសួរលើ:**

១-ឈ្មោះ ... ភេទ ប្រុស អាយុ...ឆ្នាំ

២-អញ្ញាតជន

ពីបទ៖ អំពើលួច ,ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និង ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា៣៥៣ ,៣៥៦នៃក្រមព្រហ្មទណ្ឌ និងតាមមាត្រា៤៥ ,៤០នៃច្បាប់ស្តីពីការត្រួតពិនិត្យ គ្រឿងញៀន ។

ប្រព្រឹត្តិនៅសង្កាត់... ក្រុង... ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី... ,ទី...ខែ.... ឆ្នាំ២០១៥។

**បានឃើញ** ៖ដីកាបញ្ជូនអោយឆ្លើយដើម្បីបិទបញ្ចប់ការស៊ើបសួរលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

អយ្យការអម
សាលាដំបូងខេត្ត*ពោធិ៍សាត់*
*លេខ៖*

## ដីកាស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែម

យើង **...** តំណាងអយ្យការអមសាលាដំបូងខេត្ត ពោធិ៍សាត់។

-បានឃើញមាត្រា ២៤៦ និង ១៣២នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលប្រកាសអោយប្រើ

-តាមព្រះរាជក្រមលេខ នស. រកម . ០៨០៧.០២៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ... ចុះថ្ងៃទី... ខែ ... ឆ្នាំ ២០១៥។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរលេខ ... ចុះថ្ងៃទី... ខែ... ឆ្នាំ ២០១៥។

**ដែលបានបើកការស៊ើបសួរលើ:**

១-ឈ្មោះ ... ភេទ ប្រុស អាយុ...ឆ្នាំ

២-អញ្ញាតជន

ពីបទ៖ អំពើលួច ,ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និង ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា៣៥៣ ,៣៥៦នៃក្រមព្រហ្មទណ្ឌ និងតាមមាត្រា៤៥ ,៤០នៃច្បាប់ស្តីពីការត្រួតពិនិត្យ គ្រឿងញៀន ។

ប្រព្រឹត្តិនៅសង្កាត់... ក្រុង... ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី... ,ទី...ខែ.... ឆ្នាំ២០១៥។

**បានឃើញ** ៖ដីកាបញ្ជូនអោយឆ្លើយដើម្បីបិទបញ្ចប់ការស៊ើបសួរលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរ។

អយ្យការ អម
សាលាដំបូងខេត្តបន្ទាយមានជ័យ
សំណុំរឿងព្រហ្មទណ្ឌ
លេខៈ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ដីកាសន្និដ្ឋានសុំដល់ចៅក្រមស៊ើបសួរកុំឲ្យស៊ើបសួរ

យើង ...តំណាងអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខៈ...ចុះថ្ងៃទី...ខែ ...ឆ្នាំ ២០១២របស់ អយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ។

-បានឃើញ មាត្រា១៣៧ មាត្រា១៣៨ និង មាត្រា ១៣៩នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណា ចក្រកម្ពុជា។

-បានឃើញ ដីកាសម្រេចលេខៈ...ព.ស/ព្រ.ទ ចុះថ្ងៃទី... ខែ... ឆ្នាំ២០១២របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តបន្ទាយមានជ័យ លើពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

## ក្រោយពីបានពិនិត្យឯកសារខាងលើ:

**០១**-នាមត្រកូល និងនាមខ្លួន: ...
ភេទប្រុស អាយុ ...ឆ្នាំ សញ្ជាតិ...
ទីកន្លែងកំណើត: ខេត្ត...
ទីលំនៅបច្ចុប្បន្ន: ភូមិ...ខេត្តបន្ទាយមានជ័យ
មុខរបរ: នៅផ្ទះ (ចាស់ជរា) សាសនា ព្រះពុទ្ធ
ប្រពន្ធឈ្មោះ ... (ស្លាប់)
ឪពុកឈ្មោះ ... (ស) ម្តាយឈ្មោះ ... (ស)
នីតិជន ☑ ឬអនីតិជន □

**០២**-នាមត្រកូល និងនាមខ្លួន: ...
ភេទប្រុស កើតថ្ងៃទី ... ខែ... ឆ្នាំ ... សញ្ជាតិខ្មែរ
ទីកន្លែងកំណើត: ភូមិ...ខេត្តស្វាយរៀង
ទីលំនៅបច្ចុប្បន្ន: ភូមិ... ខេត្តបន្ទាយមានជ័យ
មុខរបរ: ...សាសនា ព្រះពុទ្ធ
ប្រពន្ធឈ្មោះ ...

ឪពុកឈ្មោះ ... (ស) ម្ដាយឈ្មោះ ... (រ)
នីតិជន ☑ ឬអនីតិជន ☐

**ការសង្កេតផ្សេងៗ៖**

កាលពីថ្ងៃទី ...ឈ្មោះ ...ហៅ ...ភេទប្រុស បានមកដាក់ពាក្យប្ដឹងនៅ អយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ ដោយប្ដឹងឈ្មោះ ...ថា៖ បានធ្វើ និង ប្រើប្រាស់នូវឯកសារក្លែងក្លាយលើពាក្យស្នើ សុំដីស្រែ ចុះថ្ងៃទី...ខែ... ឆ្នាំ១...ដើម្បីយកមកធ្វើជាឯកសារយោងសំរាប់ចេញប័ណ្ណសំគាល់សិទ្ធកាន់កាប់ អចលនវត្ថុហើយ នៅក្នុងនោះមានឈ្មោះ ...ជាមេឃុំ...បានចូលរួមបញ្ជាក់ និងប្រព្រឹត្តអំពើក្លែងឯកសារនេះ ផងដែរ។ លុះថ្ងៃទី... ខែ... ឆ្នាំ... ឈ្មោះ ...ហៅ ...បានមកដាក់ពាក្យបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹង
រដ្ឋប្បវេណីតាមផ្លូវអន្តរាគន៍ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ៖... ចុះថ្ងៃទី... ខែ ... ឆ្នាំ... មក ចៅក្រមស៊ើបសួរ ។

**យល់ឃើញថា:**

-ពាក្យបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី
តាមផ្លូវអន្តរាគមន៍ក្នុងសំណុំរឿងព្រហ្មទណ្ឌ លេខ៖

... ចុះថ្ងៃទី...ខែ...ឆ្នាំ២... របស់ឈ្មោះ ...ហៅ
...បានប្ដឹងមកចៅក្រមស៊ើបសួរហើយតាមរយៈដីកាសម្រេចលើ
ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីលេខ៖... ចុះថ្ងៃទី... ខែ...ឆ្នាំ...
របស់ចៅក្រមស៊ើបសួរបានបញ្ជូនមក
អយ្យការដើម្បីអោយតំណាងអយ្យការធ្វើការពិនិត្យនិងសម្រេច។
បន្ទាប់ពីតំណាងអយ្យការទទួលបានពាក្យ បណ្ដឹងសុំតាំងខ្លួន ជាដើមបណ្ដឹងរដ្ឋប្បវេណី របស់ឈ្មោះ ...ហៅ......តាមដីកាបញ្ជូនលេខ៖ ...រប/សលដ.បជ ចុះថ្ងៃទី ... ខែ... ឆ្នាំ ... របស់សាលាដំបូងខេត្តបន្ទាយមានជ័យ និងក្រោយពីបានអង្កេតបឋមរួចរាល់តំណាងអយ្យការបានសម្រេចតម្កល់រឿងទុកឥតចាត់ការលើសំណុំរឿងព្រហ្មទណ្ឌ លេខ ៖ ... ចុះថ្ងៃទី ... ខែ ...ឆ្នាំ ... របស់ អយ្យការអមសាលាដំបូង ខេត្តបន្ទាយមានជ័យ ដោយមូលហេតុផុតអាជ្ញាយុកាលនៃបទល្មើសតាមដីកា លេខ៖... ចុះថ្ងៃទី... ខែ ...ឆ្នាំ...របស់អយ្យការអមសាលាដំបូងខេត្ត បន្ទាយមានជ័យ។

-តាមមាត្រា ១៣៩ (ការបញ្ជូនបណ្ដឹងទៅព្រះរាជអាជ្ញា) វាក្យខ័ណ្ឌ៣ នៃ ក្រមនីតិវិធីព្រហ្មទណ្ឌ ព្រះរាជ អាជ្ញា អាចសុំ ដល់ ចៅក្រមស៊ើបសួរ កុំអោយស៊ើបសួរ លើពាក្យបណ្ដឹងសុំតាំងខ្លួន ជាដើមបណ្ដឹងរដ្ឋប្បវេណី របស់ឈ្មោះ...ហៅ ...ដោយហេតុថា៖ នៅក្នុងពាក្យបណ្ដឹងរបស់ឈ្មោះ...បានប្ដឹង ពីឈ្មោះ...និង ឈ្មោះ.. ថាបានក្លែងដោយសិកសៀតអក្សរលើពាក្យ ស្នើ សុំ ដីស្រែ របស់ ឈ្មោះ...ចុះថ្ងៃ ទី... ខែ ... ឆ្នាំ ...

ឪពុកឈ្មោះ ... (ស) ម្តាយឈ្មោះ ... (រ)
នីតិជន ☑ ឬអនីតិជន □

**ការសង្កេតផ្សេងៗ៖**

កាលពីថ្ងៃទី ...ឈ្មោះ ...ហៅ ...ភេទប្រុស បានមកដាក់ពាក្យប្តឹងនៅ អយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ ដោយប្តឹងឈ្មោះ ...ថា៖ បានធ្វើ និង ប្រើប្រាស់នូវឯកសារក្លែងក្លាយលើពាក្យស្នើ សុំដីស្រែ ចុះថ្ងៃទី...ខែ... ឆ្នាំ១...ដើម្បីយកមកធ្វើជាឯកសារយោងសំរាប់ចេញប័ណ្ណសំគាល់សិទ្ធកាន់កាប់ អចលនវត្ថុហើយ នៅក្នុងនោះមានឈ្មោះ ...ជាមេឃុំ...បានចូលរួមបញ្ជាក់ និងប្រព្រឹត្តអំពើក្លែងឯកសារនេះ ផងដែរ។ លុះថ្ងៃទី... ខែ... ឆ្នាំ... ឈ្មោះ ...ហៅ ...បានមកដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹង
រដ្ឋប្បវេណីតាមផ្លូវអន្តរាគន៍ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ៖... ចុះថ្ងៃទី... ខែ ... ឆ្នាំ... មក ចៅក្រមស៊ើបសួរ ។

**យល់ឃើញថា:**

-ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី
តាមផ្លូវអន្តរាគមន៍ក្នុងសំណុំរឿងព្រហ្មទណ្ឌ លេខ៖

... ចុះថ្ងៃទី...ខែ...ឆ្នាំ២... របស់ឈ្មោះ ...ហៅ
...បានប្តឹងមកចៅក្រមស៊ើបសួរហើយតាមរយៈដីកាសម្រេចលើ
ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីលេខ៖... ចុះថ្ងៃទី... ខែ...ឆ្នាំ...
